ខ្លឹមសារ

ប្រធានទី១៖ មតិមួយលើកឡើងថា " ទុំស្លាប់មកពីមិនបង្ហាញរាជសារ " តើអ្នកយល់យ៉ាងណា ? (បែបពិភាក្សា(..... 1

ប្រធានទី២៖ ពាក្យចាស់មួយឃ្លាពោលថា " ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រវាអោបភ្នំ " ចូរពន្យល់ ? 2

ប្រធានទី៣៖ មតិមួយពោលថា " មរណភាពរបស់ទុំបណ្តាលមកពីសេចក្តីសស្នេហា"។ ឯមតិមួយទៀតថា " មរណភាពរបស់ទុំបណ្តាលមកពី អំណាចផ្តាច់ការនៃសង្គម "។ ចូរពិភាក្សាមតិខាងលើ។ 3

ប្រធានទី៤ ៖ សុភាសិតមួយពោលថា "ល្អពុម្ព ទើបល្អព្រះ" ចូរបកស្រាយ។ 4

ប្រធានទី៥ ៖ សុភាសិតមួយពោលថា "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប" ចូរបកស្រាយ។ 5

ប្រធានទី៦៖ សុភាសិតមួយបានពោលថា"ចង់ចេះអោយសំលាប់អាចារ្យ ចង់បានផ្លែផ្កាអោយយកភ្លើងដុតគល់" ចូរបកស្រាយ។ 6

ប្រធានទី៧៖ សុភាសិតមួយពោលថា "ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់" ចូរបកស្រាយ។

ប្រធានទី៨៖ ពាក្យចាស់បុរាណមួយឃ្លាពោលថា "កុំទុំមុនស្រគាល"តើពាក្យនេះមានអត្ថន័យ ដូចម្តេច ? ចូរពន្យល់។ (ថ្នាក់ទី១២)

ប្រធានទី៩៖ ទស្សនៈមួយចែងថា "ទីណាមានការជិះជាន់ ទីនោះមានការរើបំរះ"ចូរពន្យល់ដោយលើក ឧទាហរណ៍បញ្ជាក់។ (សំរាប់ថ្នាក់ទី០៩)

ប្រធានទី១០ ទ្រឹស្តីមួយពោលថា"មាតាបិតាគឺជាបុព្វទេវា បុព្វាចារ្យ និងជាព្រះរបស់បុត្រធីតា"។ចូរពន្យល់។

ប្រធានទី១១៖ មតិមួយពោលថា " ព្រះរាមធ្វើសង្គ្រាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួន គឺយកនាងសីតាពីក្រុងរាពណ៍ " ឯមតិផ្សេងទៀតថា " ព្រះរាមធ្វើសង្គ្រាមដើម្បីស្វែងរកសេចក្តីសុខអោយសង្គមមនុស្ស " តើអ្នកយល់យ៉ាងដូចម្តេចចំពោះមតិទាំងនេះ ?

ប្រធានទី១២៖ ចៅចិត្រចេះប្រឹងប្រែងកសាងជីវភាពរបស់ខ្លួនអោយរីកចំរើន។ តើចៅចិត្រខំប្រតិបត្តិតាមប្រការអ្វី ? ចូរពន្យល់អោយបានក្បោះក្បាយ ដោយលើកយកដំណើររឿង កុលាបប៉ៃលិនមកបញ្ជាក់។

ប្រធានទី១៣៖ មតិមួយពោលថា " ធ្វើស្រែអោយមើលស្មៅ ទុកជាក់កូនចៅអោយមើលផៅសណ្តាន " ចូរពន្យល់ ?

ប្រធានទី១៤៖ ពំនោលមួយពោលថា " ចង់ធំខំពីតូច បើខ្លាចខូចកុំធាប់ខឹង ការឆ្លើយអោយចេះថ្លឹង កុំបីប្រឹងជុះតាមដំរី " តើពំនោលនេះមានន័យយ៉ាងដូចម្តេច ?

ប្រធានទី១៥ ទស្សនៈមួយបានពោលថា "គ្រប់អក្សរសិល្ប៍ទាំងអស់គឺជាមធ្យោបាយដ៏សំខាន់ក្នុងការអប់រំទូន្មាន"។ ចូរស្រាយបញ្ជាក់ ។

ប្រធានទី១៦៖ មានទស្សនៈមួយពោលថា "លក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរចារឹកអត្តសញ្ញាណជាតិខ្មែរ"។ ចូរពន្យល់។

ប្រធានទី១៧៖ គេថា "នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និង គ្រួសារ"។ ចូរពន្យល់ដោយបញ្ជាក់ពីសកម្មភាពរបស់នារីក្នុងរឿងកូមិតិរច្ឆាន និង រឿងគូលីកំណែន។

ប្រធានទី១៩៖ ចូរតែងសេចក្តីអំពីបុណ្យចូលឆ្នាំប្រណីខ្មែរ។

ប្រធានទី២០៖ ចូរអធិប្បាយអំពីលក្ខណៈស្នេហារបស់ទុំទាវ ព្រមទាំងបញ្ចេញយោបល់របស់អ្នកចំពោះស្នេហាបែបទុំទាវនេះផង។

គ្រូបង្រៀនអាចទាញយកឯកសារនេះបានដោយឥតគិតថ្លៃ

ប្រធានទី១៖ មតិមួយលើកឡើងថា " ទុំស្លាប់មកពីមិនបង្ហាញរាជសារ " តើអ្នកយល់យ៉ាងណា? (បែបពិភាក្សា)

សេចក្តីអធិប្បាយ

នរណាៗក៏ធ្លាប់បានលឺ និងដឹងអំពីប្រវត្តិនៃរឿងទុំទាវហើយដែរ ដែលជារឿងដ៏ជូរចត់ ផ្អែមល្ហែម មិនចេះចប់មិនចេះហើយ នៃអំឡុងពេលដ៏យូរលង់មួយក្នុងសម័យលង្វែក។ ទុំទាវជាគូស្នេហ៍ ដ៏មហិមាមួយ ដែលតស៊ូនឹងសេចក្តីស្នេហាយ៉ាងពិតប្រាកដ ទោះមានឧបសគ្គ ការបំបែកបំបាក់ ពង្រាត់ពង្រាសយ៉ាងណាក៏ដោយ ក៏ពួកគេទាំងពីរ នៅតែស្រលាញ់គ្នាគ្មានទីបញ្ចប់។ ជាអកុសលរឿងយើងទាំងឡាយ ក៏ដូចជាតួអង្គនៃរឿងពិតនេះដែរ មិនចង់ជួប តែបានជួប ទុំស្លាប់យ៉ាងអនោចអធមន៌ ដោយក្តីស្ម័គ្រស្មោះនិងគ្នា ទាវក៏ស្លាប់ខ្លួនតាមទុំដែរក្នុងគ្រានោះទៅ។ដោយយល់ឃើញបែបនេះទើបមានមតិមួយបានលើកឡើងថា"ទុំស្លាប់មកពីមិនបង្ហាញរាជសារ"។

តើមតិដែលបានលើកឡើងខាងលើត្រឹមត្រូវដែរឬទេ?

ដើម្បីអោយបានយល់អំពីមតិយោបល់ខាងលើអោយបានក្បោះក្បាយ នោះ យើងគប្បីឈ្វេងយល់អំពីពាក្យថា " រាជសារ " ជាមុនសិន។ពាក្យថា " រាជសារ " បានដល់នូវ អក្ខរៈ ដែលព្រះរាជាទ្រង់តាក់តែងចងក្រងដោយព្រះហត្ថទ្រង់ផ្ទាល់ ដើម្បីជាសារ ឬសំបុត្រសំរាប់កោះប្រាប់ ឬបង្គាប់បញ្ជាផ្សេងៗ។ ប្រធានខាងលើចង់បង្ហាញពីគុណតំលៃ របស់ព្រះរាជសារមួយជាប់ខ្លួនទុំ ដើម្បីជាការ ការពារទុំអោយរួចផុតពីការបៀតបៀនដល់អាយុជីវិតពីសំណាក់ជន ទុច្ចរិតផ្សេងៗ។

គួយ៉ាងសម័យកាលនោះ ក្នុងរបបសក្តិភូមិ ប្រជារាស្ត្រ ឈ្មួញជួញដូរ សេនា នាយមុឺនមន្ត្រី អ្នកមុខអ្នកការ ទាំងឡាយមានការគោរពកោតខ្លាចស្តេចជាងអ្វីៗទាំងអស់។ ឋានៈ អរជួនជាស្តេចក្រាញ់ ក៏ត្រូវតែខ្លាចស្តេចមហានគរដែរ។ ហេតុនៃការស្លាប់របស់ទុំ
បណ្តាលមកពីឃាតករ ដែលអរជួនបានបញ្ជានោះ ប្រសិនទុំបានបង្ហាញរាជសារដែលព្រះរាជាទ្រង់ប្រគល់ ដោយផ្ទាល់នោះអោយអរជួនបានឃើញ បានយល់ខ្លឹមសារ ម្លោះអរជួនក៏មិនហ៊ានសំលាប់ទុំ ដោយមិនប្រណីដៃដែរ។ ដូចចំណុចត្រង់ឃ្លាថា " លើកហត្ថប្រញាប់ចាប់ លាតលាមើលដឹងស្គាល់ជាបន្ទូលថ្លៃ អរជួនភ័យខ្លួនខ្លាចលើកដៃ សំពះនិស្ស័យដល់ចេស្តា "។ ត្រង់ឃ្លានេះចង់ប្រាប់ថា ខណៈពេលដែលពួកឃាតកធ្វើសកម្មភាពសម្លាប់ទុំរួចហើយ ស្រាប់តែមានរាជសារធ្លាក់ចេញពីកាយទុំ ពេលអរជួន និងបក្សពួកបានឃើញហើយ ពន្លាមើលឃើញថាជាព្រះរាជបន្ទូល ក៏នាំគ្នាលុតជង្គង់ប្រណមសំពះនូវព្រះរាជបន្ទូលគ្រប់គ្នា ដោយកិតភ័យរកតែអាយុសរៀងៗខ្លួន។ ម៉្យាងវិញទៀតទុំខ្លួនឯង បែរជាយកស្រាធ្វើជាត្រីមុខ វង្វេងបាត់ស្មារតី ភ្លេចរាជសារដែលជាអាវុធ សំរាប់ការពារខ្លួនអោយរួចចាកទុក្ខ ទើបបណ្តាលអោយពួកអរជួនសំលាប់បានដូច្នេះ។

រួមមកទុំស្លាប់មកពី មិនបង្ហាញរាជសារពិតប្រាកដមែន។

តើទុំពិតជាស្លាប់បណ្តាលមកពីមិនបានបង្ហាញរាជសារមែនឬ?

ផ្ទុយពីមតិនេះទៅវិញ ទោះបីទុំបង្ហាញរាជសារ ក៏នៅតែពួកអរជួនសំលាប់ដដែល ព្រោះថាអរជួនអាងអំណាចខ្លួនខ្លាំង នៅស្រុកត្បូងឃ្មុំ នាមជាស្តេចក្រាញ់ ប្រចាំស្រុក។ ណាមួយអរជួន ជាពិសេសម្តាយទាវ សុទ្ធតែបានដឹងថា ទុំនិងទាវជាប្តីប្រពន្ធ ស្តេចរាជាប្រទានអោយ ក៏ប៉ុន្តែគេនៅតែហ៊ាន ចាប់ទាវអោយរៀបការ ជាមួយមុឺនងួនទៀត។ ទាំងនេះសបញ្ជាក់ថា អរជួនក៏ដូចជាម្តាយទាវ មិនដែលកោតខ្លាចអំណាចតេជៈ របស់ព្រះរាជាឡើយ ទើបហ៊ានប្រើល្បិចបោកបញ្ឆោតទាវ និងសំលាប់ទុំបានយ៉ាងនេះ។
រួមទៅទោះបីទុំបង្ហាញ រាជសារដល់អរជួន ក៏ដោយក៏ទុំនៅតែស្លាប់ ព្រោះអរជួនជាមនុស្សម្នាក់ ដែលអាងនូវអំណាច ។ តាមការលើកឡើងនៃគំនិតដែលថា ទុំស្លាប់ព្រោះមិនបង្ហាញរាជសារ ពិតណាស់ថា មិនទាន់សមស្របនិងប្រកបដោយយុត្តិធម៌នៅឡើយ។ ដោយសារការស្វែងរកភស្តុតាងមិនអាស្រ័យតែលើរបស់សំគាល់មួយ ឬសាក្សីមួយរូប អាចស្រាយបំភ្លឺគ្រប់ជ្រុងជ្រោយទេ ដូចនេះសំខាន់ត្រូវការស្វែងរក ភស្តុតាង មករួមផ្សំបន្ថែមទៀតទើបការកាត់ក្តី ប្រកបដោយតម្លាភាព យុត្តិធម៌ អាចទទួលយកបាន។ តែបើគ្មានរាជសារទេនោះ អរជួននៅតែហ៊ានសំលាប់គេគ្រប់គ្នា ដដែលដែរ។ ហេតុថា វាជារបបសក្តិភូមិ ដែលអរជួនតែងយកតំណែងអំណាច ឥទ្ធិពលរបស់ខ្លួន ទៅជិះជាន់អ្នកផ្សេង ឯទៀតដែលទន់ទាបជាងខ្លួន ជាមនុស្សដែលគេពុំពេញចិត្តទាស់ចិត្ត ដោយគ្មានជំនុំ

អ្វីឡើយ។ តាមមតិយោបល់ខាងលើវាគ្រាន់តែជាការបិទបាំង អំពើអាក្រក់របស់ពួកគេ តែប៉ុណ្ណោះ ព្រោះកស្តុតាងមិនអាចមានត្រឹមតែរាជសារប៉ុណ្ណោះនោះទេ ហើយណាមួយយើងក៏មិនអាចទៅឆ្លុះបញ្ចាំងអោយឃើញអំពីទង្វើ នៃការគិតរបស់ មនុស្សបានដែរ។

បើតាមការអង្កេតអោយបានស៊ីជម្រៅទៅអរជួននិងម្តាយទាវ ទើបសមជាឃាតករពិតប្រាកដ។

សរុបសេចក្តីមកប្រធានបទខាងលើមិនទាន់ត្រឹមត្រូវនៅឡើយទេ។ ដោយយល់ឃើញថា បញ្ហាក៏ដូចជាមូលហេតុ បង្កមានច្រើន ទុំស្លាប់នេះក៏មានការទាក់ទងនិងរបបសក្តិភូមិ ជិះជាន់អាងអំណាច។ ដូចនេះចូរយើងគ្រប់គ្នា ជាកុលបុត្រកុលធីតាខ្មែរ គ្រប់ជំនាន់ គ្រប់ស្រទាប់វណ្ណៈ គ្រប់វ័យ ចូរចេះរួមកំលាំង ទាំងកំលាំងកាយ និងកំលាំងចិត្ត សាមគ្គីជាភាតរភាព គោរពសិទ្ធសេរីភាពគ្នាទៅវិញទៅមក ទើបប្រទេសជាតិមានសុខសន្តិភាព យូរអង្វែងប្រកបដោយភាពរុងរឿងខ្ពស់ឈ្មោះកេរ្តិ៍។

ប្រធានទី២៖ ពាក្យចាស់មួយឃ្លាពោលថា “ ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រាសាអោបភ្នំ ” ចូរពន្យល់?

<u>សេចក្តីអធិប្បាយ</u>

តាមធម្មជាតិបានបង្កើតមនុស្សកំពស់នឹងភ្នំ មនុស្សក៏មិនអាចនឹង ចាប់ឈោងប្រាសាអោយភ្នំអោយនៅក្នុងរង្វង់ដៃបានដែរ។ អាស្រ័យហេតុនេះហើយ ទើបចាស់បុរាណចងក្រងពាក្យមួយឃ្លាពោលថា “ **ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រាសាអោបភ្នំ** ” ។

តើពាក្យមួយឃ្លាខាងលើមានអត្ថន័យខ្លឹមសារដូចម្តេច?

ដើម្បីជា គន្លឹះជៀសវាងក្នុងការយល់ច្រឡំដល់ការដោះស្រាយបញ្ហាខាងលើ យើងគប្បីយល់អត្ថន័យនៃពាក្យ " តោង ឈោង និង ភ្នំ " ជាមុនសិន។ **តោង** គឺសំដៅលើការលូកដៃទាំងពីរ ប្រឹងចាប់ដើម្បីអោយខ្លួនឡើងផុតពីទីទាប។ **ឈោង** មានន័យថា ការស្រវាចាប់អោយជាប់នៅក្នុងដៃ។ **ភ្នំ** គឺធនធានធម្មជាតិ ដែលមាននៅលើផែនដី ហើយវាកើតឡើង ពីកំលាំងនៃទំនើងផ្ទុត់របស់ស្នូលផែនដី រុញច្រានស្រទាប់ពីខាងក្រៅ អោយប៉ោងឡើងលើមានទំហំធំ និងខ្ពស់ឥតគណនា។ប្រធានបទខាងលើមានន័យថា មនុស្សមានមាឌតូចទាប កំលាំងតិចហើយធម្មជាតិពិតនៃមនុស្សនេះមិនអាចមានសមត្ថភាពតោងស្រវាចាប់ ឬអោបយកភ្នំទាំងមូលតែម្នាក់ឯងបានឡើយ។

ជាការពិតពាក្យថា " ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រវាអោបភ្នំ " គឺចង់បង្ហាញពីធាតុពិត របស់មនុស្ស ហើយនិងភ្នំគឺមនុស្សមានមាឌតូចបំផុត ឯភ្នំវិញមានកំពស់និងទំហំធំមហិមា ដែលហេតុធ្វើអោយមនុស្សម្នាទាំងឡាយ មិនអាចមានសមត្ថភាពឈោងចាប់ភ្នំបានឡើយ តាមសមត្ថភាពរបស់មនុស្សអាចឈោងចាប់វត្ថុអ្វីសព្វយ៉ាងដែលមាន ទំងន់ និងមាឌតូចជាងខ្លួនតែប៉ុណ្ណោះ។ បើប្រៀបធៀបទៅនឹងភ្នំ មនុស្សអាចស្លាប់បង់សង្ខារដោយសារតែជំរកភ្នំមួយភាគតូចនៃភ្នំ។ ដូចនេះមនុស្សទាំងឡាយ គប្បីមានមហិច្ឆតាខ្លួនអោយបានសមរម្យ ស្របទៅនឹងសមត្ថភាពរបស់ខ្លួនផងដែរទើបត្រឹមត្រូវ ហើយជៀសវាងមានភាពបរាជ័យ និងខាតបង់ប្រយោជ។ ឯពាក្យ " ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រវាអោបភ្នំ " ក្នុងន័យធៀបវិញគឺចង់បញ្ជាក់ចំពោះការរស់នៅរបស់មនុស្សក្នុងសង្គមសហគមន៍ ឬនៅក្នុងគ្រួសារដែលមិនចេះប៉ាន់ប្រមាណពីលទ្ធភាព និងសមត្ថភាពផ្ទាល់ខ្លួនហើយមានមហិច្ឆតា ធំហួសហេតុ ដែលនាំអោយខាតបង់ និងវិនាសអន្តរាយដល់ខ្លួនឯង។ ការប្រាថ្នាធំហួសប្រមាណនេះ ជាកត្តាមួយធ្វើអោយ កើតមាននូវបញ្ហាពិបាកជាច្រើនដល់ ការរស់នៅរបស់ខ្លួននិងគ្រួសារ ហើយនិងសង្គមជាតិផងដែរ។ ជាក់ស្តែងក្នុងសង្គមរបស់មនុស្ស អ្នកខ្លះរស់នៅក្នុងសង្គមគ្រួសារតូចទាប ខ្សត់ខ្សោយអសមត្ថភាព ដោយខ្វះការពិចារណាល្អិតល្អន់ ធ្វើអោយគេគិតខុសដោយមានមហិតច្ឆតាហួសប្រមាណ ដោយប្រថ្នាចង់អោយខ្លួនបានល្អលើសលុបដូចគេ ឬមានចិត្តប្រតិព័ទ្ធទៅលើកូនកំលោះក្រមុំដែលរស់ក្នុងអំបូរ ខ្ពង់ខ្ពស់ថ្លៃថ្នូរ។ នេះគឺជាការប្រមើស្រមៃមួយដែលមិនអាចឈានទៅរកការសំរេចជោគជ័យ បានឡើយ ហើយបែរទៅជានាំមកវិញនូវភាពខាតបង់ ទាំងពេលវេលានិងគ្រឿឈ្មោះក្នុងការរស់នៅទៀតផង។ ផ្សេងពីនេះ អ្នកខ្លះទៀតដោយសេចក្តីស្រមើប្រមៃខ្ពស់ធ្វើអោយខ្លួនបានគិតខុស ហ៊ានប្រព្រឹត្តិនូវអំពើល្មើសច្បាប់ផ្សេងៗដែលជាហេតុនាំអោយមាន ទុក្ខទោសជាប់ខ្លួន។ អាស្រ័យហេតុនេះមនុស្សត្រូវគិតពីលទ្ធភាព និងសមត្ថភាពរបស់ខ្លួនអោយច្បាស់លាស់ជាមុនសិន មុននិងចាប់កិច្ចការអ្វីមួយ ដោយហេតុនេះ ហើយទើបចាស់ទុំលោកពោលពាក្យ ប្រៀនប្រដៅ " ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រវាអោបភ្នំ " នេះជាមាគ៌ាសំរាប់ដើរទៅរកភាពរីកចំរើនជឿនលឿន និងសុភមង្គល់។

សរុបសេចក្តីពាក្យចាស់ខាងលើ ពិតជាមានលក្ខណៈល្អត្រឹមត្រូវ សំរាប់អោយមនុស្សយល់អំពីទង្វើដែលត្រូវធ្វើ និងសមត្ថភាពដែលខ្លួនមាន។

តាមរយៈការបកស្រាយខាងលើ ប្រធានបទមួយនេះមានអត្ថន័យខ្លឹមសារ ទូលំទូលាយសំរាប់អប់រំទូន្មានប្រៀនប្រដៅមនុស្សអោយយល់អំពី សមត្ថភាពផ្ទាល់របស់ខ្លួន ជៀសវាងធ្វើអ្វីអោយហួសពីសមត្ថភាព វាជាហេតុនាំអោយជួបប្រទះនិងការខាតបង់។ ដូចនេះកូនខ្មែរ ទាំងឡាយគប្បីខិតខំរៀនសូត្រ និងចេះស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួនមុននឹងប្រព្រឹត្តិកិច្ចការផ្សេងៗ។

ប្រធានទី៣៖ មតិមួយពោលថា " មរណាភាពរបស់ទុំបណ្តាលមកពីសេចក្តីសស្មៃហា"។ ឯមតិមួយទៀតថា " មរណាភាពរបស់ទុំបណ្តាលមកពី អំណោចផ្តាច់ការនៃសន្តម "។ ចូរពិភាក្សាមតិខាងលើ។

សេចក្តីអធិប្បាយ

រឿង ទុំទាវជាស្នាដៃដ៏អស្ចារ្យបំផុត ហើយវាបានចោទជាបញ្ហាជាច្រើនសំរាប់អ្នកសិក្សាលើកមកបកស្រាយ បញ្ចប់នៃរឿងអ្នកនិពន្ធបានអោយតួអង្គទុំស្លាប់យ៉ាងខ្លោចផ្សាបំផុត។ សេចក្តីស្លាប់របស់ទុំបានបង្កើតចេញជាមតិពីរផ្សេងគ្នា។ មតិមួយពោលថា "

មរណភាពរបស់ទុំបណ្តាលមកពីសេចក្តីស្នេហា “ ឯមតិមួយទៀតបានពោលផ្សេងថា ” មរណភាពរបស់ទុំបណ្តាលមកពីអំណាចផ្តាច់ការនៃសង្គម “ ។

តើការអះអាងនៃមតិទាំងពីរនេះ មួយណាត្រឹមត្រូវជាង?

ដើម្បីជាគន្លឹះនៃការដោះស្រាយបញ្ហាទាំងពីរខាងលើ យើងគួរយល់អត្ថន័យនៃពាក្យ ” មរណភាព ស្នេហា អំណាចផ្តាច់ការ “ ជាមុនសិន។ **មរណភាព** មានន័យថា ការស្លាប់បាត់បង់ជីវិត។ **ស្នេហា** មានន័យថា គឺជាការស្រលាញ់ពេញចិត្តទៅលើនរណាម្នាក់។ ឯ **អំណាចផ្តាច់ការ** គឺមានន័យថា ការប្រើអំណាច ការសង្កត់ គំរាមកំហែង ពីសំណាក់អ្នកមានអំណាច មកលើអ្នកតូចតាចទន់ខ្សោយ។ដូចនេះអត្ថន័យរបស់ប្រធានខាងលើ ចង់បង្ហាញអោយឃើញថា មតិទី១គឺទុំស្លាប់ព្រោះតែការស្រលាញ់ពេញចិត្តទៅលើនាងទាវ។ ឯមតិទី២គឺទុំស្លាប់ព្រោះតែអំណាច ផ្តាច់ការ គាបសង្កត់ គំរាមកំហែង នៃសង្គមនាសម័យកាលនោះ។

មតិដែលលើកថា “ទុំស្លាប់ព្រោះតែស្នេហា” នោះពិតជាត្រឹមត្រូវណាស់ ព្រោះផ្អែកតាមដំណើររឿង ដែលបានសិក្សាកន្លងមកឃើញថា ននេទុំ និងននេពជ្រ ទៅលក់គោកនៅស្រុកត្បូងឃ្មុំ យាយផាន់បាននិមន្តលោកននេទុំ ទៅស្នូតនៅផ្ទះគាត់។ ពេលទុំកំពុងស្នូត នាងទាវបានអើតក្បាលតាមមាត់បង្អួច ត្រហេបត្រហប រួចប្រើនាងនោរ អោយយកដណ្តប់ទៅប្រគេនននេទុំ។ ហេតុការនេះបានញុំាងអារម្មទុំអោយជាប់ចិត្តស្រលាញ់ទាវតាំងពីពេល នោះមក។ ពេលទុំត្រឡប់មកដល់វត្តវិញ ទុំបានសុំលោកចៅអធិការសឹក តែលោកគ្រូចៅអធិការពុំទាន់អោយសឹកទេ ព្រោះពេលវេលាមិនល្អ។ តែដោយអំណាចនៃអន្លង់សេចក្តីស្នេហា ទុំបានលួចសឹកម្នាក់ឯងក្បែរដំបូក ហើយធ្វើដំណើរទៅស្រុកត្បូងឃ្មុំ ជាមួយពេជ្រ។ ទុំមិនត្រឹមតែលួចសឹកខុសនឹងប្រពៃណីព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ថែមទាំងបួលរួមរ័ក្សស្នេហាខុសប្រពៃណីជាមួយទាវស្រីថែមទៀតផង។ សកម្មភាពនេះបានបណ្តាលអោយស្នេហាដឹកមុខ ងុបងុលពុលវង្វេងភ្លេចអ្វីៗទាំងអស់ ភ្លេចទាំងប្រពៃណីដ៏ល្អរបស់ខ្មែរ ដែលមានតាំងពីបរមបរាណមកម្លេះ។ក្រោយមក នាងទាវត្រូវបានស្តេចវាមាជើងព្រៃ រើសជាស្នំឯក ហើយអោយម៉ឺនទុំច្រៀងកំដរ។ ទុំឆ្លៀតច្រៀងផ្តោះផ្តងស្នេហាជាមួយទាវ ធ្វើអោយស្តេចខ្មាសយ៉ាងខ្លាំង។ ប៉ុន្តែដោយព្រះអង្គមានទសពិធរាជធម៌ព្រះអង្គមិនយកទោសពៃរ៍អ្វីឡើយ ហើយថែមទាំងប្រទានមង្គលការដល់អ្នកទាំងពីរទៀតផង។ ហេតុការនេះធ្វើអោយយាយផាន់ ខឹងក្រេវក្រោតច្រឡោតយ៉ាងខ្លាំង ហើយរកល្បិចបង្ខំនាងទាវអោយមករៀបការជាមួយម៉ឺនងួន។ លឺដំណឹងនេះទុំប្រញាប់សុំរាជានុញ្ញាតពីស្តេចវាមា មកតាមទាវដោយមានទាំងរាជសារមួយផង។ ដល់ហើយទុំបានបីត្រកងស្នេហាជាមួយអូនទាវ ថែមទាំងអោយនាងក្បាច់ស្រានឹងបាតដៃអោយផឹក ដើម្បីបញ្ជាក់ទឹកចិត្តស្នេហាស្រលាញ់ប្តូរផ្តាច់ទង្វើនេះធ្វើអោយយាយផាន់ក្រេវក្រោធយ៉ាងខ្លាំង ហើយបញ្ជាអោយអរជូនយកទុំទៅសំលាប់ចោលយ៉ាងព្រៃផ្សៃនៅក្រោមដើមពោធិមួយ។

សរុបសេចក្តីមក ទុំពិតជាបានស្លាប់ព្រោះតែស្តេចក្តីស្នេហា ជាមួយនាងទាវពិតប្រាកដមែន។

តើទុំពិតជាស្លាប់ដោយសារស្នេហាមែនឬ?

ឯមតិទី២ថា ” ទុំស្លាប់មកពីអំណាចផ្តាច់ការនៃសង្គម “ ពុំមែនមកពីសេចក្តីស្នេហាចំពោះនាងទាវឡើយ បើយើងវិភាគលើសង្គមវិញឃើញថា នាសម័យកាលនោះ គឺសង្គមផ្តាច់ការ ទាំងគ្រួសារ និងប្រទេសជាតិ ទោសប្រហារជីវិតកើតឡើងដោយ ពុំចាំបាច់មានការដោះស្រាយ ឬធ្វើការកាត់ក្តីតាមប្រព័ន្ធតុលាការអ្វីឡើយ។ ឯចំពោះគ្រួសារវិញ មានការគាបសង្កត់ផ្លូវចិត្ត កូនស្រី។ កូនស្រីគ្មានសិទ្ធិជ្រើសរើសគូស្រករដោយខ្លួនឯងទេ ពិសេសដូចយាយផាន់បានអនុវត្តតាមប្រពៃណីតឹងរឹងមួយគឺ នំមិនធំជាងនាឡិ គឺពុំព្រមអោយទាវស្រលាញ់ប្តីដោយចិត្តខ្លួនឯងឡើយ ទោះជាបានការប្រទានមង្គលការពីព្រះរាជាក៏ដោយ។ ម្យ៉ាងទៀតក្នុងសង្គមរស់នៅសម័យនោះ មានការបែងចែកវណ្ណៈ មាន ក្រ ខ្ពស់ ទាប ងប់ងុលនឹងអំណាចមាសប្រាក់ បុណ្យស័ក្តិ គួយ៉ាងដូចជាយាយផាន់ មិនព្រមអោយទាវទៅទុំឡើយ ព្រោះទុំក្រគ្មានទ្រព្យសម្បត្តិ។ ដូនចាស់រូបនេះបានបង្ខំអោយទាវ រៀបការជាមួយម៉ឺនងួន ក៏ព្រោះតែទ្រព្យសម្បត្តិស្តុកស្តម្ភរបស់ងួនដែរ។

ចំពោះអរ ជូន និងម៉ឺនងួនវិញបានដឹងហើយថា ទាវជាប្រពន្ធរបស់ទុំ ដែលស្តេចបានរៀបការអោយ តែនៅហ៊ានបំពានយកនាងទាវមករៀបការម្តងទៀតជាមួយខ្លួន ដោយមិនញញើតដល់អំណាចនៃព្រះរាជាឡើយ ព្រោះអាងថាខ្លួនជា ស្តេចក្រាញ់ដែលមានអំណា

ចដៃរ។ ឃោឃៅជាងនេះទៅទៀតនោះ អរជូនបានបញ្ជាអោយបក្ខពួករបស់ខ្លួន ចាប់ទុំទៅប្រហារដោយគ្មានការជំនុំជំរះអ្វីឡើយ ទោះបីដឹងថាទុំ ជាមនុស្សរបស់ស្តេចរាមាជើងព្រៃក៏ដោយ។

សរុបសេចក្តីមកការស្លាប់របស់ទុំ ពិតជាបណ្តាលមកពី អំណាចផ្តាច់ការក្នុងសង្គមខ្មែរ នាសម័យនោះមែន។

ឆ្លងកាត់តាមការ បកស្រាយខាងលើមតិទី១ និងមតិទី២ សុទ្ធតែមានអំណះអំណាងដូចគ្នាពិតមែន ប៉ុន្តែបើយើងធ្វើការពិនិត្យ ទៅលើខ្លឹមសារ អោយបានស៊ីជំរៅ នោះឃើញថា មរណភាពរបស់ទុំគឺបណ្តាលមកពីអំណាចផ្តាច់ការ នៃសង្គមខ្មែរ នាសម័យសង្វែកដែលជាមូលហេតុជំរុញអោយទុំស្លាប់ មិនមែនមកពីសេចក្តីស្នេហានោះទេ។

ជាបញ្ចប់នេះ មតិរបស់ប្រធានទាំង២ខាងលើ គឺមតិទី១មិនទាន់ត្រឹមត្រូវទាំងស្រុងទេ ឯមតិទី២ត្រឹមត្រូវជាង តែមតិទី១ក៏មានប្រយោជន៍ សំរាប់អ្នកសិក្សា និងយុវវ័យជំនាន់ក្រោយ អោយចេះពិចារណា មុននឹងប្រព្រឹត្តិនូវសេចក្តីស្នេហា ចៀសវាងការងុបងុលនឹងស្នេហា ភ្លេចការរៀនសូត្រ និងការងារផ្សេងៗទៀត ពិសេសគឺប្រពៃណីវប្បធម៌។ ឯមតិទី២ ក៏បានផ្តល់ទពិសោធជាច្រើនដល់យើងគ្រប់គ្នា គឺអោយចេះគោរពសិទ្ធិសេរីភាពចៀសវាងការស្អប់ខ្ពើម ជិះជាន់កេងប្រវ័ញ្ច បែងចែកវណ្ណៈ ដើម្បីអោយការរស់នៅទទួលបានសុខសុកមង្គល៕

ប្រធានទី៤ ៖ សុភាសិតមួយពោលថា "ល្អពុម្ព ទើបល្អព្រះ" ចូរបកស្រាយ។

សេចក្តីអធិប្បាយ

ដើម្បីរស់នៅបានមនុស្ស តែងមានរបរចិញ្ចឹមជីវិតផ្សេងៗពីគ្នា ខ្លះធ្វើការរាជការ ស្រែចំការ និងរបរដាប់ឆ្លាក់ចាក់ពុម្ពរូបជាជើម ដើម្បីអោយរូបដែលចាក់ចេញមកបានល្អស្អាតទាល់តែអ្នកចាក់ប្រើពុម្ព ស្អាតដែរ។ អាស្រ័យហេតុនេះហើយទើបមានសុភាសិតមួយពោលថា "ល្អពុម្ព ទើបល្អព្រះ" ។

តើសុភាសិតខាងលើនេះមានអត្ថន័យខ្លឹមសារយ៉ាងដូចម្តេច?

ដើម្បី កុំអោយយល់ច្រឡំក្នុងការដោះស្រាយបញ្ហាខាងលើយើងគប្បី យល់អត្ថន័យនៃពាក្យ "ពុម្ព" ជាមុនសិន។ "ពុម្ព" គឺជាប្រដាប់សំរាប់ចាក់រូបផ្សេងៗ ដូចជារូបព្រះជាដើម។
ប្រ ធានបទខាងលើ មានន័យថា រូបព្រះពុទ្ធបដិមាទាំងឡាយ ដែលស្អាតសមសួនតាមលក្ខណៈ អាស្រ័យលើពុម្ពនោះស្អាតល្អត្រឹមត្រូវដែរ។

ជាការពិតណាស់ ពាក្យថា "ល្អពុម្ព ទើបល្អព្រះ" នៅទីនេះសំដៅលើការប្រកបរបរសិប្បកម្មផលិតរូបព្រះពុទ្ធបដិមា ដោយប្រើពុម្ពចាក់បង្កើតឡើង។ ដើម្បីបានរូបព្រះពុទ្ធបដិមាស្អាតបាត សិប្បករទាំងឡាយគប្បីកែឆ្នៃ ឬផលិតឧបករណ៍ចាក់ពុម្ពរូបអោយបានស្អាតឥតខ្ចោះជាមុនសិន ទើបការចាក់ ពុម្ពរូបព្រះចេញមកបានស្អាតតាមនោះដែរ។ បើពុម្ពមិនល្អត្រឹមត្រូវ ខុសទម្រង់បែបបទ រូបព្រះដែលចាក់ពីពុម្ពនោះក៏ខុសទៅតាមនោះដែរ មានន័យថា ជារូបព្រះមិនល្អស្អាត មិនសមនិងតម្រូវការមនុស្ស។ ហើយបើពុម្ពប្រេះបែកឆែប រូបព្រះដែលចាក់ចេញពីពុម្ពទាំងនោះ ក៏មានស្នាមដូចពុម្ពដែរ។ ឃើញដូចនេះ ហើយ ទើបចាស់ទុំបង្កើតពាក្យពេចន៍ប្រៀនប្រដៅថា "ល្អពុម្ព ទើបល្អព្រះ" ។

ពាក្យ ពុម្ពប្រៀបធៀបទៅនិងមាតាបិតា អាណាព្យាបាល អ្នកគ្រប់គ្រង ឯពាក្យព្រះ ប្រៀបធៀបទៅនិងកុលបុត្រកុលធីតាទាំងឡាយ។ "ល្អពុម្ព ទើបល្អព្រះ" នៅក្នុងន័យធៀបគឺចង់បញ្ជាក់ពី ទំនាក់ទំនងនៃការរស់នៅ ក្នុងគ្រួសារ រវាងឪពុកម្តាយ និងកូនចៅប្រុសស្រី។ ក្នុងការរស់នៅនេះ មាតាបិតា គ្រូឧបជ្ឈាយាចា អ្នកគ្រប់គ្រង មានទួនាទីក្នុងការអប់រំនែនាំ កូនចៅប្រុសស្រី ដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ បើអ្នកទាំងនោះចាអ្នកគ្រប់គ្រងមិនបានសង្កេតពិនិត្យការរស់នៅ ឬធ្វេសប្រហែសក្នុងការនែនាំដល់កូនចៅ ធ្វើអោយកូនចៅទាំងឡាយ និងក្លាយទៅជាមនុស្សមិនល្អ ចូលចិត្តប្រព្រឹត្តិអំពើមិនសមរម្យ ល្មើសច្បាប់ ដែលនាំអោយមានទុក្ខទោសដល់ខ្លួននិងក្រុមគ្រួសារ។ ដូនកាលមាតាបិតា អាណាព្យាបាល ទាំងឡាយនោះជាមនុស្សមិនល្អ ប្រព្រឹត្តិអំពើមិនល្អជាគំរូដល់កូនចៅ។ ដូនកាលទៀតមានតាបិតាខ្លះ ធូររលុង ដោយការស្រលាញ់កូនពេក ទំរើសកូនៗអោយភ្លើតភ្លើនភ្លេចអ្វីដែលល្អត្រឹមត្រូវ។ ដូចនេះអាកប្បកិរិយាឆ្គាំឆ្គងរបស់កូនចៅ បណ្តាលមកពីម៉ែឪ អាណាព្យាបាលមិនអប់រំ នែនាំអោយបានត្រឹមត្រូវ សមដូចពាក្យចាស់ថា "ឪអាចារ្យ កូនអាចារ្យ ឯឪជាចោរកូនក៏អាចជាចោរដែរ"។ជាក់ស្តែង ក្នុងអក្សរសិល្បខ្មែររឿងកុលាបប៉ៃលិន ដោយតាមចើមជាមនុស្សល្អ និងចេះអប់រំផ្តល់គំនិតល្អៗ ធ្វើអោយចៅចិត្តក្លាយជាយុវជន ល្អមួយរូបគួរអោយកត់សំគាល់ និងគួរជាទីស្រលាញ់រាប់អាន។ ចំណែកលោកបាឡាត់ស្រុកសង្កែវិញ ដោយខ្វះការអប់រំ និងទទួលបានការទំរើសពីសំណាក់មាតាបិតា ធ្វើអោយគេក្លាយជាមនុស្សទំនើង មានចរិតក្អេងក្អាង ប្រហើនកោងកាច មិនល្អ ប្រព្រឹត្តអំពើខុសច្បាប់ជាទម្ងន់។ ដូចនេះក្នុងការរស់នៅរបស់មនុស្សគ្រប់ក្រុមគ្រួសារ បើអាណាព្យាបាល ជាមនុស្សល្អ កូនចៅដែលនៅក្រោមឱវាត ក៏ជាមនុស្សល្អដែរ។

សរុបសេចក្តីមក ធ្វើពុម្ពសំរាប់ចាក់រូបព្រះបានស្អាត ទើបចាក់ចេញ ឬបង្កើតរូបព្រះបានស្អាត ឯមាតាបិតាជាមនុស្សល្អ កូនចៅក៏និងក្លាយជាមនុស្សល្អជាក់ជាមិនខាន។

ឆ្លង តាមការបកស្រាយបញ្ជាក់ខាងលើ សុភាសិតបុរាណមួយឃ្លានេះ ពិតជាមានអត្ថន័យខ្លឹមសារត្រឹមត្រូវ ព្រោះបានអប់រំនែនាំមាតាបិតាអាណាព្យាបាល ទាំងអស់អោយខិតខំ ប្រៀនប្រដៅ និងកសាងខ្លួនអោយក្លាយជាមនុស្សល្អ ជាគំរូដល់កូនចៅ ឯកូនចៅវិញត្រូវចេះគោរពស្តាប់បង្គាប់ យកគំរូល្អតាមមាតាបិតា អាណាព្យាបាលរបស់ខ្លួន។ ដូចនេះខេមរមេត្រធីតាទាំងឡាយ គប្បីព្យាយាមស្តាប់បង្គាប់ អាណាព្យាបាល គ្រូឧជ្ឈាយាចា អោយបានល្អ ត្រឹមត្រូវ បើម្បីក្លាយជាយុវជនល្អ និងជាមេដឹកនាមល្អ របស់ប្រទេសជាតិ៕

ប្រធានទី៥ ៖ សុភាសិតមួយពោលថា "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប" ចូរបកស្រាយ។

សេចក្តីអធិប្បាយ

មនុស្សគ្រប់រូបមិនអាចជៀសផុតពីសេចក្តីស្លាប់បានឡើយ តែមុននិងស្លាប់មនុស្សគប្បីបន្សល់ទុកនូវស្នាដៃ ល្អៗ និងពោរពេញដោយកេរ្តិ៍ឈ្មោះបោះសំលេង បើនៅរស់វិញ មនុស្សគប្បីកែខៃជីវិត អោយប្រសើរថ្លៃថ្លា និងអភិវឌ្ឍន៍រីកចំរើន។ អាស្រ័យហេតុនេះហើយ ទើបមានសុភាសិតមួយពោលថា "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប"។

តើសុភាសិតខាងលើមានអត្ថន័យខ្លឹមសារយ៉ាងដូចម្តេច?

ដើម្បី កុំអោយយល់ច្រឡំ ក្នុងការដោះស្រាយ បញ្ហាខាងលើ យើងគប្បីយល់អត្ថន័យនៃពាក្យ "រស់ និងស្លាប់" អោយបានច្បាស់លាស់ជាមុនសិន។ រស់ គឺជាការរក្សាជីវិតអោយគង់នៅ។ ស្លាប់ គឺការរលត់ផុតសង្ខារ។ប្រធានបទខាងលើមានន័យថា គ្រប់

មនុស្សទាំងឡាយត្រូវស្លាប់ ដោយបន្សល់ទុកនូវកេរ្តិ៍ឈ្មោះ ល្អប្រពៃ ហើយត្រូវរស់ដោយភាពថ្លៃថ្នូរ និងអភិវឌ្ឍន៍ មិនត្រូវស្លាប់ហើយ និងរស់នៅដោយឥតប្រយោជន៍ ឥតន័យខ្លឹមសារនោះទេ។

ជាការពិតណាស់ ពាក្យថា "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប" គឺសំដៅលើសត្វពស់។ ពស់ ជាសត្វល្មូនមួយប្រភេទ ដែលខ្លះគ្មានពិស ហើយខ្លះមានពិសខ្លាំងក្លាគួរអោយខ្លាច អាចដាំសំលាប់ជីវិតមនុស្សបាន។ ដូចនេះ មនុស្សគ្រប់គ្នាកាលបើឃើញសត្វពស់នេះហើយ តែងតែវាយសំលាប់ ដោយឥតពិចារណាឡើយ ហើយពស់ត្រូវបានស្លាប់ដោយគ្មានការតវា ឬសំលេងថ្ងូរថ្ងួចអ្វីនោះទេ។ ហើយការស្លាប់របស់សត្វពស់នេះ មិនបានសន្សល់ទុកអ្វីដែលជា កេរដំណែលនិងជាស្នាដៃ សូម្បីបន្តិចក៏គ្មានដែរ មានតែការខ្លាចរអា និងការស្អប់ខ្ពើមតែប៉ុណ្ណោះ។ ដូចនេះការស្លាប់របស់ពស់ គឺស្លាប់ដោយគ្មានតំលៃ គ្មានន័យខ្លឹមសារ និងគ្មានការអាណិតអាសូរ ពីសំណាក់មនុស្សដែលបានឃើញ បានជួបពីភាពកាចសាហាវរបស់វានោះទេ។

ឯសត្វកង្កែបវិញ ជាប្រភេទសត្វលោតស៊ីសត្វល្អិតជាអាហារ ស្លូតគ្មានពិស និងមិនអាចធ្វើអ្វីដែលប៉ះពាល់ដល់ជីវិតអ្នកណាម្នាក់ឡើយ។ តែការរស់នៅរបស់សត្វប្រភេទនេះ ក៏មិនបានសុខជា មិនបានរស់ដោយស្រួលនោះទេ ព្រោះវាជាសត្វមិនឆ្លាត វារស់នៅក្នុងរន្ធ តែវាមិនអាចមានសមត្ថភាព ជីកកកាយបង្កើតរន្ធ ដើម្បីជីវិតរស់នៅរបស់វាទេ គឺវាតែងតែ ចូលរស់នៅក្នុងរន្ធក្តាម និងរន្ធសត្វផ្សេងៗ ដែលទំនេរ។ ជួនកាលវារស់នៅតាមគម្ពោតក្បែរមាត់ទឹក។ កង្កែបគ្មានពិសគ្មានចង្កូម គ្មានធ្មង់ សំរាប់ការពារខ្លួនរបស់វាទេ ជាហេតុធ្វើអោយវាងាយក្នុងការយោយីដល់ជីវិតរបស់វាពីសំណាក់ មនុស្ស និងសត្វដទៃទៀត។ ដូចនេះការរស់នៅរបស់កង្កែបពោពេញដោយភាពភិតភ័យ និងគ្មានការអភិវឌ្ឍន៍ ជីវិតរស់នៅអោយបានល្អឡើយ។

ឯពាក្យ "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប" ក្នុងន័យធៀបវិញ គឺសំដៅការរស់ និងការស្លាប់របស់មនុស្ស។ គឺមានន័យថា មនុស្សគប្បី បន្សល់ទុកនូវស្នាដៃ និងកេរដំណែលផ្សេងៗ ដែលខ្លួនខំកែច្នៃរកវិធីបង្កើតឡើង កាលពីខ្លួននៅរស់។ ដូចនេះមនុស្សគប្បី ឧស្សាហ៍ ព្យាយាម ធ្វើការងារ ផ្សេងៗជាច្រើន។ ដៀសវាងការស្លាប់ទៅដោយសោះសូន្យទទេ គ្មានបន្សល់ទុកអ្វីក្រៅពីកេរ្តិ៍ឈ្មោះអាក្រក់ ស្អុយរលួយងំ គួរអោយស្អប់ខ្ពើមដែលជារឿងមិនល្អ។ ឯកុំរស់ដូចកង្កែបវិញ គឺមានន័យថា មនុស្សម្នាគ្រប់សញ្ជាតិទាំងអស់ គប្បីចេះកែខៃការរស់នៅ អោយបានល្អប្រសើរ អភិវឌ្ឍន៍រីកចំរើន មានសេរីភាព និងសុភមង្គល។ គឺមនុស្សមិនត្រូវរស់ដោយពឹងលើកំម្លាំងអ្នកដទៃ រស់ស្តាប់តាមតែការបញ្ជារបស់គេ ឬរស់នៅក្រោមការប្រមាថមើលងាយ ជិះជាន់ កៀបសង្កត់ សព្វបែបយ៉ាង ទាំងផ្លូវកាយវាចាចិត្ត ហើយចេះតែសង្ឃឹទ្រាំ រស់ដោយគ្មានការតស៊ូ រើបំរាសផ្លាស់ប្តូរជោគវាសនារបស់ខ្លួន។ ដូចនេះមនុស្សត្រូវរស់ដោយកិត្តិយសថ្លៃថ្នូរ បើស្លាប់ក៏ត្រូវបន្សល់ទុកនូវកេរ្តិ៍ឈ្មោះ ល្អប្រសើរ តួយ៉ាងដូចជាសម្តេចសង្ឃរាជដួណាត ថ្វីត្បិតព្រះអង្គបានសុគត ចាកលោកនេះយ៉ាងយូរណាស់ទៅហើយក្តី ក៏កិត្តិស័ព្ទរបស់ព្រះអង្គ នៅតែល្បីរន្ទឺសុះសាយ គ្មានថ្ងៃនិងសាបសូន្យឡើយ ក៏ព្រោះតែស្នាដៃទាំងឡាយ ដែលព្រះអង្គបានបន្សល់ទុក មុនពេលសុគត។ ដូចនេះមនុស្សត្រូវតែកែច្នៃជីវិតរស់នៅអោយបានថ្លៃថ្នូរ និងត្រូវបង្កើតស្នាដៃ ទុកជាកេរដំណែលសំរាប់កូនចៅជំនាន់ក្រោយ។

សរុបសេចក្តីមក មនុស្សមិនត្រូវស្លាប់ដោយឥតប្រយោជន៍ ហើយក៏មិនត្រូវរស់ដោយ ឥតន័យខ្លឹមសារនោះដែរ។

ឆ្លងតាមការបក ស្រាយខាងលើឃើញថា ប្រធានបទនេះ ពិតជាមាន អត្ថន័យល្អត្រឹមត្រូវ សំរាប់ទូន្មានដល់ជន្មានុជនទាំងឡាយ អោយចេះខ្វល់ខ្វាយ កែច្នៃជីវិតរស់នៅអោយបានល្អ និងខិតខំបង្កើតស្នាដៃ ផ្សេងៗ ទុកជាកេរដំណែល ដល់កូនចៅជំនាន់ក្រោយ មុននិងខ្លួនលាចាកលោកនេះទៅ។ ដូចនេះកុលបុត្រកុលធីតាខ្មែរទាំងឡាយអើយ គួរខិតខំរៀនសូត្រ បង្កើតស្នាដៃល្អៗ សំរាប់ការរស់នៅរបស់ខ្លួនផង សំរាប់ជាកេរដំណែលទុកអោយកូនចៅក្នុងពេលអនាគតផង ៕

ប្រធានទី៦៖ សុភាសិតមួយបានពោលថា"ចង់ចេះអោយសំលាប់អាចារ្យ ចង់បានផ្លែផ្កាអោយយកភ្លើងដុតគល់" ចូរបកស្រាយ។

សេចក្តីអធិប្បាយ

អ្នកសិក្សាគ្រប់រូបតែងតែ ចូលជួបនឹងគ្រូបាអាចារ្យ ដើម្បីក្រេបជញ្ជក់យកចំណេះវិជ្ជា ឯការដាំរុក្ខជាតិទាំងឡាយក៏ដូច្នោះដែរ ដើម្បីទទួលបានផ្លែផ្កាត្រូវមើលថែ ស្រោចទឹកដាក់ជី។ អាស្រ័យហេតុនេះហើយទើបមានសុភាសិតមួយឃ្លាពោលថា "ចង់ចេះអោយសំលាប់អាចារ្យ ចង់បានផ្លែផ្កាអោយយកភ្លើងដុតគល់" ។

តើសុភាសិតខាងលើមានអត្ថន័យខ្លឹមសារយ៉ាងដូចម្តេច?

ដើម្បី កុំអោយយល់ច្រឡំក្នុងការដោះស្រាយបញ្ហាខាងលើ យើងគួរយល់អត្ថន័យនៃពាក្យ "អាចារ្យ និងផ្លែផ្កា" ជាមុនសិន។ "អាចារ្យ" គឺអ្នកបង្ហាត់បង្រៀន ប្រៀនប្រដៅ។ ឯពាក្យ" ផ្លែផ្កា" គឺផលដែលទទួលបានពីការដាំដុះ។ ប្រធានខាងលើមានន័យថា ចំណេះដឹង និងបំនិនល្អៗទាំងឡាយសុទ្ធសឹងតែ ទទួលបានពីការបង្ហាត់ បង្រៀន របស់គ្រូអាចារ្យ ឯផ្លែផ្កាទាំងអស់ គឺទទួលបានពីការដាំដុះ និងការមើលថែទាំ។

ជាការពិតណាស់ ពាក្យថា "ចង់ចេះអោយសំលាប់អាចារ្យ ចង់បានផ្លែផ្កាអោយយកភ្លើងដុតគល់" នៅទីនេះបញ្ជាក់ថា សំលាប់អាចារ្យ គឺមិនមែនអោយើងសំលាប់អាយុសង្ខារបស់គ្រូអាចារ្យ ដែលជាអ្នកបង្ហាត់បង្រៀននោះទេ គឺអោយសំលាប់ពេលវេលា កាពខ្ជិលច្រអូស សេចក្តីល្ងង់ខ្លៅ និងការងឿងឆ្ងល់ផ្សេងៗត្រូវសួរដេញដោលពីគ្រូបាអាចារ្យទាំងឡាយ នោះអោយបានច្បស់លាស់អោយអស់សេចក្តី ប៉ុន្តែបើយើងខ្ជិលច្រអូស មិនចូលចិត្តហ្វឹកហាត់ រៀនសូត្រស្តាប់គ្រូអាចារ្យ នោះយើងនិងពុំមានចំណេះដឹង អ្វីបន្តិចបន្តួចឡើយ។

ឯពាក្យ "ចង់បានផ្លែផ្កាយកភ្លើងដុតគល់" វិញនោះសំដៅលើ រុក្ខជាតិមួយចំនួន ដូចជាដើមដូង ប្រសិនបើវាអន់ខ្សោយក្នុងការលូតលាស់ ឬគ្មានផ្លែផ្កានោះ គឺបណ្តាលមកពីវាឡើងគល់ និងខ្វះជីវជាតិផ្សេងៗ ដូចនេះយើងគប្បីប្រមូលសំរាម កំទេចស្លឹកឈើស្ងួតៗ មកដាក់ដុតជុំវិញគល់របស់វា តែមិនដុះច្រើន ឬ យូពេកនោះទេ កាកសំណល់ពីការដុះគឺជាផេះដែលជាជី សំរាប់ដាក់គ្រប់រុក្ខជាតិ។ ក្រោយពេលដុះហើយត្រូវភ្លៀងធ្លាក់ ឬស្រោចទឹក ធ្វើអោយដើមដូងនោះមានផ្លែផ្កាវិញជាប្រក្រតី ។

ឯដើមឬស្សី វិញ កាលណាវាស្មោគ ក្រិន មិនមានដើមធំ មានតែដើមតូចៗ ដែលជាហេតុបាត់បង់ប្រយោជន៍ និងតម្រូវការប្រើប្រាសរបស់មនុស្សនោះ ដើម្បីទទួលបានដើមឬស្សីធំៗ សំរាប់បំពេញតម្រូវការជាប្រយោណន៍ យើងគប្បីយកភ្លើងដុតរហូតដល់ឆេះអស់ឬស្សីទាំងគុម្ព ហើយការដុះបែបនេះ មិនមែនជាការបំផ្លិចបំផ្លាញនោះទេ គល់ឬស្សីទាំងនោះនិងដុះជាទំពាំងធំៗ ជាច្រើនមកវិញ ក្រោយពេលភ្លៀងធ្លាក់ក្នុងរដូវវស្សា ដូចនេះការដុះគល់ពិតជាបានទទួលផ្លែផ្កាពិតមែន។

រីពាក្យថា ចង់ចេះអោយសំលាប់អាចារ្យ ក្នុងន័យធៀបវិញគឺ សំដៅលើការខិតខំតស៊ូព្យាយាមសិក្សារៀនសូត្រជំនះនូវភាពល្បាក និងជំនះលើកិច្ចការទាំងឡាយដែលគ្រូអាចារ្យបានដាក់អោយ ហើយទទួលនូវចំនេះវិជ្ជាយ៉ាងពិតប្រាកដ។ នេះហើយគឺសំលាប់អាចារ្យ។ ចំណែកពាក្យ យកភ្លើងដុះគល់ វិញគឺសំដៅលើការដាំដុះដំណាំបន្លែបង្គាគ្រប់ប្រភេទ បើចង់បានផលល្អច្រើនអ្នកដាំគប្បីមើលថែគល់ ដោយជ្រោយជីស្រោចទឹកដាក់ជី ទើបដំណាំទាំងឡាយនោះ លូតលាស់និងធំធាត់ឆាប់រហ័ស ហើយផ្តល់នូវផលប្រយោជន៍ ជាផ្លែផ្កាយ៉ាងច្រើនសន្ធឹកសន្ធាប់។ បើដាំដំណាំហើយ តែបែជាខ្ជិលច្រអូស មិនមើលថែដំណាំទាំងនោះ វានិងអាចងាប់បាត់ជាអសាបង់ ធ្វើអោយយើងខាតបង់ពេលវេលា និងដើមទុន។ ដូចនេះក្នុងការដាំដំណាំ គឺត្រូវតែមានការមើលថែជាដាច់ខាត ទើបអាចទទួលបានផលជាផ្លែផ្កាបាន។ជាក់ស្តែងក្នុងប្រវត្តិ សាស្ត្រខ្មែរ បានបញ្ជាក់ប្រាប់ថា ព្រះនាងឥន្ទ្រទេវី និងសម្តេចព្រះសង្ឃរាជជួនណាត ដោយការចូលចិត្តសិក្សារៀនសូត្រ ពីគ្រូអាចារ្យធ្វើអោយព្រះអង្គទាំងពីរអង្គ ទទួលបានចំណេះដឹងយ៉ាងខ្ពង់ខ្ពស់ ជាទីបំផុត។ ឯប្រជាកសិករទាំងអស់ ដោយការឧស្សាហ៍ព្យាយាមដាំដុះ និងធ្វើស្រែចំការ ហើយថែមទាំងការព្យាយាមមើលថែទាំដំណាំទាំងឡាយនោះ ធ្វើអោយពួកគាត់ទទួលបាននូវភោគផលយ៉ាងច្រើនសន្ធឹកសន្ធាប់សំរាប់ ផ្គត់ផ្គង់ជីវភាពរស់នៅក្នុងជីវភាពគ្រួសារ។ ដូច្នេះបើចង់បានចំណេះដឹង គ្រប់អ្នកសិក្សាទាំងអស់គប្បីចូលជិតគ្រូបាអាចារ្យ ដើម្បីសាក់សួរ សិក្សារៀនសូត្រ អោយបានច្បាស់លាស់។អ្នកដាំដុះវិញគប្បីថែ រក្សា គល់ដំណាំទាំងនោះទើបទទួលបានផ្លែផ្កា។

សរុបសេចក្តីមក ការរៀនសូត្រពីគ្រូអាចារ្យ ធ្វើអោយយើងមានចំណេះដឹង ហើយការចេះដាំ និងចេះថែរក្សាដំណាំធ្វើអោយយើងទទួលបានផលជាផ្លែផ្កា។

ឆ្លងតាមការបកស្រាយខាងលើ ប្រធានបទនេះពិតជាមានអត្ថន័យខ្លឹមសារ ត្រឹមត្រូវសំរាប់អប់រំ ទូន្មាន ប្រៀនប្រដៅ កូនចៅអោយមានចរិតឧស្សាហ៍ព្យាយាម រៀនសូត្រ និងចេះធ្វើការងារដាំដុះផ្សេងៗ។ ដូចនេះកុលបុត្រកុលធីតាទាំងឡាយ គប្បីប្រឹងប្រែងរៀនសូត្រ ត្រង់ត្រាប់ស្តាប់គ្រូពន្យល់ នៃនាំ ដើម្បីទទួលបានផលប្រយោជន៍ ជាទីគាប់ចិត្ត។

ប្រធានទី៧៖សុភាសិតមួយពោលថា "ស្លឹកឈើជ្រុះមិនធ្លាយពីគល់" ចូរបកស្រាយ។

សេចក្តីអធិប្បាយ

ជាទូទៅ រុក្ខជាតិទាំងឡាយ តែងវិវត្តន៍លូតលាស់ និងរុះរោយស្លឹកតាមធម្មជាតិរបស់វា ហើយស្លឹកទាំងឡាយដែលជ្រុះនោះ វាមិននៅធ្លាយពីដើម និងគល់របស់វាប៉ុន្មានទេ ប្រសិនបើគ្មានកំលាំងរុញ ច្រានពីខ្យល់។ អាស្រ័យហេតុនេះហើយ ទើបមានសុភាសិតមួយពោលថា "ស្លឹកឈើជ្រុះមិនធ្លាយពីគល់"។

តើសុភាសិតខាងលើនេះ មានអត្ថន័យខ្លឹមសារដូចម្តេច?

ដើម្បីចៀសវាងការយល់ច្រឡំក្នុងការដោះស្រាយប្រធានបទខាងលើ យើងគួរយល់អត្ថន័យនៃពាក្យ "**ជ្រុះ**"អោយច្បាស់លាស់ជាមុនសិន។ ជ្រុះ គឺជាការដាច់ ឬរបូតធ្លាក់ពីលើមកក្រោម។ប្រ ធានខាងបទខាងលើ មានន័យថា គ្រប់ស្លឹករុក្ខជាតិទាំងឡាយដែលរុះរោយចាកមែក គឺមិនដែលទៅណាធ្លាយពីគល់របស់វាឡើយ។ ជាការពិតណាស់ ពាក្យថា ស្លឹកឈើជ្រុះមិនធ្លាយពីគល់ នេះគឺសំដៅទៅលើរុក្ខជាតិទាំងអស់ដែលដុះលូតលាស់ និងរុះរោយស្លឹកចាស់ ដើម្បីដុះនូវស្លឹកថ្មី ជាធម្មតា ស្លឹករុក្ខជាតិដែលជ្រុះទាំងនោះ បណ្តាលមកពីស្លឹកចាស់ ឬទុំ ជួនកាលទៀតការត្រូវកំដៅ ក្នុងបរិយាកាសធ្វើអោយដាច់របេះ ជ្រុះចាកមែក តែការជ្រុះធ្លាក់របស់វា គឺមិនអាចទៅណាធ្លាយពីគល់របស់វាបានឡើយ។ ស្លឹកឈើឬស្លឹករុក្ខជាតិទាំងឡាយ មិនអាចកំរើក ឬធ្វើចលនា ផ្លាស់ទីដោយខ្លួនឯងបានទេ ហេតុនេះហើយទើបវាធ្លាក់នៅក្បែរគល់របស់វា។

ឯពាក្យ "ស្លឹកឈើជ្រុះមិនធ្លាយពីគល់" ក្នុងន័យធៀបវិញ គឺគល់ឈើប្រៀបធៀបទៅនឹងមាតាបិតា អាណាព្យាបាល ឯស្លឹកឈើធៀបទៅនឹងកូនចៅប្រុសស្រី។ ពាក្យខាងលើមានអត្ថន័យត្រង់ៗ ចំពោះការរស់នៅ របស់មនុស្សក្នុងគ្រួសារ រវាងឪពុកម្តាយ អាណាព្យាបាល និងកូនចៅ។ បើមាតាបិតា ទាំងអស់ជាអ្នកប្រព្រឹត្តអំពើល្អ ស្មោះត្រង់ សមរម្យ ហើយជាមនុស្សដែលមានប្រយោជន៍

ក្នុងសង្គមជាតិ កូនចៅទាំងអស់រស់ក្រោមឱវាទគល់ណា និងក្លាយជាមនុស្សបែបនោះដែរ។ ប្រសិនបើអ្នកដឹកនាំ មានមាតាបិតាជាដើមនោះ ជាមនុស្សមិនល្អប្រព្រឹត្តអំពើមិនគប្បី ទោះជាគាត់បាននែនាំអោយកូនធ្វើតាម ឬមិននែនាំអោយធ្វើតាមក្តី អំពើទាំងនោះវាជាគំរូអាក្រក់ដែលកូនចៅបានឃើញជាប្រចាំ ហើយដោយនៅវ័យក្មេងខ្ចី មិនទាន់ដឹងអំពីអ្វីដែលល្អ ឬអាក្រក់ច្បាស់លាស់ ក៏នាំគ្នាប្រព្រឹត្តនូវ អំពើទាំងឡាយនោះ ដូចឪពុកម្តាយរបស់ខ្លួនដែរ។ ជាក់ស្តែងក្នុងអក្សរសិល្ប៍ខ្មែររឿងកុលាបប៉ៃលិនដោយតាចឹមជា មនុស្សល្អ ប្រព្រឹត្តល្អ និងផ្តល់ដំបូលន្ទានល្អ ធ្វើអោយចៅចិត្រជាកូន ក៏បានក្លាយជាមនុស្សល្អ ថ្លៃថ្នូរ និងជាមនុស្សដែលមានប្រយោជន៍ដល់សង្គមជាតិ។ ចំណែកឯលោកបាឡាត់ស្រុកសង្កែវិញ ដោយការខ្វះការនែនាំពីឪពុកម្តាយធ្វើអោយគេក្លាយជាមនុស្សមួយរូប ដែលចូលចិត្ត ប្រព្រឹត្តនូវអំពើអាក្រក់គួរអោយស្អប់ខ្ពើម ដូចនេះបើឪពុកម្តាយជាមនុស្សល្អ កូនចៅក៏ជាមនុស្សល្អ បើមាតាបិតាជាមនុស្សមិនល្អ កូនចៅក៏ជាមនុស្សមិនល្អដូចគ្នាដែរ សរដូចពាក្យចាស់ពោលថា "ឆ្នាំងណាគ្របនឹង" ឬក៏ "នៅជាមួយអាចារ្យគឺអាចារ្យ នៅជាមួយចោរគឺកើតជាចោរ" ។

សរុប សេចក្តីមក "ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់" ឯកូនចៅប្រុសស្រីក៏មានចរិកលក្ខណៈមិនខុសពីអាណាព្យាបាលដែរ។

ឆ្លងតាមការបកស្រាយខាងលើ ប្រធានបទនេះមានអត្ថន័យខ្លឹមសារ ត្រឹមត្រូវ សំរាប់អប់រំមនុស្សគ្រប់ស្រទាប់វណ្ណៈអោយចេះធ្វើអំពើល្អ ជាគំរូដល់កូនចៅនិងចេះនែនាំកូនចៅអោយប្រព្រឹត្តអំពើល្អត្រឹមត្រូវ។ដូចនេះកុលបុត្រកុលធីតាទាំងឡាយ គប្បីប្រព្រឹត្តនូវអំពើល្អ ដើម្បីក្លាយខ្លួនជាយុវជនល្អ ដែលមានប្រយោជន៍សំរាប់សង្គមជាតិ៕

ប្រធានទី៨៖ពាក្យចាស់បុរាណមួយឃ្លាពោលថា "កុំទុំមុនស្រគាល"តើពាក្យនេះមានអត្ថន័យ ដូចម្តេច?

ចូរពន្យល់។ (ថ្នាក់ទី១២)

សេចក្តីអធិប្បាយ

មនុស្ស សត្វរុក្ខជាតិទាំងអស់ដែលរស់នៅលើផែនដីនេះ តែងតែមានការរីកចំរើនលូតលាស់ ទៅមុខជាលំដាប់ឥតឈប់ឈរតាមធម្មជាតិកំណត់អោយទីទៃៗពីគ្នា ហើយការរីកលូតលាស់ដុះដាលនេះ ទាល់តែត្រូវតាមលក្ខណៈ និងតំណាក់កាលរបស់វាទើបល្អ។ អាស្រ័យហេតុនេះហើយទើបមានពាក្យ មួយឃ្លាពោលថា **"កុំទុំមុនស្រគាល"** ។

តើពាក្យខាងលើនេះមានអត្ថន័យបែបណា?

ដើម្បីសំរួលដល់ការដោះស្រាយបញ្ហាអោយកាន់តែច្បាស់លាស់ យើងគួរយល់អត្ថន័យនៃពាក្យ "ទុំ និង ស្រគាល" ជាមុនសិន។ **"ទុំ"** គឺសំដៅលើផ្លែរុក្ខជាតិដែលវិវឌ្ឍន៍ ពីខ្ចីចាស់ និងស្រគាល ទើបក្លាយជាទុំអាចយកមកប្រើប្រាស ឬអាចបន្តពូជក្នុងការដាំដុះបាន។ រីឯ**"ស្រគាល"** គឺសំដៅលើផ្លែរុក្ខជាតិទាំងឡាយ លើសពីភាពចាស់ តែមិនទាន់ទុំ ដើម្បីដល់ការទុំផ្លែឈើទាំងឡាយត្រូវឆ្លងកាត់ ភាពស្រគាល ឬហៅថា ទុំស្ទើៗជាមុនសិន។

ពាក្យថា ទុំមុនស្រគាលនេះ មានន័យថា គ្រប់ផ្លែឈើត្រូវលួតលាស់ ពីក្តឹបទៅផ្លែធំ ហើយចាស់បន្ទាប់មកវាទុំមិនទាន់ល្អដែលហៅថា ស្រគាល រួចក្លាយទៅជាទុំសុះសាច់ល្អ។ តែបើទុំមុនស្រគាលមានតែផ្លែឈើនេះ មានលក្ខណៈខុសប្រក្រតី អាចនិងថាវាបាក់មែក ឬសត្វផ្សេងៗទិច ឬខាំយូរទៅ ធ្វើអោយវាទន់ជ្រាយ ទៅជាទុំដោយមិនពេញលក្ខណៈរបស់វា ហើយផ្លែឈើដែលទុំបែបនេះ មិនមានរស់ជាតិឆ្ងាញ់ និងមិនប្រយោជន៍ក្នុងការយកទៅដាំដុះវិញទៀតកើតនោះទេ។

ឯក្នុង នយធៀបវិញ ទុំមុនស្រគាលនេះ គឺផ្តោតចំពោះត្រង់ទៅលើបុត្រធីតា ទាំងឡាយដែឡហ៊ាន ប្រព្រឹត្តិអំពើខុសឆ្គងប្រាសចាកខុសពីប្រពៃណី ទំនៀមទំលាប់ពូជសាសន៍របស់ខ្លួន ដូចជាការលបលួចមានស្នេហា សង្សា សាហាយ កំបាំងមុខពីមេបា ឬ

ដោយមានស្នេហាមុនការរៀបមង្គល់ការ។ ពិសេសគឺសង្កត់ធ្ងន់ទៅលើស្រីក្រមុំ ក្មេងវ័យ គួរកុំបណ្តោយខ្លួនប្រាណ អោយទៅបុរសណាម្នាក់ មុនពេលគេចូលស្តីដណ្តឹង មុនពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើបណ្តោយខ្លួន ទៅរហូតដល់មានផ្ទៃពោះ វាជារឿងមិនល្អ ត្រូវបានបណ្តាញាតិគេស្អប់ខ្ពើម ជិនឆ្អន់ កេរ្តិ៍ឈ្មោះស្មុយអាសោច បញ្ជ្រាសខ្យល់អាប់មុខ អាប់មាត់គ្រួសារ និងកិត្តិយសខ្លួនផ្ទាល់ ហើយត្រូវគេចាត់ទុកថា ជាកូនអកតញ្ញូ។ ជាការពិតណាស់នៅក្នុងសង្គមគ្រួសារខ្លះ ពេលដែលជួបប្រទះ និងកូនស្រីបែបនេះ គឺធ្វើអោយម៉ែឪគាត់មានសេចក្តីអស់សង្ឃឹមជាខ្លាំង ជួនកាលកាត់កាលចោលមិនរាប់រក ជួនកាលទៀតក៏រកវិធីបំបែកបំបាក់ ធ្វើអោយមានភាពល្អក់កករផ្សេងៗកើតឡើងដោយភាពមិនសមនិងបំណងបែប នេះ។ ដោយមានទង្វើខុសបែបនេះហើយ ទើបចាស់ទំពីបុរាណហាមថា "កុំទុំមុនស្រគាល" ។

ជាក់ស្តែងក្នុងអក្សរសិល្បខ្មែរ រឿងទុំទាវ ដែលនិពន្ធដោយ ព្រះភិក្ខុសោម បានបង្ហាញអោយឃើញថា ទុំបានប្រព្រឹត្តិអំពើខុសធ្ងន់ ព្រោះខ្លួនជាសង្ឃ ហ៊ានមានចិត្តស្នេហាងុបងុលទៅលើនាងទាវ និងលួចសឹកតែម្នាក់ឯងនៅក្បែរដំបូក ដើម្បីមកជួបទាវ។ ឯនាងទាវខ្លួនជាស្ត្រីក្រមុំ បែរជាហ៊ានបំពារទៅលើប្រពៃណីមកធ្វើនូវសេចក្តីស្នេហាជាមួយទុំ ទោះជាអ្នកទាំងពីរស្រលាញ់គ្នាប៉ុណ្ណាក៏ដោយ សេចក្តីស្នេហានេះត្រូវបានរំខានដោយយាយផាន់ ព្រោះជារឿងខុសនិងច្បាប់ស្រី និងជាការមិនពេញចិត្តរបស់យាយផាន់ផង។ ទោះបីជាព្រះរាជាប្រទានមង្គល់ការ អោយហើយក្តីក៏យាយផាន់ នៅតែបំបែកបំបាក់ស្នេហានេះទាល់តែខាងបាន។ ចុងក្រោយស្នេហាទុំមុនស្រគាល មួយគូនេះត្រូវទទួលរងសេចក្តីវិនាស អន្តរាយទាំងស្រុង។ ឯរឿងភូមិតិរច្ឆានវិញ បានបង្ហាញអោយឃើញពីទឹកចិត្តរបស់ សុវណ្ណ មកលើ នាងតន់ ដែលមិនបានប្រព្រឹត្តិអ្វីអោយខុសពីប្រពៃណីខ្មែរឡើយ។ ពេលដែលតន់ត្រូវគេបណ្តេញចុះពីផ្ទះ នាងអស់ជំរកក៏ត្រឡប់មកផ្ទះសុវណ្ណវិញ។ ឯសុវណ្ណបានទទួលនាងជាប្រពន្ធ ដោយរៀបចំសែនព្រេន បន្តិចបន្តួចតាមប្រពៃណីខ្មែរជាមុន។ ដោយមានបំរាមទុំមុនស្រគាលនេះហើយ ទើបសុវណ្ណមិនធ្វើអ្វីអោយខុសឆ្គង។

សរុបសេចក្តីមកការ ទុំមុនស្រគាល និងការធ្វើខុសឆ្គងប្រពៃណីរបស់កូនប្រុសស្រី មានលក្ខណៈមិនល្អ មិនសមរម្យដូចគ្នា ទើបចាស់ៗហាមប្រាមកូនចៅមិនអោយ ប្រព្រឹត្តិខុស។

តាមការបក ស្រាយបញ្ជាក់ខាងលើបង្ហាញថា ពាក្យចាស់បុរាណមួយឃ្លានេះ ពិតជាមានអត្ថន័យខ្លឹមសារល្អត្រឹមត្រូវ សំរាប់អប់រំទូន្មានកូនប្រុសស្រីខ្មែរ កុំអោយធ្វើអ្វីឆ្គាំឆ្គង ប្រាសចាកពីច្បាប់ទំលាប់ប្រពៃណី។ ដូចនេះខេមរបុត្រ ខេមរធីតាទាំងឡាយ គប្បីខិតខំសិក្សារៀនសូត្រ ជៀសវាងការមានស្នេហាក្នុងវ័យសិក្សា និងការបណ្តោយខ្លួនអោយជ្រុលជ្រួស ហួសខុសពីប្រពៃណី ដែលអំពើទាំងនេះជាហេតុមិនល្អទាល់តែសោះ ៕

ប្រធានទី៩៖ទស្សនៈមួយចែងថា "ទីណាមានការជិះជាន់ ទីនោះមានការរើបំរះ"ចូរពន្យល់ដោយលើក ឧទាហរណ៍បញ្ជាក់។ (សំរាប់ថ្នាក់ទី០៩)

សេក្តីអធិប្បាយ

មនុស្ស គ្រប់រូប និងគ្រប់សញ្ជាតិតែងតែស្រលាញ់ សេរីភាព ចង់បានយុត្តិធម៌ ចៀសវាងការគាបសង្កត់ ជិះជាន់ ទើបទទួលបានសកម្មភាពនេះ មនុស្សតែងតែរើបំរះប្រឆាំងតបដោយខានមិនបាន។ដោយយល់ឃើញបែបនេះហើយ ទើបមានទស្សនៈលើកឡើងថា "***ទីណាមានការជិះជាន់ ទីនោះមានការរើបំរះ***"។

តើទស្សនៈនេះមានអត្ថន័យយ៉ាងដូចម្តេច?

ដើម្បីកែខៃបញ្ហាខាងលើអោយងាយយល់យើងគប្បីយល់ពាក្យ " ***ការជិះជាន់*** និង***ការរើបំរះ***ជាមុនសិន "។**ការជិះជាន់** "គឺជាការគាបសង្កត់គេងប្រវ័ញ្ចផ្សេងៗ។" **ឯការរើបំរះ"** គឺជាការតស៊ូប្រឆាំង ដើម្បីរកសន្តិភាព មកវិញ។ មតិរបស់ប្រធានខាងលើមានន័យថា គ្រប់ទីកន្លែង និងពេលវេលាដែលមានការជិះជាន់ សង្គត់សង្កិន តែងតែមានការប្រឆាំងតស៊ូរើបំរះទាមទា មកវិញនូវយុត្តិធម៌។

ជាការពិតជាក់ ស្តែងក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត មនុស្សម្នាក្នុងដែនកម្ពុជា រដ្ឋទាំងមូល បានរស់រងទុក្ខវេទនាក្រោមអំពើជិះជាន់កេងប្រវ័ញ្ច យ៉ាងព្រៃផ្សៃបំផុត។ មនុស្សម្នាសុទ្ធតែរស់ក្រោមអំណាចដ៏សាហាវ ឃោរឃៅរកទីបំផុតគ្មាន របស់អង្គការដ៏មហាប្រល័យមួយនោះ បើអង្គការថា យ៉ាងណាពលរដ្ឋទាំងអស់ត្រូវតែធ្វើយ៉ាងនោះ ដោយគ្មានការប្រកែកតវា។ ដោយអំពើជិះជាន់ទាំងផ្លូវកាយ ចិត្តគំនិត ស្មារតីនិងជីវិតបែបនេះហើយ ទើបធ្វើអោយមានចលនារើបំរះយ៉ាងខ្លាំងក្លាកើតឡើង។ ចុងក្រោយរបបដែលអង្គការរបស់ពួកគេបាន អួតថាជារបបមហាអស្ចារ្យ មហាលោតផ្លោះ នោះត្រូវបានកំទេចចោលទាំងស្រុង ដោយកំលាំងតស៊ូរើបំរះ ពីសំណាក់ប្រជាជន។ ផ្សេងពីនេះ របបអីថ្លៃនៃប្រទេសអាឡឺម៉ង់ដែលកសាង និងសាបព្រោះមហាវិនាសកម្ម ជិះជាន់ឈ្លានពានទៅលើប្រទេសដ៏ទៃ ក៏ត្រូវបានបរាជ័យយ៉ាងធ្ងន់ធ្ងរ ក្រោមអំណាចនៃការតស៊ូ ប្រឆាំងរបស់មនុស្សដែលត្រូវការសេរីភាព។ ម្យ៉ាងវិញទៀតក្នុងអក្សរសិល្ប៍ខ្មែរ រឿងភូមិតិរច្ឆាន ប្រជាជនខ្មែររស់រងក្រោមគំនាប របស់ពួកអាណានិគមនិយមបារាំងយ៉ាងល្វីងជូចត់បំផុត។ ពួកបារាំងនេះបានជិះជាន់កេងប្រវ័ញ្ច ប្រកបដោយអំពើអយុត្តិធម៌ និងគ្មានមនុស្សធម៌ មកលើខ្មែរដែលជាជនជាតិម្ចាស់ស្រុក។ អំពើ

នេះបានធ្វើអោយប្រជាជនមានកំហឹង ពុះកញ្ជ្រោលឡើងបង្កើតបាន ជាភ្លើងកំហឹងតស៊ូ រើបំរះយ៉ាងខ្លាំងខ្លាវាយតបទៅលើពួកអាណានិគមនិយមបារាំង និងបក្សពួកដោយគ្មានញញើតដៃឡើយ។ ដោយមូលហេតុនៃការរើបំរះនេះ ធ្វើអោយពួកបារាំងទាល់ច្រកទទួលរងនូវបរាជ័យយ៉ាងអាម៉ាស ហើយក៏ប្រគល់សិទ្ធិសេរីភាពជូនដល់កម្ពុជាវិញ។ពេលនេះប្រទេស កម្ពុជាទាំងមូល បានទទួលជោគជ័យប្រកបដោយសិទ្ធិសេរីភាពពេញលេញ បរិបូរហើយ បានក្លាយជាប្រទេសដែលមានឯករាជ្យ លេងស្ថិតក្រោមក្រញ៉ាដៃបីសាចបារាំងសេសភ្នែកសទៀតហើយ។

សរុប សេចក្តីមក គ្រប់ទីកន្លែងដែលមានការជិះជាន់ ដល់ការរស់នៅ មនុស្សអោយទទួលអយុត្តិធម៌ ទីនោះតែងតែទទួលបាននូវការតស៊ូ ប្រឆាំងរើបំរះ តបវិញជាក់ជាមិនខាន។

មតិរបស់ប្រធានខាងលើ ពិតជា ត្រឹមត្រូវព្រោះបានអប់រំដល់មនុស្សអោយចេះតស៊ូរើបំរះ ពីការជិះជាន់ និងអោយចេះរស់នៅចុះសំរុងគ្នា មិនបៀតបៀនគ្នាដោយអំពើអាក្រក់។ ដូចនេះកុលបុត្រកុលធីតាខ្មែរ ទាំងអស់គប្បីចេះរួបរួមសាមគ្គីដើម្បីបំបាត់រាល់អំពើជិះជាន់ ផ្សេងៗ ពីសំណាក់ពពួកមនុស្សអាក្រក់៕

ប្រធានទី១០ ទ្រឹស្តីមួយពោលថា"មាតាបិតាគឺជាបុព្វទេវា បុព្វាចារ្យ និងជាព្រះរបស់បុត្រធីតា"។ចូរពន្យល់។

សេចក្តីអធិប្បាយ

មនុស្សទាំងឡាយដែលកើតមកហើយ តែងតែមានមេបាជាអ្នកបង្កើត និងចិញ្ចឹមបីបាច់ ថែរក្សា។ តាមទ្រឹស្តីព្រះពុទ្ធសាសនាបានចែងថា "មាតាបិតាគឺជាបុព្វទេវា បុព្វាចារ្យ និងជាព្រះរបស់បុត្រធីតា"។

តើទ្រឹស្តីនេះត្រឹមត្រូវឬទេ?

ជាដំនួយដល់ការបកស្រាយបញ្ហាខាងលើយើងគួរយល់អត្ថន័យនៃពាក្យ **មាតាបិតា** និង**បុត្រធីតា** ជាមុនសិន។ មាតាបិតា គឺជាឪពុកម្តាយដែលជាអ្នកផ្តល់កំណើតដល់កូន។ បុត្រធីតា គឺកូនប្រុសស្រី។ ប្រធានខាងលើមានន័យថា មាតាបិតាគឺជាទេវា ជាគ្រូ និងជាព្រះសំរាប់កូន។មាតាបិតាជា បុព្វទេវានៃបុត្រធីតាមានន័យថា គឺជាទេវតាដើម ដែលផ្តល់កំណើតកើតជាដល់កូនប្រុសស្រី ហើយថែមទាំងចិញ្ចឹមបីបាច់ថែរក្សាអោយកូនមានជីវិតថ្លៃថ្នូរល្អ ប្រពៃ។ ក្រៅពីការចិញ្ចឹមមាតាបិតាផ្តល់នូវភាពកក់ក្តៅជាច្រើនទៀត ដូចជា បញ្ជូនកូនអោយសាលារៀនសូត្រយកចំណេះផ្សេងៗ អោយកូនមានឱកាសចូលរួមសកម្មភាពនានាដើម្បីសប្បាយរីករាយក្នុងជីវិត។

ផ្សេងពីនេះមាតាបិតាផ្តល់ក្តីសង្ឃឹមគ្រប់បែបយ៉ាង អោយកូនរស់នៅបានសុខស្រួល និងមានភាពកក់ក្តៅក្នុងជីវិត។ មាតាបិតាសុខចិត្តរងគ្រោះក្នុងទុក្ខលំបាកវេទនាដោយខ្លួនឯង ដើម្បីអោយកូនបានសុខស្រួល និងមានភាពសុខសាន្ត។ មានតាបិតាហ៊ានស្លាប់បាត់បង់ជីវិតជំនួសបុត្រធីតា។ ដូចនេះបើគ្មានមាតាបិតា ក៏គ្មានបុត្រធីតា បើគ្មានបុព្វទេវា បុត្រធីតាទាំងឡាយ ក៏ក្មានសេចក្តីសុខចំរើនដែរ។

ឯបុព្វា ចារ្យនេះសំដៅលើអាចារ្យខាងដើម មាតាបិតាគឺជាគ្រូអាចារ្យដែលបាន អប់រំទូន្មាន ប្រៀនប្រដៅកូនចៅអោយខិតខំរៀនសូត្រ ចេះគោរពចាស់ទុំ គ្រូបាអាចារ្យ ចេះធ្វើអំពើល្អ ដោយកាយវាចាចិត្ត គោរពច្បាប់សង្គម និងមិនប្រព្រឹត្តអំពើអាក្រក់ទុច្ចរិតដែលនាំអោយសង្គមស្អប់ ខ្ពើម។

មិនតែប៉ុណ្ណោះបាននែនាំកូនអោយចេះដឹងគុណ និងតបស្នងសងគុណដល់គ្រូឧបជ្ឈាយាចារ្យ។ ចេះស្រលាញ់ថែរក្សាបងប្អូន ពូជពង្សរង្សត្រកូលផៅសណ្តាន ចេះជួយទុក្ខធុរៈ ញាតិមិត្តមិនរើសអើង និងមិនប្រកាន់វណ្ណៈឡើយ។ សេចក្តីល្អទាំងឡានដែល

កូនបានចេះដឹងសុទ្ធសឹងតែ ទទួលបានពីការអប់រំរបស់មាតាបិតាទាំងអស់។ ឯព្រះព្រហ្មមាតាបិតាជាព្រះព្រហ្មយ៉ាងពិតប្រាកដ ណាស់ សំរាប់បុត្រធីតា ឧបេក្ខា ក្តីមេតា របស់ម៉ែឪចំពោះកូននោះ មានជាអនេក គឺការផ្តល់នូវសេចក្តីស្រលាញ់ ពេញចិត្តដល់កូន គ្រប់ៗរូបស្មើគ្នាឥតមានមន្ទិលសៅហ្មង។

ករុណា ការអាណិតអាសូរប្តូរផ្តាច់ របស់មាតាបិតាចំពោះកូន ដោយហ៊ានធ្វើពលីកម្ម ខ្លួនឯងសព្វបែបយ៉ាងដើម្បីអោយកូន បានសុខស្រួល និងមានអនាគតល្អ។ មុទិតា គឺសេចក្តីត្រេកអរ សប្បាយរីករាយ យ៉ាងខ្លាំងឥតឧបមារបស់ម៉ែឪ នៅពេលកូនចៅរបស់ ខ្លួនទទួលបានសេចក្តីសុខចំរើនរុងរឿង។ ឧបេក្ខា គឺជាការប្រមើលមើល ដ៏វែងឆ្ងាយទាំងផ្លូវកាយចិត្តបញ្ញាស្មារតី របស់មាតាបិតា ក្នុង គោលបំណងចង់អោយបុត្រធីតារបស់ខ្លួនមានចំណេះដឹងខ្ពស់ មានកិត្តិយស មានបុណ្យស័ក្តិធំ មានទ្រព្យសម្បត្តិមហិមា មានគេស្រ លាញ់រាប់អាន គោរពកោតខ្លាច និងជាមនុស្សសំខាន់សំរាប់សង្គម។ ដោយអំណាចនៃព្រហ្មវិហារធម៌នេះ លោកជាមាតាបិតាខំព្យា យាមស្វែងរក ទ្រព្យសម្បត្តិអោយបានច្រើន សំរាប់ទុកជួយឧបត្ថមដល់បុត្រធីតា។ ទោះបីជាប្រទះនិងសេចក្តីក្រលំបាកវេទនាយ៉ាង ណាក៏ដោយ ក៏លោកនៅតែប្រឹងប្រែងព្យាយាម ជួយឧបត្ថមបុត្រធីតា របស់ខ្លួនតាមលទ្ធភាពដែលមាន។ សរុបសេចក្តីមានតាបិតា ពិតជា ទេវតាដើមដំបូង និងជាព្រះព្រហ្មសំរាប់បុត្រធីតាពិតមែន។

ប្រធានបទខាងលើពិតជាត្រឹមត្រូវល្អ ព្រោះបានអប់រំមនុស្សអោយដឹង ពីគុណ និងចេះតបស្នងសងគុណចំពោះមាតាបិតា របស់ខ្លួន។ ដូចនេះក្នុងនាមជាខេមរបុត្រទាំងអស់គប្បីចេះ គោរពស្តាប់បង្គាប់ម៉ែឪ ខិតខំរៀនសូត្រ កុំធ្វើអោយលោកពិបាកព្រោះតែ យើង។

ប្រធានទី១១៖ មតិមួយពោលថា " ព្រះរាមធ្វើសង្គ្រាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួន គឺយកនាងសីតាពីក្រុងរាពណ៍ " ឯមតិផ្សេងទៀត ថា " ព្រះរាមធ្វើសង្គ្រាមដើម្បីស្វែងរកសេចក្តីសុខអោយសង្គមមនុស្ស " តើអ្នកយល់យ៉ាងដូចម្តេចចំពោះមតិទាំងនេះ?

សេចក្តីអធិប្បាយ

ពេលដែល យក្សចាប់ពង្រាត់សីតានៅក្រុងលង្កាភ្លាម ព្រះរាមសោយមិនសុខ ហើយបានរិះរកគ្រប់មធ្យោបាយ និងបានប្រ មូលទាហានស្វាយ៉ាងច្រើន ទៅធ្វើសង្គ្រាមជាមួយយក្សក្រុងរាពណ៍ ក្នុងគោលបំណងរំដោះប្រពន្ធខ្លួនមកវិញ គឺនាយសីតា។ បញ្ហា សង្គ្រាមរវាងព្រះរាម និងក្រុមយក្ស ធ្វើអោយមានមតិ២ផ្សេង។ពីគ្នា មតិ១យល់ថា " ព្រះរាមធ្វើសង្គ្រាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួន គឺ យកនាងសីតាពីក្រុងរាពណ៍ " ឯមតិទី២ថា " ព្រះរាមធ្វើសង្គ្រាមដើម្បីស្វែងរកសេចក្តីសុខអោយសង្គមមនុស្ស "។

តើមតិទាំង២នេះ១ណាត្រឹមត្រូវជាង?

ដើម្បីជាគ្រឹះវិស័យក្នុងការដោះស្រាយបញ្ហាទាំងពីរខាងលើនេះ យើងគប្បីយល់អត្ថន័យនៃពាក្យ សង្គ្រាមជាមុនសិន។"សង្ គ្រាម" គឺជាការប្រឆាំងច្បាំងគ្នាទៅវិញទៅមក ដោយអាវុធ យុទ្ធភណ្ឌ ផ្សេង។។ ប្រធានបទខាងលើចង់អោយ ដោយស្រាយបញ្ហា និងរកមូលហេតុនៃការធ្វើសង្គ្រាម រវាងព្រះរាម និងក្រុងរាពណ៍។

ចំពោះមតិដែលពោលថា " ព្រះរាមធ្វើសង្គ្រាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួន គឺយកនាងសីតាពីក្រុងរាពណ៍ " គឺយកនាងសីតា វិញនោះ មានហេតុផលថា ពេលដែលព្រះរាមសំលាប់យក្សមួយចំនួន អោយស្លាប់ហើយ រាពណ៍កើតក្តីក្តៅក្រហាយណាស់ ក៏ប្រើម ធ្យោបាយឆក់យកនាងសីតា ទៅកាន់លង្កាវិញ។ មូលហេតុនេះហើយដែលធ្វើអោយរាម សោកសង្រេងដល់នាងសីតាយ៉ាងខ្លាំ។ រាម ចងកំហឹងជាមួយក្រុងលង្កា ដែលគ្រប់គ្រងដោយយក្សរាពណ៍ ព្រះរាមបានប្រមូលទ័ពស្វា ទៅច្បាំងជាមួយក្រុងរាពណ៍ រហូតស្លាប់ ទ័ពស្វាស្ទើតែអស់។

យោងតាមហេតុផលនេះហើយអាចបញ្ជាក់ថា សង្គ្រាមដែលព្រះរាមបង្កើតឡើយ ដោយមានទ័ពស្វាជាបរិវារនេះ គឺបំណង យកនាងសីតាមកវិញតែប៉ុណ្ណោះ មិនមានបញ្ហាអ្វីផ្សេងនោះឡើយ។ មូលហេតុនេះបញ្ជាក់អោយឃើញថា ព្រះសង្គ្រាមរបស់ព្រះរាម ពិតជាដើម្បីប្រយោជន៍ផ្ទាល់ខ្លួនពិតមែន។

តើព្រះរាមពិតជាធ្វើសង្គ្រាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួនពិតមែនឬ?

ទន្ទឹម និងមតិខាងលើនេះ ក៏មានមតិមួយទៀតពោលផងដែរថា " ព្រះរាមធ្វើសង្គ្រាមដើម្បីស្វែងរកសេចក្តីសុខអោយសង្គមមនុស្ស អោយផុតពីការជិះជាន់ របស់ពួកយក្ស " តាមរឿងរាមកេរពោលថា ពេលដែលកើតកលិយុគ្គ ដោយពួកយក្ស ធ្វើទុក្ខបុកម្នេញដល់មនុស្សសត្វ ទទួលការលំបាក ព្រះវិស្ណុ ក៏អោយអវតារចុះចាប់កំណើតជាព្រះរាម ដើម្បីបង្ក្រាបពួកយក្ស អាក្រក់អស់នោះ អោយវិនាសបាត់បង់។ ដោយមានបញ្ហារាជសម្បត្តិ ទ្រង់ក៏ទៅនៅក្នុងព្រៃ ហើយរាពណ៍ក៏ឆក់យកនាងសីតាទៅ ព្រះរាមបានដៃក្នុងការធ្វើសង្គ្រាម បង្ក្រាបពួកយក្សនិងពួកបីសាច មិនអោយមានសល់ក្នុងផែនដីនេះទៀតឡើយ។ ដូចនេះព្រះរាមបានធ្វើសង្គ្រាមសំលាប់ពួកយក្ស មិនមែនដើម្បីប្រយោជផ្ទាល់ខ្លួនទេ គឺដើម្បីរកសុខសន្តិភាពជូនសង្គម មនុស្សទូទៅ។ តែឆ្លងតាមការបកស្រាយ មតិទី២ឃើញថា បើក្រុងរាពណ៍មិនចាប់យកនាងសីតាទៅក្រុងលង្កា ព្រះរាមក៏មិនធ្វើសង្គ្រាមដែរ ដូចនេះការនិយាយថា ព្រះរាមធ្វើសង្គ្រាមដើម្បីស្វែងរកសេចក្តីសុខ អោយសង្គមសមមនុស្ស ក៏ពុំសូវជាសមរម្យដែរ ព្រោះពេលដែលសង្គ្រាមនេះកើតឡើង ព្រះរាមក៏ឥតបានរស់នៅក្នុងសង្គមមនុស្សដែរ ហើយថែមទាំងបង្កទុក្ខលំបាកអោយពួកស្វាស្លាប់បាត់បង់ជីវិតជា ច្រើនទៀតផង។ ម្យ៉ាងទៀតតាំងពីដើមមកពួកយក្ស បីសាចមិនដែលរុកគួនដល់សង្គមមនុស្សទេ ពួកយក្ស និងបីសាចបៀតបៀនតែពួកឥសីដែលនៅក្នុងព្រៃតែប៉ុណ្ណោះ។

បញ្ចប់ សេចក្តីមក យើងអាចសន្និដ្ឋានបានថា ការធ្វើសង្គ្រាមរបស់រាម គឺដើម្បីប្រយោជខ្លួន ពោលគឺធ្វើសង្គ្រាមដើម្បីដណ្តើមនាងសីតា ពីក្រុងរាពណ៍ តែប៉ុណ្ណោះ។ ព្រោះក្រោយពេលដែលក្រុងរាពណ៍ចាប់សីតាទៅ ទើបសង្គ្រាមផ្ទុះឡើង បើរាពណ៍មិនឆក់សីតាដែលជាព្រះមហេសីរាមទេ សង្គ្រាមក៏ឥតកើតមានដែរ។ដូចនេះកុលបុត្រកុលធីតាខ្មែរ គ្រប់ជំនាន់ គប្បីស្រលាញ់សន្តិភាពចៀសវាងបៀតបៀនគ្នាដែលនាំអោយ កើតសង្គ្រាម ព្រោះសង្គ្រាមមិនដែលបណ្តាលអោយមានផលប្រយោជល្អទេ នាំមកតែក្តីវិនាសអន្តរាយ ៕

ប្រធានទី១២៖ ចៅចិត្រចេះប្រឹងប្រែងកសាងជីវភាពរបស់ខ្លួនអោយរីកចំរើន។ តើចៅចិត្រខំប្រតិបត្តិតាមប្រការអ្វី? ចូរពន្យល់អោយបានក្បោះក្បាយ ដោយលើកយកដំណើររឿង កុលាបប៉ៃលិនមកបញ្ជាក់។

សេចក្តីអធិប្បាយ

ដើម្បីសាងជីវភាព គ្រួសារ អោយបានសម្បូរសប្បាយ រុងរឿងមានកិត្តិយស យើងគប្បីស្រលាញ់ និងខិតខំធ្វើការងារកុំបីខ្ជិលច្រអូស។ ក្នុងរឿងកុលាបប៉ៃលីនក្រោយឪពុកចែកឋានទៅ ចិត្របានប្រឹងប្រែងកាសាងជីវភាពរបស់ខ្លួនបានរុងរឿងរីកចំរើន។

តើចៅចិត្រខំប្រតិបត្តិតាមអ្វីដែលនាំអោយខ្លួនទទួលបានជោគជ័យ ក្នុងជីវិតរស់នៅ?

ដើម្បីជាជំនួយដល់ការបកស្រាយបញ្ហាខាងលើយើងគួរយល់អត្ថន័យនៃពាក្យ "កសាងជីវភាព" អោយបានច្បាស់លាស់ជាមុនសិន។ "***កសាងជីវភាព***" មានន័យថា ការរៀបចំជីវិតរស់នៅអោយបានល្អប្រសើរ។ ប្រធានបទខាងលើមានន័យថា ការចេះប្រឹងប្រែងរៀបចំឆាកជីវិតរបស់ខ្លួន ដើម្បីអោយខ្លួនទទួលបានភាពជោគជ័យ និងរីកចំរើន។

មុននឹងឪពុក ចែកឋានទៅគាត់បានផ្តាំដល់ចិត្តថា "អត្តាហិអត្តនោនាថោ" គឺខ្លួនទីពឹងខ្លួន។ បណ្តាំនេះបាននៅជាប់ក្នុងក្រអៅបេះដូចចៅចិត្តជានិច្ច ហើយជាកត្តាជំរុញចិត្តអោយមានស្មារតីមុះមុតប្រឹងប្រែងប្រតិបត្តិ តាមយ៉ាងខ្ជាប់ខ្ជួនឥតបីធ្វេសប្រហែស។ ដោយចិត្តជាមនុស្សមានទំនុកចិត្តលើខ្លួនឯងយ៉ាងមួតមាំនេះហើយ ទើបធ្វើអោយការបំពេញការងារផ្សេងៗរបស់គេចេះតែទទួលបានជ័យជំនះ ចំណុចនេះលេចចេញពីគំនិតមួយដែលគិតថា "គេដទៃយ៉ាងណា ខ្ញុំក៏គង់តែធ្វើបានដូចគេដែរ"។ ហើយជ័យជំនះដែលចិត្តទទួលបានជាបន្តបន្ទាប់នេះ ក៏ព្រោះតែចិត្រមានចំណេះដឹងគ្រប់គ្រាន់ ទាំងការសិក្សារៀនសូត្រ និងបំនិនប្រសព្វក្នុងដំនាញផ្សេងៗដែរ។ ចៅចិត្របានឆ្លងកាត់ការសិក្សារហូតបានទទួលប្រកាសនីប័ត្រ ធ្វើអោយគេមានសមត្ថភាពអាចគ្រប់គ្រងកម្មករ និងលុយកាក់បាន។ មិនត្រឹមតែជួសជុល និងបើកបររថយន្តទេ គេអាចធ្វើជាកម្មករត្បូងដ៏ល្អ មានមិត្តភក្តិស្រលាញ់រាប់អានច្រើន ពិសេសជាងនេះទៅទៀត គេចេះធ្វើអោយចៅហ្វាយនាយពេញចិត្តនឹងគេទៀតផង ក្នុងការងារដណ្តាំបាយស្លស្លុក ធ្វើម្ហូបអាហារ និងការចេះកាន់កាំភ្លើងយ៉ាងអង់អាចក្លាហានក្នុងការការពារចៅ ហ្វាយនាយអោយរួចផុតពីគ្រោះថ្នាក់។ បន្ថែមពីនេះ ចៅចិត្រជាមនុស្សមានបទពិសោធជាមួយនឹងការងារ ទាក់ទងល្អជាមួយមិត្តភក្តិកម្មកររផ្សេងៗទៀត និងចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមកយ៉ាងស្និទ្ធស្នាលទៀតផង។ សូម្បីតែតាសុនជាអ្នកបើកឡានជូនលោក ហ្វុងក៏ពេញចិត្តចៅចិត្រដែរ ជាក់ស្តែងពេលតាសុនបញ្ជេះឡានមិនឆេះ ចៅចិត្រចេះជួយឈឺឆ្អាល បើកឡានជូនលោកហ្វុងជំនួសតាសុនវិញ ធ្វើអោយតាសុនសប្បាយចិត្តជាខ្លាំង ហើយពោលថា "ពូកែគ្រាន់បើក្មួយអញ"។ មិនតែប៉ុណ្ណោះចៅចិត្តចេះសម្របសម្រួលខ្លួនគ្រប់មជ្ឈដ្ឋានដូចជា រស់នៅជាមួយកម្មកររដូចគ្នា ក៏ដូចជាការយួរកន្ត្រៃទៅផ្សារតាមឃុននារីយ៉ាងតត្រុក។ មិនតែប៉ុណ្ណោះចៅចិត្រមានកំលាំងកាយគ្រប់គ្រាន់អាចធ្វើជាកម្ម ករ អណ្តូងរ៉ែដូចកម្មករ

ដទៃទៀតបាន ព្រមទាំងអាចប្រយុទ្ធជាមួយចោរហាយនៅក្នុងព្រៃ ការពារម្ចាស់យ៉ាងស្វាហាប់ និងវាយបាឡាត់ដួលផ្ងារនៅពេលដែលបំរុងរំលោក ឃុននារីស្រី។ ផ្សេងពីនេះទៅទៀត ប្រការដែលជំរុញអោយចៅចិត្រមានជីវភាព រីកចំរើននោះគឺកំលាំងចិត្រ និងកំលាំងប្រាជ្ញារបស់គេផ្ទាល់។ កំលាំងចិត្តនេះសំខាន់ណាស់ក្នុងការជួយមនុស្សអោយទទួលជោគជ័យ ក្នុងការងារគ្រប់យ៉ាង។ ចៅចិត្រចេះតស៊ូអំណត់អត់ធន់ ក្នុងការងារភ្លាហានចំពោះបញ្ហាដែលកើនមានចំពោះមុខ និងឈ្លាសវៃក្នុងការដោះស្រាយបានភ្លាមៗ។ ចំណុចពិសេសមួយទៀតនោះគឺចៅចិត្រអាចធ្វើអោយចៅហ្វាយនាយស្រលាញ់ គឺគេមិនចេះរើសអើងការងារ ហើយការងារអ្វីក៏ចិត្រធ្វើបានដែរ។ ប្រសើលើសអ្វីទាំងអស់នោះ ចៅចិត្រជាមនុស្សស្មោះត្រង់ជាមួយចៅហ្វាយនាយ កម្មករដូចគ្នា ព្រមទាំងឃុននារី។ ចៅចិត្រមិនដែលកិបកេងយកចំណេញពីចៅម្ចាយនាយឡើយទាំងការងារ និងសេចក្តីស្នេហា។ បើចៅចិត្រមិនស្មោះត្រង់ទេប្រហែលជាមិនបានហានៈកូនប្រសារចៅកែត្បូងឡើយ។

សរុបសេចក្តីមក ចៅចិត្រមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការងាររស់នៅរបស់ខ្លួន នឹងអាចធ្វើអោយខ្លួនទទួលបានជោគជ័យ នេះក៏សំអាងបណ្តាំឪពុក "អត្តាហិអត្តនោនាថោ" នេះហើយ។

ប្រធានបទខាងលើមានអត្ថន័យ ល្អត្រឹមត្រូវសំរាប់អប់រំមនុស្សអោយចេះជឿជាក់លើសមត្ថភាពរបស់ ខ្លួន និងចេះតស៊ូអំណត់អត់ធនក្នុងការធ្វើការងារ។ ដូចនេះខេមរបុត្រទាំងឡាយអើយ ត្រូវចេះកសាងខ្លួនអោយមានសមត្ថភាពក្នុងការដឹកនាំជោគវាសនារបស់ ខ្លួនអោយបានល្អប្រសើរ និងពោពេញដោយភាពជោគជ័យ៕

ប្រធានទី១៣៖ មតិមួយពោលថា " ធ្វើស្រែអោយមើលស្មៅ ទុកដាក់កូនចៅអោយមើលផៅសណ្តាន " ចូរពន្យល់?

អត្ថាធិប្បាយ

ក្នុងសង្គមរស់នៅអ្នកជាឪពុកម្តាយ អាណាព្យាបាល តែងតែចង់អោយកូនចៅរបស់ខ្លួន រស់នៅបានសម្បូរសប្បាយ មានសេចក្តីសុខសុភមង្គល។ អាស្រ័យហេតុនេះហើយ ទើបមានមតិមួយពោលថា " ធ្វើស្រែអោយមើលស្មៅ ទុកដាក់កូនចៅអោយមើលផៅសណ្តាន " ។ តើមតិខាងលើនេះអត្ថន័យខ្លឹមសារដូចម្តេចខ្លះ? ទាក់ទងនិងការរស់នៅរបស់មនុស្ស។

ដើម្បីជាជំនួយដល់ការដោះ ស្រាយបញ្ហាខាងលើ យើងកប្បីយល់អត្ថន័យនៃសំនួនពាក្យ " មើលស្មៅ ទុកដាក់កូនចៅ ផៅសណ្តាន " ជាមុនសិន។

មើលស្មៅ មានន័យថា អោយចេះបេះបោចស្មៅវល្លិ៍ចេញពីដំណាំដែលបានដាំដុះ។ ទុកដាក់កូនចៅ សំដៅលើការផ្សំផ្គុំកូនចៅ អោយមានគូស្រករ ប្តីប្រពន្ធ។ ផៅសណ្តាន គឺសំដៅទៅលើពូជអំបូរ សាច់សាលោហិត។ប្រ ធានបទខាងលើមានន័យថា ក្នុងការធ្វើស្រែចំការរបស់ប្រជាកសិករ ត្រូវតែចេះពិនិត្យ ថែទាំដំណាំសំណាបសន្ទុង ដោយដកស្មៅឬបោចវល្លិ៍ស្អាស់ផ្សេងៗ ចេញពីដំណាំ ឯការរៀបចំកូនចៅ អោយមានប្តីប្រពន្ធ គប្បីពិនិត្យអោយបានច្បាស់ ពីប្រវត្តិពូជអំបូរ កូនប្រុសឬស្រីម្ខាងទៀត។

ពាក្យ " ធ្វើស្រែអោយមើលស្មៅ " នៅទីនេះមិនមានន័យថា អោយយើងអង្គុយមើលស្មៅ ឬល្អាស់ផ្សេងៗដែលដុះជាមួយស្រូវនោះទេ គឺសំដៅលើការឧស្សាហ៍ព្យាយាម មើលថែដំណាំ ដាំដុះ ឬស្រូវស្រែចំការរបស់ខ្លួន ដោយចេះបេះបោច វល្លិ៍ល្អាស់ និងស្មៅចេញ ទើបដំណាំ ឬស្រូវរបស់យើងវាអាចដុះលូតលាស់បានល្អ និងផ្តល់ផលប្រយោជន៍ ជាផ្លែផ្កាច្រើនជាទីគាប់ចិត្ត។ ប្រសិនបើយើងខ្ជិលច្រអូសមិនមើលថែជួនដំណាំ ដែលបានដាំហើយនៅទេ ទុកអោយស្មៅដុះ លាយឡំជាមួយគ្នានោះ ដំណាំទាំងឡាយរបស់យើងពិតជាវិនាស អន្តរាយ មិនបានផ្តល់ផលប្រយោជន៍ អ្វីបន្តិចសោះឡើយ ហើយថែមទាំងធ្វើអោយ ខាតកំលាំងនិងពេលវេលា ក្នុងការដាំទៀតផង។ សរុបមកក្នុងការធ្វើស្រែចំការ ច្បារដំណាំផ្សេងៗ គប្បីចេះថែរក្សា ស្រោចទឹកដាក់ជី ហើយថែមទាំងចេះការពារ បោចស្មៅល្អាស់ចេញទៀតផង ទើបប្រសើរ។

ឯឃ្លាចុងក្រោយ " ទុកដាក់កូនចៅអោយមើលផៅសណ្តាន " មានន័យថា ការរៀបចំទុកដាក់កូនចៅអោយមានប្តីប្រពន្ធ អ្នកជាមេបា មាតាបិតា អាណាព្យាបាល ត្រូវតែពិនិត្យតាមដាន យ៉ាងម៉ត់ចត់ អំពីពូជអំបូរ ញាតិផៅសាវតា របស់កូនប្រុសស្រីម្ខាងទៀតដែលបំរុងទុកដាក់អោយបានគ្នាជាគូគាប់។ ការធ្វើបែបនេះគឺជា កត្តាសំខាន់បំផុត សំរាប់កំណត់វាសនា កូនរបស់ខ្លួន អោយបានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ និងមានសុភមង្គល់។ ខ្លឹមសារនៃការអង្កេតពិនិត្យ គឺសំដៅលើទឹកចិត្ត អាកប្បកិរិយា មិនសង្កត់ធ្ងន់លើ ជីវភាពក្រ ឬមាននោះទេ។ ផ្ទុយទៅវិញបើមេបា អាណាព្យាបាល ធ្វេសប្រហែសមិនបានពិចារណា លើបញ្ហានេះទេ កូនប្រុសស្រីរបស់ខ្លួនពិតជា មិនបានសុខឡើយ ពោលគឺ នឹងទទួលបានភាពអវិជ្ជមាន គ្មានសុភមង្គល ជួបភាពកំសត់ ក្រលំបាក នៅថ្ងៃមុខជាក់ជាមិនខាន។

រួមសេចក្តីមកការរៀមចំកូនចៅអោយមាន គួស្រករ គប្បីពិនិត្យអោយបានល្អិតល្អន់ និងចេះស្វែងយល់ពីទឹកចិត្ត របស់កូនប្រុសស្រីផងដែរ ទើបល្អ មិនមានភាពខកខាន និងស្តាយក្រោយ។

ជារួមមកឆ្លងកាត់តាមការ បកស្រាយខាងលើយើញថា ប្រធានបទនេះពិតជាត្រឹមត្រូវ និងមានអត្ថន័យទូលំទូលាយ សំរាប់អប់រំទូន្មានប្រៀនប្រដៅ កូនខ្មែរ ជំនាន់ក្រោយៗអោយយល់ដឹងបានច្បាស់លាស់ អំពីរបៀបរបបរស់នៅ ដែលនាំអោយទទួលបានសេចក្តីសុខសុកមង្គល ចៀសវាងភាពលង់ខ្លៅ គិតខុសដែលនាំអោយវិនាស ដល់ខ្លួនឯងព្រមទាំងក្រុមគ្រួសារ ទៀតផង។ ដូចនេះខេមរបុត្រទាំងឡាយ គប្បីខិតខំប្រឹងប្រែងស្វែងរករៀនសូត្រ ដើម្បីទទួលចំណេះ និងបំនិន ក៏ដូចជាបទពិសោធ ផ្សេងៗ ទុកខ្លួនសំរាប់ជាទុន ក្នុងការកំណត់វាសនារបស់ខ្លួន ព្រមទាំងកូនចៅនិងក្រុមគ្រួសារ៕

ប្រធានទី១៤៖ ពំនោលមួយពោលថា " ចង់ធំខំពីតូច បើខ្លាចខូចកុំធាប់ខឹង ការឆ្លើយអោយចេះថ្លឹង កុំបីប្រឹងជុះតាមដំរី ។ តើពំនោលនេះមានន័យយ៉ាងដូចម្តេច?

សេចក្តីអធិប្បាយ

សុភាសិត ពាក្យស្លោក ពំនោលច្បាប់ពាក្យចាស់ គឺត្រូវបានបង្កើតឡើងដោយស្នាដៃកវីនិពន្ធ និងអ្នកប្រាជ្ញជំនាន់ដើមទុកជាច្បាប់សំរាប់អប់រំ ទូលមានប្រៀនបប្រដៅកូនចៅជំនាន់ក្រោយអោយមានការគ្រេះរិះ ពិចារណាសិក្សារៀនសូត្រស្វែងរកគំណិតត្រូវផ្លូវល្អ គួរប្រព្រឹត្ត ឬមិនគួរប្រព្រឹត្ត។ ដោយសេចក្តីពិតមែននេះហើយទើបមានពុំនោលមួយពោលថា " ចង់ធំខំពីតូច បើខ្លាចខូចកុំធាប់ខឹង ការឆ្លើយអោយចេះថ្លឹង កុំបីប្រឹងជុះតាមដំរី "។

ពំនោលខាងលើនេះមានអត្ថន័យយ៉ាងណា?

ក្នុងសង្គមខ្មែរពីអតីតកាល មនុស្សភាគច្រើនអវិជ្ជាល្ងង់ខ្លៅ យើញបែបនេះហើយទើបកវីនិពន្ធ អ្នកប្រាជ្ញលើកច្បាប់នែនាំថា " ចង់ធំខំពីតូច "។ ចង់សំដៅទីនេះ គឺមានអត្ថន័យឆ្ពោះទៅលើការចង់មានចំណេះវិជ្ជាច្រើន មានកិត្តិយសល្បីល្បាញដោយសេចក្តីល្អ មានបុណ្យស័ក្តិ និងទ្រព្យសម្បត្តិសុកស្តម្ភ មានគេស្រលាញ់រាប់អានស្ងើចសរសើរគោរពស្រលាញ់។ ឯខំពីតូច គឺបញ្ជាក់ថាខំពីកុមារ ឬនៅពីយុវវ័យ ព្រោះវ័យនេះកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ឬអាណាព្យាបាល គឺងាយក្នុងការខិតខំសន្សំយកនូវចំណេះវិជ្ជាផ្សេងៗ ព្រោះក្នុងវ័យនេះមិនមានជាប់ជំពាក់ការងារអ្វីក្រៅពីខិតខំ ព្យាយាមប្រឹងប្រែងរៀនសូត្រទទួលយកចំណេះដឹង និងបំនិនពិតប្រាកដ ជាមូលហេតុនាំអោយយើង ចិញ្ចឹមជីវិតបានងាយស្រួល។ ទាំងនេះបញ្ជាក់ថា ការខំពីក្មេង គឺមានប្រយោជ។ ផ្ទុយទៅវិញបើយើងមានការធ្វេសប្រហែស មិនបានខំរៀនសូត្រ ឬស្អប់ខ្ពើមការធ្វើការងារផ្សេងៗ នោះជាមនុស្សល្ងង់ខ្លៅជាហេតុនាំអោយយើងជួបភាពលំបាក វេទនាគ្មានសុកមង្គល។ កវីបានបន្តទៀតថា " បើខ្លាចខូចកុំធាប់ខឹង " គឺមានន័យបញ្ជាក់ថាត្រូវតែមានអំណត់អត់ធន់ ខាំមាត់សង្កត់ចិត្ត ជំនះលើឧបសគ្គទាំងឡាយ ថែមទាំងមានអត្តចរិករឹងប៉ឹងមាំមួនចំពោះការងារដែលត្រូវធ្វើ វាជាកត្តានាំទៅរកសេចក្តីសំរេចជោគជ័យ។ ប៉ុន្តែបើយើងគ្មានចិត្តអំណត់ ឆេវឆាវនោះ នឹងមិនបានទទួលជ័យជំនះលើការងារបានឡើយ។ សមដូចពាក១ឃ្លាពោលថា ខឹងខុសខឹងខូចខឹងខាត។ ដូចនេះយើងគប្បីជៀសវាង នូវអំពើក្រោធខឹង ទោសៈ មោហៈ ប្រកាន់ធម៌ខន្តី អហឹង្សាជានិច្ចទើបល្អប្រសើក្នុងដំណើរជីវិតរស់នៅ។ បន្ថែមទៀតកវីពោលថា " ការធ្វើអោយចេះថ្លឹង " គឺជាការទាមទាអោយចេះថ្លឹងថ្លែងពិចារណាមើលពីសមត្ថភាពដែលខ្លួន មាន ជៀសទទួលបានភាពខកខានខាត បង់ប្រយោជទើបស្តាយក្រោយ។ ជាក់ស្តែងក្នុងការចូលប្រឡូក រកមុខរបរចិញ្ចឹមជីវិត យើងត្រូវគិតថ្លឹងថ្លែងមើលពីដើមទុនរបស់ខ្លួន តើអាចធ្វើដោយកំរិតណា? ហើយផលចំណេញដែលទទួលអាចមានកំរិតប៉ុណ្ណាដែរ។ បើយើងចេះតែធ្វើទាំងងងឹតងងុលគ្មានគិតគូរពិចារណាទេនោះ យើងនឹងទទួលបានមកវិញនូវភាពបរាជ័យ អស់សង្ឃឹមក្នុងឆាកជីវិត។ ដូចនេះយើងគួរគិតរួចសឹមគូ ទើបល្អប្រសើរ និងមានភាពជោគជ័យក្នុងការរស់នៅ។ ជាចុងក្រោយនៃពំនោលក្នុងប្រធានបទនេះគឺ " កុំបីប្រឹងជុះតាមដំរី " ឱ្យគិតពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន

ទាំងផ្នែកចំណេះវិជ្ជា កំលាំពលំ ទ្រព្យសម្បត្តិ ស័ក្តិយស និងប្រាជ្ញាស្មារតី កុំអោយប្រឹងធ្វើញទង្វើអ្វីដែលហួសពីសមត្ថភាពរបស់ខ្លួន ជាហេតុនាំអោយខាតប្រយោជ។ នេះវាជារឿងពិតប្រាកដបំផុតក្នុងសង្គមរស់នៅរបស់មនុស្ស អ្នកមានទ្រព្យសម្បត្តិច្រើន គេអាចចាយវាយ ធ្វើផ្ទះសំបែងបានធំខ្ពស់ស្អាតបាត ប្រើប្រាសសុទ្ធតែវត្ថុមានតំលៃ។ ឯអ្នកក្រខិតខំប្រឹងធ្វើតាមគេមិនបានកើតឡើយពីព្រោះវាហួសពី លទ្ធភាព និងសមត្ថភាពរបស់ខ្លួន។ បើយើងនៅតែជំនះធ្វើតទៅទៀតមិនត្រឹមតែមិនសំរេចទេ វាថែមទាំងធ្វើអោយជីវភាពរស់នៅកាន់តែធ្លាក់ដុនដាបកាន់ខ្លាំងថែម ទៀត។ ដើម្បីរស់នៅបានស្រណុកសុខស្រួលនោះយើងគួរធ្វើអ្វីៗឱ្យសមស្រប និងសមត្ថភាពរបស់ខ្លួន។

សរុបសេចក្តីមក កវីចង់អប់រំកុលបុត្រកុលធំតាខ្មែរជំនាន់ក្រោយ ឱ្យខិតខំរៀនសូត្រតាំងពីវ័យកុមារ និងយុវជន ហើយមានខ័ន្តីអំណត់អត់ធន់ ចេះគិតគូរពិចារណាឱ្យបានល្អិតល្អន់ មុនធ្វើការងារអ្វីមួយព្រមទាំងមានចិត្តតស៊ូព្យាយាម។ ពិសេសឱ្យចេះប្រមើល់មើលពីសមត្ថភាពរបស់ខ្លួន។

យោងតាមការបកស្រាយខាងលើយើងឃើញថា ប្រធានបទនេះមានអត្ថន័យល្អ សំរាប់អប់កូនចៅខ្មែរ ជំនាន់ក្រោយ ឱ្យចេះដើរតាមផ្លូវល្អ ត្រឹមត្រូវមានអំណត់អត់ធន់ ព្យាយាមរៀនសូត្រ។ ដូចនេះយើងជាខេមរបុត្រគ្រប់ជំនាន់ទាំងអស់ត្រូវខិតខំអនុ វត្តឱ្យបានល្អត្រឹមត្រូវតាមការអប់រំដែលជាគំនិត ដ៏វិសេសវិសាលរបស់ចាស់ទុំបរមបុរាណ៕

ប្រធានទី១៥ ទស្សនៈមួយបានពោលថា "គ្រប់អក្សរសិល្ប៍ទាំងអស់គឺជាមធ្យោបាយដ៏សំខាន់ក្នុងការអប់រំទូន្មាន"។ ចូរស្រាយបញ្ជាក់ ។

<u>សេចក្តីអធិប្បាយ</u>

អក្សរសិល្ប៍ជាកំរងអត្ថបទ ដែលកវីនិពន្ធបានតាក់តែងឡើងមានជាពាក្យរាយ និងជាពាក្យកាព្យ ព្រម ទាំងបានលើកយកពីបញ្ហាមនុស្សក្នុងសង្គមកាលនីមួយៗ មកចោទនិងបង្ហាញ រួចធ្វើការដោះស្រាយទៅតាម គំនិតរបស់ខ្លួន ។អាស្រ័យដោយហេតុនេះបានជាគេចាត់ទុកគ្រប់អក្សរ សិល្ប៍ទាំងអស់គឺជាមធ្យោបាយដ៏សំខាន់ក្នុងការអប់រំទូន្មាន ។

តើមតិខាងលើបានអប់រំទូន្មានដូចម្តេចខ្លះ ?

ដើម្បីជាជំនួយក្នុងការធ្វើដំណោះស្រាយបញ្ហាខាងលើឲបានស៊ីជុំវៅត្រូវយល់ន័យ " អក្សរសិល្ប៍ " និង " ការអប់រំទូន្មាន" ជាមុនសិន។ អក្សរសិល្ប៍ជាវិជ្ជាស្បង់ ដែលចោទនឹងដោះស្រាយបញ្ហាមនុស្សដោយសិល្បវិធី ទៅតាមសង្គមនីមួយៗ (របស់កេងវ៉ាន់ សាក់) ។ រីឯ ការអប់រំទូន្មានគឺការនែនាំប្រដៅមនុស្សឲអនុវត្តផ្លូវល្អ ។

អក្សរសិល្ប៍គ្រប់ប្រភេទោះរឿងព្រេងក្តី បុរាណក្តី ទំនើបក្តី ពុំមែនគ្រាន់តែសំរាប់ការអានកំសាន្ត បណ្តែតអារម្មណ៍ រឺ កំដរ កែអផ្សុកប៉ុណ្ណោះទេ ។ តែវាមានតួនាទីសំរាប់អប់រំទូន្មានផ្តល់បទពិសោធជាច្រើន ដល់អ្នកអាន អ្នកស្តាប់ផងដែរ ។ ម៉្យាងទៀតកាលណាគេអានរឿង គេស្តាប់រឿង រមែងតែងតែមានអារម្មណ៍ ប្លែកៗ ទៅតាមចលនារឿង នៃសកម្មភាពតួអង្គនីមួយៗ ។

ក្នុងរឿងព្រេងប្រជាប្រិយ ដូចជារឿងចចកអប់រំមនុស្សពីរពួក គឺពួកអាងកំលាំង និងអំណាចរំលោភជិះ ជាន់គេ ។ ពួកកំពឹសនៅពេលគ្រោះមរណៈមកដល់គេមិនបណ្តោយខ្លួនទៅតាមយថាកម្មឡើយ ដោយអស់ សង្ឃឹមនោះទេ ។ គឺត្រូវប្រើប្រាជ្ញាដើម្បីរំដោះខ្លួន ។ ត្រីក្រាញ់គំរូតស៊ូអង់អាចក្លាហាន ហ៊ានធ្វើពលីកម្មដើម្បីបុព្វ ហេតុជីវិតសមូហភាព ។ នេះជាមេរៀនជីវិតសំរាប់អ្នកទន់ខ្សោយ ។ ចំពោះអ្នកខ្លាំងពូកែត្រូវចៀសវាងការជិះ ជាន់គេ ព្រោះជាហេតុនាំមកនូវការគ្រោះថ្នាក់ដូចពួកចចក ។ រឿងធនញ្ជ័យបានអប់រំនែនាំសេដ្ឋីកុំឲជិះជាន់ កេងប្រវ័ញ្ចគេ ។ ចំពោះនាមីនមន្ត្រីកុំឲមើលងាយប្រជាជនក្រខ្សត់ ។ ចំនែកប្រជាកសិករបានអប់រំឲហ៊ានតស៊ូរើបំរាស់ ។ ជាពិសេសបានអប់រំនែនាំអ្នកដឹកនាំប្រទេសឲដឹងថាកំលាំងការពារ និងការសាងប្រទេសគឺប្រជាជន ។ ដូច្នេះក្នុងអក្សសិល្ប៍ប្រជាប្រិយ៍ បានអប់រំបង្ហាញឲឃើញពីការជិះជាន់ កេងប្រវ័ញ្ចពីអ្នកមានអំណាច មកលើ អ្នកទន់ខ្សោយ និងបង្ហាញពីកំលាំងប្រជាជនជាកំលាំងដ៏រឹងមាំរបស់ប្រទេសជាតិ ។

រឿងបុរាណក៏បានផ្តល់មេរៀនល្អៗសំរាប់យើងរៀនសូត្រតាមដែរ ។ ដូចជារឿងមាយើង គឺចៅមាណព បានធ្វើតាមពាក្យរបស់ប្រពន្ធគ្រប់លក្ខណ៍នាំឲមានហានៈដាមាយើង ព្រោះខ្មែរឲតំលៃថា " សំណាបយោងដី ស្ត្រីយោងប្រុស " ចំណែកច្បាប់ផ្សេងៗបានអប់រំ គ្រប់ផ្នែកតាំងពីសីលធម៌ រស់នៅ ទាំងពីពលកម្ម ដូចច្បាប់កេរ កាលថ្មីរបស់ក្រមង៉ុយបានពោលថា " កុំដេកចាំសំណាង កុំក្អេងក្អាងចាំបុព្វេ ខំរកកុំទំនេរ រៀនរិះចេះឲគ្រប់ " ។ដូចនេះក្នុងអក្សរសិល្ប៍បុរាណបានអប់រំបង្ហាញពីតំលៃរបស់នារី ព្រមទាំង អប់រំ

បណ្តុះស្មារតី ខិតខំរក ខំរៀន កុំឲដេកចាំព្រេងវាសនា ។រីឯរឿងទំនើប មានរឿងសឹមអ្នកបរឡាន បានអប់រំយើងឲឃើញពីទុក្ខវេទនារបស់កម្មករមកពីនាយ ទុនកេងប្រវ័ញ្ច គឺមិនមែនមកពីព្រេងវាសនាទេ ។ ថែមទាំងបានអប់រំបំផុសកម្មករ កសិករឲយល់ដឹងតំលៃនៃរឿង ដោយឲកម្មករខិតខំរៀនសូត្រនៅពេលទំនេរ និងបានបង្កើតសមាគមសហជីព ។ ចំណែករឿងកុលាបស ិលិន បានអប់រំមនុស្សឲមានចិត្ត អំណត់តស៊ូព្យាយាមធ្វើអំពើល្អ ព្រមទាំងបានបង្ហាញពីសេចក្តីស្នេហាគ្មាន បែងចែកវណ្ណៈ ហើយនិងអ្នកសាងបុណ្យបានបុណ្យ អ្នកសាងបាបបានបាប ។ ដូច្នេះអក្សរសិល្ប៍ទំនើបក៏បាន អប់រំយើង ឲស្រលាញ់ចំនេះដឹង កុំជឿលើអបិយជំនឿ ថែមទាំងឲមានចិត្តតស៊ូក្នុងជីវិតទៀតផង ។

សរុបសេចក្តីមកការអប់រំក្នុងអក្សរសិល្ប៍ បានបង្ហាញយើងឲឃើញនូវអំពើអាក្រក់ និងអំពើល្អ ។ មួយចំ ណែកទៀតអប់រំឲយើងស្អប់និងចៀសវាង ជឿលើអបិយជំនឿ ព្រមទាំងឲខិតខំរៀនសូត្រ ។

តាមការបកស្រាយខាងលើមកបង្ហាញឲឃើញថា អក្សរសិល្ប៍ជាមធ្យោបាយក្នុងការអប់រំទូន្មានល្អៗ ទាំងអស់ តាំងពីអក្សរសិល្ប៍ប្រជាប្រិយ បុរាណ និងទំនើប ។ ព្រមទាំងបង្ហាញនូវអត្ថប្រយោជន៍ល្អ ជាបទពិសោធក្នុងជីវិតទៀតផង ។ ដូចនេះយើងជាកុលបុត្រកុលធីតា ត្រូវខិតខំស្រង់យកបទពិសោធល្អក្នុង អក្សរសិល្ប៍ទុកជាផ្លូវសំរាបអនុវត្ត ។

ប្រធានទី១៦៖ មានទស្សនៈមួយពោលថា “លក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរចារឹកអត្តសញ្ញាណជាតិខ្មែរ”។ ចូរពន្យល់។

<u>សេចក្តីអធិប្បាយ</u>

វណ្ណកម្មអក្សរសិល្ប៍ដែលជាសមិទ្ធផលប្រសូតចេញពីទឹកដៃច្នៃប្រឌិត បង្កើតរបស់បណ្តាកវីអ្នកនិពន្ធតែងបង្កប់នូវលក្ខណៈទាំងប្រាំបីរបស់ខ្លួនក្នុងនោះមានលក្ខណៈមនុស្ស លក្ខណៈវណ្ណៈ លក្ខណៈប្រជាជន លក្ខណៈបក្ស លក្ខណៈប្រវត្តិ លក្ខណៈជាតិ និង លក្ខណៈអន្តរជាតិ។ និយាយពាក់ព័ន្ធទៅនឹងលក្ខណៈជាតិបានប្រការធ្វើឲ្យអ្នកវិភាគក្នុងមជ្ឈដ្ឋានខ្លះបានលើកឡើងថា៖ “លក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរចារឹកអត្តសញ្ញាណជាតិខ្មែរ”។

តើលក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរចារឹកអត្តសញ្ញាណខ្មែរយ៉ាងដូចម្តេចខ្លះ?

ដើម្បីបានជាស្ពានឈានទៅដល់ការបកស្រាយចំណោទបញ្ហារបស់ប្រធានខាងលើឲ្យកាន់តែជាលក្ខណៈពិស្តារ ប្រកបដោយខ្លឹមសារកាន់តែបានស៊ីជម្រៅមួយកម្រិតទ្វេឡើងទៀតនោះ គេចាំបាច់ត្រូវតែយល់ជាមុនសិននូវអត្ថន័យនៃពាក្យ “លក្ខណៈជាតិនៃអក្សរសិល្ប៍” , “ចារឹក” និង “អត្តសញ្ញាណជាតិខ្មែរ”។ ពាក្យថា “លក្ខណៈជាតិនៃអក្សរសិល្ប៍” គឺជាលក្ខណៈពិសេសរបស់ជាតិនីមួយៗលេចធ្លោខុសពីជាតិដទៃដែលស្តែងចេញតាមរយៈអក្សរសិល្ប៍។ ចំពោះពាក្យថា “ចារឹក” នោះគឺការសរសេរ ចារកត់ត្រា បង្ហាញ។ ដោយឡែកពាក្យថា “អត្តសញ្ញាណជាតិខ្មែរ” បានដល់សញ្ញាដែលធ្វើឲ្យគេស្គាល់ពីខ្មែរ។ មតិដែលវិភាគឃើញដោយប្រធានខាងលើមានអត្ថន័យចង់និយាយថាគេអាចស្គាល់ជាតិខ្មែរបានដោយរំពឹងមើលទៅក្នុងលក្ខណៈជាតិរបស់អក្សរសិល្ប៍។

ជាមួយនឹងការសិក្សាចលនាអក្សរសិល្ប៍រួចមកហើយ បានជាមូលហេតុដែលធ្វើឲ្យស្រទាប់យុវវ័យខ្មែរអ្នកសិក្សាផ្តោតការយល់ឃើញរបស់ខ្លួនថា “លក្ខណៈជាតិនៃអក្សរសិល្ប៍ខ្មែរចារឹកអត្តសញ្ញាណខ្មែរ”។ ពិតដូចការលើកឡើងរបស់មតិខាងលើនេះមែន គេអាចស្គាល់ជាតិខ្មែរបានជាប្រត្យក្សតាមរយៈលក្ខណៈជាតិខ្មែរដែលគេកត់ត្រាឃើញក្នុងរឿងរ៉ាវអក្សរសិល្ប៍។ យ៉ាងណាមិញបើគេសិក្សារឿងភូមិតិរច្ឆាន គេនឹងបានស្គាល់ខ្មែរតាមរយៈជំនឿដែលជាទូទៅមនុស្សខ្មែរតែងតែជឿលើវត្ថុសក្តិសិទ្ធិ មានទម្លាប់ក្នុងការបន់ស្រន់ បួងសួងដូចនៅក្នុងរឿងភូមិតិរច្ឆាន គេឃើញថាពួកទាហានបារាំងដែលមានទាហានខ្លះជុះអាចម៍រាករូស គ្រុនក្តៅ ញាក់ញ័រ គេថាដោយសារទាហានទាំងនោះមិនគោរពវត្ថុសក្តិសិទ្ធិដែលនៅថែរក្សាវិហារព្រះកែវមរកត។ ស្ថិតនៅក្នុងទម្លាប់បន់ស្រន់គេឃើញថាមាននារីខ្លះដែលមានសង្សាចុះកប៉ាល់ទៅច្បាំងនៅស្រុកបារាំងបានលួចទៅបន់ស្រន់ព្រះអង្គដងកើឲ្យបារមីព្រះអង្គទៅជួយគាំពារធានាថែរក្សាសង្សាឲ្យឆាប់មកស្រុកខ្មែរវិញ។ ក្នុងរឿងដដែលនេះគេឃើញមនុស្សខ្មែរមានជំនឿលើអព្ភូតហេតុធម្មជាតិដូចបានបង្ហាញថាមានរន្ធះបាញ់ចេតិយព្រះវិហារព្រះកែវមរកតខាងត្បូង។ តាមជំនឿគេថាស្រុកនឹងកើតគ្រោះរឹកវរ ចលាចល ឬកើតមានហេតុទុរភិក្ស។ ដំណើររឿងបានបង្ហាញនូវជំនឿរបស់ខ្មែរនៅក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងខណៈពេលដែលគេរត់ទៅពួននៅលើភ្នំតាបាំង អ្នកភូមិក្រាំងលាវបានយកដីនៅតាមក្រហែងថ្មមកបាចសាចលើក្បាលដើម្បីឲ្យព្រះធរណីជួយបិទបាំង កុំឲ្យបារាំងឃើញ។ បើគេនិយាយពីលក្ខណៈជាតិខ្មែរនោះគេពុំភ្លេចទាល់តែសោះឡើយថាខ្មែរគឺជាប្រជាជាតិមួយដែលមានទម្លាប់ជាទំនៀមក្នុងការចូលចែចូវ ចូលស្តីដណ្តឹងដូចជាសុវណ្ណដែលជាពោះម៉ាយកូនមួយបានឲ្យមេបាចាស់ទុំចូលទៅស្តីដណ្តឹងនាងតំ ក្រមុំសៅកែ

មកជាគូដណ្តឹង ជាប្រពន្ធទី២របស់ខ្លួនប៉ុន្តែបើគេមើលមកក្នុងរឿងទុំទាវ នោះគេនឹងឃើញពីលក្ខណៈជាតិរបស់ខ្មែរនៅសម័យលង្វែក គឺមនុស្សខ្មែរមានទម្លាប់របស់ខ្លួនមួយគឺថាបើអ្នកមានកូនប្រុសគេទម្លាប់ឲ្យចូលសាងផ្ទះ។ បើបួសជាសាមណេរដូចនេនទុំ និងនេនពេជ្រគឺបួសដើម្បីសងគុណម្តាយ តែបើបួសជាភិក្ខុគឺបួសដើម្បីសងគុណឪពុក។ បើនិយាយពីរឿងជំនឿវិញ គេឃើញថាខ្មែរនាសម័យលង្វែកនិយមជឿលើមន្តអាគម អូមអាមដូចនាយទុំទៅស្នូត្រនៅផ្ទះម្តាយទាវបានដាក់មន្តសារិកាលិនថោងឲ្យពិរោះក្រអួនដើម្បីទាក់ទាញអ្នកស្តាប់ឲ្យចេះតែចូលចិត្តស្តាប់។ ដោយឡែកចំណែកអ្នកមានកូនស្រី ដូចករណីម្តាយទាវតែងទម្លាប់ឲ្យកូនស្រីចូលម្លប់។ បើគេរំពឹងសំលឹងមើលមកក្នុងវិស័យជំនឿ គេឃើញមនុស្សសម័យលង្វែកនិយមជឿលើមន្តអាគមផង ជឿលើការទស្សទាយផងដូចព្រះគ្រូចៅអធិការវត្តវិហារធំ មុនពេលឲ្យទុំលាចាកសិក្ខាបទ លោកគ្រូបានទាញក្តារ ទាញដីសមកគូសរៀសលេខអត្តមើលជោគជតារាសីជាមុនសិន។សិក្សាអំពីប្រពៃណីឃើញថាសង្គមខ្មែរសម័យលង្វែកមានប្រពៃណីជាក់លាក់របស់ខ្លួនដោយអនុវត្តតាមទស្សនៈ “នំមិនធំជាងនាឡិ” ដែលមាតាបិតាដែលមានកូនប្រុសកូនស្រីមិនផ្តល់សិទ្ធិស្វ័យសម្រេចឲ្យកូនៗនោះទេ គឺឪពុកម្តាយជាអ្នកសម្រេចអ្វីៗគ្រប់យ៉ាង។ ទំនៀមទម្លាប់នោះក៏ដូចជាសម័យបច្ចុប្បន្នដែរគឺកូនប្រុសត្រូវតែចុលខ្លួនទៅរៀបការនៅផ្ទះខាងកូនស្រីដូចករណីមុឺនងួនត្រូវរៀបការជាមួយនឹងនាងទាវនៅផ្ទះខាងស្រី។ ចំពោះសាសនាវិញគេឃើញសង្គមខ្មែរសម័យលង្វែកផ្តោតជំនឿលើព្រះពុទ្ធសាសនានិកាយហិនយានទទួលឥទ្ធិពលពីមហាយានមានអ្នកបួសក្នុងសំណាក់ពុទ្ធសាសនានេះដែរ។

ដូចនេះបើនិយាយឲ្យខ្លីក្នុងអត្ថន័យជាសរុបសេចក្តីមកឃើញថាតាមរយៈលក្ខណៈជាតិខ្មែរដែលកវីនិពន្ធបានកត់ត្រាក្នុងបណ្តាស្នាដៃអក្សរសិល្ប៍ខ្មែរនានាសុទ្ធសឹងតែជាសញ្ញាសំគាល់ឲ្យគេស្គាល់មនុស្សខ្មែរបានដោយងាយ។

យោងតាមបណ្តាហេតុផលដែលបានលើកបង្ហាញរួចហើយខាងលើ អាចឲ្យយើងធ្វើការវិនិច្ឆ័យ វាយតម្លៃទស្សនៈលើកឡើងរបស់ប្រធានថាពិតជាមានអត្ថន័យត្រឹមត្រូវសមស្របដែលយើងអាចទទួលបានដោយហេតុថាអក្សរសិល្ប៍ខ្មែរមានសារៈសំខាន់ដូចខាងលើទើបតម្រូវឲ្យយុវសិក្ខាកាមជនលើកស្ទួយវប្បធម៌ អក្សរសាស្ត្រសីលធម៌ដូចជា “វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិប្តើងថ្កាន”។

ប្រធានទី១៧៖ គេថា "នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និង គ្រួសារ"។ ចូរពន្យល់ដោយបញ្ជាក់ពីសកម្មភាពរបស់នារីក្នុងរឿងភូមិតិរច្ឆាន និង រឿងគូលីកំណែន។

<u>សេចក្តីអធិប្បាយ</u>

ចំពោះការអភិវឌ្ឍន៍ប្រទេសជាតិកាលពីសម័យមុនក៏ដូចជាសម័យបច្ចុប្បន្នដែរគេត្រូវការចាំបាច់នូវការចូលរួមពីកម្លាំងរបស់នារីភេទ។ តាមរយៈប្រវត្តិសាស្ត្រ និង ទំនៀមទម្លាប់ប្រពៃណីខ្មែរ សង្គមខ្មែរយើងបានលើកតម្កើងស្ត្រីជាធំ។ ទាំងនេះបញ្ជាក់ថាស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរ។ ស្របទៅនឹងទស្សនៈខាងលើនេះហើយទើបមានមតិមួយយល់ថា " នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និង គ្រួសារ"។

តើនារីបានចូលរួមសកម្មភាពអ្វីខ្លះចំពោះការអភិវឌ្ឍន៍សង្គមជាតិនិងគ្រួសារ?

ដើម្បីងាយស្រួលដល់ការបកស្រាយនូវចំណាចទបញ្ហាខាងលើ យើងគប្បីយល់នូវអត្ថន័យរបស់ពាក្យ "រួមវិភាគទាន និង អភិវឌ្ឍ " ជាមុនសិន។ ពាក្យថា "រួមវិភាគទាន"មានន័យថា ការចូលរួមចំណែកធ្វើនូវអំពើណាមួយជាមួយអ្នកដទៃ។ រីឯពាក្យ "អភិវឌ្ឍ " មានន័យថា ការធ្វើអ្វីមួយឲ្យលូតលាស់រីកចម្រើន។ តាមរយៈអត្ថន័យរបស់ពាក្យខាងលើទស្សនៈរបស់ប្រធានមានន័យថា នារីភេទបានចូលរួមចំណែកយ៉ាងច្រើនសន្ធឹកសន្ធាប់ណាស់ក្នុងការស្ថាបនិងកសាងនូវជីវភាពគ្រួសារ និង សង្គមជាតិឲ្យមានការរីកចម្រើនលូតលាស់។

វាប្រាកដណាស់ដែលថា នារីជាកម្លាំងដ៏សំខាន់មួយក្នុងការអភិឌ្ឍន៍សង្គមជាតិនិង គ្រួសារឲ្យរីកចម្រើន។ បើយើងក្រឡេកទៅមើលនារីក្នុងរឿងភូមិតិរច្ឆានវិញយើងក៏ឃើញថា លោក ឱឹក អំ និង ឌឹក គាមបានបង្ហាញច្បាស់នូវសកម្មភាពនារីខ្មែរមួយចំនួននៅភូមិក្រាំងលាវ ដែលតំណាងឲ្យនារីខ្មែរទូទៅនៅក្នុងប្រទេសដែលមានទឹកចិត្តក្លាហានក្នុងការបញ្ចេញនូវមតិដែលសុទ្ធតែគំនិតឈ្លើនក្នុងការតបតជាមួយពួកអាណាគមន៍បារាំង និង បរិវា។ តួយ៉ាងដូចជានាងតន់ករិយារបស់សុវណ្ណ ក្រោយពីបាត់ប្តីក៏ខំដើរកនៅមន្ទីរឃុំឃាំងដោយនាងសាកសួរអ្នកយាមម្នាក់ដែលជាបរិវាបំរើដាច់ថ្លៃរបស់បារាំង។ អ្នកទាំងពីរក៏បានប្រកែកគ្នាយ៉ាងតឹងសសៃកដូចសំជីនាងតន់បញ្ជាក់ថា "រឿងស្លាប់ជាការធម្មតាទេចឹ ! បើអ្នកស្រុកក្រាំងលាវមិនស្លាប់នឹងគ្រាប់កាំភ្លើងរបស់ចឹ ក៏គង់តែស្លាប់នឹងចាស់ជរា ឬ ស្លាប់នឹងរោគាផ្សេងៗ" ។ នាងតន់ក៏និយាយទៀតថា " មកពីគេទុកខ្មែរដូចសត្វតិរច្ឆានហ្នឹងហើយ បានជាមានរឿងធំដល់បុណ្ណឹង! ហើយខ្ញុំនឹកស្មានថា លោកចិត្តជាខ្មែរ! "។លើសពីនេះទៅទៀត នាងនី នាងប៊ី ក៏មានសេចក្តីក្លាហានក្នុងការប្រកែកតវ៉ាជាមួយពួកអាណានិគមបារាំងផងដែរ។ ដូចជាមានឃ្លាបញ្ជាក់ថា " នែលោកធំ! លោកប្រើអំណាចលើខ្ញុំ និង ជាតិខ្ញុំជ្រុលពេកហើយ។ លោកជាក់ខ្នោះប្តីមិនស្កប់ចិត្ត ឥឡូវលោកគិតជាក់ខ្នោះប្រពន្ធទៀត ...."។ ដោយឆ្អែតចិត្តនឹងពួកបារាំងជិះជាន់នាងប៊ីបានបន្តទៀតថា " លោកធ្វើចៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមតែប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ចង់ខ្មែរជាច់ពោះស្លាប់ លោកឥតឈឺក្បាលទេ លោកគិតតែពីសង្កើញទារពន្ធឲ្យខានតែបាន។ នេះឬដែលហៅថា អាណាព្យាបាល? "។ សកម្មភាពទាំងនេះបញ្ជាក់ថានារីបានចូលរួមក្នុងការអភិវឌ្ឍន៍សង្គមជាតិ។

ចំពោះក្នុងគ្រួសារវិញ នារីមានតួនាទីសំខាន់ណាស់ក្នុងការមើលថែទាំកូនចៅមើលការខុសត្រូវចំពោះផ្ទះសម្បែង។ នារីជាទីប្រឹក្សាមួយដ៏ល្អជាមួយប្តីកូនចៅមុនសម្រេចធ្វើអ្វីមួយ។ ចំពោះស្ថានភាពសង្គមនាពេលបច្ចុប្បន្ននារីក៏បានជួយបង្កើននូវជីវភាពគ្រួសារផងដែរ តាមរយៈការបង្កបង្កើនផល ឬលក់ដូរប្រកបអាជីវកម្មផ្សេងៗជាមួយកម្លាំងបុរស។ បើយើងក្រឡេកមើលក្នុងរឿងគូលីកំណែនវិញម្តងយើងក៏ឃើញថា លោកអឹមថុកក៏បានបង្ហាញអំពីសកម្មភាពនារីក្នុងផ្នែករឿងផងដែរ។ នៅក្នុងចំនុចនេះយើងឃើញថា អ្នកគ្រូ

គូ រស់ បានផ្តល់កម្លាំងគ្រប់យ៉ាងដល់ម៉ឹងក្នុងការតស៊ូរំដោះជាតិមាតុភូមិពីកណ្តាប់ដៃបរទេសឈ្លានពាន។ទោះបីមិនបានចេញតស៊ូដោយផ្ទាល់ក៏ដោយ ក៏អ្នកគ្រូបានចូលរួមចំណែកដោយប្រយោលដោយជួយជាគំនិតយោបល់ និង គាំទ្រដល់ការសម្រេចចិត្តរបស់ម៉ឹងដែរ។ ម៉្យាងវិញទៀតចំពោះជីវភាពគ្រួសារវិញ នារីក៏បានខិតខំជួយជាកម្លាំងបុរសផងដៃរក្នុងការធ្វើស្រែចំការ និង ធ្វើការងារស្រាលៗនៅឯផ្ទះជំនួសកំលាំងប្តី។ សកម្មភាពទាំងនេះជាការសម្រាលនូវបន្ទុកជីវភាពគ្រួសារមួយផ្នែកដែរ។ចំនុចមួយទៀតគឺការស្មោះត្រង់ប្តូរផ្តាច់ក្នុងគ្រាមានអាសន្ន ឬការលំបាកផ្សេងៗ។ ជាក់ស្តែងដូចជានាងហោងមិនបណ្តោយខ្លួនឲ្យភ្លាយជាចំណីតណ្ហារបស់ចៅហ្វាយស្រុកតាមរយៈអំណាចទឹកប្រាក់ឡើយ។ នាងហោងសុខចិត្តរត់គេចពីស្រុកកំណើតជាមួយឪពុកម្តាយលឺមមកភ្នំពេញរហូតបាត់បង់ជីវិត។

សរុបមក នារីពិតជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ និង គ្រួសារប្រាកដមែន។

រួមសេចក្តីមកតាមរយៈការបកស្រាយក្នុងអក្សរសិល្ប៍រឿងទាំងពីររួចមកយើងអាចសន្និដ្ឋានបានថានារីជាកំលាំងដ៏សំខាន់ក្នុងការរួមចំណែកធ្វើឲ្យសង្គមគ្រួសារ និង សង្គមជាតិរីកចំរើន។ នារីបានជួយជ្រោមជ្រែងចំពោះការងារបុរសជាច្រើនទាំងការស្រួលលំបាកគ្រប់បែបយ៉ាងដើម្បីបំរើឲ្យការរស់នៅប្រកបដោយលក្ខណៈល្អប្រសើរ។

ដូចនេះក្នុងនាមយើងជាពលរដ្ឋគ្រប់រូប យើងត្រូវលុបបំបាត់នូវគំនិតរើសអើងស្ត្រីភេទដោយយើងត្រូវចាត់ទុកស្ត្រីភេទជាកំលាំងចលករមួយចូលរួមក្នុងសកម្មភាពផ្សេងៗទាំងក្នុងគ្រួសារ និង សង្គមជាតិដូចយើងដែរ។ យើងត្រូវគិតថាស្ត្រី និង បុរសមានសិទ្ធិស្មើគ្នាក្នុងការរស់នៅក្នុងសង្គមជាតិ៕

ប្រធានទី១៨៖ ចូរតែងសេចក្តីអំពីបុណ្យចូលឆ្នាំប្រណីខ្មែរ។

<u>សេចក្តីអធិប្បាយ</u>

ជាតិសាសន៍និមួយៗលើលោកយើងនេះមានវប្បធម៌ប្រពៃណីផ្សេងៗពីគ្នា។ ចំណែកប្រជាជនខ្មែរដែលជាជាតិសាសន៍មួយមានវប្បធម៌ប្រពៃរុងរឿងតាំងពីយូរយោណាស់មកហើយក៏មានខឿនអរីយធម៌ដ៏ល្អរបស់ខ្លួនបន្សល់ទុកមកដល់បច្ចុប្បន្ននេះដែរ។ យ៉ាងណាមិញ ចំពោះបុណ្យចូលឆ្នាំប្រពៃណីខ្មែរមានលក្ខណៈពិសេសគួរជាទីចាប់អារម្មណ៍។

តើបុណ្យចូលឆ្នាំប្រពៃណីខ្មែរមានលក្ខណៈយ៉ាងណាខ្លះ?

ដើម្បីងាយស្រួលដល់ការស្វែងយល់ពីប្រភពនៃបុណ្យចូលឆ្នាំខ្មែរ យើងត្រូវយល់ដឹងពីប្រភពនៃរឿងនិទានទាក់ទងនឹងពិធីបុណ្យចូលឆ្នាំខ្មែរនេះ។ រឿងនិទានប្រវត្តិពិធីបុណ្យចូលឆ្នាំ ប្រវត្តិនៃពិធីបុណ្យចូលឆ្នាំខ្មែរបានដល់រឿងនិទានមួយ នៅក្នុងសង្ក្រានសូត្រនិទានថាមានបុរសម្នាក់ឈ្មោះថាធម្មបាលជាអ្នក ប្រាជ្ញាចេះចប់ត្រៃវេទ ព្រមទាំងចេះភាសាសត្វបក្សីផង ហើយតែងតែសម្តែងមង្គលដល់មនុស្សទាំងអស់។

លុះកបិលមហាព្រហ្ម (សម័យនោះគេគោរពបូជាមហាព្រហ្ម និងកបិលមហាព្រហ្ម)ជ្រាបថាធម្មបាលកុមារជាអ្នកប្រាជ្ញ ក៏មកសួរប្រស្នា៣ខ ហើយសន្យាថា ប្រសិនបើធម្មបាលដោះប្រស្នានេះរួច កបិលមហាព្រហ្មនឹងកាត់ក្បាលខ្លួនបូជាធម្មបាល។ តែបើធម្មបាលមិនអាចដោះស្រាយប្រស្នារួច ទេ ត្រូវកាត់ក្បាលបូជាជូនមហាព្រហ្មវិញ។ ធម្មបាលសូមបង្អង់៧ថ្ងៃសិន ដើម្បីគិតប្រស្នា ប៉ុន្តែ៦ថ្ងៃបានកន្លងផុតទៅហើយ នៅតែគិត មិនឃើញ ធម្មបាលក៏ភៀសខ្លួនទៅពួនក្រោមដើមត្នោតមួយគូដែលជាលំនៅសម្បុកនៃសត្វឥន្ទ្រី។ ជាភ័ព្វសំណាងល្អ យប់នោះធម្មបាលក៏បានឮសត្វឥន្ទ្រីញីឈ្មោលនិយាយគ្នា។ សត្វឥន្ទ្រីញីបានសួរទៅសត្វឥន្ទ្រីឈ្មោលថា ថ្ងៃនេះយើងបានអ្វីជាអាហារ? សត្វឥន្ទ្រីឈ្មោលនិយាយទៅសត្វឥន្ទ្រីញីថា ថ្ងៃនេះ នឹងបានសាច់ធម្មបាលកុមារស៊ីជាអាហារដែលត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីញីបានសួរទៀតថា ប្រស្នា នោះដូចម្តេច? ឥន្ទ្រីឈ្មោលឆ្លើយថា ៖ • ខ១ ៖ នៅវេលាព្រឹក សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅមុខ ហេតុនេះហើយមនុស្សទាំងឡាយ ត្រូវយកទឹកលុបលាងមុខ។ • ខ២ ៖ ថ្ងៃត្រង់ សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅទ្រូង ហេតុនេះទើបមនុស្សទាំងឡាយយកទឹកលាងទ្រូង។ • ខ៣ ៖ វេលាល្ងាច សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថានៅជើង ហេតុនោះទើបមនុស្សទាំងឡាយយកទឹកលាងជើង។ ពាក្យពេចន៍ទាំងប៉ុន្មានរបស់ឥន្ទ្រីក៏បានមកជាពន្លឺមកបំភ្លឺដោះស្រាយប្រស្នាកបិលមហាព្រហ្ម រួចចៀសផុតពីក្តីមរណៈ។ កបិលមហាព្រហ្មសុខចិត្តចាញ់ ព្រមកាត់ក្បាលបូជាធម្មបាល។ មុនពេលកាត់ក្បាល កបិលមហាព្រហ្មបានកោះហៅទេពធីតា ទាំង៧អង្គដែលជាបុត្រីរបស់ខ្លួនឱ្យយកពានមកទ្រក្បាល ព្រោះថាបើដាក់ក្បាលនោះនៅលើផែនដីនឹងឆេះលោកធាតុ។ បើបោះទៅ លើអាកាសនឹងរាំងភ្លៀង បើចោលទៅក្នុងសមុទ្រ ទឹកនឹងរីងស្ងួតអស់ រួចក៏កាត់ក្បាលឱ្យទៅនាងទុង្សាជាកូនច្បង។ នាងទុង្សាហៅ ក្បាលកបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុ ៦០នាទី ទើបអញ្ជើញក្បាលនោះទៅប្រតិស្ឋានទុកក្នុងមណ្ឌលភ្នំកៃលាស។ លុះដល់ គម្រប់មួយឆ្នាំសង្ក្រាន ទើបនាងទេពធីតាទាំង៧អង្គផ្លាស់វេនគ្នាមកដង្ហែក្បាលកបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុជារៀងរាល់ ឆ្នាំ។ 1. បើសង្ក្រានត្រូវចំថ្ងៃអាទិត្យ ត្រូវវេននាងទស្សា 2. បើសង្ក្រានត្រូវចំថ្ងៃច័ន្ទ ត្រូវវេននាងគោរាគ 3. បើសង្ក្រានត្រូវចំថ្ងៃអង្គារ ត្រូវវេននាងរាក្សសា 4. បើសង្ក្រានត្រូវចំថ្ងៃពុធ ត្រូវវេននាងមណ្ឌា 5. បើសង្ក្រានត្រូវចំថ្ងៃព្រហស្បត៍ ត្រូវវេននាងកិរិណី 6. បើសង្ក្រានត្រូវចំថ្ងៃសុក្រ ត្រូវវេននាងកិមិរា 7. បើសង្ក្រានត្រូវចំថ្ងៃសៅរ៍ ត្រូវវេននាងមហោទរ ដោយមាននិទានបែបនេះហើយ ទើបខ្មែរយើងមានជំនឿ ហើយបានរៀបចំជាពិធីបូជាទេវតាដែលត្រូវវេនដង្ហែក្បាលកបិល មហាព្រហ្ម និងត្រូវអកិបាលពិភពលោករៀងរាល់ឆ្នាំថ្មីចូលមកដល់ពុំដែលអាក់ខានឡើយ។ បុណ្យចូលឆ្នាំប្រព្រឹត្តទៅរយៈពេលបីថ្ងៃ គឺនៅថ្ងៃ១២ ១៣ ១៤ រោចខែចេត្រត្រូវនឹងថ្ងៃទី១៣ ១៤ ១៥ ឬថ្ងៃទី១៤ ១៥ ១៦ ខែមេសាជារៀងរាល់ឆ្នាំពុំដែលខានឡើយ ៕ តាំងពី ចុល្លសករាជ គេបានបង្កើតទំរង់តាម ប្រតិទិនសុរិយគតិ ហើយបានយក ថ្ងៃនៃបុណ្យ ចូលឆ្នាំខ្មែរនៅ

ខែចេត្រ ជាខែដែលប្រជាជន ទំនេរពីការងារស្រែចំការ។ មានរដូវបួន នៅក្នុង ប្រតិទិននៃ ឆ្នាំសុរិយគតិ គឺ រដូវរងារ រដូវផ្ការីក រដូវក្តៅ និង សរទរដូវ ប្រជាជនខ្មែរ បានអនុវត្ត យកខែទីប្រាំ គឺខែចេត្រ ដើម្បីប្រារព្ធពិធីបុណ្យចូលឆ្នាំ។ តាមធម្មតា ត្រូវនឹងថ្ងៃទី១៣ ខែ មេសា ឬ ពេលខ្លះត្រូវចំថ្ងៃទី ១៤ ខែមេសា។ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំ គឺបានបង្ហាញតាមតារាសាស្ត្រមហាសង្ក្រាន ហើយអូសបន្លាយ ក្នុងរយៈពេលបីថ្ងៃ។ ថ្ងៃទី១ ហៅថ្ងៃ មហាសង្ក្រាន ថ្ងៃទី២ ហៅថ្ងៃ វារវនបត និងថ្ងៃទីបីហៅថ្ងៃវារឡើងសក្តិជាថ្ងៃដែលគេសន្មតថាមានឫទ្ធិជាងគេ។

ក្នុងអំលុងបុណ្យចូលឆ្នាំខ្មែរ យុវជន យុវតី បានប្រមូលផ្តុំគ្នាលេង ល្បែងប្រជាប្រិយ ប្រពៃណី ដូចជា ចោលឈូង បោះអង្គញ់ ទាញព្រាត់ ៕នេះជាល្បែងដែលប្រជាជនខ្មែរនិយមចូលចិត្តលេងតាំងពីរដើមមករហូតដល់បច្ចុប្បន្ននេះ ៕ ក្នុងផ្នែកខ្លះនៃប្រទេសកម្ពុជា ដូចជា ខេត្តសៀមរាប និង បាត់ដំបង ឬខេត្តមួយចំនួនទៀតគេលេងល្បែងទាំងនោះ។ បុរសម្នាក់ជិះឈើកោងមួយ ដោយពាក់ក្បាលរមាំង នៅលើក្បាល និងមានចង្រ្កងនៅខាងក្រោយ ដូចជាកន្ទុយរមាំង។ បុរសពីនាក់ទៀតត្រៀមខ្លួនដើម្បីប្រម៉ាញ់ ដោយមានកាន់ធ្នូរក្នុងដៃ។ នៅពេល ទទួលបានទេយ្យទានហើយ ពួកគេបរិច្ចាគសំរាប់ជា**ទេយ្យវត្ថុ**សំរាប់ព្រះសង្ឃនៅវត្ត។ ក្នុងភូមិតាមបណ្តោយដងទន្លេមេគង្គ ស្ត្រីខេត្តកណ្តាល ប្រមូលផ្តុំគ្នាទៅលេងនៅវត្ត ៕ សកម្មភាព នេះត្រូវគេជឿថានឹងធ្វើឲ្យក្រពើស្ងប់ស្ងាត់។ ទំនៀមទំលាប់នេះ មានប្រភពយូរលង់ណាស់មកហើយនៅពេលដែលមានក្រពើជាច្រើនក្បាល បានរស់នៅក្នុងទន្លេ។ ភូមិខ្លះ ប្រជាជនជាន់រូបសំនាក ដើម្បីឲ្យខ្មោចព្រាយ រស់នៅតាមដើមឈើជិតៗវត្ត ស្ងប់ស្ងាត់ ហើយសុំសេចក្តីសុខក្នុងឆ្នាំថ្មី ចូលមក ដល់ខ្លួននិងក្រុមគ្រួសារផង។ ប្រជាជនខ្មែរ បានប្រមូលផ្តុំគ្នាទៅលេងវត្ត ទៅលេងតាមមាត់សមុទ្រ រមណីដ្ឋានឬ តាមប្រាសាទនានា ដែលមាននៅក្នុងប្រទេសឬក្រៅប្រទេស ក្នុងឱកាសពិធីបុណ្យ ចូលឆ្នាំ ខ្មែរប្រពៃណីជាតិហើយប្រជាជនខ្លះជួមជុំបង ប្អូនគ្រួសារញាតិមិត្តនៅឯផ្ទះរបស់ពួកគេដោយក្តីរីករាយ។

សរុបសេចក្តីមកពិធីបុណ្យចូលឆ្នាំពិតជាពិធីបុណ្យមួយដ៏ពិសេសរបស់ជាតិសាសន៍ខ្មែរដែលមានប្រវត្តិទាក់ទងនឹងជំនឿរបស់ខ្មែរ។ ជាពិសេសដូនតាខ្មែរយើងបានប្រារព្ធពិធីបុណ្យនេះឡើងដើម្បីផ្តល់ឱកាសដល់ជនានុជនប្រុសស្រីបានជួបជុំក្នុងក្រុមគ្រួសារ និង បានទៅវត្តធ្វើបុណ្យរួមគ្នា ហើយចូលរួមកំសាន្តលែងល្បែងប្រជាប្រិយកំសាន្តសប្បាយរីករាយក្រោយពីប្រមូលផលស្រូវរួចផងដែរ។

ប្រធានទី១៩៖ ចូរអធិប្បាយអំពីលក្ខណៈស្នេហារបស់ទុំទាវ ព្រមទាំងបញ្ចេញយោបល់របស់អ្នកចំពោះស្នេហាបែបទុំទាវនេះផង។

សេចក្តីអធិប្បាយ

បើយើងបើកក្រាំងគម្ពីរប្រវត្តិនៃអក្សរសិល្ប៍ខ្មែរមួយទំព័រម្តងៗពិនិត្យយ៉ាងម៉ត់ចត់យើងនឹងឃើញថា នៅគ្រប់រឿងប្រលោមលោក រឿងល្ខោន រឿងនិទានខ្លីៗ ឬកំណាព្យកាពឃ្លោងផ្សេងៗសុទ្ធតែលំអដោយជីវិតស្នេហាទាំងអស់។ រឿងកុលាបប៉ៃលិន ផ្កាស្រពោន រឿងសូផាត...សុទ្ធតែចោទឡើងដោយបញ្ហាស្នេហាទាំងអស់។ ចំណែកឯរឿងទុំទាវវិញ សេចក្តីស្នេហារបស់ទុំទាវក៏មានលក្ខណៈល្អ និង ប្លែកអំពីរឿងខាងលើដែរ។

តើសេចក្តីស្នេហាទុំទាវមានលក្ខណៈបែបណាទៅ?

មុននឹងឈានទៅរកដំណោះស្រាយរបស់ចំណោទបញ្ហាខាងលើយើងត្រូវយល់នូវន័យរបសើពាក្យ " ស្នេហា " ជាមុនសិន។ ពាក្យថា "ស្នេហា"មានន័យថាការស្រឡាញ់ពេញចិត្តទៅលើអ្វីមួយ។ ដោយផ្អែកទៅលើអត្ថន័យរបស់ពាក្យខាងលើ ទស្សនៈរបស់ប្រធានខាងលើមានន័យថា ការស្រឡាញ់ពេញចិត្តគ្នាទៅវិញទៅមករបស់យុវជនពីររូបគឺទុំ និង ទាវ។

ស្លាបប៉ាការបស់កិក្ខុសោមបានបង្ហាញ និង ពន្យល់អ្នកសិក្សាក៏ដូចអ្នកអានគ្រប់ៗគ្នាបានឃើញពីជីវិតស្នេហារបស់យុវជនពីរនេះក្នុងការទំនាក់ទំនងបឋមវ័យ។ នាងទាវគឺជាបុត្រីរបស់ស្ត្រីមេម៉ាយចំណាស់ម្នាក់នៅត្បូងឃ្មុំដែលមានរូបសម្រស់ល្អលើសនារីទាំងឡាយ និង ជាក្រមុំកំពុងចូលម្លប់។ ចំណែករូបទុំជាយុវជនមានរូបឆោមស្រស់សង្ហាសំលេងពិរោះដោយទុំចេះស្មូត ព្រមទាំងកំពុងបួសរៀនក្នុងវត្តវិហារធំ។ ទុំបានធ្វើដំណើរផ្ទុកគោកដើរលក់ជាហូរហែរហូតមកដល់ស្រុកត្បូងឃ្មុំ។ ដោយសារសម្លេង និង រូបសម្បត្តិ ទុំត្រូវបានអ្នកស្រុកចាប់ចិត្តស្រឡាញ់រាប់អានយ៉ាងខ្លាំង។ ក្រោយមកនេនទុំ និង នេនពេជ្រត្រូវបានម្តាយទាវនិមន្តឲ្យទៅស្មូតនៅផ្ទះរបស់ខ្លួន។ ខណៈដែលទុំកំពុងស្មូតនាងទាវចង់ចេញមកក្រៅមកមើលរូបទុំណាស់ដូចមានឃ្លាបញ្ជាក់ថា " អើតអើមដកកប្រហាមាត់ ចង់ចេញប្រាកដគ្មានគេហៅ.....ស្ទុះចូលយកអាវពាក់ពានា។ នៅពេលដែលឃើញភក្រ័ផូរផង់របស់ទុំភ្លាម នាងទាវបានគួចចិត្តប្រតិព័ទ្ធដោយពុំបានគិតពិចារណាថាទុំនេះមានចរិយាបែបណា? កើតក្នុងត្រកូលណា? មិនតែប៉ុណ្ណោះបានបួងសួងប្រាថ្នាជួបទុំជាគូគាប់ទៀតផង។ រីឯសាមណេទុំវិញ ខណៈដែលបានឃើញវង់កត្រ្តក់ដ៏ស្រស់បំព្រងរបស់នាងទាវ រូបគេក៏បានកើតចិត្តលួចបេតីលើរូបនាងផងដែរ។ ដោយរូបគេពុំបានគិតគូរពិចារណាថានាងនាងជានារីនៅក្រមុំ ឬ ស្ត្រីមេម៉ាយប្តីលែង ឬ ក៏មានគេចូលស្តីដណ្តឹងហើយឬនៅ? ស្នេហារបស់ទុំទាវខាងលើជាស្នេហាបែបកាំរន្ធ: ដែលជាស្នេហាឆាប់រហ័សគ្មានគិតពិចារណា ឬស៊ើបអង្កេតមើលអតីតកាលរបស់គ្នាទៅវិញទៅមកឡើយ។ ស្នេហាអន្ទះសាររបស់ទុំទាវមានលក្ខណៈប្លែកជាងស្នេហាអន្ទះសាររបសខេមរៈជនទូទៅដទៃទៀតនៅត្រង់លក្ខណៈពិសេសរបស់បុគ្គលទុំទាវនេះ មួយជាសាមណេរ មួយទៀតជាក្រមុំកំពុងចូលម្លប់ទៅតាមទំនៀមទំលាប់ប្រពៃណីជាតិដែលម្នាក់ៗសុទ្ធតែមានវិន័យគោរពរៀងៗខ្លួន។នាងទាវបានប្រគេនផាហ៊ុមថ្មីមួយដល់នេនទុំ មិនបានប៉ុន្មានថ្ងៃផង ទុំបានដោះស្បង់ហើយរត់ទៅរកនាងទាវយ៉ាងរួសរាន់។ គេទាំងពីរបានបង្កើតស្នេហាលួចលាក់ហើយបានធ្វើខុសនឹងទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិថែមទៀត។

ម៉្យាងវិញទៀត ថ្វីត្បិតតែការប្រព្រឹត្តរបស់ទុំទាវមានគុណវិបត្តិច្រើនជាងគុណសម្បត្តិយ៉ាងណាក៏ដោយ ក៏យើងឃើញថាស្នេហារបស់ទុំទាវជារូបភាពនៃការតស៊ូដើម្បីសិទ្ធិសេរីភាពស្នេហាបរិសុទ្ធ និង កក្តីភាព។ មនោសញ្ចេតនារបស់ទុំទាវបានត្របាញ់ចូលគ្នាជាឆ្លងមួយ។ ស្នេហានេះជាស្នេហាកើតឡើងដោយឆាប់រហ័សហើយក៏ជារូបភាពនៃស្នេហាបរិសុទ្ធក្នុងដំណើរប្រព្រឹត្តទៅនៃធម្មជាតិចិត្តរបស់យុវជនគ្មានលាយឡំទៅដោយការលោភលន់ ចំពោះបុណ្យសក្តិ ឬ ទ្រព្យសម្បត្តិអ្វីឡើយ។ បន្ទាប់ពីព្រះបាទរាមាដើងព្រៃរៀបចំផ្សំផ្គុំរួចមកទុំនិងទាវមានទឹកចិត្តកក្តីរវាងគ្នានិងគ្នាក្នុងហានៈជាប្តីប្រពន្ធបានកើនឡើងមួយទ្វេរដាពីរ។ នៅពេលនាងទាវត្រឡប់ពីក្រុងលង្វែកមកត្បូងឃ្មុំវិញ ទុំក៏បានធ្វើដំណើរមកត្បូងឃ្មុំដែរ។ នៅពេលដឹងថានាងទាវរៀបការជាមួយមឺនងួន ទុំរន្ធត់ចិត្តយ៉ាងខ្លាំង

ហើយទុំក៏បានឡើងលើផ្ទះការច្រៀងឲ្យចេញមកទទួលខ្លួនដូចមានឃ្លាបញ្ជាក់ " ទុំថាឲ្យទាវស្រស់នួនល្អង នួនល្អងម៉ត់ដូចកែវ ចរណៃ បងមកដល់ឃូរគួរអាល័យ ទាវថ្លៅក់ខ្លួនពួនដល់ណា "។ ទាំងនេះបញ្ជាក់ថា ទុំស្រឡាញ់ទាវខ្លាំងណាស់ ស្រឡាញ់លើសកែវភ្នែករបស់ខ្លួនទៅទៀត។ នេះជាភក្តីភាពរបស់ទុំចំពោះទាវ។ រីឯនាងទាវវិញ ក៏មិនខុសអ្វីពីទុំឡើយ នាងក៏នឹកទុំដែរ។ " ទុំអើយ អ្នកខ្សត់មិនខាន ម្លេះសមមិនហ៊ានរុករានមក ទើបបានប្រុសបាត់ឈឺងជ្រងំ ទុក្ខប្អូនស្មើភ្នំក្រំក្រោក " ។ ចំណែកឯមរណភាពរបស់អ្នកទាំងពីរក៏បញ្ជាក់នូវភក្តីភាពរបស់គេដែរ។ ការស្លាប់របស់ពួកគេគឺព្រោះរបបសង្គមនាសម័យនោះ។ មិនត្រឹមតែប៉ុណ្ណោះ សេចក្តីស្នេហារបស់យុវជនទុំទាវត្រូវទទួលរងទុក្ខសោកឥតស្រាកស្រាន។ ប៉ុន្តែស្នេហារបស់យុវជនយុវនារីដទៃទៀតក៏តែងទទួលរងនូវទុក្ខសោករឿយៗផងដែរ។ ចំនុចមួយទៀតក៏បណ្តាលមកពីមជ្ឈដ្ឋានជុំវិញខ្លួនផងដែរ។

សរុបសេចក្តីមក លក្ខណៈស្នេហាទុំទាវគឺជាលក្ខណៈស្នេហាដែលកើតឡើងរវាងចិត្ត នឹង ចិត្ត និងជាស្នេហាមួយដែលមានភក្តីភាព និង ស្មោះស្មគ្រ័រវាងគ្នា និង គ្នា។ ម៉្យាងទៀតស្នេហារបស់ទុំនិងទាវក៏មានគុណវិបត្តិច្រើនផងដែរចំពោះទំនៀមទំលាប់ប្រពៃណីរបស់ខ្មែរយើង។

រួមសេចក្តីមក តាមរយៈការបកស្រាយនូវលក្ខណៈស្នេហារបស់ទុំទាវរួចខាងលើមកយើងអាចសន្និដ្ឋានបានថា ស្នេហារបស់អ្នកទាំងពីរជាសេចក្តីស្នេហាដែលរើបំរះនឹងទស្សនៈទំនៀមទំលាប់ចាស់គំរិលហួសហេតុគឺនំមិនធំជាងនាឡិ។ ជាពិសេសជាសេចក្តីស្នេហាដែលពោរពេញដោយភក្តីភាព ជាស្នេហាកើតឡើងដោយចិត្ត នឹងចិត្តផងដែរ។ ចំណែកឯឧបសគ្គនៃសេចក្តីស្នេហារបស់អ្នកទាំងពីរវាជាឧបសគ្គមួយដែលតែងតែកើតឡើងសម្រាប់មនុស្សជាតិជាដរាប។

ដូច្នេះក្នុងនាមយើងជាយុវជនជំនាន់ក្រោយ មុនឈានចូលដល់ដំណាក់កាលជ្រើសរើសគូស្រករ ត្រូវខិតខំសិក្សារៀនសូត្រស្វែងរកចំណេះវិជ្ជា ឬជំនាញណាមួយសឹមបង្កើតស្នេហាជាក្រោយ ទើបយើងអាចរកនូវសុភមង្គលគ្មានក្តីបារម្ភទុក្ខព្រួយដូចស្នេហាទុំទាវ៕

ប្រធានទី២១៖ គេថា "នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និង គ្រួសារ"។ ចូរពន្យល់ដោយបញ្ជាក់ពីសកម្មភាពរបស់នារីក្នុងរឿងកូមិតិរច្ឆាន និង រឿងគូលីកំណែន។

<u>សេចក្តីអធិប្បាយ</u>

ចំពោះការអភិវឌ្ឍន៍ប្រទេសជាតិកាលពីសម័យមុនក៏ដូចជាសម័យបច្ចុប្បន្នដែរគេត្រូវការចាំបាច់នូវការចូលរួមពីកម្លាំងរបស់នារីភេទ។ តាមរយៈប្រវត្តិសាស្ត្រ និង ទំនៀមទម្លាប់ប្រពៃណីខ្មែរ សង្គមខ្មែរយើងបានលើកតម្កើងស្ត្រីជាធំ។ ទាំងនេះបញ្ជាក់ថាស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរ។ ស្របទៅនឹងទស្សនៈខាងលើនេះហើយទើបមានមតិមួយយល់ថា " នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និង គ្រួសារ"។

តើនារីបានចូលរួមសកម្មភាពអ្វីខ្លះចំពោះការអភិវឌ្ឍន៍សង្គមជាតិនិងគ្រួសារ?

ដើម្បីងាយស្រួលដល់ការបកស្រាយនូវចំណាេទបញ្ហាខាងលើ យើងគប្បីយល់នូវអត្ថន័យរបស់ពាក្យ "រួមវិភាគទាន និង អភិវឌ្ឍ " ជាមុនសិន។ ពាក្យថា "រួមវិភាគទាន"មានន័យថា ការចូលរួមចំណែកធ្វើនូវអំពើណាមួយជាមួយអ្នកដទៃ។ រីឯពាក្យ "អភិវឌ្ឍ " មានន័យថា ការធ្វើអ្វីមួយឲ្យលូតលាស់រីកចម្រើន។ តាមរយៈអត្ថន័យរបស់ពាក្យខាងលើទស្សនៈរបស់ប្រធានមានន័យថា នារីភេទបានចូលរួមចំណែកយ៉ាងច្រើនសន្ធឹកសន្ធាប់ណាស់ក្នុងការស្តារនិងកសាងនូវជីវភាពគ្រួសារ និង សង្គមជាតិឲ្យមានការរីកចម្រើនលូតលាស់។

វាប្រាកដណាស់ដែលថា នារីជាកម្លាំងដ៏សំខាន់មួយក្នុងការអភិឌ្ឍន៍សង្គមជាតិនិង គ្រួសារឲ្យរីកចម្រើេីន។ បើយើងក្រឡេកទៅមើលនារីក្នុងរឿងកូមិតិរច្ឆានវិញយើងក៏ឃើញថា លោក ឱឹក អំ និង ឌឹក តាមបានបង្ហាញច្បាស់នូវសកម្មភាពនារីខ្មែរមួួយចំនួននៅភូមិក្រាំងលាវ ដែលតំណាងឲ្យនារីខ្មែរទូទៅនៅក្នុងប្រទេសដែលមានទឹកចិត្តក្លាហានក្នុងការបញ្ចេញនូវមតិដែលសុទ្ធតែគំនិតជឿនលឿនក្នុងការតបតជាមួយពួកអាណាគមន៍បារាំង និង បរិវា។ តួយ៉ាងដូចជានាងតន់ភរិយារបស់សុវណ្ណ ក្រោយពីបាត់ប្តីក៏ខំដើររកនៅមន្ទីរឃុំឃាំងដោយនាងសាកសួរអ្នកយាមម្នាក់ដែលដាបរិបំរើដាច់ថ្លៃរបស់បារាំង។ អ្នកទាំងពីរក៏បានប្រកែកគ្នាយ៉ាងតឹងសសៃកដូចសំដីនាងតន់បញ្ជាក់ថា "រឿងស្លាប់ជាការធម្មតាទេថី ! បើអ្នកស្រុកក្រាំងលាវមិនស្លាប់នឹងគ្រាប់កាំភ្លើងរបស់ថី ក៏គង់តែស្លាប់នឹងចាស់ជរា ឬ ស្លាប់នឹងរោគាផ្សេងៗ" ។ នាងតន់ក៏និយាយទៀតថា " មកពីគេទុកខ្មែរដូចសត្វតិរច្ឆានហ្នឹងហើយ បានជាមានរឿងធំដល់បុណ្ណឹង! ហើយខ្ញុំនឹកស្មានថា លោកចិត្តជាខ្មែរ! "។លើសពីនេះទៅទៀត នាងនី នាងប៊ី ក៏មានសេចក្តីក្លាហានក្នុងការប្រកេេកតវ៉ាជាមួយពួកអាណានិគមបារាំងផងដែរ។ ដូចជាមានឃ្លាបញ្ជាក់ថា " នែលោកធំ! លោកប្រើអំណាចលើខ្ញុំ និង ជាតិខ្ញុំជ្រុលពេកហើយ។ លោកដាក់ខ្នោះប្តីមិនស្កប់ចិត្ត ឥឡូវលោកគិតដាក់ខ្នោះប្រពន្ធទៀត ...."។ ដោយឆ្អែតចិត្តនឹងពួកបារាំងជិះជាន់ នាងប៊ីបានបន្តទៀតថា " លោកធ្វើចៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមតែប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ចង់ខ្មែរដាច់ពោះស្លាប់ លោកឥតឈឺក្បាលទេ លោកគិតតែពីសង្វើញទារពន្ធឲ្យខានតែបាន។ នេះឬដែលហៅថា អាណាព្យាបាល? "។ សកម្មភាពទាំងនេះបញ្ជាក់ថានារីបានចូលរួមក្នុងការអភិវឌ្ឍន៍សង្គមជាតិ។ចំពោះក្នុងគ្រួសារវិញ នារីមានតួនាទីសំខាន់ណាស់ក្នុងការមើលថែទាំកូនចៅមើលការខុសត្រូវចំពោះផ្ទះសម្បែង។ នារីជាទីប្រឹក្សាមួយដ៏ល្អជាមួយប្តីកូនចៅមុនសម្រេចធ្វើអ្វីមួយ។ ចំពោះស្ថានភាពសង្គមនាពេលបច្ចុប្បន្ននារីក៏បានជួយបង្កើននូវជីវភាពគ្រួសារផងដែរ តាមរយៈការបង្ករបង្កើនផល ឬលក់ដូរប្រកបអាជីវកម្មផ្សេងៗជាមួយកម្លាំងបុរស។បើយើងក្រឡេកមើលក្នុងរឿងគូលីកំណែនវិញម្តងយើងក៏ឃើញថា លោកអឹមថុកក៏បានបង្ហាញអំពីសកម្មភាពនារីក្នុងផ្នែរឿងផងដែរ។ នៅក្នុងចំនុចនេះយើងឃើញថា អ្នកគ្រូ គូ រស់ បានផ្តល់កម្លាំងគ្រប់យ៉ាងដល់ម៉ឺងក្នុងការតស៊ូរំដោះជាតិមាតុភូមិពីកណ្តាប់ដៃបរទេសឈ្លានពាន។ ទោះបីមិនបានចេញតស៊ូដោយផ្ទាល់ក៏ដោយ ក៏អ្នកគ្រូបានចូលរួមចំណែកដោយប្រយោលដោយជួយជាគំនិតយោបល់ និង គាំទ្រដល់ការសម្រេចចិត្តរបស់ម៉ឺងដែរ។ម្យ៉ាងវិញទៀតចំពោះជីវភាពគ្រួសារវិញនារីក៏បានខិតខំជួយជាកម្លាំងបុរសផងដែរក្នុងការធ្វើស្រែចំការ និង ធ្វើការងារស្រាលៗនៅឯផ្ទះជំនួសកំលាំងប្តី។ សកម្មភាពទាំងនេះជាការសម្រាលនូវបន្ទុកជីវភាពគ្រួសារមួយផ្នែក

ដែរ។ចំណុចមួយទៀតគឺការស្មោះត្រង់ប្តូរផ្តាច់ក្នុងគ្រាមានអាសន្ន ឬការលំបាកផ្សេងៗ។ ជាក់ស្តែងដូចជានាងហេងមិនបណ្តោយខ្លួនឲ្យក្លាយជាចំណីតណ្ហារបស់ចៅហ្វាយស្រុកតាមរយៈអំណាចទឹកប្រាក់ឡើយ។ នាងហេងសុខចិត្តរត់គេចពីស្រុកកំណើតជាមួយឪពុកម្តាយលឺមមកភ្នំពេញរហូតបាត់បង់ជីវិត។

សរុបមក នារីពិតជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ និង គ្រួសារប្រាកដមែន។

រួមសេចក្តីមកតាមរយៈការបកស្រាយក្នុងអក្សរសិល្ប៍រឿងទាំងពីរួចមកយើងអាចសន្និដ្ឋានបានថានារីជាកំលាំងដ៏សំខាន់ក្នុងការរួមចំណែកធ្វើឲ្យសង្គមគ្រួសារ និង សង្គមជាតិរីកចំរើន។ នារីបានជួយជ្រោមជ្រែងចំពោះការងារបុរសជាច្រើនទាំងការស្រួលលំបាកគ្រប់បែបយ៉ាងដើម្បីបំរើឲ្យការរស់នៅប្រកបដោយលក្ខណៈល្អប្រសើរ។

ដូចនេះក្នុងនាមយើងជាពលរដ្ឋគ្រប់រូប យើងត្រូវលុបបំបាត់នូវគំនិតរើសអើងស្ត្រីភេទដោយយើងត្រូវចាត់ទុកស្ត្រីភេទជាកំលាំងចលករមួយចូលរួមក្នុងសកម្មភាពផ្សេងៗទាំងក្នុងគ្រួសារ និង សង្គមជាតិដូចយើងដែរ។ យើងត្រូវគិតថាស្ត្រី និង បុរសមានសិទ្ធិស្មើគ្នាក្នុងការរស់នៅក្នុងសង្គមជាតិ៕

ប្រធានទី២២ ៖ មានមតិមួយយល់ថា « ប្រទេសអាប់ឱនព្រោះតែអំពើពុករលួយ» ឯមតិមួយទៀតយល់ថា « ប្រទសអាប់ឱនព្រោះតែអំពើមិនប្រក្រតីចំពោះការងារ» ។ ចូពិភាក្សាដោយលើកអំណះអំណាងមកបញ្ជាក់ ។

<u>សេចក្តីអធិប្បាយ</u>

ប្រទេសណាក៏ដូចប្រទេសណាដែរតែងតែចង់បាននូវភាពរីកចំរើនលូតលាស់ប្រកបទៅដោយភាពរុងរឿង និង កិត្យានុភាពជានិច្ច ។ ចំពោះការចង់បាននេះ វាតែងតែប្រឈមទៅនឹងឧបសគ្គ និង បញ្ហាផ្សេងៗមិនអាចចៀសផុត ។ បញ្ហាទាំងនោះវាតែងបណ្តាលឲ្យកើតមានការអាប់ឱន ទន់ខ្សោយ ប្រជាជនជួបការលំបាកគ្រប់បែបយ៉ាង ។ ជាពិសេសប្រទេសជាតិលិចលង់ បាត់បង់កិត្យានុភាពក្លាយជាប្រទេសអន់ថយគួរឲ្យអាម៉ាស ។ ទាក់ទងនឹងបញ្ហាខាងលើនេះ មានមតិពីរលើកឡើងខុសគ្នាថា " ប្រទេសជាតិអាប់ឱនព្រោះតែអំពើពុករលួយ " ឯមតិទីពិរយល់ថា " ប្រទេសជាតិអាប់ឱនព្រោះតែអំពើមិនប្រក្រតីលើការងារ ".

តើប្រទេសទាំងពីរអប់ឱនបណ្តាលមកពីបញ្ហាទាំងពីរខាងលើឬ យ៉ាងណា ?

ដើម្បីងាយស្រួលដល់ការបកស្រាយយើងគួរប្បីយល់នូវន័យរបស់ពាក្យ "អំពើពុករលួយ និង អំពើមិនប្រក្រតីលើការងារ " ជាមុនសិន ។ ពាក្យថា “អំពើពុករលួយ” មានន័យថា អំពើមិនត្រឹមត្រូវបំបានលើច្បាប់ក្បត់នឹងផលប្រយោជន៍មនុស្សជាតិ ។ រីឯពាក្យ ” អំពើមិនប្រក្រតីលើការងារ” គឺសំដៅលើអំពើទាំងឡាយណាដែលរាំងស្ទះលើការងារមិនឲ្យការងារមានការលូតលាស់ ។ តាមរយៈខ្លឹមសារនៃពាក្យទាំងនេះទស្សនៈប្រធានខាងលើមានន័យថា ប្រទេសជាតិអាប់ឱនអន់ថយ ព្រោះតែសកម្មភាពទាំងឡាយណាដែលជាអំពើមិនត្រឹមត្រូវបំពានលើច្បាប់ក្បត់នឹងផលប្រយោជន៍ជាតិ ។ ឯមិតិទីពីរមានន័យថា ប្រទេសជាតិអាប់ឱនអន់ថយព្រោះតែអំពើទាំងឡាយណាដែលរាំងស្ទះដល់ការងារមិនឲ្យការងារមានការលូតលាស់ល្អ ។

មែនហើយជាការពិតណាស់កត្តាដែលនាំឲ្យប្រទេសជាតិអាប់ឱនមានច្រើនណាស់ដែលពាក់ព័ន្ធទៅនឹងប្រយោជន៍បុគ្គល ។ នៅពេលណាដែលគេបោះបង់ប្រយោជន៍ទូទៅហើយ ឈោងចាប់ប្រយោជន៍ផ្ទាល់ខ្លួនជាធំ គេសង្កេតឃើញថា ផលអវិជ្ជមានកើតឡើងចំពោះជាតិមិនអាចចៀសផុត ។ តួយ៉ាងចោរៈពោះការលួចកិបកេង បន្លំថវិកាជាតិវាជាទង្វើមួយដែលប៉ះពាល់យ៉ាងខ្លាំងទៅនឹងការលូតលាស់នៃសេដ្ឋកិច្ចជាតិ ។ បើសិនជាទង្វើនេះវារីកក្នុងទ្រង់ទ្រាយធំ រដ្ឋនឹងត្រូវបាត់បង់ប្រាក់ចំណូលមិនតិចទេក្នុងមួយឆ្នាំៗ ។ ប្រការនេះវានឹងធ្វើឲ្យរដ្ឋមានការខ្វះខាតប្រាក់សម្រាប់ផ្គត់ផ្គង់ ដឹកនាំ ឬ ធ្វើការអភិវឌ្ឍនវិស័យផ្សេងៗតៀត ។ នៅពេលនោះហើយជាហេតុនាំមកនូវផលវិបាកដល់ការរស់នៅរបស់ប្រជជន ក៏ដូចជាការដឹកនាំគ្រប់គ្រង ។ ជាឧទាហរណ៍ក្នុងស្ថាប័នណាមួយ បើកាលណាគេធ្វើការបន្លំដោយលើកគម្រោងពន្លឺតម្លៃដោយបំប៉ោងចំណាយខុសបែបបទហិរញ្ញវត្ថុ ហើយបែរមកបង្កើនបុគ្គលិកធ្វើការច្រើន នេះជាប្រការមួយដែលជំរុញឲ្យជំណើរការអភិវឌ្ឍជាតិមានជំណើរថយក្រោយ នឹង ធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះ ឈានទៅធ្វើឲ្យប្រទេសជាតិជួបបញ្ហាក្រីក្រ អាប់ឱនមុខមាត់នៅលើឆាកអន្តរជាតិ ។ទន្ទឹមនឹងនេះដែរការយកមូលដ្ឋានសម្ភារៈរដ្ឋធ្វើជាមជ្ឈមណ្ឌលអាជីវកម្មផ្ទាល់ខ្លួន ជាទង្វើមួយប៉ះពាល់ដល់ប្រយោជន៍សាធារណៈដែរព្រោះទង្វើនេះស្តែងឡើងដោយផលប្រយោជន៍បុគ្គលដែលជាទង្វើឲ្យជាតិខាតបង់ ។ តួយ៉ាងបុគ្គលខ្លះបានប្រើធនធាន អគារទីតាំងរដ្ឋរកស៊ីយ៉ាងអាណាធិបតេយ្យ ។ ចំណែកឯរដ្ឋពុំបានប្រាក់ចំណូលពីអាជីវកម្មនេះឡើយគឺបានតែបុគ្គលដែលជាអ្នកធ្វើអាជីវកម្មលើទ្រព្យសម្បត្តរដ្ឋតែបុណ្ណោះ ។ ត្រង់នេះហើយដែលជាភាពខាតបង់នាំឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះនិងអាប់ឱន ។

ប្រការមួយទៀត កាលណាគេឃុបឃិតជាមួយឈ្មួញទុច្ចរិតរកស៊ីខុសច្បាប់ វាក៏ជាអំពើមួយធ្វើឲ្យជាតិបាត់បង់ភាពថ្លៃថ្នូរដែរ ។ ចំពោះបញ្ហានេះគេប្រទះឃើញច្រើនក្នុងប្រទេសនានា ដោយគេធ្វើការរកស៊ីគេចពន្ធ ព្រោះគេត្រូវរួមជាមួយសមត្ថកិច្ចទទួលខុសត្រូវដែលធ្វើឲ្យរដ្ឋខាតបង់ចំណូលហើយវាអាចធ្វើឲ្យមានភាពអាណាធិបតេយ្យនៅក្នុងសង្គមកាន់តែខ្លាំងឡើយៗនាំឲ្យវាគ្មានសណ្តាប់ធ្នាប់ល្អ ។ មិនតែប៉ុណ្ណោះការរកស៊ីជួញដូរគ្រឿងញៀន លក់ទំនិញក្លែងក្លាយ ទំនិញគ្មានគុណភាពក៏ជាមូលហេតុធ្វើឲ្យជាតិលិចលង់បាត់បង់ភាពថ្លៃថ្នូររបស់ខ្លួនដែរ ។ ជាពិសេសការកៀបសង្កត់អ្នកក្រីក្រ កិបកេងកំលាំងពលកម្មរបស់គេដើម្បីបង្កើនទ្រព្យរបស់ខ្លួនក៏ជាបញ្ហាធ្ងន់ធ្ងរក្នុងចំណោមបញ្ហាខាងលើដែលធ្វើឲ្យសង្គមធ្លាក់ចុះមុខមាត់ ។

លើសពីនេះទៅទៀត ការប្រើអំណាចរំលោភយកទ្រព្យសម្បត្តិសាធារណៈជាកម្មសិទ្ធិវាជាហេតុមួយស្តែងឲ្យឃើញពីការធ្វើអាជីវកម្មលើជាតិ ហើយធ្វើឲ្យជាតិលិចលង់ធ្លាក់ទៅជាអន់ថយបន្តិចម្តងៗ ព្រោះទង្វើនេះជាការបន្លំភ្នែកស្រស់ៗដែលសាធារណជនទូទៅស្អប់ខ្ពើម និង ថ្កោលទោសដល់បុគ្គលដែលប្រព្រឹត្តទង្វើអវិជ្ជមានបែបនេះ។

រួមមកទង្វើខាងលើនេះពិតជានាំឲ្យជាតិអាប់ឱន រដ្ឋបាត់បង់ប្រាក់ចំណូល ហើយសម្បត្តិមានតម្លៃរបស់ជាតិត្រូវរលាយហិនហោច។ ចំណែកឯផលទុនធ្លាក់ចុះ ជាតិ និង រាស្ត្រក្រទៅៗ ឯជនពុករលួយកាន់តែមានទៅៗ។

តើប្រទេសជាតិអាប់ឱនដោយសារកត្តាទាំងនេះមែនឬ?

ផ្ទុយពីមតិខាងលើនេះវិញ មតិទីពីរបែរជាយល់ថា ប្រទេសអាប់ឱន ព្រោះតែអំពើមិនប្រក្រតីលើការងារទៅវិញ។ ការដែលគេហ៊ានអះអាងដូចនេះមកពីគេយល់ឃើញថា បើកាលណាគេធ្វើការបញ្ចូលជនអសមត្ថភាពឲ្យកាន់កាប់ការងារសំខាន់ៗតាមរយៈខ្សែស្រឡាយរបស់ខ្លួនដោយមិនឆ្លងកាត់ការប្រឡងបញ្ជាក់ពីសមត្ថភាពត្រឹមត្រូវនឹងធ្វើឲ្យការងារដែលគេធ្វើមិនមនប្រសិទ្ធិភាព ហើយលទ្ធផលការងារមានលក្ខណៈមិនល្អ ឬ មិនបានទទួលជោគជ័យ។មិនតែប៉ុណ្ណោះ បើកាលណាគេបែរជាមិនគោរពអនុវត្តតាមច្បាប់ការងារវិញ វាធ្វើឲ្យបញ្ហាកើតឡើងចំពោះសង្គមដែរ ព្រោះទង្វើនេះសង្គមចាំតែទទួលរងផលអវិជ្ជមានតែប៉ុណ្ណោះ។ បើគេបណ្តោយឲ្យនាយទុនរំលោភបំពានលើច្បាប់ការងារឬសិទ្ធិរបស់កម្មករស្រេចតែចិត្ត វានឹងបង្កភាពស្មុកស្មាញកាន់តែច្រើនឡើងៗដល់សង្គមដែលវាអាចឈានទៅរកការធ្វើបាតុកម្ម កូដកម្ម ឬអំពើហឹង្សាផ្សេងៗដាក់គ្នាទៅវិញទៅមក ហើយវានឹងធ្វើឲ្យបាត់បង់ស្ថេរភាពសង្គម ឬភាពចលាចលរឹតវក្តុងសង្គមមិនខាន។ ម៉្យាងទៀតបើបុគ្គលិករដ្ឋវិញ បើបណ្តោយឲ្យឈប់ស្រេចតែអំពើចិត្ត ហើយមិនគោរពតួនាទី និង ភារកិច្ច ពេលវាលាធ្វើការ វាក៏ធ្វើឲ្យការងារដើរថយក្រោយ ជះឥទ្ធិពលមិនល្អដល់សង្គមផងដែរ។ម៉្យាងទៀតចំពោះជនដែលគ្មានមនសិការលើការងារវិញ ក៏អាចចាត់ទុកជាអ្នកធ្វើឲ្យការងារមានលក្ខណៈមិនប្រក្រតី ហើយមិនសូវរីកចម្រើនដែរ។ ជនដែលធ្វើការឡេះឡោះខ្ជីខ្ជាមិនតស៊ូប្រឹងប្រែងក្នុងការបំពេញការងារ នាំឲ្យការងារមានលក្ខណៈមិនល្អប្រសើរ ព្រោះតែអ្នកបំពេញការងារមិនយកចិត្តទុកដាក់ ធ្វើការឲ្យរួចពីដៃ ធ្វើការងារដោយមិនស្រឡាញ់ការងារ។ ទន្ទឹមនឹងនេះដែរចំពោះបុគ្គលធ្វើការផ្តេកផ្តួលទៅតាមតែប្រាក់បៀវត្សវាក៏ធ្វើឲ្យការងារមានលក្ខណៈមិនល្អដែរ ព្រោះការធ្វើការងារបែបនេះវាធ្វើឲ្យដំណើរការមានលក្ខណៈមិនស្មើល្អ ម្តងល្អ ម្តងអាក្រក់ យឺតយ៉ាវ ឬលៀនដែលជាការបង្ហាញឲ្យឃើញពីលទ្ធផលវិជ្ជមាន និង អវិជ្ជមាន។លើសពីនេះទៅទៀតបើជនគ្មានសុឆន្ទៈលើការងារវិញក៏ដូច្នេះដែរព្រោះថាគេធ្វើការដោយគ្មានគំនិតម្ចាស់ការលើខ្លួនឯង ចាំតែគេប្រាប់ គេបញ្ជា វាក៏ធ្វើឲ្យកើតមានភាពអវិជ្ជមានដល់សកម្មភាពនៃប្រព័ន្ធការងារនៅក្នុងស្ថាប័ន ឬកន្លែងណាមួយដែលនាំឲ្យស្ថាប័ន ឬកន្លែងនោះងាយនឹងទទួលរងនូវភាពអាប់ឱនឬ អន់ថយ។ ត្រង់គឺសំដៅបុគ្គលដែលបំពេញការងារធ្វើការទាល់តែគេត្រួត ហើយគេពុំប្រើបញ្ញាស្មារតីក្នុងការច្នៃប្រឌិតលើការងារ មិនសូវសិក្សាស្រាវជ្រាវធ្វើការងារឲ្យទៅមុខ ហើយចេះតែបណ្តែតបណ្តោយទៅតាមដំណើរ។

សរុបសេចក្តីមកភាពអសកម្មខាងលើវានឹងធ្វើឲ្យជាតិទ្រុឌទ្រោមដោយសារកិច្ចការទាំងអស់ពុំសម្រេចតាមផែនការព្រោះការច្រើនធ្វើការបានតិច ជាតិខ្វះខាតផលិតផលសម្រាប់លក់ដូរ ហើយជាកត្តាធ្វើឲ្យគ្មានការប្រណាំងប្រជែងធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះ។

រួមសេចក្តីមកតាមរយៈការពិភាក្សាខាងលើយើងឃើញថាភាពអសកម្មដែលកើតមកពីមិនប្រក្រតីលើការងារធ្វើឲ្យជាតិជួបបញ្ហាភាពក្រីក្រ ទន់ខ្សោយ ហើយត្រូវជាតិដទៃមើលងាយ។ ជាពិសេសគ្រប់វិស័យទាំងអស់អសកម្ម រដ្ឋគ្មានទុនបំរុងរាស្ត្រកាន់តែក្រៗទៅព្រោះកើតពីអំពើពុករលួយ។

សរុបសេចក្តីមកតាមរយៈការបកស្រាយខាងលើយើងអាចវាយតម្លៃបានថាទស្សនៈរបស់ប្រធានខាងលើមានលក្ខណៈត្រឹមត្រូវដូចគ្នា។ ប្រទេសដែលមានការអាប់ឱនគឺបណ្តាលមកពីកត្តាយ៉ាងច្រើន ហើយក៏មិនអាចចៀសផុតពីកត្តាទាំងពីរខាងលើនេះដែរ។ ចំពោះបញ្ហានេះជាតុពិតនៃការលិចលង់របស់ជាតិផ្តើមចេញពីអំពើពុករលួយ ព្រោះអំពើនេះវារាលដាលធ្វើឲ្យមានភាពអសកម្មនៃការងារដែលនាំឲ្យការងារមានភាពអន់ថយឈានទៅដល់ការមើលបណាំគ្នាលែងខ្លាចច្បាប់ទម្លាប់ទៅជាអាណាធិបតេយ្យគ្មាននរណាស្តាប់នរណា។ ដូចនេះដើម្បីឲ្យសង្គមរីកចម្រើន និង ដំណើរការល្អ គេត្រូវបំបាត់អំពើពុករលួយតាំងពីថ្នាក់លើដល់ក្រោម

ដោយកុំយោគយល់ ហើយព្រមព្រៀងគ្នាក្នុងការបំពេញការងារប្រកបដោយឆន្ទៈ ទើបជាតិទទួលបានភាពលូតលាស់ និង មានភាពរុងរឿងព្រមទាំងកិត្យានុភាពល្អ ៕

តែងសេចក្តីអត្ថាធិប្បាយ ប្រធាន(ពន្យល់ ពិភាក្សា ប្រៀបធៀប)

ប្រធានទី២៣៖ចូរអ្នកធ្វើការប្រៀបធៀបពុទ្ធសាសនា និង ព្រហ្មញ្ញសាសនាដែលខ្មែរធ្លាប់ទទួលមកគោរពបូជាតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។

សេចក្តីអធិប្បាយ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានខឿនវប្បធម៌ល្អីឈ្លាញរុងរឿងព្រមទាំងមានទំនៀមទំលាប់ជំនឿសាសនាប្រពៃណីដ៏សំបូរបែប។ វប្បធម៌អរិយធម៌ទាំងនេះកើតមានដំណាលនឹងវត្តមានជនជាតិខ្មែរដែរ ប៉ុន្តែក្រោយមកខ្មែរបានទទួលយកវប្បធម៌អរិយធម៌ ភាសា អក្សរ សាសនា របស់ឥណ្ឌាមកច្នៃប្រឌិតបន្ថែមទៀត។ ចំពោះបញ្ហាសាសនាវិញ យើងលើកយកព្រះពុទ្ធសាសនា និង ព្រហ្មញ្ញសាសនាមកធ្វើការប្រៀបធៀបដើម្បីរកឲ្យឃើញនូវលក្ខណៈដូចគ្នា និង ខុសគ្នារវាងសាសនាទាំងពីរនេះ។

តើសាសនាទាំងពីរនេះមានលក្ខណៈដូចគ្នា និង ខុសគ្នាយ៉ាងណាខ្លះ?

មែនហើយជាការពិតណាស់ សាសនាទាំងពីរនេះមានវត្តមាននៅលើទឹកដីខ្មែរតាំងពីយូរយារណាស់មកហើយ ហើយត្រូវបានប្រជាជនខ្មែរនិយមរាប់អានទទួលយកមកគោរពបូជាតាំងពីដើមសតវត្សទី១នៃគ្រឹស្តសករាជសម័យនគរភ្នំមកម្ល៉េះ។

ចំពោះលក្ខណៈដូចគ្នានៃសាសនាទាំងពីរនេះគេសង្កេតឃើញថា សាសនាទាំងពីរនេះមានប្រភពមកពីប្រទេសឥណ្ឌាដូចគ្នា ហើយវាបានហូរចូលមកប្រទេសកម្ពុជាបន្តបន្ទាប់គ្នាគ្រាន់តែមុន និង ក្រោយគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ ចំពោះវត្តមានព្រហ្មញ្ញសាសនាគេសង្កេតឃើញវត្តមានមុនពុទ្ធសាសនាគឺនៅពេលដែលព្រះបាទកៅណ្ឌិន្យបានរៀបអភិសេកជាមួយព្រះនាងសោមាហើយបានគ្រប់គ្រងប្រទេសកម្ពុជា។ ពេលនោះហើយដែលអង្គក្សត្រនេះបានផ្សាយវប្បធម៌ព្រហ្មញ្ញសាសនាដល់ប្រជារាស្ត្រព្រះអង្គ។ យ៉ាងណាមិញចំពោះពុទ្ធសាសនាប្រហែលជាហូរចូលក្រោយព្រហ្មញ្ញសាសនា១សតវត្ស គឺប្រហែលសតវត្សទី២នៃគ្រឹស្តសករាជតាមរយៈសមណៈទូតពីរអង្គដែលព្រះបាទធម្មាសោកក្សត្រប្រទេសឥណ្ឌាបញ្ជូនមកផ្សព្វផ្សាយនៅដែនដីសុវណ្ណភូមិ គឺព្រះសោណត្ថេ និង ព្រះឧត្តរត្ថេរ។ចំពោះលក្ខណៈដូចគ្នាមួយទៀតនៃសាសនាទាំងពីរនេះគឺអប់រំមនុស្សឲ្យធ្វើអំពើល្អ ជឿលើបុណ្យបាបដូចគ្នា។ ថ្វីត្បិតតែសាសនាទាំងពីរនេះមានមាគ៌ាសម្រាប់គោរពប្រតិបត្តិខុសគ្នា ប៉ុន្តែគោលបំណងគឺដូចគ្នានៅត្រង់អប់រំកាយ ចិត្តរបស់មនុស្ស ឲ្យធ្វើអំពើល្អវៀចាកអំពើអាក្រក់ ឲ្យចេះខ្លាចបាប ពោលគឺឲ្យមនុស្សហាត់ពុតលត់ដំចិត្តឲ្យប្រកាន់យកតែសេចក្តីល្អប្រកបដោយមេត្តាករុណាមុទិតា ដែលក្នុងព្រហ្មញ្ញសាសនាមានព្រះព្រហ្មជាតំណាង(ព្រះកត្តែទាំងបួន)។ ការអប់រំបែបនេះគឺបានជ្រាបដល់សន្តានចិត្តខ្មែរគ្រប់រូបរហូតដល់ការគ្រប់គ្រងប្រទេស ក៏ព្រះរាជាខ្មែរយកទ្រឹស្តីនេះមកអនុវត្តផងដែរ។រីឯទ្រឹស្តីនៃសាសនាទាំងពីរនេះវិញ ថ្វីត្បិតតែមានលក្ខណៈក៏ពិតមែនក៏គេឃើញមានលក្ខណៈដូចគ្នាខ្លះដែរ គឺនៅត្រង់សាសនាទាំងពីរនេះមាននិយាយពីភពទាំងបីដូចជា ឋានមនុស្ស ឋាន សួគ៌ ឋាននរក។ នៅត្រង់ចំនុចនេះគឺសំដៅទីកន្លែងដែលមនុស្ស ទេវតា និង សត្វនរកស់នៅ។ ភពទាំងបីនេះមនុស្សតែងតែរៀលរ៉ល់កើតទីណាមួយមិនអាចជៀសផុត ដោយវាអាស្រ័យលើសកម្មភាពល្អ អាក្រក់តែប៉ុណ្ណោះ។ ស្ថានទាំងបីនេះ គឺមនុស្សយើងអាចមើលឃើញតែស្ថានមនុស្សលោកយើងតែមួយប៉ុណ្ណោះ។ ប៉ុន្តែស្ថានសួគ៌នរកវិញមនុស្សមិនអាចមើលឃើញបានទេ។ម៉្យាងវិញទៀតសាសនាទាំងពីរនេះខ្មែរបានទទួលយកមកគោរពបូជាដូចគ្នាតាំងពីសម័យបុរាណមកម្ល៉េះ។ ដោយសារជំនឿទៅលើសាសនាទាំងពីរនេះហើយ ទើបបានជាខ្មែរបានកសាងនូវប្រាង្គប្រាសាទជាច្រើនដើម្បីឧទ្ទិសចំពោះអាទិទេពនៃសាសនាទាំងពីរក្នុងន័យលើកតម្កើងអាទិទេពសុំសេចក្តីសុខផ្សេងៗ។ មិនតែប៉ុណ្ណោះខ្មែរបានធ្វើសមាហរណកម្មសាសនាទាំងពីរឲ្យចូលគ្នាមកគោរពប្រតិបត្តិរហូតមកដល់សព្វថ្ងៃ។

សរុបមកចំណុចខាងលើនេះជាលក្ខណៈដូចគ្នារវាងពុទ្ធសាសនា និងព្រាហ្មសាសនា។

បើគេពិនិត្យលក្ខណៈខុសគ្នាវិញគេឃើញថា ព្រះពុទ្ធសាសនាគឺមិននិយាយពីអាទិទេពទេព្រោះព្រះពុទ្ធជាមនុស្សហើយក៏ជាម្ចាស់សាសនានិងជាអ្នកសិក្សាស្រាវជ្រាវរកឃើញទ្រឹស្តីនេះដែរ។ព្រះនាមសទត្ថ មានមាតាបិតា និង នគរនៅលើផែនដីនេះ ហើយការដែលព្រះអង្គអាចត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ក៏ព្រោះតែការខិតខំព្យាយាមបំពេញបារមីទាំងដប់នេះដែរ។ ផ្ទុយពីព្រះពុទ្ធសាសនានេះវិញ ព្រហ្មញ្ញសាសនាគឺមានអាទិទេពបីអង្គជាអ្នកបង្កើតទ្រឹស្តី គឺព្រះព្រហ្ម ព្រះសិវៈ និង ព្រះវិស្ណុ។ អាទិទេពទាំងបីអង្គនេះមាននាទីផ្សេងៗពីគ្នាគឺព្រះព្រហ្មជាអ្នកបង្កើតលោក ព្រះសិវៈជាអ្នកបំផ្លាញលោក និង ព្រះវិស្ណុជាអ្នកថែរក្សាលោក។ ព្រះពុទ្ធ

សាសនាក្រៅពីព្រះពុទ្ធ មានតែអង្គព្រះអរហន្តជាសាវ័គ្គដែលមាននាទីជួយផ្សព្វផ្សាយគោរពប្រតិបត្តិទៅតាមទ្រឹស្តីរបស់ព្រះពុទ្ធ។ ផ្ទុយពីនេះព្រហ្មញ្ញសាសនាព្រះវិស្ណុមានអវតារហូតដល់ទៅដប់ដែលអវតារនិមួយៗមាននាទីជួយមនុស្សនៅពេលណាដែលពិភពលោកគ្រាអាសន្នដោយពួកអសុរៈអុកឡុកធ្វើបាបម្តងៗ។រីព្រះពុទ្ធសាសនាគោរពប្រតិបត្តិតាមពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធដែលទ្រង់បានស្រាវជ្រាវរកឃើញដោយព្រះអង្គផ្ទាល់ក្នុងរយៈពេល៤៥ព្រះវស្សាក្រោយពេលត្រាស់ដឹងដោយគេបានប្រមូលចងក្រងជាគម្ពីព្រះត្រៃបិដកដែលមាន៨៤០០០ធម្មក្ខន្ធចែកចេញជាបីគម្ពីរគឺ វិន័យបិដក សុត្តន្តបិដក និង អភិធម្មបិដក ដើម្បីទុកឲ្យពុទ្ធបរិស័ទគោរពប្រតិបត្តិតាម។ ឯព្រហ្មញ្ញសាសនាវិញមានគម្ពីរវេទជាគោលដែលជាទ្រឹស្តីអាទិទេពទាំងបីអង្គនេះហើយគម្ពីរនេះចែកចេញជាបួនគឺសម្រាប់បរិស័ទគោរពប្រតិបត្តិតាម។ ទ្រឹស្តីនៃសាសនាទាំងពីរនេះមានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំង នៅត្រង់ព្រះពុទ្ធសាសនាអប់រំមនុស្សឲ្យជឿនិងផ្អែកលើសមត្ថភាពខ្លួនឯង រីឯព្រហ្មញ្ញសាសនាអប់រំមនុស្សឲ្យជឿលើអាទិទេពព្រេងសំណាងទៅវិញ។ម៉្យាងទៀតចំពោះសេចក្តីសុខ និង ទុក្ខវិញក៏មានលក្ខណៈខុសគ្នាច្រើនដែរ ព្រោះតាមពុទ្ធសាសនា សេចក្តីសុខ និង ទុក្ខរបស់មនុស្សគឺស្ថិតនៅលើអំពើរបស់មនុស្សជាអ្នកប្រព្រឹត្ត។ បើកាលណាគេធ្វើអំពើល្អ នឹងបានល្អ គេធ្វើអំពើអាក្រក់ នឹងបានអាក្រក់ ពោលគឺសុខ និង ទុក្ខ តាមរយៈកម្ម និងផលនេះឯង។ ចំណែកតាមរយៈព្រហ្មញ្ញសាសនាវិញសេចក្តីសុខ និង ទុក្ខគឺស្ថិតនៅលើកណ្តាប់ដៃអាទិទេព ព្រោះបើកាលណាអាទិទេពឲ្យសុខគឺមនុស្ស នឹងបានសុខ បើកាលណាអាទិទេពឲ្យទុក្ខមនុស្សនឹងបានទុក្ខដោយមិនអាចចៀសផុតឡើយ។ ពោលគឺអាទិទេពជាកំណត់ជោគវាសនា សុខ ទុក្ខ ល្អអាក្រក់របស់មនុស្ស។បើកាលណាគេចង់សុខគឺគេត្រូវខិតខំព្យាយាមធ្វើការអង្វរកអាទិទេព សុំសេចក្តីសុខតាមរយៈវិធីប្រតិបត្តិទាំងបួនគឺ តបៈ យោគៈ បូជាយញ្ញ និង ពិធីលាងបាប ឬ សិរៈរាត្រី។ ឯព្រះពុទ្ធសាសនាវិញ កាលណាមនុស្សចង់បានសុខ គេត្រូវលះបង់អំពើអាក្រក់ចោល ហើយប្រកាន់យកអំពើល្អទាំងកាយ វាចា និង ចិត្តនោះ គេនឹងបានសុខ។ទន្ទឹមនឹងនេះដែរ ចំពោះវាសនារបស់មនុស្សដែលល្អ អាក្រក់ មាន ក្រ លំបាកវេទនា ស្រួលស្រណុក មានឋានៈធំតូចយ៉ាងណា តាមទ្រឹស្តីព្រហ្មញ្ញសាសនាគឺស្ថិតនៅលើកណ្តាប់ដៃរបស់អាទិទេពផងដែរ ព្រោះអាទិទេពបានចារវាសនារបស់មនុស្សរួចជាស្រេចនៅពេលមនុស្សកើតមកដោយមិនអាចកែប្រែបានឡើយ ដូចជាការបែងចែកឋានៈទាំងបួននៅក្នុងសាសនានេះអញ្ចឹង គឺវណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវៃស្យៈ និង វណ្ណៈសូទ្រៈ ដែលវណ្ណៈទាំងបួននេះមិនអាចផ្លាស់ប្តូរបានឡើយ។ រីឯព្រះពុទ្ធសាសនាវិញ ចំពោះបញ្ហាខាងលើក៏ស្ថិតនៅលើមនុស្សជាអ្នកកំណត់ខ្លួនឯងដែរ ព្រោះបើកាលណាមនុស្សប្រកាន់យកសេចក្តីព្យាយាមត្រូវ គិតត្រូវ ធ្វើអំពើជាកុសល ទាំងកាយ វាយចា និង ចិត្តទៅលើសកម្មភាពការងាររបស់គេដោយផ្ចិតផ្ចង់ និង យកចិត្តទុកដាក់គេនឹងទទួលបានសម្រេចជោគវាសនារបស់គេមិនខានដូចជាចំណេះដឹងជាដើម។ បើកាលណាយើងខិតខំរៀនយើងនឹងទទួលបានចំណេះដឹង ផ្ទុយពីព្រហ្មញ្ញសាសនាដែលថា ពុទ្ធិគឺអាទិទេពជាអ្នកផ្តល់ឲ្យទៅវិញ។

សរុបសេចក្តីមកចំណុចដែលបាននិយាយនេះគឺជាលក្ខណៈខុសគ្នារវាងសាសនាពុទ្ធ និងព្រាហ្មសាសនា។

ឆ្លងកាត់តាមរយៈការបកស្រាយប្រៀបធៀបនូវលក្ខណៈដូច និង លក្ខណៈខុសគ្នានៃសាសនាទាំងពីររួចមកយើងអាចវាយតម្លៃ និង សន្និដ្ឋានបានថា ថ្វីត្បិតតែសាសនាទាំងពីរនេះមានលក្ខណៈដូចគ្នាខ្លះក៏ដោយ ខុសគ្នាខ្លះក៏ដោយក៏ខ្មែរយើងទទួលយកមកគោរពបូជា ដោយធ្វើការកែច្នៃទ្រឹស្តីខ្លះមកជាការកសាងដើម្បីសាសនាទៅវិញដូចជាការកសាងប្រាសាទភ្នំដើម្បីឧទ្ទិសដល់អាទិទេពដែលមានច្រើនពាសពេញផ្ទៃប្រទេស។ មិនតែប៉ុណ្ណោះទស្សនៈសាសនាទាំងពីរ ខ្មែរបានយកមកបញ្ចូលលាយឡំគ្នាដើម្បីគោរពប្រតិបត្តិរហូតមកដល់សព្វថ្ងៃ។ ម៉្យាងទៀតដោយយល់ឃើញថា ទ្រឹស្តីព្រះពុទ្ធសាសនាមានលក្ខណៈវិជ្ជមានជាងទើបខ្មែរលះបង់ព្រហ្មញ្ញសាសនា បែរមកគោរពពុទ្ធសាសនារហូតមកដល់សព្វថ្ងៃ ប៉ុន្តែខ្មែរបានយកទ្រឹស្តីនៃព្រហ្មញ្ញសាសនាខ្លះមកបញ្ចូលក្នុងព្រះពុទ្ធសាសនាដើម្បីគោរពប្រតិបត្តិផងដែរ។ ដូច្នេះទ្រឹស្តី នៃសាសនាទាំងពីរនេះមានវត្តមាននៅលើទឹកដីខ្មែរ និង សណ្តានចិត្តខ្មែរមិនសាបសូន្យឡើយ៕

ប្រធានទី២៤៖ ចូរអធិប្បាយអំពីលក្ខណៈស្នេហារបស់ទុំទាវ ព្រមទាំងបញ្ចេញយោបល់របស់អ្នកចំពោះស្នេហាបែបទុំទាវនេះផង។

<u>សេចក្តីអធិប្បាយ</u>

បើយើងបើកក្រាំងគម្ពីរប្រវត្តិនៃអក្សរសិល្ប៍ខ្មែរមួយទំព័រម្តងៗពិនិត្យយ៉ាងម៉ត់ចត់យើងនឹងឃើញថា នៅគ្រប់រឿងប្រលោមលោក រឿងល្ខោន រឿងនិទានខ្លីៗ ឬកំណាព្យកាពឃ្លោងផ្សែងៗសុទ្ធតែលំអដោយជីវិតស្នេហាទាំងអស់។ រឿងកុលាបប៉ៃលិន ផ្កាស្រពោន រឿងសូផាត...សុទ្ធតែចោទឡើងដោយបញ្ហាស្នេហាទាំងអស់។ ចំណែកឯរឿងទុំទាវិញ សេចក្តីស្នេហារបស់ទុំទាវក៏មានលក្ខណៈល្អ និង ប្លែកអំពីរឿងខាងលើដែរ។

តើសេចក្តីស្នេហាទុំទាវមានលក្ខណៈបែបណាទៅ?

មុននឹងឈានទៅរកដំណោះស្រាយរបស់ចំណោទបញ្ហាខាងលើយើងត្រូវយល់នូវន័យរបសើពាក្យ " ស្នេហា " ជាមុនសិន។ ពាក្យថា ស្នេហាមានន័យថាការស្រឡាញ់ពេញចិត្តទៅលើអ្វីមួយ។ ដោយផ្អែកទៅលើអត្ថន័យរបស់ពាក្យខាងលើ ទស្សនៈរបស់ប្រធានខាងលើមានន័យថា ការស្រឡាញ់ពេញចិត្តគ្នាទៅវិញទៅមករបស់យុវជនពីររូបគឺទុំ និង ទាវ។

តួយ៉ាងតាមរយៈស្លាបប៉ាការបស់កិក្ខុសោមបានបង្ហាញ និង ពន្យល់អ្នកសិក្សាក៏ដូចអ្នកអានគ្រប់ៗគ្នាបានឃើញពីជីវិតស្នេហារបស់យុវជនពីរនេះក្នុងការទំនាក់ទំនងបឋមវិយ។ នាងទាវគឺជាបុត្រីរបស់ស្ត្រីមេម៉ាយចំណាស់ម្នាក់នៅតួ្លងឃ្មុំដែលមានរូបសម្រស់ល្អលើសនារីទាំងឡាយ និង ជាក្រមុំកំពុងចូលម្លប់។ ចំណែករូបទុំជាយុវជនមានរូបឆោមស្រស់សង្ហារសំលេងពិរោះដោយទុំចេះស្មូត ព្រមទាំងកំពុងបួសរៀនក្នុងវត្តវិហារធំ។ ទុំបានធ្វើដំណើរផ្ទុកតោកដើរលក់ជាហូរហែរហូតមកដល់ស្រុកតួ្លងឃ្មុំ។ ដោយសារសម្លេង និង រូបសម្បត្តិ ទុំត្រូវបានអ្នកស្រុកចាប់ចិត្តស្រឡាញ់រាប់អានយ៉ាងខ្លាំង។ ក្រោយមកនេនទុំ និង នេនពេជ្រត្រូវបានម្តាយទាវនិមន្តឲ្យទៅស្មូតនៅផ្ទះរបស់ខ្លួន។ ខណៈពេលដែលទុំកំពុងតែស្មូតនាងទាវចង់ចេញមកក្រៅមកមើលរូបទុំណាស់ដូចមានឃ្លាបញ្ជាក់ថា " អើតអើមដកកច្រហាមាត់ ចង់ចេញប្រាកដគ្មានគេហៅ.....ស្មុះចូលយកអាវពាក់ពានា។ នៅពេលដែលឃើញកក្រៃផ្ទៃផង់របស់ទុំភ្លាម នាងទាវបានគួចចិត្តប្រតិព័ទ្ធដោយពុំបានគិតពិចារណាថាទុំនេះមានចរិយាបែបណា? កើតក្នុងត្រកូលណា? មិនតែប៉ុណ្ណោះបានបួងសួងប្រាថ្នាជួបទុំជាគូគាប់ទៀតផង។ រីឯសាមណេទុំវិញ ខណៈដែលបានឃើញវង់កក្រើដ៏ស្រស់បំព្រងរបស់នាងទាវ រូបគេក៏បានកើតចិត្តលួចបេតីលើរូបនាងផងដែរ។ ដោយរូបគេពុំបានគិតគូរពិចារណាថានាងជានារីនៅក្រមុំ ឬ ស្ត្រីមេម៉ាយប្តីលែង ឬ ក៏មានគេចូលស្តីដណ្តឹងហើយឬនៅ? ស្នេហារបស់ទុំទាវខាងលើជាស្នេហាបែបកាំរន្ទះ ដែលជាស្នេហាឆាប់រហ័សគ្មានគិតពិចារណា ឬស៊ើបអង្កេតមើលអតីតកាលរបស់គ្នាទៅវិញទៅមកឡើយ។ ស្នេហាអន្ទះសាររបស់ទុំទាវមានលក្ខណៈប្លែកជាងស្នេហាអន្ទះសាររបស់ខេមរៈជនទូទៅដទៃទៀតនៅត្រង់លក្ខណៈពិសេសរបស់បុគ្គលទុំទាវនេះ មួយជាសាមណេរមួយទៀតជាក្រមុំកំពុងចូលម្លប់ទៅតាមទំនៀមទំលាប់ប្រពៃណីជាតិដែលម្នាក់ៗសុទ្ធតែមានវិន័យគោរពរៀងៗខ្លួន។ នាងទាវបានប្រគេនផាហ៊ុមថ្មីមួយដល់នេនទុំ មិនបានប៉ុន្មានថ្ងៃផង ទុំបានដោះស្បង់ហើយរត់ទៅរកនាងទាវយ៉ាងរួសរាន់។ គេទាំងពីរបានបង្កើតស្នេហាលួចលាក់ហើយបានធ្វើខុសនឹងទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិថែមទៀត។

ម៉្យាងវិញទៀត ថ្វីត្បិតតែការប្រព្រឹត្តរបស់ទុំទាវមានគុណវិបត្តិច្រើនជាងគុណសម្បត្តិយ៉ាងណាក៏ដោយ ក៏យើងឃើញថាស្នេហារបស់ទុំទាវជារូបភាពនៃការតស៊ូដើម្បីសិទ្ធិសេរីភាពស្នេហាបរិសុទ្ធ និង កក្តីភាព។ មនោសញ្ចេតនារបស់ទុំទាវបានត្របាញ់ចូលគ្នាជាឆ្លងមួយ។ ស្នេហានេះជាស្នេហាកើតឡើងដោយឆាប់រហ័សហើយក៏ជារូបភាពនៃស្នេហាបរិសុទ្ធក្នុងដំណើរប្រព្រឹត្តទៅនៃធម្មជាតិចិត្តរបស់យុវជនគ្មានលាយឡំទៅដោយការលោភលន់ ចំពោះបុណ្យសក្តិ ឬ ទ្រព្យសម្បត្តិអ្វីឡើយ។ បន្ទាប់ពីព្រះបាទរាមាជើងព្រៃរៀបចំផ្សំផ្គុំរួចមកទុំនិងទាវមានទឹកចិត្តកក្តីរវាងគ្នានិងគ្នាក្នុងឋានៈជាប្តីប្រពន្ធបានកើនឡើងមួយទ្វេជាពីរ។ នៅពេលនាងទាវត្រឡប់ពីក្រុងលង្វែកមកតួ្លងឃ្មុំវិញ ទុំក៏បានធ្វើដំណើរមកតួ្លងឃ្មុំដែរ។ នៅពេលដឹងថានាងទាវរៀបការជាមួយមឺនងួន ទុំរន្ធត់ចិត្តយ៉ាងខ្លាំងហើយទុំក៏បានឡើងលើផ្ទះការច្រៀងឲ្យចេញមកទទួលខ្លួនដូចមានឃ្លាបញ្ជាក់ " ទុំថាឲ្យទាវស្រស់នួនល្អង នួនល្អងម៉ត់ដូចកែវចរណៃ បងមកដល់ឃូរគួរអាល័យ ទាវថ្លៃលាក់ខ្លួនពួនដល់ណា "។ ទាំងនេះបញ្ជាក់ថា ទុំស្រឡាញ់ទាវខ្លាំងណាស់ ស្រឡាញ់លើសកែវភ្នែករបស់ខ្លួនទៅទៀត។ នេះជាភក្តីភាពរបស់ទុំចំពោះទាវ។ រីឯនាងទាវវិញ ក៏មិនខុសអ្វីពីទុំឡើយ នាងក៏នឹកទុំដែរ។ " ទុំអើយអ្នកខ្សត់មិនខាន ម្ល៉េះសមមិនហ៊ានរុករានមក ទើបបានប្រុសបាត់ឈឹងជ្រងំ ទុក្ខប្អូនស្មើភ្នំក្រំក្រោក " ។ ចំណែកឯមរណភាពរបស់អ្នកទាំងពីរក៏បញ្ជាក់នូវភក្តីភាពរបស់គេដែរ។ ការស្លាប់របស់ពួកគេគឺព្រោះរបបសង្គមនាសម័យនោះ។ មិនត្រឹមតែប៉ុណ្ណោះ សេចក្តី

ស្នេហារបស់យុវជនទុំទាវត្រូវទទួលរងទុក្ខសោកឥតស្រាកស្រាន។ ប៉ុន្តែស្នេហារបស់យុវជនយុវនារីដទៃទៀតក៏តែងទទួលរងនូវទុក្ខសោករឿយៗផងដែរ។ ចំនុចមួយទៀតក៏បណ្តាលមកពីមជ្ឈដ្ឋានជុំវិញខ្លួនផងដែរ។

សរុបសេចក្តីមក លក្ខណៈស្នេហាទុំទាវគឺជាលក្ខណៈស្នេហាដែលកើតឡើងរវាងចិត្ត នឹង ចិត្ត និងជាស្នេហាមួយដែលមានភក្តីភាព និង ស្មោះស្មគ្រ័រវាងគ្នា និង គ្នា។ ម៉្យាងទៀតស្នេហារបស់ទុំនិងទាវក៏មានគុណវិបត្តិច្រើនផងដែរចំពោះទំនៀមទំលាប់ប្រពៃណីរបស់ខ្មែរយើង។

រួមសេចក្តីមក ឆ្លងកាត់តាមរយៈការបកស្រាយនូវលក្ខណៈស្នេហារបស់ទុំទាវរួចខាងលើមកយើងអាចសន្និដ្ឋានបានថា ស្នេហារបស់អ្នកទាំងពីរជាសេចក្តីស្នេហាដែលរើបំរះនឹងទស្សនៈទំនៀមទំលាប់ចាស់គំរិលហួសហេតុគឺ"នំមិនធំជាងនាឡិ"។ ជាពិសេសជាសេចក្តីស្នេហាដែលពោរពេញដោយភក្តីភាព ជាស្នេហាកើតឡើងដោយចិត្ត នឹងចិត្តផងដែរ។ ចំណែកឯឧបសគ្គនៃសេចក្តីស្នេហារបស់អ្នកទាំងពីរវាជាឧបសគ្គមួយដែលតែងតែកើតឡើងសម្រាប់មនុស្សជាតិជាដរាប។ដូច្នេះក្នុងនាមយើងជាយុវជនជំនាន់ក្រោយ មុនឈានចូលដល់ដំណាក់កាលជ្រើសរើសគូស្រករ ត្រូវខិតខំសិក្សារៀនសូត្រស្វែងរកចំណេះវិជ្ជា ឬជំនាញណាមួយសឹមបង្កើតស្នេហាជាក្រោយ ទើបយើងអាចរកនូវសុភមង្គលគ្មានក្តីបារម្ភទុក្ខព្រួយដូចស្នេហាទុំទាវ។

ប្រធានទី២៥៖ឆ្លងកាត់បទពិសោធនៃការរស់នៅកន្លងមក មានមនុស្សជាច្រើនយល់ថា "មានតែចំណេះវិជ្ជាទេ ដែលអាចធ្វើឲ្យមនុស្សមានសុភមង្គលយូរអង្វែងបាន"។ តើចំណេះវិជ្ជាផ្តល់សុភមង្គលដល់មនុស្សយ៉ាងដូចម្តេចខ្លះ? ចូរលើកឧទាហរណ៍បញ្ជាក់ផង។

សេចក្តីអធិប្បាយ

ឆ្លងកាត់នបវបទពិសោធន៍របស់មនុស្ស យើងឃើញថាដំណើរជីវិតមនុស្សគ្រប់រូប គ្រប់សម័យកាល ពោរពេញទៅដោយឧបសគ្គរាប់មិនអស់។ ឧបសគ្គទាំងនោះបានជំរុញឲ្យមនុស្សប្រើគ្រប់បញ្ញាញាណដើម្បីទម្លាយភាពទាល់ច្រករបស់ខ្លួន។ ហើយជារឿយៗ

ឃើញថាទោះបីជាមានឧបសគ្គធំតូចយ៉ាងណាក៏ដោយ ក៏មនុស្សម្នាក់ៗប្រើប្រាស់ខួរក្បាល ដែលផ្ទុកទៅដោយចំណេះវិជ្ជាយកមកដោះស្រាយបានប្រកបដោយជោគជ័យ។ ហេតុនេះហើយទើបមានមតិជាច្រើនយល់ថា "មានតែចំណេះវិជ្ជាទេដែលអាចធ្វើឲ្យមនុស្សមានសុភមង្គលយូរអង្វែងបាន"។

តើចំណេះវិជ្ជាផ្តល់សុភមង្គលដល់មនុស្សយ៉ាងណា?

.....(សាកល្បងរៀនសរសេរឃ្លាភ្ជាប់សេចក្តី។)ពាក្យថា "ចំណេះវិជ្ជា" សំដៅដល់ការចេះដឹងនូវផ្នែក ឬជំនាញផ្សេងៗ។ ឯ "សុភមង្គល" មានន័យថាមង្គលល្អ ឬសេចក្តីសុខទាំងផ្លូវចិត្ត និងផ្លូវកាយ។ អត្ថន័យរបស់ប្រធាននេះចង់និយាយថា ការចេះដឹងនូវជំនាញផ្សេងៗឲ្យពិតប្រាកដ រមែងនាំមកនូវសេចក្តីសុខទាំងផ្លូវចិត្ត ទាំងផ្លូវកាយបានយូរអង្វែង។

ជាការពិតណាស់ ការដែលចេះដឹងនូវមុខជំនាញណាមួយឲ្យបានច្បាស់លាស់ រមែងនាំឲ្យយើងមានភាពងាយស្រួលក្នុងការរកការងារធ្វើ មានសេចក្តីសុខ សុភមង្គល និងមានកិត្តិយសថែមទៀតផង។ វិជ្ជានាំឲ្យយើងមានទ្រព្យសម្បត្តិធូរធារព្រោះបើកាលណាយើងចេះអ្វីមួយពិតប្រាកដ យើងយកវិជ្ជានោះទៅប្រកបរបរទទួលទាននឹងបានកម្រៃមកផ្គត់ផ្គង់ជីវភាពគ្រួសារបានយ៉ាងងាយស្រួល។ មនុស្សមានចំណេះដឹងជាប់ខ្លួនមិនងាយនឹងចាញ់បោកគេ ពោលគឺយើងអាចនិយាយបានថាចំណេះវិជ្ជាអាចបញ្ចៀសផុតពីការគេងប្រវ័ញ្ចគ្រប់រូបភាពពីសំណាក់ជនខិលខូច។ ជាក់ស្តែងនៅក្នុងរឿងកុលាបប៉ៃលិន ដោយសារចំណេះវិជ្ជានេះហើយ ទើបធ្វើឲ្យចៅចិត្រអ៊ោះខ្លួនពីភាពជាកម្មករ មកជាអ្នកត្រួតមើលបញ្ជីត្បូង រួចក្លាយជាកូនប្រសារថៅកែត្បូងថែមទៀត។ ចំណែកក្នុងរឿងធនញ័យវិញ តួអង្គធនញ័យត្រូវទទួលរងនូវការប្រមាថពីសំណាក់ពួកមន្ត្រីខិលខូចមានទាំងសេដ្ឋី និងស្តេចផង តែដោយសារធនញ័យមានប្រាជ្ញា ធនញ័យអាចការពារខ្លួនបានជោគជ័យរាល់ពេលដូចជាយកកូនមាន់ និងកូនដំរីទៅប្រជល់ជាមួយនឹងមាន់ ដំរីរបស់ស្តេច យកសេះចត្រង្គរត់តាមស្តេចទៅប្រពាតព្រៃ ធ្វើមាន់ឈ្នោលរងាវក្នុងទឹកជាដើម...។ ផលប្រយោជន៍នៃវិជ្ជាមួយទៀតគឺអាចបង្កើត ឬច្នៃប្រឌិតបាននូវផលិតផលគ្រប់បែបយ៉ាង ដើម្បីរំដោះខ្លួនពីគ្រោះអាសន្នផ្សេងៗ។ ពេលទៅដល់ស្រុកចិន ធនញ័យធ្វើនំបញ្ចុកលក់យកប្រាក់ចិញ្ចឹមខ្លួន។ លុះពេលជាប់ក្នុងគុកសំរិទ្ធ ធនញ័យចេះធ្វើខ្លែងឯកបង្ហោះបំភ័យស្តេចចិន ធ្វើឲ្យស្តេចចិនភិតភ័យក៏ដោះលែងធនញ័យឲ្យរួចខ្លួន រួចបញ្ជូនមកស្រុកខ្មែរវិញដោយមានបរិវារ និងទ្រព្យសម្បត្តិហែហមមកជាមួយផង។ ក្រៅពីការរកកម្រៃទាញយកទ្រព្យសម្បត្តិ ចំណេះវិជ្ជាក៏អាចជួយយើងឲ្យមានសេចក្តីសុខផ្នែកផ្លូវកាយបានយ៉ាងស្រួល ដូចជាការស្វែងយល់ពីសុខភាព អនាម័យ បរិស្ថាន ការយល់ដឹងពីជំងឺផ្សេងៗ ក៏ដូចជាវិធីការពារខ្លួនឲ្យរួចផុតពីជំងឺគ្រប់ប្រភេទ។ល។ គួយ៉ាងដូចជាចៅចិត្រត្រូវទៅរស់នៅតំបន់ប៉ៃលិនដែលជាស្រុកមានជំងឺគ្រុនចាញ់ ក៏ប៉ុន្តែដោយការជួយពន្យល់ពីគ្រូពេទ្យស្អាត គួបផ្សំនឹងចំណេះវិជ្ជាដែលបានរៀននៅសាលាផង ចៅចិត្រអាចថែរក្សាសុខភាពបានយ៉ាងល្អប្រសើរ។ ម្យ៉ាងវិញទៀតចំណេះវិជ្ជាបានជួយសម្រាលបន្ទុកយើងឲ្យរួចផុតពីការងារដែលប្រើកម្លាំងបាយ ដូចជាកម្មករសែងធ្ងន់ៗ ដូចករណីចៅចិត្រអីចឹង។ ពីដំបូងក៏ជាកម្មករដូចគេដែរ ក៏ប៉ុន្តែដោយចៅចិត្រមានចំណេះវិជ្ជាក៏បានឡើងឋានៈជាអ្នកមើលការខុសត្រូវវិញម្តង។

ជាងនេះទៅទៀត វិជ្ជានាំឲ្យមនុស្សមានវិន័យ និងសេចក្តីថ្លៃថ្នូរក្នុងជីវិតរស់នៅ ព្រោះចំណេះវិជ្ជាអាចតម្រង់មនុស្សឲ្យប្រកបតែរបរណាដែលសុចរិតត្រឹមត្រូវ មិនប៉ះពាល់សិទ្ធិអ្នកដទៃ មិនប្រព្រឹត្តអំពើដែលផ្ទុយពីច្បាប់រដ្ឋ។ ហើយវិជ្ជាធ្វើឲ្យមនុស្សមានឯករាជ្យភាព ព្រោះមិនចាំបាច់រស់នៅដោយពឹងពាក់លើអ្នកដទៃ ឬត្រូវរណបគេយកបាយហូបនោះទេ ពោលគឺអាចរស់នៅបានដោយខ្លួនឯង។ កាលណាមនុស្សមានការងារធ្វើ រកបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារបានធូរធារនោះនឹងមានការកោតសរសើរ ពីគ្រប់មជ្ឈដ្ឋាន ដែលអាចញុំាងជីវិតឲ្យរស់នៅចុះសម្រុងជាមួយអ្នកដទៃប្រកបដោយសុខដុមរមនា។ កម្មករទាំងឡាយមួយណាក៏ស្រឡាញ់ និងលើកតំកើងចៅចិត្រគ្រប់ៗគ្នា ឥតមានច្រណែននិន្ទាអាក់អន់ស្រពន់ចិត្តអ្វីបន្តិចទាល់តែសោះ។

ដូចនេះយើងឃើញថា វិជ្ជាពិតជាបាននាំមកនូវសុភមង្គល ទាំងផ្លូវកាយ និងផ្លូវចិត្តដល់មនុស្សលោកពិតប្រាកដមែន។

ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាត្រឹមត្រូវដែលអាចយកជាគតិសម្រាប់អប់រំមនុស្សគ្រប់រូបឲ្យខិតខំរៀនសូត្រស្វះស្វែងរកចំណេះវិជ្ជាមកទុកក្នុងខ្លួនដើម្បីញុំាងជីវិតឲ្យរីករាយ និងមានសុភមង្គលសមដូចពាក្យ

ចាស់មួយឃ្លាថា "បើចេះប្រាកដប្រាក់រត់តាមហៅ"។ ប៉ុន្តែត្រូវចងចាំថាចំណេះវិជ្ជាទាំងនោះត្រូវតែប្រកបដោយក្រមសីលធម៌ផង។ ដូចនេះយុវជនទាំងឡាយ មិនត្រូវបណ្តោយឲ្យពេលវេលាដ៏មានថាមពលក្នុងការសិក្សារៀនសូត្រកន្លងទៅអសារបង់ឡើយ។

រក្សាសិទ្ធិដោយ ម៉ន ម៉ៅ ឯកទេសអក្សរសាស្ត្រខ្មែរ

ប្រធានទី២៦៖ចូរអ្នកធ្វើការប្រៀបធៀបពុទ្ធសាសនា និង ព្រហ្មញ្ញសាសនាដែលខ្មែរធ្លាប់ទទួលមកគោរពបូជាតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។

សេចក្តីអធិប្បាយ

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានខឿនវប្បធម៌ល្បីល្បាញរុងរឿង ព្រមទាំងមានទំនៀមទំលាប់ជំនឿសាសនាប្រពៃណីដ៏សំបូរបែប។ វប្បធម៌អរិយធម៌ទាំងនេះកើតមានដំណាលនឹងវត្តមានជនជាតិខ្មែរដែរ ប៉ុន្តែក្រោយមកខ្មែរបានទទួលយកវប្បធម៌អរិយធម៌ ភាសា អក្សរ សាសនា របស់ឥណ្ឌាមកច្នៃប្រឌិតបន្ថែមទៀត។ ចំពោះបញ្ហាសាសនាវិញ យើងលើកយកព្រះពុទ្ធសាសនា និង ព្រហ្មញ្ញសាសនាមកធ្វើការប្រៀបធៀបដើម្បីរកឲ្យឃើញនូវលក្ខណៈដូចគ្នា និង ខុសគ្នារវាងសាសនាទាំងពីរនេះ។

តើសាសនាទាំងពីរនេះមានលក្ខណៈដូចគ្នា និង ខុសគ្នាយ៉ាងណាខ្លះ?

មែនហើយជាការពិតណាស់ សាសនាទាំងពីរនេះមានវត្តមាននៅលើទឹកដីខ្មែរតាំងពីយូរយារណាស់មកហើយ ហើយត្រូវបានប្រជាជនខ្មែរនិយមរាប់អានទទួលយកមកគោរពបូជាតាំងពីដើមសតវត្សទី១នៃគ្រឹស្តសករាជសម័យនគរភ្នំមកម្ល៉េះ។ ចំពោះលក្ខណៈដូចគ្នានៃសាសនាទាំងពីរនេះគេសង្កេតឃើញថា សាសនាទាំងពីរនេះមានប្រភពមកពីប្រទេសឥណ្ឌាដូចគ្នា ហើយវាបានហូរចូលមកប្រទេសកម្ពុជាបន្តបន្ទាប់គ្នាគ្រាន់តែមុន និង ក្រោយគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ ចំពោះវត្តមានព្រហ្មញ្ញសាសនាគេសង្កេតឃើញវត្តមានមុនពុទ្ធសាសនាគឺនៅពេលដែលព្រះបាទកៅណ្ឌិន្យបានរៀបអភិសេកជាមួយព្រះនាងសោមាហើយបានគ្រប់គ្រងប្រទេសកម្ពុជា។ ពេលនោះហើយដែលអង្គក្សត្រនេះបានផ្សាយវប្បធម៌ព្រហ្មញ្ញសាសនាដល់ប្រជារាស្ត្រព្រះអង្គ។ យ៉ាងណាមិញចំពោះពុទ្ធសាសនាប្រហែលជាហូរចូលក្រោយព្រហ្មញ្ញសាសនា១សតវត្ស គឺប្រហែលសតវត្សទី២នៃគ្រឹស្តសករាជតាមរយៈសមណៈទូតពីរអង្គដែលព្រះបាទធម្មាសោកក្សត្រប្រទេសឥណ្ឌាបញ្ជូនមកផ្សព្វផ្សាយនៅដែនដីសុវណ្ណភូមិ គឺព្រះសោណត្ថេ និង ព្រះឧត្តរត្ថេរ។ ចំពោះលក្ខណៈដូចគ្នាមួយទៀតនៃសាសនាទាំងពីរនេះគឺអប់រំមនុស្សឲ្យធ្វើអំពើល្អ ជឿលើបុណ្យបាបដូចគ្នា។ ថ្វីត្បិតតែសាសនាទាំងពីរនេះមានមាគ៌ាសម្រាប់គោរពប្រតិបត្តិខុសគ្នា ប៉ុន្តែគោលបំណងគឺដូចគ្នានៅត្រង់អប់រំកាយ ចិត្តរបស់មនុស្ស ឲ្យធ្វើអំពើល្អវៀចាកអំពើអាក្រក់ ឲ្យចេះខ្លាចបាប ពោលគឺឲ្យមនុស្សហាត់ពុតលត់ដំចិត្តឲ្យប្រកាន់យកតែសេចក្តីល្អប្រកបដោយមេត្តាករុណាមុទិតា ដែលក្នុងព្រហ្មញ្ញសាសនាមានព្រះព្រហ្មជាតំណាង(ព្រះភក្ត្រទាំងបួន)។ ការអប់រំបែបនេះគឺបានជ្រាបដល់សន្តានចិត្តខ្មែរគ្រប់រូបរហូតដល់ការគ្រប់គ្រងប្រទេស ក៏ព្រះរាជាខ្មែរយកទ្រឹស្តីនេះមកអនុវត្តផងដែរ។

រីឯទ្រឹស្តីនៃសាសនាទាំងពីរនេះវិញ ថ្វីត្បិតតែមានលក្ខណៈក៏ពិតមែនក៏គេឃើញមានលក្ខណៈដូចគ្នាខ្លះដែរ គឺនៅត្រង់សាសនាទាំងពីរនេះមាននិយាយពីភពទាំងបីដូចជា ឋានមនុស្ស ឋាន សួគ៌ ឋាននរក។ នៅត្រង់ចំនុចនេះគឺសំដៅទីកន្លែងដែលមនុស្ស ទេវតា និង សត្វនរកស់នៅ។ ភពទាំងបីនេះមនុស្សតែងតែវិលវល់កើតទីណាមួយមិនអាចជៀសផុត ដោយវាអាស្រ័យលើសកម្មភាពល្អអាក្រក់តែប៉ុណ្ណោះ។ ស្ថានទាំងបីនេះ គឺមនុស្សយើងអាចមើលឃើញតែស្ថានមនុស្សលោកយើងតែមួយប៉ុណ្ណោះ។ ប៉ុន្តែស្ថានសួគ៌ នរកវិញមនុស្សមិនអាចមើលឃើញបានទេ។ ម៉្យាងវិញទៀតសាសនាទាំងពីរនេះខ្មែរបានទទួលយកមកគោរពបូជាដូចគ្នាតាំងពីសម័យបុរាណមកម្ល៉េះ។ ដោយសារជំនឿទៅលើសាសនាទាំងពីរនេះហើយ ទើបបានជាខ្មែរបានកសាងនូវប្រាង្គប្រាសាទជាច្រើនដើម្បីឧទ្ទិសចំពោះអាទិទេពនៃសាសនាទាំងពីរក្នុងន័យលើកតម្កើងអាទិទេពសុំសេចក្តីសុខផ្សេងៗ។ មិនតែប៉ុណ្ណោះខ្មែរបានធ្វើសមាហរណកម្មសាសនាទាំងពីរឲ្យចូលគ្នាមកគោរពប្រតិបត្តិរហូតមកដល់សព្វថ្ងៃ។

បើគេពិនិត្យលក្ខណៈខុសគ្នាវិញគេឃើញថា ព្រះពុទ្ធសាសនាគឺមិននិយាយពីអាទិទេពទេព្រោះព្រះពុទ្ធជាមនុស្សហើយក៏ជាម្ចាស់សាសនានិងជាអ្នកសិក្សាស្រាវជ្រាវរកឃើញទ្រឹស្តីនេះដែរ។ ព្រះនាមសទត្ថ មានមាតាបិតា និង នគរនៅលើផែនដីនេះ ហើយការដែលព្រះអង្គអាចត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ក៏ព្រោះតែការខិតខំព្យាយាមបំពេញបារមីទាំងដប់នេះដែរ។ ផ្ទុយពីព្រះពុទ្ធសាសនានេះវិញ ព្រហ្មញ្ញសាសនាគឺមានអាទិទេពបីអង្គជាអ្នកបង្កើតទ្រឹស្តី គឺព្រះព្រហ្ម ព្រះសិវៈ និង ព្រះវិស្ណុ។ អាទិទេពទាំងបីអង្គនេះមាននាទីផ្សេងៗពីគ្នាគឺព្រះព្រហ្មជាអ្នកបង្កើតលោក ព្រះសិវៈជាអ្នកបំផ្លាញលោក និង ព្រះវិស្ណុជាអ្នកថែរក្សាលោក។ ព្រះពុទ្ធសាសនាក្រៅពីព្រះពុទ្ធ មានតែអង្គព្រះអរហន្តជាសាវ័កដែលមាននាទីជួយផ្សព្វផ្សាយគោរពប្រតិបត្តិទៅតាមទ្រឹស្តីរបស់ព្រះពុទ្ធ។ ផ្ទុយពីនេះព្រហ្មញ្ញសាសនាព្រះវិស្ណុមានអវតាររហូតដល់ទៅដប់ដែលអវតារនិមួយៗមាននាទីជួយមនុស្ស នៅពេលណាដែលពិភពលោកត្រាអាសន្នដោយពួកអសុរៈអុកឡុកធ្វើបាបម្តងៗ។

រីព្រះពុទ្ធសាសនាគោរពប្រតិបត្តិតាមពុទ្ធវចនៈ របស់ព្រះសម្មាសម្ពុទ្ធដែលទ្រង់បានស្រាវជ្រាវរកឃើញដោយព្រះអង្គផ្ទាល់ក្នុងរយៈពេល៤៥ព្រះវស្សាក្រោយពេលត្រាស់ដឹង ដោយគេបានប្រមូលចងក្រងជាគម្ពីរព្រះត្រៃបិដកដែលមាន៨៤០០០ធម្មក្ខន្ធចែកចេញជាបីគម្ពីរគឺ វិនៃយបិដក សុត្តន្តបិដក និង អភិធម្មបិដក ដើម្បីទុកឲ្យពុទ្ធបរិស័ទគោរពប្រតិបត្តិតាម។ ឯព្រហ្មញ្ញសាសនាវិញមានគម្ពីរវេទជាគោលដែលជាទ្រឹស្តីអាទិទេពទាំងបីអង្គនេះហើយគម្ពីរនេះចែកចេញជាបួនគឺសម្រាប់បរិស័ទគោរពប្រតិបត្តិតាម។

ទ្រឹស្តីនៃសាសនាទាំងពីរនេះមានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំង នៅត្រង់ព្រះពុទ្ធសាសនាអប់រំមនុស្សឲ្យជឿនិងផ្អែកលើសមត្ថភាពខ្លួនឯង រីឯព្រហ្មញ្ញសាសនាអប់រំមនុស្សឲ្យជឿលើអាទិទេពព្រេងសំណាងទៅវិញ។

ម៉្យាងទៀតចំពោះសេចក្តីសុខ និង ទុក្ខវិញក៏មានលក្ខណៈខុសគ្នាច្រើនដែរ ព្រោះតាមពុទ្ធសាសនា សេចក្តីសុខ និង ទុក្ខរបស់មនុស្ស គឺស្ថិតនៅលើអំពើរបស់មនុស្សជាអ្នកប្រព្រឹត្ត។ បើកាលណាគេធ្វើអំពើល្អ នឹងបានល្អ គេធ្វើអំពើអាក្រក់ នឹងបានអាក្រក់ ពោលគឺសុខ និង ទុក្ខ តាមរយៈកម្ម និងផលនេះឯង។ ចំណែកតាមរយៈព្រហ្មញ្ញសាសនាវិញសេចក្តីសុខ និង ទុក្ខគឺស្ថិតនៅលើកណ្តាប់ដៃអាទិទេព ព្រោះបើកាលណាអាទិទេពឲ្យសុខគឺមនុស្ស នឹងបានសុខ បើកាលណាអាទិទេពឲ្យទុក្ខមនុស្សនឹងបានទុក្ខដោយមិនអាចចៀសផុតឡើយ។ ពោលគឺអាទិទេពជាកំណត់ជោគវាសនា សុខ ទុក្ខ ល្អអាក្រក់របស់មនុស្ស។ បើកាលណាគេចង់សុខគឺគេត្រូវខិតខំព្យាយាមធ្វើការអង្វរកអាទិទេព សុំសេចក្តីសុខតាមរយៈវិធីប្រតិបត្តិទាំងបួនគឺ តបៈ យោគៈ បូជាយញ្ញ និង ពិធីលាងបាប ឬ សិរៈរាត្រី។ ឯព្រះពុទ្ធសាសនាវិញ កាលណាមនុស្សចង់បានសុខ គេត្រូវលះបង់អំពើអាក្រក់ចោល ហើយប្រកាន់យកអំពើល្អទាំងកាយ វាចា និង ចិត្តនោះ គេនឹងបានសុខ។

ទន្ទឹមនឹងនេះដែរ ចំពោះវាសនារបស់មនុស្សដែលល្អ អាក្រក់ មាន ក្រ លំបាកវេទនា ស្រួលស្រណុក មានឋានៈធំតូចយ៉ាងណា តាមទ្រឹស្តីព្រហ្មញ្ញសាសនាគឺស្ថិតនៅលើកណ្តាប់ដៃរបស់អាទិទេពផងដែរ ព្រោះអាទិទេពបានចារវាសនារបស់មនុស្សរួចជាស្រេចនៅពេលមនុស្សកើតមកដោយមិនអាចកែប្រែបានឡើយ ដូចជាការបែងចែកឋានៈទាំងបួននៅក្នុងសាសនានេះអញ្ចឹង គឺវណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវៃស្យៈ និង វណ្ណៈសូទ្រៈ ដែលវណ្ណៈទាំងបួននេះមិនអាចផ្លាស់ប្តូរបានឡើយ។ រីឯព្រះពុទ្ធសាសនាវិញ ចំពោះបញ្ហាខាងលើក៏ស្ថិតនៅលើមនុស្សជាអ្នកកំណត់ខ្លួនឯងដែរ ព្រោះបើកាលណាមនុស្សប្រកាន់យកសេចក្តីព្យាយាមត្រូវ គិតត្រូវធ្វើអំពើជាកុសល ទាំងកាយ វាយចា និង ចិត្តទៅលើសកម្មភាពការងាររបស់គេដោយផ្ចិតផ្ចង់ និង យកចិត្តទុកដាក់គេនឹងទទួលបានសម្រេចជោគវាសនារបស់គេមិនខានដូចជាចំណេះដឹងជាដើម។ បើកាលណាយើងខិតខំរៀនយើងនឹងទទួលបានចំណេះដឹង ផ្ទុយពីព្រហ្មញ្ញសាសនាដែលថា ពុទ្ធិគឺអាទិទេពជាអ្នកផ្តល់ឲ្យទៅវិញ។

សរុបមកតាមរយៈការបកស្រាយប្រៀបធៀបនូវលក្ខណៈដូច និង លក្ខណៈខុសគ្នានៃសាសនាទាំងពីររួចមកយើងអាចវាយតម្លៃ និង សន្និដ្ឋានបានថា ថ្វីត្បិតតែសាសនាទាំងពីរនេះមានលក្ខណដូចគ្នាខ្លះក៏ដោយ ខុសគ្នាខ្លះក៏ដោយក៏ខ្មែរយើងទទួលយកមកគោរពបូជា ដោយធ្វើការកែច្នៃទ្រឹស្តីខ្លះមកជាការកសាងដើម្បីសាសនាទៅវិញដូចជាការកសាងប្រាសាទភ្នំដើម្បីឧទ្ទិសដល់អាទិទេពដែលមានច្រើនពាសពេញផ្ទៃប្រទេស។ មិនតែប៉ុណ្ណោះទស្សនៈសាសនាទាំងពីរ ខ្មែរបានយកមកបញ្ចូលលាយឡំគ្នាដើម្បីគោរពប្រតិបត្តិរហូតមកដល់សព្វថ្ងៃ។ ម៉្យាងទៀតដោយយល់ឃើញថា ទ្រឹស្តីព្រះពុទ្ធសាសនាមានលក្ខណៈវិជ្ជមានជាងទើបខ្មែរលះបង់ព្រហ្មញ្ញសាសនា បែរមកគោរពពុទ្ធសាសនារហូតមកដល់សព្វថ្ងៃ ប៉ុន្តែខ្មែរបានយកទ្រឹស្តីនៃព្រហ្មញ្ញសាសនាខ្លះមកបញ្ចូលក្នុងព្រះពុទ្ធសាសនាដើម្បីគោរពប្រតិបត្តិផងដែរ។ ដូច្នេះទ្រឹស្តី នៃសាសនាទាំងពីរនេះមានវត្តមាននៅលើទឹកដីខ្មែរ និង សណ្តានចិត្តខ្មែរមិនសាបសូន្យឡើយ៕

ប្រធានទី២៧៖ ចូរអធិប្បាយអំពីលក្ខណៈស្នេហារបស់ទុំទាវ ព្រមទាំងបញ្ចេញយោបល់របស់អ្នកចំពោះស្នេហាបែបទុំទាវនេះផង។

<u>សេចក្តីអធិប្បាយ</u>

បើយើងបើកក្រាំងគម្ពីរប្រវត្តិនៃអក្សរសិល្ប៍ខ្មែរមួយទំព័រម្តងៗ ពិនិត្យយ៉ាងម៉ត់ចត់យើងនឹងឃើញថា នៅគ្រប់រឿងប្រលោមលោក រឿងល្ខោន រឿងនិទានខ្លីៗ ឬកំណាព្យកាពឃ្លោងផ្សេងៗសុទ្ធតែលំអដោយជីវិតស្នេហាទាំងអស់។ រឿងកុលាបប៉ៃលិន ផ្កាស្រពោន រឿងសូផាត...សុទ្ធតែចោទឡើងដោយបញ្ហាស្នេហាទាំងអស់។ ចំណែកឯរឿងទុំទាវវិញ សេចក្តីស្នេហារបស់ទុំទាវក៏មានលក្ខណៈល្អ និង ប្លែកអំពីរឿងខាងលើដែរ។

តើសេចក្តីស្នេហាទុំទាវមានលក្ខណៈបែបណាទៅ?

មុននឹងឈានទៅរកដំណោះស្រាយរបស់ចំណោទបញ្ហាខាងលើ យើងត្រូវយល់នូវន័យរបស់ពាក្យ " ស្នេហា " ជាមុនសិន។ ពាក្យថា ស្នេហាមានន័យថាការស្រឡាញ់ពេញចិត្តទៅលើអ្វីមួយ។ ដោយផ្អែកទៅលើអត្ថន័យរបស់ពាក្យខាងលើ ទស្សនៈរបស់ប្រធានខាងលើមានន័យថា ការស្រឡាញ់ពេញចិត្តគ្នាទៅវិញទៅមករបស់យុវជនពីររូបគឺទុំ និង ទាវ។

ស្លាបប៉ាការបស់កិក្ខុសោមបានបង្ហាញ និង ពន្យល់អ្នកសិក្សាក៏ដូចអ្នកអានគ្រប់ៗគ្នាបានឃើញពីជីវិតស្នេហារបស់យុវជនពីរនេះក្នុងការទំនាក់ទំនងបឋមវិយ។ នាងទាវគឺជាបុត្រីរបស់ស្ត្រីមេម៉ាយចំណាស់ម្នាក់នៅត្បូងឃ្មុំដែលមានរូបសម្រស់ល្អលើសនារីទាំងឡាយ និង ជាក្រមុំកំពុងចូលម្លប់។ ចំណែករូបទុំជាយុវជនមានរូបឆោមស្រស់សង្ហារសំលេងពិរោះដោយទុំចេះស្មូត ព្រមទាំងកំពុងបួសរៀនក្នុងវត្តវិហារធំ។ ទុំបានធ្វើដំណើរផ្ទុកគោកដើរលក់ជាហូរហែរហូតមកដល់ស្រុកត្បូងឃ្មុំ។ ដោយសារសម្លេង និង រូបសម្បត្តិ ទុំត្រូវបានអ្នកស្រុកចាប់ចិត្តស្រឡាញ់រាប់អានយ៉ាងខ្លាំង។ ក្រោយមកនេនទុំ និង នេនពេជ្រត្រូវបានម្តាយទាវនិមន្តឲ្យទៅស្មូតនៅផ្ទះរបស់ខ្លួន។ ខណៈដែលទុំកំពុងស្មូតនាងទាវចង់ចេញមកក្រៅមកមើលរូបទុំណាស់ដូចមានឃ្លាបញ្ជាក់ថា " អើតអើមដកកច្រហាមាត់ ចង់ចេញប្រាកដគ្មានគេហៅ.....

ស្ទុះចូលយកអាវពាក់ពានា។ នៅពេលដែលឃើញភក្រ័ផូរផង់របស់ទុំភ្លាម នាងទាវបានគួចចិត្តប្រតិព័ទ្ធដោយពុំបានគិតពិចារណាថាទុំនេះមានចរិយាបែបណា? កើតក្នុងត្រកូលណា? មិនតែប៉ុណ្ណោះបានបួងសួងប្រាថ្នាជួបទុំជាគូគាប់ទៀតផង។ រីឯសាមណេទុំវិញ ខណៈដែលបានឃើញវង់ភក្ត្រដ៏ស្រស់បំព្រងរបស់នាងទាវ រូបគេក៏បានកើតចិត្តលួចបេតីលើរូបនាងផងដែរ។ ដោយរូបគេពុំបានគិតគូរពិចារណាថានាងនាងជានារីនៅក្រមុំ ឬ ស្ត្រីមេម៉ាយប្តីលែង ឬ ក៏មានគេចូលស្តីដណ្តឹងហើយឬនៅ? ស្នេហារបស់ទុំទាវខាងលើជាស្នេហាបែបកាំរន្ធ ដែលជាស្នេហាឆាប់រហ័សគ្មានគិតពិចារណា ឬស៊ើបអង្កេតមើលអតីតកាលរបស់គ្នាទៅវិញទៅមកឡើយ។ ស្នេហាអន្ទះសាររបស់ទុំទាវមានលក្ខណៈប្លែកជាងស្នេហាអន្ទះសាររបសខេមរៈជនទូទៅដទៃទៀតនៅត្រង់លក្ខណៈពិសេសរបស់បុគ្គលទុំទាវនេះ មួយជាសាមណេរ មួយទៀតជាក្រមុំកំពុងចូលម្លប់ទៅតាមទំនៀមទំលាប់ប្រពៃណីជាតិដែលម្នាក់ៗសុទ្ធតែមានវិន័យគោរពរៀងៗខ្លួន។ នាងទាវបានប្រគេនផាហ៊ុមថ្មីមួយដល់នេនទុំ មិនបានប៉ុន្មានថ្ងៃផង ទុំបានដោះស្បង់ហើយរត់ទៅរកនាងទាវយ៉ាងរួសរាន់។ គេទាំងពីរបានបង្កើតស្នេហាលួចលាក់ហើយបានធ្វើខុសនឹងទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិថែមទៀត។

ម៉្យាងវិញទៀត ថ្វីត្បិតតែការប្រព្រឹត្តរបស់ទុំទាវមានគុណវិបត្តិច្រើនជាងគុណសម្បត្តិយ៉ាងណាក៏ដោយ ក៏យើងឃើញថាស្នេហារបស់ទុំទាវជារូបភាពនៃការតស៊ូដើម្បីសិទ្ធិសេរីភាពស្នេហាបរិសុទ្ធ និង ភក្តីភាព។ មនោសញ្ចេតនារបស់ទុំទាវបានត្របាញ់ចូលគ្នាជាឆ្កងមួយ។ ស្នេហានេះជាស្នេហាកើតឡើងដោយឆាប់រហ័សហើយក៏ជារូបភាពនៃស្នេហាបរិសុទ្ធក្នុងដំណើរប្រព្រឹត្តទៅនៃធម្មជាតិចិត្តរបស់យុវជនគ្មានលាយឡំទៅដោយការលោភលន់ ចំពោះបុណ្យសក្តិ ឬ ទ្រព្យសម្បត្តិអ្វីឡើយ។ បន្ទាប់ពីព្រះបាទរាមាជើងព្រៃរៀបចំផ្សំផ្គុំរួចមកទុំនិងទាវមានទឹកចិត្តភក្តីរវាងគ្នានិងគ្នាក្នុងហានៈជាប្តីប្រពន្ធបានកើនឡើងមួយទ្វេរជាពីរ។ នៅពេលនាងទាវត្រឡប់ពីក្រុងលង្វែកមកត្បូងឃ្មុំវិញ ទុំក៏បានធ្វើដំណើរមកត្បូងឃ្មុំដែរ។ នៅពេលដឹងថានាងទាវរៀបការជាមួយម៉ឺនងួន ទុំរន្ធត់ចិត្តយ៉ាងខ្លាំងហើយទុំក៏បានឡើងលើផ្ទះការច្រៀងឲ្យចេញមកទទួលខ្លួនដូចមានឃ្លាបញ្ជាក់ " ទុំថាឲ្យទាវស្រស់នួនល្អង នួនល្អងម៉ត់ដូចកែវចរណៃ បងមកដល់ឃូរគួរអាល័យ ទាវថ្លៅលាក់ខ្លួនពួនដល់ណា "។ ទាំងនេះបញ្ជាក់ថា ទុំស្រឡាញ់ទាវខ្លាំងណាស់ ស្រឡាញ់លើសកែវភ្នែករបស់ខ្លួនទៅទៀត។ នេះជាភក្តីភាពរបស់ទុំចំពោះទាវ។ រីឯនាងទាវិញ ក៏មិនខុសអ្វីពីទុំឡើយ នាងក៏នឹកទុំដែរ។ " ទុំអើយអ្នកខ្សត់មិនខាន ម្លេះសមមិនហ៊ានរុករានមក ទើបបានប្រុសបាត់ឈឺងជ្រងំ ទុក្ខប្អូនស្មើភ្នំក្រំក្រោក " ។ ចំណែកឯមរណភាពរបស់អ្នកទាំងពីរក៏បញ្ជាក់នូវកក្តីភាពរបស់គេដែរ។ ការស្លាប់របស់ពួកគេគឺព្រោះរបសសង្គមនាសម័យនោះ។ មិនត្រឹមតែប៉ុណ្ណោះ សេចក្តីស្នេហារបស់យុវជនទុំទាវត្រូវទទួលរងទុក្ខសោកឥតស្រាកស្រាន។ ប៉ុន្តែស្នេហារបស់យុវជនយុវនារីដទៃទៀតក៏តែងទទួលរងនូវទុក្ខសោករឿយៗផងដែរ។ ចំនុចមួយទៀតក៏បណ្តាលមកពីមជ្ឈដ្ឋានជុំវិញខ្លួនផងដែរ។

សរុបសេចក្តីមក លក្ខណៈស្នេហាទុំទាវគឺជាលក្ខណៈស្នេហាដែលកើតឡើងរវាងចិត្ត នឹង ចិត្ត និងជាស្នេហាមួយដែលមានភក្តីភាព និង ស្មោះស្មគ្រ័រវាងគ្នា និង គ្នា។ ម៉្យាងទៀតស្នេហារបស់ទុំនិងទាវក៏មានគុណវិបត្តិច្រើនផងដែរចំពោះទំនៀមទំលាប់ប្រពៃណីរបស់ខ្មែរយើង។

រួមសេចក្តីមក តាមរយៈការបកស្រាយនូវលក្ខណៈស្នេហារបស់ទុំទាវរួចខាងលើមកយើងអាចសន្និដ្ឋានបានថា ស្នេហារបស់អ្នកទាំងពីរជាសេចក្តីស្នេហាដែលរើបំរះនឹងទស្សនៈទំនៀមទំលាប់ចាស់គំរិលហួសហេតុគឺនំមិនធំជាងនាឡិ។ ជាពិសេសជាសេចក្តីស្នេហាដែលពោរពេញដោយភក្តីភាព ជាស្នេហាកើតឡើងដោយចិត្ត នឹងចិត្តផងដែរ។ ចំណែកឯឧបសគ្គនៃសេចក្តីស្នេហារបស់អ្នកទាំងពីរវាជាឧបសគ្គមួយដែលតែងតែកើតឡើងសម្រាប់មនុស្សជាតិជាដរាប។ដូច្នេះក្នុងនាមយើងជាយុវជនជំនាន់ក្រោយ មុនឈានចូលដល់ដំណាក់កាលជ្រើសរើសគូរស្រករ ត្រូវខិតខំសិក្សារៀនសូត្រស្វែងរកចំណេះវិជ្ជា ឬជំនាញណាមួយសឹមបង្កើតស្នេហាជាក្រោយ ទើបយើងអាចរកនូវសុភមង្គល គ្មានក្តីបារម្ភទុក្ខព្រួយដូចស្នេហាទុំទាវ៕

ប្រធានទី២៨៖គេតែងនិយាយថា” ប្រាសាទអង្គរវត្ត គឺជាកេរដំណែរបស់ខ្មែរ ដែលមិនអាចកាត់ថ្លៃបាន”។ តើប្រាសាទអង្គរវត្តមានចំណុចពិសេសដូចម្តេចខ្ល? ចូរពន្យល់បកស្រាយ។

សេចក្តីអត្ថាធិប្បាយ

ប្រទេសកម្ពុជា គឺជាប្រទេសតូចមួយក៏ពិតមែនប៉ុន្តែសម្បូរសម្បត្តិធម្មជាតិសម្បត្តិវប្បធម៌ជាច្រើ-ន។ ដោយឡែកសម្បត្តិវប្បធម៌រួមមាន ប្រាង្គប្រាសាទបុរាណ គម្ពីរក្បួនខ្នាត ក្បួនច្បាប់បុរាណពាក្យទូ-ន្មាន ចម្រៀង របាំ តន្ត្រី កំណាព្យ

ប្រពៃណីទំនៀមទម្លាប់ជាដើម។ ក្នុងនោះប្រាង្គប្រាសាទបុរាណខ្មែរ គេសង្កេតឃើញប្រាសាទ អង្គរវត្តមានកេរឈ្មោះល្បីល្បាញជាងសម្បត្តិណាទាំងអស់។ ហេតុដូចនេះហើយទើបបានជាមានទស្សនៈមួយបានលើកឡើងថា"ប្រាសាទអង្គរវត្តគឺជាកេរដំណែលរបស់ខ្មែរ ដែលមិនអាចកាត់ថ្លៃបាន"។

តើប្រាសាទអង្គរវត្តមានលក្ខណៈពិសេសដូចម្តេចខ្លះទើបជាកេរដំណែលមិនអាចកាត់ថ្លៃបានយ៉ាងនេះ?

ដើម្បីឱ្យមានភាពកាន់តែងាយស្រួលក្នុងការបកស្រាយប្រធានខាងលើ យើងគប្បីស្វែងយល់នូវន័យនៃពាក្យថា" កេរដំណែល" និង"មិនអាចកាត់ថ្លៃបាន" ជាមុនសិន។ពាក្យថា"កេរដំណែល" មានន័យថាទ្រព្យសម្បត្តិដែលដូនតាឬបុព្វបុរសជំនាន់មុនបានបន្សល់ទុកមក។ ចំណែកឯពាក្យ"មិនអាចកាត់ថ្លៃបាន" មានន័យថា មានតម្លៃយ៉ាងខ្លាំង ល្អល្អះណាស់ ពិសេសវិសាលណាស់។ តាមន័យនៃពាក្យទាំងពីរប្រធានចង់បញ្ជាក់ថា ប្រាសាទអង្គរវត្ត ជាសម្បត្តិ ទ្រព្យដែលបន្សល់ទុកពីដូនតាមករបស់ខ្មែរ គឺជាសម្បត្តិដែលមានតម្លៃយ៉ាងខ្លាំង ល្អល្អះណាស់ពិសេសវិសាលជាទីបំផុត។

ជាការពិតណាស់ "ប្រសាទអង្គរវត្ត គឺជាកេរដំណែលរបស់ខ្មែរ ដែលមិនអាចកាត់ថ្លៃបាន" គឺពិតជាត្រឹមត្រូវណាស់ ព្រោះវាមានលក្ខណៈពិសេសបីយ៉ាងដែលគួរឱ្យកត់សំគាល់។ លក្ខណៈពិសេសទីមួយ គឺទាក់ទងនឹងប្រវត្តិសាស្ត្រ។ ចំណុចនេះចង់បញ្ជាក់ថា ប្រសាទអង្គរវត្តគឺត្រូវបានស្ថាបនាឡើងក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី២ ក្នុងអំឡុងសតវត្សទី១៧ នៃគ្រឹស្តរាជ ដើម្បីឧទិទ្ទិសថ្វាយព្រះវិស្ណុ។ វាបានចូលរួមបម្រើដល់វិស័យសាសនានៅក្នុងប្រទេសកម្ពុជា នាសម័យមហានគរ ជាពិសេសសាសនាព្រាហ្មណ៍ ជាក់ស្តែងស្តេចដែលកសាងប្រសាទនេះ គឺក្នុងគោលបំណងទុកបញ្ចុះសព្វរបស់ទ្រង់នៅពេលចូលទីវង្គត់ទៅ។ នេះហើយជាលក្ខណៈបង្ហាញពីការបម្រើ ដល់សាសនាព្រាហ្មណ៍ដែលជាប្រាសាទផ្នូរនេះឯង។ លក្ខណៈពិសេសទីពីរ គឺប្រាសាទអង្គរវត្ត ជាស្ថាបត្យកម្មវប្បធម៌ និងសិល្បៈរបស់ខ្មែរ។ ត្រង់ចំណុចនេះគឺចង់បញ្ជាក់ថា ប្រាសាទដ៏អស្ចារ្យនេះមានភាពរឹងមាំរបស់ខ្លួន គឺសង់តាមក្បួនខ្នាត ចច្នៃកទេសត្រឹមត្រូវ មានក្បួនខ្នាតក្នុងការសាងសង់ប្រាសាទតួប្រាសាទ និងកំពូលទាំងប្រាំខ្ពស់របស់វា។ ជាពិសេសជាងនេះទៅទៀតគឺវាមានក្បូរក្បាច់រចនា ចម្លាក់តាមរោងជាង តាមជញ្ជាំងប្រាសាទ ក្លោងទ្វារជាដើម ដែលមើលទៅគួរឱ្យចាប់អារម្មណ៍ក្រៃលែង។ ក្បាច់ចម្លាក់ទាំងនោះគឺ សុទ្ធតែបានបង្ហាញពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរ ក្នុងសម័យអង្គរ និងសម័យផ្សេងៗទៀតផង។ លក្ខណៈពិសេសទីបី គឺទាក់ទងនឹងបរិស្ថាន។ មានន័យថា ប្រាសាទបុរាណនេះបានសាងសង់ឡើងក្នុងទីតាំងស្ថិតលើវាលដ៏ធំធេងមានស្រះអមសង់ខាងផ្លូវ មានសោភណភាពស្រស់ស្អាតនាថ្ងៃរៀបលិច ហើយចាំងចែងមកលើតួប្រាសាទ ដែលជាកេរដំណែលមួយធ្វើឱ្យមនុស្សកោតស្ងប់ស្ងែងក្រៃលែង។

ជារួមមក បានជាគេថា ប្រាសាទអង្គរវត្តជាកេរដំណែលមួយ មិនអាចកាត់ថ្លៃបានគឺមកពី ប្រាសាទនេះសាងសង់ឡើង ដោយព្រះមហាក្សត្ររបស់ខ្មែរក៏ល្បីល្បាញ មានក្បូរក្បាច់រចនា ល្អល្អះទាំងតួប្រាសាទ កំពូល នឹងកន្លែងផ្សេងទៀត ហើយថែមទាំងកសាងឡើងលើទីតាំងមួយដ៏ល្អប្រសើរ។

ឆ្លងកាត់តាមបកស្រាយទស្សនៈរបស់ប្រធានខាងលើ ប្រធានមានអត្ថន័យជ្រោលជ្រៅក្រៃលែង ព្រោះបានបង្ហាញពីលក្ខណៈពិសេសភាពនៃសម្បត្តិអច្ឆរិយៈរបស់ខ្មែរ គឺប្រាសាទអង្គរវត្ត។ ដូច្នេះក្នុងនាមយើងជាកូនខ្មែរជំនាន់ក្រោយមិនត្រូវភ្លើតភ្លើនភ្លេចខ្លួន ហើយផ្តល់តម្លៃឱ្យវប្បធម៌ ជាតិផ្សេង ជាជាងសម្បត្តិរបស់ខ្លួននោះទេ ពោលគឺត្រូវផ្តល់អទិភាព និងតម្លៃខ្លាំងលើកេរដំណែលរបស់បុព្វបុរសយើង និងជួយការងារថែរក្សាឱ្យបានគង់វង្ស ដើម្បីឱ្យកូនចៅជំនាន់ក្រោយបានស្គាល់ផង។

ប្រធានទី២៩ ៖គេតែងគិតថា “ មនុស្សម្នាក់ៗ តែប្រាថ្នាចង់បានសេចក្តីថ្លៃថ្នូរ និងកិត្តិយសពិរោះពិសាជានិច្ច”។ តើមនុស្សត្រូវធ្វើដូចម្តេចខ្លះ ដើម្បីទទួលបាននូវសេចក្តីថ្លៃថ្នូរ និងកិត្តិយស ? ចូរពន្យល់បកស្រាយ និងលើកជាឧទាហរណ៍មកបញ្ជាក់។

សេចក្តីអធិប្បាយ

នៅលើលោកសន្និវាសយើងនេះ គ្មានបុគ្គលណាម្នាក់ចង់រស់នៅដែលមានប្រវត្តិអាក្រក់ មានកេរ្តិ៍ឈ្មោះស្អុយរលួយក្នុងសង្គមឡើយ។ ផ្ទុយទៅវិញមនុស្សគឺតែងប្រាថ្នាចង់បានកិត្តិយស និងកេរ្តិ៍ឈ្មោះល្អជានិច្ច ។ អាស្រ័យហេតុនេះហើយទើបបានជាគេតែងពោលថា “ មនុស្សម្នាក់ៗ តែប្រាថ្នាចង់បានសេចក្តីថ្លៃថ្នូរ និងកិត្តិយសពិរោះពិសាជានិច្ច”។

តើមនុស្សត្រូវធ្វើដូចម្តេច ដើម្បីទទួលបានសេចក្តីថ្លៃថ្នូរ និងកិត្តិយស ?

ដើម្បីជាជំនួយដល់ការបកស្រាយប្រធានខាងលើ យើងត្រូវយល់នៃន័យពាក្យក្នុងប្រធានជាមុនសិន។ ពាក្យថា” ប្រាថ្នា” មានន័យថា ប៉ងចង់បាន មានបំណងចង់បាន។ ចំណែកឯ”សេចក្តីថ្លៃថ្នូរ” ចង់សម្តៅទៅលើភាពថ្លៃថ្នូរ ដែលផ្ទុយស្រលះពីភាពថោកទាប។ ហើយចំពោះពាក្យ”កិត្តិយស”វិញមានន័យថា កេរ្តិ៍ឈ្មោះល្បីល្បាញ មានហាន: និងយសក្តិខ្ពង់

ខ្ពស់។ តាមន័យនៃពាក្យខាងលើ ប្រធានចង់ចង់បញ្ជាក់ថា សញ្ជាតិជាមនុស្ស គឺតែងតែចង់បាន ឬប្រាថ្នាចង់បាន ភាពថ្លៃថ្នូរដែលផ្ទុយស្រលះពីភាពថោកទាប ហើយនិងមានកេរ្តិ៍ឈ្មោះហាន: និងយសក្តិខ្ពង់ខ្ពស់នៅក្នុងសង្គម។

ជាសត្យានុម័ត មនុស្សម្នាក់ៗគឺតែងតែប្រាថ្នាចង់បានភាពថ្លៃថ្នូរ ដែលផ្ទុយស្រលះពីភាពថោកទាប និងមានកេរ្តិ៍ឈ្មោះ ហាន: និងយសក្តិខ្ពង់ខ្ពស់នៅក្នុងសង្គមប្រាកដមែន ព្រោះមនុស្សជាច្រើនបានខិតខំកសាងសម្បត្តិទ្រព្យនេះ ដើម្បីឱ្យជីវិតមានន័យ។ ដើម្បីមានកិត្តិយស និងសេចក្តីថ្លៃថ្នូរទៅបាន គឺផ្តើមចេញពីខ្លួនយើងផ្ទាល់ គឺប្រព្រឹត្តតែអំពើល្អ ប្រកបដោយគុណធម៌ សីលធម៌ និងសុចរិត។ ចំណុចនេះចង់មានន័យថាកាលណាមនុស្សប្រព្រឹត្តតែអំពើល្អ ដោយកាយ វាចា និងចិត្ត ចេះជួយសង្គ្រោះគ្នា ជួយគ្នាទៅវិញទៅមកដោយភាពស្មោះត្រង់ មិនប្រែប្រួល មិនកេងប្រវ័ញ្ចគ្នា។ លើសពីនេះទៀតមនុស្សក៏ត្រូវគោរពគ្នាទៅវិញទៅមកដែរ មានការជួយសង្គ្រោះ អាណិតអាសូរ យោគយល់ អធ្យាស្រ័យ និងមានក្តីករុណាជានិច្ច។ មួយវិញទៀតគឺមនុស្សដែឡមានកិត្តិយស សេចក្តីថ្លៃថ្នូរទៅបាន គឺទល់តែមានការផ្តល់តម្លៃ គោរព ស្រឡាញ់ពីសំណាក់មនុស្សនៅជុំវិញខ្លួន។ ពិសេសបំផុតនោះ មនុស្សត្រូវមានគំនិតលះបង់អំពើអាក្រក់ ការមើលងាយ មើលថោកការងារផ្សេងៗ ព្យាយាមប្រព្រឹត្តតែអំពើល្អប្រពៃ មានសេចក្តីក្លាហាន ហ៊ានលះបង់ពេលវេលា ទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនស្តាយក្រោយ។ ចំនុចពិសេសមួយទៀតដែលត្រូវបំពេញនោះ គឺត្រូវមានចិត្តអំណត់ តស៊ូ អត់ធ្មត់ និងការងារបានគ្រប់យ៉ាង ឱ្យតែការងារនោះជាការងារសុច្ចរិត ត្រឹមត្រូវ ទៀងត្រង់ ស្របតាមច្បាប់របស់សង្គម។

ជារួមមក ពំនោលដែលបានលើកឡើងថា" មនុស្សម្នាក់ៗ តែងតែប្រាថ្នាចង់បានសេចក្តីថ្លៃថ្នូរ និងកិត្តិយសពិរោះពិសាជានិច្ច" គឺពិតជាត្រឹមត្រូវ ព្រោះមនុស្សដែលមានកិត្តិយស និងសេចក្តីថ្លៃថ្នូរទៅបានអាស្រ័យដោយបុគ្គលនោះមានគុណធម៌ សច្ចធម៌ និងសុច្ចរិតជានិច្ច។

ឆ្លងកាត់តាមរយៈការបកស្រាយប្រធានខាងលើ ប្រធានពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំដល់មនុស្សឱ្យដើរលើគន្លងមួយដ៏ត្រឹមត្រូវ ពោលឆ្ពោះទៅរកសេចក្តីល្អបរិសុទ្ធ ដែលមានកិត្តិយស និងសេចក្តីថ្លៃថ្នូរនេះឯង។ ដូច្នេះក្នុងនាមយើងជាមនុស្សដែលស្រឡាញ់កិត្តិយស និងសេចក្តីថ្លៃថ្នូរត្រូវប្រកាន់ជាប់នូវគំនិតល្អ មានគុណធម៌ សីលធម៌ សប្បុរសធម៌ និងសុចរិត ទើបខ្លួនឯង និងសង្គមជាតិមានភាពរីកចម្រើនឡើង។

ប្រធានទី៣០៖ប្រធាន: ក្នុងរឿងថៅកែចិត្តចោរពូហំបានពោលពាក្យថា “ អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះ ដើម្បីសេចក្តីពិតផ្ទុះឡើងវិញ”។ ចូរពន្យល់គំនិតខាងលើនេះ ឱ្យបានក្បោះក្បាយ។(ប្រឡងគ្រូមធ្យមសិក្សាបឋមភូមិឆ្នាំ ២០០២ឯកទេសទី១)

សេចក្តីអធិប្បាយ

ជាទូទៅទំនាស់ដែលធំបំផុតនៅក្នុងរឿង ថៅកែចិត្តចោរ ពីជាទំនាស់រវាងថៅកែនិងតែកុងហំ។ វាបានកើតឡើងដោយសារពូហំចាញ់បោកថៅកែ ដែលបានជួលគាត់ឱ្យបោកឡានបុកឡានថៅកែហុងលីតែក្រោយមកថៅកែបែរជាបដិសេធមិនព្រមទទួលខុសត្រូវចំពោះហេតុការណ៍នេះ។ ការឈឺចាប់នេះបានជម្រុញឱ្យពូហំភ្ញាក់រលឹកចង់កែកំហុសស្តារកិត្តិយសរបស់ខ្លួនដែលបានប្រព្រឹត្តិខុស និងជួយរកយុត្តិធម៌ដល់អ្នកបានរងគ្រោះ។ អាស្រ័យហេតុនេះហើយទើបបានជាគាត់បានពោលពាក្យបន្ថែមចំពោះមុខកម្មករទាំងអស់ថា ” អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះដើម្បីឱ្យសេចក្តីពិតផ្ទុះឡើងវិញ”។

តើពូហំយល់យ៉ាងដូចម្តេចបានជាគាត់ពោលបែបនេះ?

មុននឹងឈានទៅដំការបកស្រាយនូវគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់នូវន័យនៃពាក្យគន្លឹះសំខាន់ៗមានក្នុងប្រធានជាមុនសិន។ពាក្យថា”វង្សត្រកូល” សម្តៅទៅលើក្រុមគ្រួសារឬក៏ជាពូជអំបូរសាច់ញាតិដែលមានជាប់សាច់សាររលោហិតជាដៅសន្តាននឹងគ្នា។ ចំណែកឯ “សេចក្តីពិត” មានន័យថាជាភាពប្រាកដជាក់ច្បាស់ ភាពប្រាកដប្រជាឥតក្លែងក្លាយដែលសេចក្តីពិតនៅទីនេះចង់សម្តៅលើភាពជាក់ច្បាស់ឬសេចក្តីពិតនៃដើមហេតុជាទំនាស់រវាងថៅកែ

និងពូហំនេះឯង។ ដូច្នេះទស្សនៈដែលពូហំបានបញ្ជាក់ខាងលើមានន័យថាគាត់សុខចិត្តឱ្យក្រុមគ្រួសារឬសាច់សារលោហិត ផៅសន្តានរបស់គាត់ស្លាប់ ឬបាត់បង់កិត្តិយសសិនចុះ គាត់នឹងលាតត្រដាងនូវល្បិចកិច្ចកលដ៏ខ្មៅងងឹតរបស់ថៅកែចិត្តអប្រិយ ដើម្បីឱ្យរឿងរឿងរ៉ាវពិតទាំងឡាយនោះបានផ្ទុះឡើងឱ្យមហាជនបានដឹងឮនិងចងចាំនូវអំពើពិសពុលយោរយៅរបស់ថៅកែ។

ជាការពិតណាស់ នៅក្នុងសង្គមគ្រួសារ មនុស្សគ្រប់រូបតែងប្រាថ្នាឱ្យគ្រួសារខ្លួនមានសេចក្តីសុខសុភមង្គលនឹងជីវភាពធូរធា។ បើគ្រួសាររបស់ខ្លួនធ្លាក់ទៅក្នុងរឿងអាក្រក់ សមាជិកគ្រួសារ ពិសេសមេគ្រួសារប្រាកដជានឹងរិះរកនូវគ្រប់វិធី ដើម្បីស្រោចស្រង់ស្ថានភាពនោះឱ្យប្រសើរឡើងជាក់ជាពុំខាន បើទោះបីជាដំណោះស្រាយនោះជាទង្វើល្អ ឬក៏ជាទង្វើអាក្រក់ ថោកទាប ប៉ះពាល់ដល់សេចក្តីសុខអ្នកដទៃក៏គេពុំខ្វល់ គឺឱ្យតែបានប្រយោជន៍មកសម្រាលទម្ងន់នៃអម្រែកដ៏ធ្ងន់របស់គ្រួសារខ្លួនមួយគ្រាសិននោះ គឺរាប់ថាជាការដ៏ប្រពៃមួយ។ជាក់ស្តែងនៅក្នុងស្នាដៃអក្សរសិល្ប៍រឿងថៅកែចិត្តចោរក៏ដូច្នេះដែរ។ ជីវភាពនៃគ្រួសាររបស់តែកុងហំ គឺស្ថិតនៅក្នុងស្ថានភាពមួយលំបាកខ្វះខាតគ្រប់យ៉ាង បើទោះបីជាគាត់ខិតខំធ្វើការរកប្រាក់ទាំងថ្ងៃទាំងយប់យ៉ាងណា ក៏នៅតែមិនអាចធ្វើឱ្យជីវភាពរបស់គាត់បានប្រសើរឡើងនោះដែរ។ ប្រពន្ធមានជំងឺប្រចាំកាយរ៉ាំរ៉ៃត្រូវការការព្យាបាល ចំណែកឯទ្រព្យសម្បត្តិទ្រនាប់ខ្លួនបន្តិចបន្តួចក៏សឹងគ្មាន គឺពឹងលើប្រាក់ខែស្តួចស្តើងដែលគាត់ធ្វើការជាតែកុងឡាន។ កូនស្រីត្រូវការប្រាក់ទិញសម្ភារៈសិក្សានៅអនុវិទ្យាល័យ។ យាយចាន់ជាម្តាយមានវ័យចាស់ណាស់ហើយ គាត់ចង់ធ្វើបុណ្យទានសន្សំកុសលឱ្យបានច្រើន។ អាស្រ័យដោយស្ថានភាពគ្រួសារ ស្ថិតលើកត្តាចំបងទាំងបីនេះហើយ ទើបជម្រុញចិត្តពូហំឱ្យប្រព្រឹត្តអំពើអមនុស្សធម៌ ដោយបើកឡានទៅបុកឡានថៅកែហុងលី តាមពាក្យបញ្ជារបស់ថៅកែ។ប៉ុន្តែក្រោយការងាសម្រេចហើយ ថៅកែបែរជាក្បត់ពាក្យសន្យាមិនព្រមទទួលខុសត្រូវបញ្ជាឱ្យហំរត់គេចខ្លួន និងស្តីប្រមាថដាក់គាត់ទៀត។នៅពេលបានស្គាល់ពីគំនិតអាក្រក់របស់ថៅកែខ្លួនហើយ ពូហំមានសេចក្តីអៀនខ្មាស់ នឹងស្តាយក្រោយនូវកំហុសដែលខ្លួនបានប្រព្រឹត្តដោយការជឿងប់ទៅលើពាក្យកុហក់បោកប្រាស របស់ថៅកែដែលស្គាល់តែមុខមាត់តែមិនស្គាល់ចិត្តថ្លើម។ ពូហំមិនបានរត់គេចទេ ហើយពេលនោះចិត្តដែលពីដំបូងត្រូវការប្រាក់ជាចាំបាច់នោះ ត្រូវបានផ្លាស់ប្តូរថ្មីយ៉ាងឆាប់ហ៊ស ទឹកមុខដែលសំដែងពីការអង្វរករក៏ប្រែក្លាយជាមុតមាំភ្លាមលែងចង់បានប្រាក់១ម៉ឺនរៀលពីថៅកែទៀតហើយ ព្រោះឆ្អែតឆ្អន់នឹងការបោកប្រាស់ ពាក្យសម្តីមិនស្មោះត្រង់របស់ថៅកែដែលស្រឡាញ់តែលុយជាធំជាងទឹកចិត្តកម្មករទុគ៌តរបស់ខ្លួន។ ពេលនោះពូហំបានដកការជឿជាក់ សេចក្តីគោរព និងបញ្ចប់ការគាំទ្រទាំងស្រុងពីថៅកែអមនុស្សនេះទៀតហើយបើទោះបីជាលទ្ធផលគាត់ត្រូវជាប់គុក គ្រួសារអាប់ឱនកិត្តិយសយ៉ាងណាក្តី គឺដល់ពេលដែលត្រូវលាតត្រដាងនូវរឿងពិតទាំងអស់ឱ្យក្រុមកម្មករ និងមនុស្សទូទៅបានដឹងពីអំពើឧក្រិដ្ឋរបស់ថៅកែចិត្តជាចោរនេះហើយ។ ពូហំហ៊ានលះបង់គ្រប់យ៉ាងដើម្បីបង្ហាញឱ្យឃើញនូវអ្វីជាសនិងខ្មៅ យុត្តិធម៌និងអយុត្តិធម៌ដូចសម្តីដែលគាត់បាននិយាយនឹងតួអង្គសុខថា" អាសុខអញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ ដើម្បីឱ្យសេចក្តីពិតផ្ទុះឡើងរួច ទើបបានដឹងគ្រប់គ្នាហើយអាចរកវិធីដោះស្រាយបាន"។លើសពីនេះទៀតគាត់ហាមមិនឱ្យនាងយ៉ានដែលជាប្រពន្ធយកលុយពីថៅកែដូចមានឃ្លាមួយថា" កុំទទួលបុណ្យពីមនុស្សបាប"។ សម្តីទាំងនេះបញ្ជាក់ថា គាត់ស្អប់ខ្ពើបមនុស្សបោកប្រាស់ដែលយកទង្វើល្អបន្តិចបន្តួចមកបិទបាំងអំពើអាក្រក់របស់ខ្លួន។ ក្នុងជំហរដែលមានស្មារតីជាបង្អែកក៏រឹងមាំនេះពូហំពុំបានចុះញោមនឹងអំណាចថៅកែទៀតឡើយដូចជាពេលដែលថៅកែប្រើទឹកលុយ ដើម្បីទាក់ទាញពួកកម្មករឱ្យជួយបិទបាំងការពិតនិងកាត់ជើងខាងខ្លួន ពូហំបានដាស់តឿនកម្មករកុំឱ្យគ្រាំទ្រថៅកែទៀត។ ការដែលពូហំបកអាក្រាធអំពីគំនិតអាក្រក់របស់ថៅកែនេះ មិនមែនដោយសារតែតូចចិត្តនឹងការដែលខ្លួនចាញ់កលថៅកែហើយចង់សងសឹងវិញនោះទេ គឺដោយសារតែការហ៊ានទទួលស្គាល់នូវកំហុសខ្លួនដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយត្រូវបាននាយទុនប្រើ

ប្រាស់ជាឈ្នាន់ ហើយចង់ឱ្យសង្គមមើលឃើញ ជាពិសេសចង់ឱ្យច្បាប់ជួយរកយុត្តិធម៌ជូនខ្លួន ក៏ដូចជាកម្មករនិងសង្គមទាំងមូលផងដែរ។ គាត់សុខចិត្តទទួលទោសកំហុសគ្រប់យ៉ាង ប៉ុន្តែគាត់ក៏ចង់ឱ្យថៅកែទទួលនូវទោសកំហុសនេះដែរ។ ក្រៅពីពូហំ កម្មករដទៃទៀតក៏ពុំគ្រាំទ្រនូវទង្វើអាក្រក់របស់ថៅកែនេះដែរដូចជាផានីតក៏បាចូលរួមបកអាក្រាធថៅកែដែរដោយបានពោលថា" ខ្ញុំចោទថៅកែថាជាចោរជាន់ខ្ពស់ព្រោះចេះបន្លំ ជាមនុស្សសម្លាប់មនុស្សដូចជាបានសម្លាប់មនុស្សបីនាក់កាលពីបុកឡានម្សិលមិញ"។ចំណែកនាងយ៉ាន សុខ គង់ មាន ទ្រី ក៏សុទ្ធតែជួយពូហំក្នុងការប្រឆាំងនឹងថៅកែនិងលាតត្រដាងពីការពិតនៃឧក្រិដ្ឋកម្មដែលមានថៅកែជាមេខ្លោងប្រាប់ដល់ប៉ូលីសបើទោះបីព្យាយាមយកប្រាក់មកអូសទាញយ៉ាងណាក៏ដោយ។ ដូច្នេះឃើញថាទាំងពូហំ និងពួកកម្មករទាំងអស់តស៊ូលះបង់គ្រប់យ៉ាងគឺដើម្បីទាមទារឱ្យមានភាពយុត្តិធម៌ ដោយគេយល់ថាស៊ូក្រក្រចុះ ស្លាប់ៗចុះឱ្យតែមានភាពយុត្តិធម៌នៅក្នុងខ្លួនក្នុងឧត្តមគតិនោះគេនឹងទទួលបាននូវតម្លៃកិត្តិយស និងភាពថ្លៃថ្នូរមិនខាន។

សរុបមកយើងអាចធ្វើការសន្និដ្ឋានបានថា ការដែលពូហំចេញមកសារភាព និងហ៊ានបកអាក្រាធទង្វើអាក្រក់របស់ថៅកែគឺគាត់មានការភ្ញាក់ខ្លួនឡើងវិញ និងបានធ្វើការគិតពិចារណាច្បាស់លាស់ថារាល់ទង្វើដែលបានធ្វើទោះបីល្អឬអាក្រក់ក្តី សំខាន់ត្រូវតែមានស្មារតីទទួលខុសត្រូវ។

ឆ្លងកាត់តាមរយៈការបកស្រាយប្រធានខាងលើ បង្ហាញថាពូហំគឺជាមនុស្សដែលមានស្មារតីចេះភ្ញាក់រឭក និងកែប្រែកំហុសរបស់ខ្លួនដែលជាគម្រូដ៏ល្អសម្រាប់មនុស្សគ្រប់រូប។ ដូច្នេះក្នុងនាមយើងក៏ត្រូវមានគំនិតចេះភ្ញាក់រឭកបែបនេះដែរ ព្រោះមនុស្សរមែងមានកំហុសជាធម្មតា តែសំខាន់គឺការចេះកែប្រែខ្លួនឯង ទៅរកផ្លូវត្រឹមត្រូវវិញនេះឯង។

ប្រធានទី៣១

ប្រធាន: ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ លោករដ្ឋមន្ត្រីក្មេងបានពោលទៅកាន់សមថា “ ខ្ញុំមិនត្រូវការអីក្រៅពីសេចក្តីស្មោះត្រង់សុចរិតរបស់បងឯងទេ”។ ចូរពន្យល់គំនិតខាងលើឱ្យបានក្បោះក្បាយ។(ប្រឡងគ្រូមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០០២,២០០៥, ២០០៩)

សេចក្តីធធិប្បាយ

បញ្ហាជីវិតរបស់តួអង្គសមនៅក្នុងរឿងព្រះអាទិត្យរះលើផែនដីចាស់ ដែលជាស្នាដៃរបស់លោក សួន សុរិន្ទគឺតម្រូវឱ្យតួអង្គសមជួបប្រទះតែនូវឧបសគ្គ និងការលំបាកជាបន្តបន្ទាប់គ្មានស្រាកស្រាន។ប៉ុន្តែដោយសារតែចរិតស្លូតស្មោះត្រង់របស់ខ្លួន បានធ្វើឱ្យជីវិតចាប់ផ្តើមប្រសើរឡើងបន្តិចម្តងៗជាលំដាប់។ ក្នុងពេលដែលសមជួបគ្រោះថ្នាក់ចរាចរណ៍ដោយឡានបុក សមបានសំដែងនូវទឹកចិត្តដ៏សុភាព ស្លូតបូត និងសុចរិតរបស់ខ្លួន ដែលបានធ្វើឱ្យលោករដ្ឋមន្ត្រីពេញចិត្ត និងជួយវិញដោយសេចក្តីស្មោះត្រង់វិញដែរ។ដែលពេលនោះលោកបានពោលថា”ខ្ញុំនឹងជួយបងឯងឱ្យបានស្រួល ខ្ញុំមិនត្រូវការអីក្រៅពីភាពស្មោះត្រង់សុចរិតរបស់បងឯងទេបង”។

តើមូលហេតុអ្វីបានជាលោករដ្ឋមន្ត្រីវ័យក្មេងនិយាយដូច្នេះ?

មុននឹងបកស្រាយសំដីខាងលើ ជាបឋមយើងគប្បីយល់ន័យនៃពាក្យគន្លឹះដែលមាននូវក្នុងប្រធានជាមុនសិន។ ពាក្យថា”សេចក្តីស្មោះត្រង់” មានន័យថាភាពមិនកុហក់បោកប្រាស់ មិនវៀចវេរ មិនមានកិច្ចកល បន្លំបំភ្លៃពីការពិត។រីឯពាក្យ”សុចរិត”វិញសម្តៅទៅភាពត្រឹមត្រូវ ទៀតត្រង់ដោយប្រតិបត្តិតែទង្វើសីលធម៌ល្អ។ ដូច្នេះតាមអត្ថន័យបកស្រាយនៃពាក្យខាងលើគំនិតរបស់ប្រធានខាងលើចង់បង្ហាញឱ្យយើងបានដឹងថាការដែលលោករដ្ឋមន្ត្រី បានជួយយកអាសារនិងទំនុកបម្រុងសមឱ្យមានការងារធ្វើ មានទីពុំនាក់អាស្រ័យរួចពីភាពវេទនាទុគ៌តនោះ គឺលោកពុំដែលនឹកនាចង់បានការតបស្នងសងគុណពីសមវិញឡើយ។ ការសំខាន់ដៃលោកត្រូវការនោះគឺ ភាពទៀងត្រង់ ត្រឹមត្រូវ មិនមាន ការកុហក់បោកប្រាស់ ហើយនឹងទង្វើល្អទាំងអស់របស់សមនេះឯង។

យ៉ាងណាមិញតាមរយៈរឿងខាងលើយើងបានដឹងយ៉ាងច្បាស់ថាតួអង្គសម មុននឹងបានជួយសង្គ្រោះដោយលោករដ្ឋមន្ត្រី គឺសមគ្រាន់តែជាកម្មករក្រីក្ររកព្រឹកខ្វះល្ងាចហើយពុំមានទ្រព្យសម្បត្តិ ជាទីពឹងជាប់នឹងខ្លួនតែប៉ុណ្ណោះ។រីឯពួកអ្នកមានឬថៅកែវិញគ្រាន់តែឃើញមុខសម គេមិនទទួលស្វាគមន៍បាត់ទៅហើយ ព្រោះសមប្រៀបបាននឹងអ្នកសុំទានដែលមានសម្លៀកបំពាក់គគ្រិច រាងកាយស្គមស្គាំងគ្មានកម្លាំង ដូច្នេះគេមិនទុកចិត្តបុគ្គលប្រភេទនេះដើម្បីទទួលឱ្យធ្វើការងារឱ្យគេទេ។ចំណែកលោករដ្ឋមន្ត្រីវិញ មានការយល់ផ្សេងពីអ្នកនោះ ដោយលោកយល់និងជឿជាក់ថាសមជាមនុស្សល្អដឹងការខុសត្រូវ មានសីលធម៌រស់នៅល្អ ស្រឡាញ់ការងារសុចរិតនិងកិត្តិយស។ មិនតែប៉ុណ្ណោះគាត់បានយល់ទៀតថាសមជាមនុស្សគួរឱ្យជឿទុកចិត្តអាចរាប់អាន និងពឹងពាក់បានទៀតផង។អាស្រ័យហេតុនេះហើយទើបគាត់យកសមមកឱ្យថែទាំផ្ទះរបស់គាត់។ គំនិតយល់ឃើញនេះសរបញ្ជាក់ឱ្យឃើញថាលោករដ្ឋមន្ត្រីពិតជាបុគ្គល ដែលប្រកបដោយចំណេះដឹងគុណធម៌ និងចេះពិចារណាជិតដល់ស្គាល់តម្លៃមនុស្សដោយមិនវាយតម្លៃតែសម្បកក្រៅ។ ជាពិសេសលោកតែងប្រកាន់ខ្ជាប់នូវឥរិយាបថដ៏ថ្លៃថ្នូរ ចេះពោលពាក្យទន់ភ្លន់ សុភាពរាបសាដោយមិនប្រកាន់ខ្លួនក្នុងការរាប់អានមនុស្សទូទៅនិងម៉ឺងម៉ាត់ សក្តិសមជាបញ្ញាវន្តគួរជាទីគោរព និងលើកតម្កើងក្រៃលែង។ មិនតែប៉ុណ្ណោះលោកជាបុគ្គលដែលមានមនុស្សធម៌ ដែលជានិច្ចកាលលោកតែងជួយទុក្ខធុរៈអ្នកដទៃឥតរើសមុខ ព្រមទាំងមានការទទួលខុសត្រូវខ្ពស់ទៀតផង។ ជាក់ស្តែងនៅពេលដែលធ្វើឱ្យសមមានគ្រោះថ្នាក់លោកស្រាវចុះពីរថយន្តទៅមើលភ្លាមព្រមទាំងជួយលើកសមដាក់លើរថយន្តពិនិត្យរបួសដោយយកចិត្តទុកដាក់។ អាកប្បកិរិយាដ៏ទន់ភ្លន់ទាំងនេះបានធ្វើឱ្យសម មានចិត្តរំភើបយ៉ាងខ្លាំងហើយមានកម្លាំងខ្លះៗទៀតវិញភ្លេចអស់នូវការឈឺចាប់នៃមុខរបួសបានមួយរយៈខ្លី។ ជាងនេះទៅទៀតយើងសង្កេងឃើញថាលោកគឺជាមនុស្សដែលប្រកបដោយភាពវ័យឆ្លាត និងមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការរាប់អានមិត្តព្រោះលោកចេះវិធីសាស្ត្រស្ទាបស្ទង់ពីចិត្តមនុស្សមុននឹងផ្តល់ទំនុកចិត្ត ទៅលើនរណាម្នាក់ដូចជាពេលជជែកជាមួយសមលោកបានឆ្លៀតសួរនាំពីសាវតាគ្រួសារ ការងារ ញាតិជាដើមដើម្បីជាទិន្នន័យសម្រាប់ជាគោលវិភាគ រង្វាយតម្លៃលើលក្ខណៈមនុស្សបានត្រឹមត្រូវ។ ពាក្យពេជន៍គ្រប់ម៉ាត់របស់លោកសុទ្ធសឹងពោរពេញទៅដោយអត្ថន័យសេចក្តីមេត្តា ករុណា និងការសណ្តាសប្រណីដែលសរបញ្ជាក់ថា លោកជាមនុស្សដែលស្គាល់ទុក្ខធុរៈគ្នាក្នុងគ្រាដែលលំបាកមានអាសន្ន ហើយក៏ជាអ្នកដែលចេះជួយឧបត្ថម្ភលើកទឹកចិត្តអ្នកដែលទន់ខ្សោយ ក្រខ្សត់ឱ្យប្រសើរឡើងផងដែរ។ លោកយល់ច្បាស់ពីខ្សែបន្ទាត់ព្រំដែននៃសិទ្ធិសេរីភាព និងបានអនុវត្តវា បានសង្គ្រោះសម ព្រោះថាលោកគឺជាដើមហេតុនៃការបង្កគ្រោះថ្នាក់នោះដែលបង្ហាញថាលោកគឺជាមនុស្សដែលមានទំនួលខុសត្រូវខ្ពស់ចំពោះទង្វើរបស់ខ្លួន។ ផ្នត់គំនឹតរបស់លោកដែលបានជួយសង្គ្រោះសមសរបញ្ជាក់ឱ្យឃើញថារវាងមនុស្សល្អនិងមនុស្សអាក្រក់ពុំអាចរស់នៅឱ្យចុះសម្រុងជាមួយគ្នាបានឡើយ គឺមានតែមនុស្សដែលមានទឹកចិត្តល្អដូចគ្នាទេ ទើបអាចសម្របខ្លួនឱ្យត្រូវគ្នាបានហើយមានតែមនុស្សស្មោះត្រង់សុចរិតទេ ទើបសង្គមជ្រោមជ្រែង និងអឱ្យតម្លៃ។ ដូចជាលោកអ៊ីចឹង ការដែលសម្រេចចិត្តជួយ និងទទួលសមឱ្យនៅជាមួយអាស្រ័យសមជាមនុស្សល្អនេះផង។ ម្យ៉ាងទៀតលោកចង់ជួយសមឱ្យទៅជាពលរដ្ឋល្អម្នាក់ ដែលជាធនធានដ៏ប្រសើររបស់សង្គម។ ការដែលសមទទួលបានជីវិតជោគជ័យគឺដោយសារសមប្រតិបត្តិតាមគន្លងដ៏ត្រឹមត្រូវ ដែលលោករដ្ឋមន្ត្រីជួយកែតម្រូវតម្រង់ផ្លូវដោយផ្ទាល់ ព្រោះលោកជាបុគ្គលដែលស្រឡាញ់នូវសុចរិតភាព និងមានបទពិសោធន៍ទូលំទូលាយក្នុងការងារ និងចិត្តសាស្ត្រសង្គម ជាពិសេសជាមនុស្សថ្លៃថ្នូរមានសីលធម៌រស់នៅល្អ និងមានមនុស្សធម៌ដែលសក្តិសមមានការភ្ញាក់រឭក ចេះគិតពិចារណារំលែងឆ្ងាយពីឆាកជីវិតរបស់ខ្លួនប្រកបដោយគំនិតសុទិដ្ឋិនិយម ហើយមានកម្លាំងចិត្តគ្រប់គ្រាន់ដើម្បីវិលត្រឡប់ទៅស្រុកកំណើតប្រកបរបរកសិកម្មវិញទទួលបានជោគជ័យជាបន្តបន្ទាប់។ មិនតែប៉ុណ្ណោះដោយនិស្ស័យជាមនុស្សល្អសុចរិត ព្យាយាម និងចេះជួយយកអាសារអ្នកដទៃនោះសមមិនត្រឹមតែអាចកសាងជីវភាព

បានយ៉ាងធូរធាប៉ុណ្ណោះទេថែមទាំងទទួលបាននូវការគោរពរាប់អានពីប្រជាជន ហើយត្រូវបានគេបោះឆ្នោតជ្រើសរើសតាំងធ្វើជាបេក្ខជនតំណាងឃុំទៀតផង។ បើមើលនៅក្នុងសង្គមជាក់ស្តែងវិញ ប្រសិនបើមនុស្សប្រព្រឹត្តិតែអំពើល្អ សុចរិតស្មោះត្រង់បានខ្ជាប់ខ្ជួននោះ គេតែងទទួលបាននូវការគោរពស្រឡាញ់ ស្ងើចសរសើរពីសង្គម ហើយរស់នៅប្រកបដោយសេចក្តីសុខសុកមង្គល និងមានកិត្តិយស ពុំមានអ្នកបៀតបៀនបានឡើយ។

សរុបសេចក្តីមក ការបកស្រាយគំនិតរបស់លោករដ្ឋមន្ត្រី គឺជាគំនិតអប់រំមួយដ៏ប្រសើរសម្រាប់សមក័ដូចជាមនុស្សទូទៅផងដែរ ព្រោះតាមរយៈតួអង្គសមអាស្រ័យដោយចរិតលក្ខណៈស្លូតបូត សុចរិតត្រឹមត្រូវរបស់ខ្លួននេះហើយដែលធ្វើឱ្យទទួលបាននូវការស្រឡាញ់ពីលោករដ្ឋមន្ត្រី និងប្រជាជននៅក្នុងសង្គម។

ឆ្លងកាត់តាមរយៈការបកស្រាយប្រធានដែលបានពោលខាងលើ គឺមានបំណងចង់ឱ្យមនុស្សមានទឹកចិត្តសុខរិតស្មោះត្រង់ មានទំនួលខុសត្រូវ និងចេះស្រឡាញ់នូវយុត្តិធម៌។ ដូច្នេះទស្សនៈនេះជាឧត្តមគតិក៏ប្រសើរបំផុតមួយសម្រាប់អប់រំមនុស្សទូទៅឱ្យប្រកាន់នូវសុខចរិត យុត្តិធម៌ដែលជាមាគ៌ាដឹកនាំជីវិតនិងសង្គមទៅរកឧត្តមភាព ក្នុងនាមយើងជាពលរដ្ឋត្រូវចេះប្រកាន់ខ្ជាប់នូវគំនិតបែបនេះដែរព្រោះវាជាគុណធម៌ដ៏ប្រសើររបស់មនុស្សដែលជាគន្លឹះដ៏ប្រសើរបំផុតសម្រាប់កសាងវប្បធម៌សន្តិភាព និងភាពរីកចម្រើនប្រកបដោយសុភមង្គលរវាងមនុស្សជាតិនៅក្នុងពិភពលោក។

ប្រធានទី៣២ ៖ មានទស្សនៈមួយបានពោលថា " ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ប្រកបដោយសុខសុវត្ថិភាពមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលធនធានមនុស្សបានឡើយ"។ នៅក្នុងស្ថានភាពបច្ចុប្បន្ន តើគេត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ? (ប្រឡឹងគ្រូមធ្យមសិក្សាបឋមភូមិឆ្នាំ ២០០២)

សេចក្តីធធិប្បាយ

ប្រទេសនីមួយៗលើសកលោក មានគោលការណ៍នៃការអភិវឌ្ឍប្រទេសខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ប្រទេសខ្លះអាចពឹងផ្អែងលើវិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ សិប្បកម្មជាដើម។ ដោយសារវិស័យទាំងអស់នោះហើយបានធ្វើឱ្យប្រទេសជាតិនោះមានការរីកចម្រើនឡើងគួរឱ្យកត់សម្គាល់។ ប៉ុន្តែសម្រាប់វិស័យនីមួយៗនេះ អាចមានដំណើរការល្អទៅបានគឺអាស្រ័យដោយមានធនធានមនុស្ស ជាកត្តាសំខាន់។ អាស្រ័យហេតុនេះហើយទើបបានជាគេតែងគិតជាទូទៅថា "ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ប្រកបដោយសុខសុវត្ថិភាពមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលធនធានមនុស្សបានឡើយ"។

តើការគិតខាងលើនេះចង់មានអត្ថន័យយ៉ាងដូចម្តេច? តើធនធានមនុស្សដែលត្រូវចូលរួមក្នុងការអភិវឌ្ឍមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយនូវគំនិតខាងលើ យើងគួរគប្បីយល់នូវន័យនៃពាក្យគន្លឹះមាននៅក្នុងប្រធានជាមុនសិន។ " ការអភិវឌ្ឍ" មានន័យថាការរីកចម្រើនខ្លាំង ការលូតលាស់ក្រៃលែង។ រីឯពាក្យ " ធនធានមនុស្ស " សំដៅដល់មនុស្ស ដែលមានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់បម្រើការងារណា
មួយ។ និងពាក្យ "សុវត្ថិភាព" គឺជាការប្រកបដោយសេចក្តីសុខ ភាពសុខសាន្ត។ តាមរយៈន័យនៃពាក្យទាំងនេះ ប្រធានចង់មានន័យថា ការធ្វើឱ្យប្រទេសជាតិរីកចម្រើនប្រកបដោយសេចក្តីសុខសាន្តចំបាច់ត្រូវមានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់។

ជាការពិតណាស់ យើងដឹងហើយថា ប្រទេសដែលមានធនធានធម្មជាតិច្រើនមិនប្រកដថាជា ប្រទេសអភិវឌ្ឍនោះទេ ចំណែកប្រទេសដែលមិនសូវមានធនធានធម្មជាតិច្រើនក៏មិនប្រកដថាប្រទេសនោះអន់ថយដែរ។ ប្រទេសខ្លះមិនមានធនធានធម្មជាតិច្រើនក៏ពិតមែន ប៉ុន្តែប្រទេសនោះសម្បូរទៅដោយធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ដែលមានប្រទេសជប៉ុននិងសឹង្ហបុរីជាដើម។ដូច្នេះធនធានមនុស្សជាកត្តាដ៏សំខាន់ណាស់ក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ។ប៉ុន្តែចំណុចសំខាន់ដែលត្រូវគិតនោះគឺថា ត្រូវអភិវឌ្ឍធនធានមនុស្សនោះដោយរបៀបណា។ សម្រាប់ប្រទេសអភិវឌ្ឍ កំពុងអភិវឌ្ឍ និងប្រទេសក្រីក្រ គេយកចិត្តទុកដាក់លើកត្តាធនធានមនុស្សនេះណាស់ដោយ

បង្កើននូវការបណ្តុះបណ្តាលលើធនធានមនុស្សនោះជាច្រើន។ គេ បានបណ្តុះបណ្តាលលើផ្នែកកាយសម្បទា។ មានន័យថា ប្រទេសទាំងនោះត្រូវបង្កើនឱ្យមានកីឡាផ្សេងៗដូចជា កីឡាបាល់ទាត់ ប្រដាល់ បាល់ទះជាដើម ដើម្បីឱ្យមនុស្សចូលរួម ក្នុងគោលបំណងដើម្បីទទួលបានសុខភាពល្អ និងមានរាងកាយមាំមួន។ម្យ៉ាងទៀត ប្រទេសទាំងអស់ត្រូវធ្វើការបណ្តុះបណ្តាលលើផ្នែកស្មារតី គឺប្រាជ្ញាសម្បទារបស់មនុស្សផងដែរ។ ត្រូវបង្កើតឱ្យមានគោលនយោបាយផ្សេងក្នុងបង្កើននិងវឹកវឹនមនុស្សឱ្យមានជំនាញច្បាស់លាស់ និងអាចបម្រើប្រយោជន៍សម្រាប់សង្គម សម្រាប់មនុស្សដែលមានសមត្ថភាពចំណេះដឹងខ្ពស់ បង្ហាត់បង្រៀនដល់អ្នកចេះបង្ហូរ ចំណែកអ្នកចេះបង្ហូរបង្ហាត់ដល់អ្នកចេះមធ្យម និងអ្នកចេះមធ្យមបង្ហាត់ដល់អ្នកមិនទាន់ចេះសោះ។ លើសពីនេះទៅទៀត គេត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានបំណិន ឥរិយាបថត្រឹមត្រូវ និងមានបទពិសោធន៍ច្រើន។ នេះគឺការបណ្តុះបណ្តាលផ្នែកប្រាជ្ញាសម្បទា។ ចំណុចទាំងនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺត្រូវបណ្តុះបណ្តាលមនុស្សឱ្យមានសីលធម៌ល្អក្នុងការរស់នៅ សាកសម្បជាមនុស្ស ពោលគឺមិនបណ្តាយឱ្យធនធានមនុស្សនោះធ្វើអ្វីដែលប្រាកចាកពីសីលធម៌សង្គម និងច្បាប់បានឡើយ។ មិនតែប៉ុណ្ណោះ ត្រូវអប់រំមនុស្សត្រូវតែចេះរួមរស់ក្នុងសង្គមសន្តិភាព មិនចេះបង្កជម្លោះ ឬបទល្មើសផ្សេងៗដែលបណ្តាលឱ្យសង្គមមានចលាចល។ អប់រំមនុស្សឱ្យដឹងថាមនុស្សមានសិទ្ធិសេរីភាពស្មើៗគ្នាចំពោះមុខច្បាប់ដែលជាគោលការណ៍ នៃប្រទេសប្រជាធិបតេយ្យ។ ចំណុចនេះជាការអភិវឌ្ឍលើសីលសម្បទារបស់មនុស្ស។ បើប្រទេសនីមួយៗបណ្តុះបណ្តាលមនុស្សឱ្យមានលក្ខណៈទាំងអស់នេះ ប្រាកដណាស់ប្រទេសនឹងមានការរីកចម្រើនជាក់ជាពំខាន។

សរុបសេចក្តីមក ក្នុងស្ថានភាពបច្ចុប្បន្ន យើងត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពគ្រប់គ្រាន់ទាំងផ្នែករាងកាយ ប្រាជ្ញាស្មារតី សីលធម៌ និងបំណិនឬជំនាញ។

ឆ្លងតាត់តាមការបកស្រាយគំនិតរបស់ទស្សនៈប្រធានខាងលើនេះ យើងសង្កេតឃើញថាប្រធានខាងលើពិតជាមានអត្ថន័យល្អប្រសើរ នឹងត្រឹមត្រូវព្រោះធនធានមនុស្ស គឺជាកត្តានៃការកំណត់ការអភិវឌ្ឍក្នុងសង្គម។មនុស្សអភិវឌ្ឍឥតឈប់ឈរដែលខុសប្លែកពីសត្វនានា ដែលមានត្រឹមត្រូវសភាវគតិ។ដើម្បីមានលទ្ធភាពក្នុងការចូលរួមក្នុងការកសាងជាតិ។ដូច្នេះក្នុងនាមយើង ជាកុលបុត្រខ្មែរត្រូវខិតខំរៀនសូត្រអោយមានសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធ និងបំណិនអោយបានច្បាស់លាស់។ អក្ខរជន គឺជាឧបសគ្គនៃការអភិវឌ្ឍប្រទេសជាតិ។ ក្នុងការរៀនសូត្រទៀតសោត យើងត្រូវធ្វើយ៉ាងអោយមានការស៊ីសង្វាក់គ្នានៃការរីកចម្រើនផ្លូវកាយ និងប្រាជ្ញារាងវិទ្យាសាស្ត្រ និងសីលធម៌រវាងបុគ្គល និងសង្គម រវាងជាតិ និងអន្តរជាតិ។

ប្រធានទី៣៣៖ ថៅកែរបស់ពូហំបានពោលថា" យុត្តិធម៌របស់ជនមួយក្រុមខុសនិងយុត្តិធម៌របស់ជនមួយក្រុមទៀត"។ ចូរពន្យល់គំនិតខាងលើនេះដោយលើកយកនៅឧទាហរណ៍ក្នុងរឿងថៅកែចិត្តចោរមកបញ្ជាក់។ (ប្រឡងគ្រូមធ្យមសិក្សា ឆ្នាំ ២០០៤ ឯកទេសទី២)

សេចក្តីអធិប្បាយ

ការរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗក្នុងសង្គម តែងតែចង់បាននៅជីវភាពមួយប្រកបដោយសេចក្តីសុខ សុភមង្គល និងជាពិសេសមានបំណងប្រាថ្នាសំខាន់គឺ ចង់បានសេចក្តីយុត្តិធម៌។ តែនៅក្នុងរឿងថៅកែចិត្តចោររបស់ លោកអ៊ុំ ឈឺន និងពៅ យូឡេង តួអង្គថៅកែបែរជាពោលថា" យុត្តិធម៌របស់ជនមួយក្រុម ខុសពីយុត្តិធម៌របស់ជនមួយក្រុមទៀត" ទៅវិញ។

តើតាមសម្តីរបស់តួអង្គថៅចង់មានន័យដូចម្តេច?

ជាបឋម ដើម្បីបានជាប្រទីបសម្រាប់ស្រាយបំភ្លឺប្រធានឱ្យបានច្បាស់ក្នុងការបកស្រាយទស្សនៈរបស់ប្រធានខាងលើ យើងគួរស្វែងយល់ន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ ពាក្យ"យុត្តិធម៌" សំដៅលើភាពសុចរិតត្រឹមត្រូវឬទៀងត្រង់ មិនលំអៀង ត្រឹមត្រូវស្របច្បាប់ របស់សង្គម ។ចំណែកឯពាក្យពាក្យ"ក្រុម" មានន័យថាជាចង្កោម ហ្វូង ឬពួកដែលមានឧត្តមគតិ និងបំណងប្រាថ្នាក្នុងផលប្រយោជន៍រួមដូចគ្នា។ តាមន័យប្រធានខាងលើ ចង់មានន័យថា ការយល់ឃើញនូវភាពសុចរិត ទៀងត្រង់ របស់មនុស្សមួយពួក គឺវាខុសនឹងភាពសុចរិតទៀងត្រង់របស់មនុស្សមួយពួកទៀត។

យ៉ាងណាមិញ ថៅកែជាមនុស្សដែលស្គាល់យ៉ាងច្បាស់អំពីរបត់នៃការរស់នៅក្នុងសង្គម គឺគាត់ ចេះយ៉ាងច្បាស់ល្បិចរកស៊ី ធ្វើអាជីវកម្ម ហើយដឹងយ៉ាងច្បាស់ថាមនុស្សម្នាក់ៗមានឧត្តមគតិ ការយល់ឃើញខុសៗគ្នាឬទៅតាមលក្ខណៈស្ថានភាពដែលគេរស់នៅ ទើបគាត់ ហ៊ានពោលអះអាងបែបនេះ។ មិនតែប៉ុណ្ណោះមនុស្សទូទៅតែងចង់បានប្រយោជន៍ពីទង្វើរបស់ខ្លួនដូចៗគ្នា ប៉ុន្តែអ្វីដែលខុសគ្នានោះ គឺផលប្រយោជន៍ត្រូវយកទៅបម្រើឱ្យគោលដៅជីវិតផ្សេងពីគ្នាប៉ុណ្ណោះ។ ម៉្យាងទៀត គាត់ យល់ទៀតថាមនុស្សរស់នៅក្នុងវង្សត្រកូល ឬវណ្ណៈណា តែងមានទស្សនៈ លំអៀង ឬនិន្នាការការងារទៅរកផលប្រយោជន៍របស់វណ្ណៈ របស់ខ្លួនជាក់ជាពុំខានឡើយ។នៅក្នុងន័យនេះយើងអាចនិយាយបានថាទស្សនៈពីជីវិតរបស់ពួកមូលធន តែងតែខុសនឹងទស្សនៈពីជីវិតរបស់វណ្ណៈកសិករ កម្មករ។ដូច្នេះទស្សនៈលើផលប្រយោជន៍របស់វណ្ណៈទាំងពីរនេះក៏មិនមានសភាពដូចគ្នាដែរ។ បញ្ហាទំនាស់នៃគំនិតរបស់ក្រុមទាំងពីរនេះ គឺគេ ឱ្យនិយមន័យយុត្តិធម៌ផ្សេងពីគ្នា។ ក្រុមថៅកែៗយល់ថា ក្នុងសង្គមការកែងប្រវ័ញ្ច បោកបញ្ឆោតរវាងមនុស្សនិងមនុស្ស គឺជាសេចក្តីធម្មតានៃជីវិតអ្នកមានអំនាច បុណ្យសក្តិ លុយកាក តែងបង្កើតឱកាសរបស់ខ្លួន ដើម្បីកងចំណេញផលប្រយោជន៍ពីអ្នកក្រីក្រ តូចតាចជាងខ្លួន។ អ្នកធំត្រូវកេងបន្លំ សង្កត់លើអ្នកតូច ដែលនេះរឿងដ៏សាមញ្ញៗនៃសង្គម។ លើសពីនេះទៀតយុត្តិធម៌សម្រាប់ថៅកែគឺត្រូវតែទទួលបានប្រាក់ចំនេញច្រើនៗលើសគេ ព្រោះគេ ជាអ្នកបង្កើតឱកាសឱ្យកម្មករ គេជាមេគំនិត ជាអ្នកមានដើមទុន ជាម្ចាស់រោងចក្រ សហគ្រាស ជាអ្នកគ្រប់គ្រង ទទួលខុសត្រូវ។រីឯកម្មកវិញ គ្រាន់តែចាំប្រតិបត្តិការតាមបទបញ្ជា

និងចាំតែប្រើកម្លាំងកាយបំពេញការងារឱ្យបានល្អក្នុងសហគ្រាស រោងចក្រ បានហើយ។ ទាំងអស់នេះហើយ គឺជាសច្ចៈភាពនៃភាពសុចរិត យុត្តិធម៌ របស់វណ្ណៈមូលធន នាយទុន ថៅកែដែលតែងតែប្រកាន់យកកន្លងមក។ផ្ទុយពីទស្សនៈនេះចំពោះទស្សនៈរបស់មនុស្សមួយក្រុមទៀតដែលក្នុងវណ្ណៈកម្មករក្រីក្រ ចាំតែប្រើប្រាស់កម្លាំងកាយជាមធ្យោបាយធ្វើការងារ ដើម្បីប្តូរយកប្រាក់មកចិញ្ចឹមក្រពះនោះ គេពុំបានយល់ដូចមនុស្សក្នុងវណ្ណៈមូលធនទេ។ សេចក្តីពិតនៃពាក្យយុត្តិធម៌សម្រាប់ពួកគេ គឺត្រូវទាមទារឱ្យបាននូវប្រាក់កម្រៃច្រើនពីការងារដែលគេបានបំពេញ ព្រោះរាល់សមទ្ធិផល និងផលប្រយោជន៍ ដែលថៅកែមានទាំងអស់នេះ សុទ្ធតែកើតចេញពីញើសឈាមរបស់ពួកគេ។ ហើយបើគ្មានពួកគេយកញើសឈាមទៅប្តូរទេនោះ រោងចក្រសហគ្រាសទាំងមូលនិងមិនដំណើរការទៅមុខបានឡើយ។ បើរោងចក្រមិនដំណើរការថៅកែក៏មិនទទួលបានផលចំនេញដែរ ដូច្នេះថៅកែត្រូវតែលើកទឹកចិត្ត និងផ្តល់ឱ្យពួកគេនូវប្រាក់បៀវត្សដ៏សមរម្យស្របតាមកម្លាំងពលកម្ម និងតម្រូវការផ្សេងៗដែលគេ ចង់បានទើបជាការត្រឹមត្រូវ។ ពួកគេ និយាយថាការដែលថៅកែនិយាយដូចខាងលើនេះ គឺពុំមានសច្ចៈភាពទាល់តែសោះនៅក្នុងតម្លៃការងារ ព្រោះការពោលនេះវា គ្រាន់តែជាលេសសម្រាប់ការពារផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ។ ធាតុពិតជាក់ស្តែងបំផុត គឺពួកកម្មករទៅវិញទេដែលត្រូវទទួលបានផលប្រយោជន៍ច្រើនពីថៅកែទើបសក្តិសមបំផុត។

សរុបសេចក្តីមក តាមទស្សនៈសត្យានុម័តយើងអាច និយាយបានថា ទោះបីមនុស្សយល់ពីយុត្តិធម៌យ៉ាងណាក៏ដោយ គឺយុត្តិធម៌នេះមានរូបរាងតែមួយប៉ុណ្ណោះដែលបម្រើអោយផលប្រយោជន៍មនុស្សទូទៅ គ្រប់ស្រទាប់វណ្ណៈឥតមានការរើសអើស។ ការដែលសំខាន់បំផុតនោះគឺវា ត្រូវតែប្រកបដោយសីលធម៌ មិនលំអៀង ស្របតាមគតិ យុត្តិធម៌មានសច្ចភាព ទើបអាចជាយុត្តិធម៌មួយដ៏មានតម្លៃប្រកាន់យកបាន។

ឆ្លងកាត់តាមការបកស្រាយ ទស្សនៈរបស់ថៅកែខាងលើនេះយើងអាចសន្និដ្ឋានបានថា នៅមានការខ្វះចន្លោះជាច្រើនដោយពុំមាននូវអំណះអំណាងហេតុផលត្រឹមត្រូវនោះទេ ពោលគឺគ្មានសច្ចភាពនេះឯង។ ជាពិសេសវាពុំមានជាទស្សនៈដែលមនុស្សទូទៅចង់បាននោះឡើយ។ អាស្រ័យហេតុនេះយើងម្នាក់ៗ ជាកោសិកាសំខាន់របស់សង្គមជាអ្នកទ្រទ្រង់សង្គមនោះយើង គប្បីត្រូវតស៊ូជំនះនៅរាល់ឧបសគ្គប្រកបដោយភាពវាងវៃ ធ្វើយ៉ាងណាដើម្បីរៀបចំកសាងនូវយុត្តិធម៌មួយដែលមានលក្ខណៈវិនិច្ឆ័យត្រឹមត្រូវច្បាស់លាស់ប្រកបដោយការគោរពសិទ្ធិនិងប្រជាធិបតេយ្យទើបអាចជួយឱ្យសង្គមជាតិមានយុត្តិធម៌ពិតៗនិងអភិវឌ្ឍន៍ជានិរន្តន៍បាន។

ប្រធានទី៣៤ ៖ នៅក្នុងរឿងកុលាបប៉ៃលិន ចៅចិត្រញញឹមញញែមហើយជម្រាបទៅលោកគ្រូពេទ្យថា “ ខ្ញុំ បានទទួលអត់ធនសេចក្តីលំបាកគ្រប់យ៉ាងបានទាំងអស់ សូមឱ្យតែមានការងារធ្វើនិងគេចុះ...”។ ចូរពន្យល់គំនិតខាងលើ ដោយបញ្ជាក់ពីតម្លៃអប់រំនៃអត្ថបទប្រលោមលើកនេះ។(ប្រឡងគ្រូមធ្យមសិក្សា ឆ្នាំ ២០០៤ ឯកទេសទី២) (ប្រឡងគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ២០០៤)។

សេចក្តីអធិប្បាយ

ក្រោយពីតាចឹមបានទទួលអនិច្ចកម្មទៅគេ ឃើញចៅចិត្របានរស់នៅក្នុងគេហដ្ឋានតែម្នាក់ឯង ពោរពេញទៅដោយសេចក្តីទុក្ខព្រួយ និងភាពឯកោជាពន់ប្រមាណ ដោយសារតែសេចក្តីនឹករឭកដល់ឪពុកផង និងព្រួយប្រារម្ភពីវាសនាការងាររបស់ខ្លួនផង។ ដោយក្តីរាប់អាននិងអាណិតអាសូរផងនោះ លោកគ្រូពេទ្យស្អាតរតន:សម្បត្តិនៅឯបប៉ៃលិនឱ្យទៅធ្វើជាកម្មករត្បូងរបស់លោកហ្លួងរតន:សម្បត្តិនៅប៉ៃលិន។ ដោយទទួលបាននូវការជួយជ្រោមជ្រែងនេះ ចៅចិត្រមានចិត្តរីករាយយ៉ាងខ្លាំង ហើយបានពោលជម្រាបទលោកដោយក្តីរំភើបថា” ខ្ញុំ បាទទទួលអត់ធន់សេចក្តីលំបាកគ្រប់យ៉ាងបានទាំងអស់ សូមឱ្យតែមានការងារធ្វើនឹងគេចុះ...”។

តើតាមសម្តីនេះបានបង្កប់នូវខ្លឹមសារអប់រំ និងលាតត្រដាងពីគុណសម្បត្តិចៅចិត្រយ៉ាងដូចម្តេចខ្លះ?

មុននឹងធ្វើការបកស្រាយប្រធានបទខាងលើឱ្យបានក្បោះក្បាយនឹងស៊ីជម្រៅនោះ យើង ត្រូវគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះមួយចំនួនរបស់ប្រធានជាមុនសិន។ ពាក្យ”ភាពអត់ធន់” គឺជាក្តីតស៊ូព្យាយាមនឹងទ្រាំទ្រនូវក្តីលំបាកគ្រប់យ៉ាងពុំខ្លាចនឿយហត់។ រីឯ”ការងារ” គឺសំដៅទៅលើអាជីព ឬមុខរបរសម្រាប់ចិញ្ចឹមជីវិតដោយមធ្យោបាយផ្សេងៗ ទៅតាមប្រភេទនៃចំណង់ចំណូលចិត្តឬសមត្ថភាពរបស់បុគ្គលម្នាក់ៗ។ ដូច្នេះតាមសម្តីរបស់ចៅចិត្រ ការងារដែលលំបាកតម្រូវឱ្យចៅចិត្រស៊ូទ្រាំក្នុងការបំពេញការងារ ការបំពេញការងារ សម្តៅលើការងារជាកម្មករត្បូងនៅឯបប៉ៃលិនរបស់លោករតន:សម្បត្តិនេះឯង។

យ៉ាងណាមិញ ការដែលចៅចិត្រមានទំនុកចិត្តហ៊ានពោលរាប់រងរាល់ការងារលំបាកបាន ដោយសារតែខ្លួនគេបានយល់យ៉ាងច្បាស់ថា ដើម្បីរស់នៅប្រកបដោយភាពសុខសាន្តបានមនុស្សចាំបាច់ត្រូវតែមានការងារធ្វើណាមួយសម្រាប់ទ្រទ្រង់ជីវិតរបស់ខ្លួន។ លើសពីនេះទៅទៀត ការងារ អាចធ្វើឱ្យមនុស្សរស់នៅបានដោយមានគ្រឿងហូបចុកគ្រប់គ្រាន់ សម្លៀកបំពាក់ ជម្រកសមរម្យ និងញាតិ មិត្តភក្តិពឹងពាក់។ ម្យ៉ាងទៀតការងារសុចរិតធ្វើឱ្យមនុស្សរស់នៅ ដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរជាដរាប។ ដើម្បីទទួលបានប្រយោជន៍ទាំងនេះពីការងារ មនុស្សត្រូវមានភាពជឿជាក់លើសមត្ថភាព ចេះអត់ធន់ ដំនះនូវរាល់ឧបសគគគ្រប់យ៉ាងចំពោះមុខ និងមានឆន្ទៈប្តូរផ្តាច់ដោយឥតងាករេឬរាថយ ទើបទទួលបានលទ្ធផលល្អ។ តួយ៉ាងដូចជា តួអង្គចៅចិត្រ ក្រោយពីបានទទួលការអនុញ្ញាតពីលោករតន:សម្បត្តិឱ្យធ្វើជាកម្មករត្បូងមក គេបានខិតខំធ្វើការយ៉ាងអស់ពីកម្លាំងកាយចិត្ត ពុំខ្លាចនឿយហត់ និងពុំមានការរើសអើងចំពោះការងារឡើយ។ គេយល់ពីតម្លៃការងារ គឺគ្មានការងារណាដែលថោកទាបឡើយ វៀរលែងតែជាការងារបោកប្រាស់ចាក់នូវសីលធម៌ និងគន្លងច្បាប់។ គេពុំដែលនិកគួចចិត្តថាការងារដែលធ្វើជាកម្មកររនេះ គឺពុំសមទៅនឹងសមត្ថភាពចំណេះដឹងខ្លួនឡើយ ទោះបីជារៀនសូត្របាន ជាប់ប្រកាសនីយបត្រក៏ដោយ។ គេថែមទាំងពេញចិត្ត ហើយប្រឹងប្រែងបំពេញការងារបន្ថែមពុំប្រកាន់ខ្លួន

ឡើយ ដូចជាសុខចិត្តធ្វើជាអ្នកយួរឥវ៉ាន់នៅពេលទៅផ្សារជាមួយ និងឃុននារីជាដើ-ម។ កត្តាដែលសំខាន់គឺគេមានមនសិការក្នុងការងារ និងពោពេញដោយជំនឿជាក់លើសមត្ថភាពខ្លួនដូចដែលគេបានពោលទៅកាន់នាងឃុននារីថា"ខ្លួនខ្ញុំស្គមមែនពិតប៉ុន្តែអ្នកដទៃធ្វើបានយ៉ាងណា ខ្ញុំក៏អាចធ្វើបានយ៉ាងនោះដែរ គ្រាន់តែរូបកាយពុំសូវមានសាច់ឈាមបរិបូរណ៌ដូចគេទេតើ"។ដោ-យមនសិការ និងការប្រឹងប្រែងក្នុងការងារគេត្រូវបានក្រុមកម្មករគ្រប់ៗគ្នា និងលោកតេន:សម្បត្តិស្រឡាញ់រាប់អាននិងេជឿជាក់រហូតឡើងហាន:បន្តបន្ទាប់ទៀតផង។ ទាំងនេះដោយពិចារណាឃើញថាការមានការងារធ្វើទើបប្រសើរ ព្រោះថាជីវិតដែលឥតការងារធ្វើអាចធ្វើឱ្យខ្លួន អាចភ្លាត់ធ្លាក់ចូលក្នុងផ្លូវអបាយមុខ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្សហើយពុំអាចធ្វើឱ្យជីវិតបានប្រសើរឡើយ។ គេ គិតទៀតថាត្រូវតែពឹងលើកម្លាំងខ្លួនឯង មិនត្រូវរស់នៅក្នុងស្ថានភាពជាមនុស្សបញ្ឆើរក្អែករង់ចាំការទ្រទ្រង់ពីអ្នកដទៃឡើយ។ ហើយគេក៏យល់ច្បាស់ពីលក្ខខណ្ឌចាំបាច់នៃជីវិត និងឱ្យតម្លៃខ្ពស់ចំពោះការងារព្រោះវាបានទ្រទ្រង់សព្វបែបយ៉ាងដែលជាតម្រូវការរបស់មនុស្ស។ មនុស្សមានការធ្វើងារធ្វើទើបធ្វើឱ្យសេដ្ឋកិច្ចគ្រួសារីកចម្រើន និងជួយសង្គមឱ្យអភិវឌ្ឍបាន។ បន្ថែមពីទៅទៀត ឧត្តមគតិរបស់ ចៅចិត្រ បានឆ្លុះបញ្ចាំងឱ្យមនុស្សគ្រប់រូបពិសេសយុវជនឃើញថា ប្រទេសយើងសំបូរដោយកោគទ្រព្យដ៏មានតម្លៃជាច្រើនដែលត្រូវការកម្លាំងពលកម្មរបស់យុវជនយើងមកប្រើប្រាស់ដើម្បីទាញយកផលពីវា។ ដូច្នេះយុវជនគួរកុំមានការប្រកាន់ខ្លួនចំពោះការងារ ហើយកុំសម្លឹងឃើញ និងឱ្យតម្លៃតែលើការងារក្នុងការិយាល័យតែមួយមុខនោះសំខាន់ត្រូវយល់ថាការងារសុចរិតដែលមនុស្សធ្វើសុទ្ធតែមានតម្លៃដូចៗគ្នាទាំងអស់។ ជានេះទៅទៀតត្រូវដឹងថាការបំពេញការងារនីមួយៗត្រូវតែស្មោះត្រង់ និងជឿជាក់លើសមត្ថភាពខ្លួនត្រូវមានក្តីអត់ធ្មត់ ជំនះនូវាល់គ្រប់ឧបសគ្គដោយអង់អាចក្លាហាន និងត្រូវមានសាមគ្គីភាពរវាងគ្នា និងគ្នាទើបអាចឈានដល់ការសម្រេចនូវជោគជ័យបាន។ ដោយឡែកការជ្រើសរើសគូជីវិតវិញ យុវជនចាំបាច់ ត្រូវចេះប្រើប្រាស់ពេលវេលាដើម្បីសង្កេតសិក្សាពីគ្នាទៅវិញទៅមក ទើបធ្វើការសម្រេចចិត្តនោះអាចចៀសផុតពីកំហុសឆ្គង និងវិប្បដិសារី ដូចដែលតួអង្គចៅចិត្រ និងនាងឃុននារី បានប្រព្រឹត្តិមកនេះទើបប្រពៃ ព្រោះថាការជ្រើសរើសគូអនាគតបើខុសម្តង គឺខុសមួយជីវិត។ចំណែកឯបទពិសោធន៍ខាងចំណេះវិជ្ជាតាមរយៈរឿងនេះ ចង់បង្ហាញដល់យុវជនឱ្យចងចាំថាឱ្យជាក់ ថាទាំងចំណេះដឹងដែលបានមកពីសាលាក្តី ពីការប្រតិបត្តិខាងក្រៅសាលាក្តី ចាំបាច់ត្រូវចេះផ្សៃផ្សំរួមច្របាច់ចូលគ្នា និងចេះយកទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមកាល:ទេស:ទើបអាចដឹងនាំជីវិតឱ្យឆ្ពោះទៅរកសុខសុភមង្គលក្នុងជីវិតបាន។

សរុបមកសម្តីដែលចៅចិត្របានពោលខាងលើ គឺចង់បញ្ជាក់យ៉ាងច្បាស់នូវទឹកចិត្តក្នុងនាមជាយុវជនមួយរូបដែលមានចំណេះដឹងខ្ពង់ខ្ពស់ប្រកបដោយគំនិតជឿនលឿនក្នុងការឱ្យតម្លៃលើការងារ។មានការងារធ្វើគឺធ្វើឱ្យមនុស្សរស់ធ្វើឱ្យមនុស្សមានសីលធម៌ និងសេចក្តីថ្លៃថ្នូរ ហើយធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់និងរីកចម្រើន។

ឆ្លងតាមការបកស្រាយរួចមក យើងអាចសន្និដ្ឋានប្រធានបានថា ទស្សន:ចៅចិត្រ គឺពិតជាគតិប្រសើរបំផុតសម្រាប់យុវ័យយើង ប្រកាន់យក។ ដូច្នេះក្នុងនាមយើងកុលបុត្រជំនាន់ក្រោយ ត្រូវមានស្មារតី និងឆន្ទ:ដូចតួអង្គនេះទើបអាចជួយខ្លួនឯងឱ្យមានកិត្តិយស កាត់បន្ថយភាពរើសអើងការងារ កាត់បន្ថយភាពគ្មានការងារធ្វើ ដែលធ្វើឱ្យជីវិតងាយផុងខ្លួនចូលជ្រៅក្នុងអបាយមុខ ជាពិសេសអាចជួយឱ្យគ្រួសារ និងសង្គម មានការីកចម្រើនលូតលាស់ទៅមុខបានជានិច្ច។

ប្រធានទី៣៥៖ សមបាននិយាយថា" កុំឱ្យលុយ៥០០ខ្ញុំបាទធ្វើអ្វីទានប្រោស សុំតែជួយរកមុខរមរឱ្យខ្ញុំបាទបានធ្វើវិញទៅល្អជាង"។ ចូរពន្យល់ និងលើកឧទាហរណ៍មកបញ្ជាក់ឱ្យបានក្បោះក្បាយ។ (ប្រឡងគ្រូបឋម និងមត្តេយ្យសិក្សា ២០០៤)(ប្រឡងគ្រូមធ្យមសិក្សា ២០១៨)។

សេចក្តីអធិប្បាយ

នៅក្នុងអក្សរសិល្ប៍ខ្មែររឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ គឺជាស្នាដៃនិពន្ធរបស់លោក សួន សុរិន្ទ ដែលបានទទួលជ័យលេកីឥន្ទ្រទេវីនៅឆ្នាំ មួយពាន់ប្រាំបួនរយហុកសិប ដល់មួយពាន់ប្រាំបួនរយហុកសិបមួយ។ តាមរយៈដំណើររឿងសមមានជីវិតរស់នៅក្នុងស្ថានភាពត្រដាបត្រដួសជីវភាពក្រីក្រ ម្តាយឪពុកស្លាប់ និងប្រពន្ធស្លាប់ចោលទៀត។ប៉ុន្តែនៅក្នុងវគ្គទីដប់ប្រាំមួយ ដែលមានចំណងជើងថា"ទីពឹងថ្មី" យើងសង្កេតឃើញថាតួអង្គសមត្រូវរថយន្តរបស់លោករដ្ឋមន្ត្រីក្មេងបានបុកសមបណ្តាលឱ្យសមរងស្រាល។ ក្រោយឧប្បត្តវហេតុ សមតួអង្គ និងលោករដ្ឋមន្ត្រីក្មេងបានសន្ទនាគ្នាចុះឡើងតាមដំណើររឿង។ សមបានពោលទៅកាន់លោករដ្ឋមន្ត្រីក្មេងថា" កុំឱ្យលុយ៥០០ខ្ញុំបាទធ្វើអ្វី...សុំជួយតែរកមុខរបរឱ្យខ្ញុំបាទបានធ្វើវិញទៅល្អជាង"។

តើពាក្យសម្តីសមនិយាយទៅលោករដ្ឋមន្ត្រីមានន័យយ៉ាងដូចម្តេច?

មុននឹងឈានដល់ការបកស្រាយពាក្យសំដីខាងលើ យើងគប្បីស្វែងយល់ន័យនៃពាក្យមួយចំនួនសិន។ ពាក្យថា" ការងារ" មានន័យថា មុខរបរដែលអាចទ្រទ្រង់ជីវិតមនុស្សបាន។ ចំណែកឯពាក្យ"ប្រាក់" មានន័យថាលុយរបស់ដែលគេអាចចាយវាយបាន។តាមរយៈន័យនៃពាក្យទាំងនេះប្រធានចង់បញ្ជាក់សម្តីរបស់សមថា" កុំឱ្យលុយ៥០០រៀល មកខ្ញុំបាទធ្វើអ្វី សុំជួយតែរករបរឱ្យខ្ញុំបាទវិញប្រសើរជាង"។

តួយ៉ាង យើងបានដឹងហើយថា មុនពេលទទួលរងគ្រោះថ្នាក់ចរាចរណ៍ដោយសាររថយន្តរបស់លោករដ្ឋមន្ត្រីក្មេងបុកមក សមទើបនឹងចេញពីគុកប៉ុណ្ណោះ។ ក្នុងស្ថានភាពនេះសម មិនមានប្រាក់កាស់ចាយវាយ ឬការងារអ្វីធ្វើជាធំដុំឡើយ។ ប៉ុន្តែនៅពេលលោករដ្ឋមន្ត្រីក្មេងឱ្យប្រាក់ទៅសមចំនួន៥០០រៀលសមបែរជាមិនព្រមទទួលយក បែរជាចង់បានការងារធ្វើទៅវិញ។ ទង្វើរបស់សមបែបនេះគឺចង់សបញ្ជាក់ឱ្យឃើញថា មានការគិតបានវែងឆ្ងាយ។ សមយល់ថាប្រាក់៥០០រៀល បើចាយបានត្រឹមមួយភ្លែតអស់ទៅវិញហើយ បន្ទាប់មកគាត់នៅតែក្រលំបាកដដែល។ គាត់ គិតច្បាស់ថាមានតែការងារតែមួយគត់ដែលអាចជួយសម្រេចឱ្យរួចចាកផុតពីសេចក្តីលំបាកវេទនាទាំងឡាយបាន។ បើមានការងារធ្វើគាត់មានជីវភាពប្រសើរជាងប្រាក់៥០០រៀលម្ល៉ោះហើយទើបបានជាគាត់ មិនព្រមទទួលយកលុយ។ លើសពីនេះទៀតសមក៏បានគិតទៀតថា ជីវិតមនុស្សមានតម្លៃ រុងរឿងទៅបានគឺអាស្រ័យដោយមានការងារធ្វើនេះឯង។ ម្យ៉ាងទៀតក្នុងខណៈពេលនោះជាពេលដែលប្រសើរបំផុត ព្រោះសមបានជួបមនុស្សដែលគិតថាអាចជួយខ្លួនបានគឺ លើករដ្ឋមន្ត្រីក្មេងជាហេតុញុំាងឱ្យចិត្តរបស់សមមិនអោយទទួលយកប្រាក់៥០០រៀលនោះឡើយ។ ជាក់ស្តែងក្រោយពីទទួលបានការងារធ្វើហើយនោះសមបានក្លាយជាមានជីវភាពប្រសើរជាងមុន រស់នៅក្នុងភាពសុខសាន្តក្រោមដំបូលផ្ទះរបស់លោករដ្ឋមន្ត្រីក្មេង។ ក្រោយមកទៀត គាត់ក៏បានវិលត្រឡប់ទៅកាន់ស្រុកកំណើត ទៅកសាងជីវភាពជាកសិករតាមគោលនយោបាយរបស់សម្តេចតា បិតាកសិកម្មនៃយើង។ ដោយសារសេចក្តីព្យាយាមធ្វើការងារ សមទទួលបានការគោរពស្រឡាញ់ពីប្រជាពលរដ្ឋនៅក្នុងភូមិ រហូតបានបោះឆ្នោតជ្រើសរើសសមជាតំណាងឃុំទៀតផង។ ក្រោយទទួលបាននាទីជាតំណាងឃុំមកសមបានដោះស្រាយបញ្ហានានាជាច្រើនតាមគោលនយោបាយរបស់សម្តេចឪ។ជីវភាពរបស់ប្រជាជនក្នុងភូមិមានប្រសើរ

ឡើងពីមួយថ្ងៃទៅមួយ។ផ្ទុយពីការគិតខាងលើ សមបានគិតទៀតថា ប្រសិនបើខ្លួនគ្មានការងារធ្វើនោះទេ ខ្លួននឹងមិនអាចគេចផុតពីគ្រោះកំណាចបាននោះឡើយ។បើយើងពិនិត្យមើលស្ថានភាពមនុស្សគ្មានការងារក្នុងសង្គមមនុស្សជាក់ស្តែង យើងឃើញថា មនុស្សម្នាក់ៗដែលគ្មានការងារធ្វើ គឺជាមនុស្សតែលតោល គ្មានតម្លៃសម្រាប់សង្គម ប្រព្រឹត្តអំពើពាលផ្សេងៗ និងជីវិតរកថ្ងៃប្រសើរឡើងមិនរួចឡើយ តែកាលណាសង្គមមនុស្សមួយមានមនុស្សគ្មានការងារធ្វើកាន់តែច្រើនប្រទេសនោះក៏មិនអាចឈានទៅរកការរីកចម្រើនបានដែរ។

សរុបសេចក្តីមក សមជ្រើសរើសយកការងារធ្វើ គឺមានន័យថាសមបានជ្រើសរើសយកសេចក្តីថ្លៃថ្នូររបស់ខ្លួន។ នេះដោយសមយល់ថាទទួលយកត្រីមួយមកស៊ី វាមិនប្រសើរចេះស្ទូចត្រីរហូតនោះទេ។

ឆ្លងកាត់តាមការបកស្រាយសម្តីរបស់សមខាងលើនេះ ពាក្យសម្តីរបស់សមពិតជាមានអត្ថន័យប្រសើរក្រៃលែង ព្រោះបានអប់រំមនុស្សឱ្យចេះគិតគូឱ្យបានវែងឆ្ងាយ កុំចង់បានប្រយោជន៍ដែលមានរយៈពេលខ្លី គួរណាស់យករបស់ឬអ្វីមួយដែលមានប្រយោជន៍យូរវែងឆ្ងាយ ដែលមានតួអង្គសមជាតឹកតាងស្រាច់។ គួរណាស់គិតគួរកការងារធ្វើសម្រាប់ជីវិតមួយទើបប្រសើរ។ ដូច្នេះក្នុងនាមយើងជាកូនខ្មែរជំនាន់ក្រោយ គួរគប្បីយកគំនិតរបស់សមមកពិចារណាដើម្បីជាគតិក្នុងការងារដឹងនាំខ្លួនឆ្ពោះទៅកាន់ទីប្រសើរ និងរុងរឿង។

ប្រធានទី៣៦៖ តួអង្គគឺជាអ្នកបង្កទំនាស់នៅក្នុងសាច់រឿង។ ចូរលើកយកទំនាស់ក្រៅខ្លួន និងទំនាស់ក្នុងខ្លួនរបស់តួអង្គ ហំនៅក្នុងរឿងថៅកែចិត្រចោរមកបកស្រាយពន្យល់ឱ្យបានក្បោះក្បាយ។ (ប្រឡងជ្រើសរើសគ្រូ មធ្យមសិក្សា ឆ្នាំ ២០០៥)។

សេចក្តីអធិប្បាយ

អក្សរសិល្ប៍ មានតួនាទីឆ្លុះបញ្ចាំងឱ្យយើងបានឃើញពិតថភាពនៃការរស់នៅរបស់មនុស្សក្នុងសង្គម។ អក្សរសិល្ប៍ សិក្សាពីមនុស្ស លើកយកបញ្ហារបស់មនុស្សមកចោទ និងដោះស្រាយទៅតាមវិធីសាស្ត្ររបស់អ្នកនិពន្ធ។ ដោយយល់ឃើញថាអក្សរមានតួនាទីបែបនេះ ទើបបានលេចចេញនៅទំនាស់រវាងថៅកែនិងពូហំ ដែលអាចឱ្យយើងមើលឃើញ និងសន្និដ្ឋានបានយ៉ាងច្បាស់ថា ទំនាស់ទាំងនេះចែកចេញជាពីរគឺទំនាស់នៅក្នុងខ្លួន និងទំនាស់ក្រៅខ្លួន។

តើទំនាស់ក្នុងខ្លួន និងទំនាស់ក្រៅខ្លួនក្នុងរឿងនេះមានលក្ខណៈយ៉ាងណាខ្លះ?

ដើម្បីអាចធ្វើការបកស្រាយឱ្យមានភាពស៊ីជម្រៅទៅលើទស្សនៈរបស់ប្រធាន យើងគប្បីស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ ពាក្យ"ទំនាស់ក្រៅខ្លួន" គឺជាការប្រឆាំងឬប្រឈមដាក់គ្នារវាងតួអង្គមួយទៅនឹងតួអង្គមួយទៀត ឬជាមួយបញ្ហាផ្សេងៗទៀតដែលខ្លួនត្រូវប្រឈម ក្រៅពីសភាពជាមនុស្សដូចជាបញ្ហាជីវភាព អាកាធាតុ ការលំបាកក្នុងការងារចិញ្ចឹមជីវិតជាដើម។ រីឯ
"ទំនាស់ក្នុងខ្លួន" គឺជាបញ្ហាដែលកើតឡើងក្នុងខ្លួនផ្ទាល់របស់តួអង្គ ជាទំនាស់រវាងមនោសញ្ចេតនា ចិត្ត អារម្មណ៍នឹងខ្លួនឯងផ្ទាល់ ឬអាចនិយាយបានថាតួអង្គនោះមានកម្លាំងទឹកចិត្តផ្សេងគ្នាពីរឬច្រើនប្រឆាំងគ្នា។ គេអាចនិយាយបានថា ជាទំនាស់រវាងអញនិងអញ។ តាមការពន្យល់ពាក្យទាំងនេះរួចមក ន័យប្រធានចង់មានន័យថា នៅក្នុងសាច់រឿងទាំងមូលអាស្រ័យដោយមានទស្សនៈ ផ្ទុយគ្នា ឬផលប្រយោជន៍មិនដូចគ្នា ជាហេតុធ្វើឱ្យតួអង្គប្រឈមមុខដាក់គ្នា ដើម្បីសម្រេចបំណងរៀងៗខ្លួន។ ជួនកាលសូម្បីតែខ្លួនឯងផ្ទាល់ក៏មានចិត្តពីរដែលមិនស្របគ្នាហើយត្រូវប្រឆាំងដាក់គ្នាដែរ។

តួយ៉ាង តាមរយៈរឿងដោយភាពប៉ិនប្រសប់ក្នុងការតែនិពន្ធប្រកបដោយសីល្បវិធីអ្នកនិពន្ធបានលើកយកទំនាស់ផ្សេងៗជាច្រើនមកបង្ហាញជាមូលន័យរបស់រឿង។ ក្នុងនោះផងដែរទំនាស់ក្រៅខ្លួនមានដូចជា ទំនាស់រវាងពូហំ និងថៅកែ ដោយសារតែការមិនគោរពនៅពាក្យសត្យរបស់ថៅកែ បង្កឱ្យមានបញ្ហាបន្តបន្ទាប់ រហូតដល់មានការជជែកគ្នាខ្លាំងៗជាមួយពូហំទៀតផង។ ទំនាស់នេះកើតឡើងដោយសារតែការទាមទារប្រាក់រង្វាន់ដែលបន្ទាប់ពីបានប្រព្រឹត្តិអំពើទុចរិត គឺបានបង្កឱ្យមានគ្រោះថ្នាក់រថយន្តបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស តាមបញ្ជារបស់ថៅកែពីសំណាក់ពូហំ។ ដោយសារតែបញ្ហានេះហើយទើបធ្វើឱ្យពូហំឆ្អែតចិត្តលែងជឿលើថៅកែហើយព្យាយាមបកអាក្រាតពីមុខមាត់នៃទង្វើអាក្រក់របស់ថៅកែដោយគ្មានខ្លាចញញើតថាខ្លួនត្រូវមានទោសជាប់គុក ឬខ្លាចខូចកិត្តិយសវង្សត្រកូលលើយ ដូចដែលគាត់បាននិយាយថា" អញសុខចិត្ត ឱ្យវង្សត្រកូលអញស្លាប់ចុះដើម្បីឱ្យសេចក្តីពិតផ្ទុះឡើងរួច"ជាដើម។ ម្យ៉ាងទៀត សក្ខីភាពនៃទំនាស់មួយទៀតគឺរវាងពូហំ និងមីងយ៉ាន។ នៅពេលតាមកប្តីគាត់នៅផ្ទះរបស់ថៅកែបន្ទាប់ពីបានបាត់មិនចូលផ្ទះមួយថ្ងៃរួចមក។ ក្រោយពីដឹងរឿងគ្រោះថ្នាក់ និងជឿលើពាក្យសំដីរបស់ថៅកែ ដោយសារស្រឡាញ់ប្តី ស្រឡាញ់កិត្តិយសគ្រួសារមិនចង់ឱ្យមានឈ្មោះជាប់គុក ហើយបានណែនាំប្តីឱ្យធ្វើតាមពាក្យថៅកែ រត់គេចខ្លួន ប៉ុន្តែត្រូវបានពូហំបដិដេធ និងស្តីបន្ទោសដោយកំហឹងថា "មីនេះគំនិតខ្ញុំគេក្រាស់ណាស់ ជ្រៅណាស់..."។ ទាំងនេះដោយសារតែមីងយ៉ានមិនបានដឹងរឿងរបស់ប្តីគាត់ ។ក្រៅពីនេះគឺទំនាស់រវាង ថៅកែ ពូហំ និងពួកកម្មករ។ ដោយសារទឹកប្រាក់បង្ខំ ពូហំបានក្លាយទៅជាមនុស្សខ្វាក់បាត់បង់វិចារណញ្ញាណ លែងស្គាល់ខុសត្រូវហ៊ានប្រព្រឹត្តិអំពើល្មើសនឹងច្បាប់ ដោយឥតបានថ្លឹង

ថ្លែងអំពីលទ្ធផលរបស់វា បើទោះបីក្រុមកម្មករ បានទូន្មានគាត់កុំឱ្យទទួល ក៏ដោយក៏ពុំអាចរារាំងការសម្រេចចិត្តខុសនេះបានដែរ។

រួចសេចក្តីមក ក្នុងរឿងថៅកែចិត្តចោរ ពិតជាមានទំនាស់ក្នុងខ្លួន និងក្រៅខ្លួនប្រាកដមែន។

ឆ្លងកាត់តាមការបកស្រាយទស្សនៈប្រធានខាងលើមក ប្រធានពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញពីទំនាស់ដែលតែងកើតឡើងចំពោះមនុស្ស គឺទំនាស់ក្នុងខ្លួន និងទំនាស់ក្រៅខ្លួននេះឯង។ ដូច្នេះក្នុងនាមជាកូនខ្មែរជំនាន់ក្រោយ ក្នុងការដោះស្រាយបញ្ហាទំនាស់ណាមួយ គឺត្រូវគិតលើធម៌អហិង្សាជាធំទើបប្រសើរ។

តែងសេចក្តីអត្ថាធិប្បាយប្រធានអក្សរសាស្ត្រខ្មែរ

ប្រធានទី៣៧៖ តម្លៃអប់រំ គឺជាគំនិតដ៏ថ្លៃថ្លារបស់អ្នកនិពន្ធ។ ចូរពន្យល់តម្លៃអប់រំរបស់អ្នកនិពន្ធក្នុងរឿងថៅកែចិត្តចោរ ដែលលើកពីការភ្ញាក់ខ្លួនរបស់ពូហំ។ (វប្បធម៌ទូទៅ ប្រឡគ្រូបឋមសិក្សា និងមត្តេយ្យសិក្សា ឆ្នាំ២០០៥)។

សេចក្តីអធិប្បាយ

អក្សរសិល្ប៍ គឺជាការសិក្សាពីមនុស្ស និងលើកយកបញ្ហារបស់មនុស្សមកចោទ និងដោះស្រាយ។ មិនតែប៉ុណ្ណោះ វាបានបង្កប់និងបង្ហាញនូវតម្លៃអប់រំជាច្រើនតាមរយៈសកម្មភាពរបស់តួអង្គ។ទាំងអស់នេះគឺសុទ្ធសឹងជាគោលបំណងរបស់អ្នកនិពន្ធ ក្នុងន័យដើម្បីពន្លេចស្នាដៃរបស់ខ្លួនឱ្យបានប្រសើរឡើង មានឈ្មោះបោះសំលេង និងប្រយោជន៍សម្រាប់មនុស្សទូទៅយកទៅទូន្មានកូនចៅ។ ដោយយល់ឃើញបែបនេះហើយ បានជានៅទស្សនៈប្រធានលើកឡើងថា “ស្នាដៃអក្សរសិល្ប៍រឿងថៅកែចិត្តចោរក៏បានបង្ហាញតម្លៃអប់រំតាមរយៈតួអង្គពូហំដែរ”។

តើតម្លៃអប់រំទាំងនោះក្នុងរឿងថៅកែចិត្តចោរ ដែលស្តែងឡើងតាមរយៈតួអង្គពូហំនេះមានអ្វីខ្លះ?

ដើម្បីជាដំនួយដល់ការបកស្រាយប្រធានខាងលើ អោយបានក្បោះក្បាយ នឹងស៊ីជម្រៅ យើងគប្បីស្វែងយល់ន័យនៃពាក្យមួយចំនួនជាមុនសិន។ពាក្យ”អប់រំ” មានន័យថា ការដឹងនាំទៅរកផ្លូវល្អ ការអោយដំបូន្មាន ការប្រៀនប្រដៅ។ ចំណែក”ការក្បាក់ខ្លួន” មានន័យថា ជាការដឹងកំហុសរបស់ខ្លួន ហើយចេះកែខ្លួនវិញ។ តាមរយៈអត្ថន័យនៃពាក្យការពន្យល់ពាក្យទាំងនេះ ប្រធានចង់បញ្ជាក់ថា ការឱ្យអោយដំបូន្មាន គឺជាគំនិតដ៏ប្រសើររបស់អ្នកសរសេររឿង។

តួយ៉ាង តម្លៃអប់រំរបស់អ្នកនិពន្ធគឺជាគំនិតមួយដ៏ប្រសើរបំផុតដែលបានបង្កប់នៅក្នុងរឿងអក្សរសិល្ប៍មួយ។ យ៉ាងណាមិញ នៅក្នុងអក្សរសិល្ប៍រឿងថៅកែចិត្តចោរក៏បានបង្ហាញពីតម្លៃអប់រំរបស់អ្នកនិព-ន្ធផងដែរ។ តម្លៃអប់រំទាំងនោះគឺបានឆ្លុះបញ្ចាំងតាមរយៈតួអង្គពូហំ។តម្លៃអប់រំទីមួយគឺ បានអប់រំមនុស្សឱ្យចេះស្រឡាញ់អំពើយុត្តិធម៌ សុចរិតទៀងត្រង់ នឹងសច្ចធម៌។ តម្លៃអប់រំនេះបានបង្ហាញគឺបង្ហាញនៅពេលដែលពូហំបានបើកឡានទៅបុកឡានរបស់ថៅកែហុងលីបានសម្រេចហើយ តែបែរជាថៅកែរបស់ពូហំមិនព្រមទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឡើយ។ ចំនុចធ្វើឱ្យពូហំខឹងសម្បានឹងថៅកែជាខ្លាំង ជាហេតុនាំអោយពូហំបកអាក្រាធថៅកែវែកមុខជនល្មើសពីតប្រាកដដែលឈរពីក្រោយពូហំ។ ចំណែកតម្លៃអប់រំទីពីរ គឺអប់រំមនុស្សឱ្យមានចិត្តអង់អាចក្លាហាន ហ៊ានប្រឆាំងនឹងអំពើអយុត្តិធម៌ កែងប្រវ័ញ្ច និងជិះជាន់វណ្ណៈ។ជាក់ស្តែងការដែលពូហំវែកមុខថៅកែចិត្តចោរនេះហើយ នឹងជាសេចក្តីក្លាហានដែលគាត់មាន ហ៊ានងើបប្រឆាំងនឹងការជិះជាន់ពីថៅកែរបស់ខ្លួន។ តម្លៃអប់រំទីបី គឺបានអប់រំមនុស្សទូទៅឱ្យមានសាមគ្គីធម៌ ដើម្បីជាកម្លាំងក្នុងការបំបាក់ក្រុមជនបោកប្រាសទាំងឡាយ ។ តាមរយៈដំណើររឿង ក៏បានបង្ហាញពីសាមគ្គីធម៌នេះផងដែរ។ ជាក់ស្តែងនៅពេលថៅកែបានប្រើប្រាស់លុយដើម្បីបង្វែចិត្តរបស់មិត្តភក្តិខ្លួន ប៉ុន្តែមិត្តភក្តិរបស់ពូហំមានសុខ មាន គង់ ទ្រី មិនទទួលយកឡើយ។ ប៉ុន្តែពួកគាត់បានពួតដៃគ្នាផ្តួលរំលំអំពើអមនុស្សធម៌របស់ថៅកែឱ្យសេចក្តីសុខរបស់ខ្លួន ដើម្បីឱ្យបានសេចក្តីសុខមនុស្សក្នុងគ្រួសារទាំងមូល។ ចំណុចនេះមានបង្ហាញឡើងនៅពេលដែលពូហំបានគិតឃើញច្បាស់ថា ខ្លួនត្រូវតែលះបង់សេចក្តីសុខរបស់ខ្លួនមួយពេលដើម្បីសេចក្តីសុខរបស់ម្តាយ ប្រពន្ធ និងកូនស្រី។ ដូច្នេះគាត់ជាមនុស្សដែឡមានការលះបង់ខ្ពស់គួរឱ្យកោតសរសើរ។ តម្លៃអប់រំទីប្រាំ គឺអប់រំមនុស្សឱ្យស្អប់ខ្ពើមអំទុច្ចរិត និងអំពើពុករលួយ។ អំពើពុករលួយនេះបានស្តែងឡើងតាមរយៈតួអង្គលោកថៅកែចិត្តចោរ ដែលបានប្រើប្រាស់សូកលុយមនុស្សដុំវិញខ្លួនមានសុខ គង់ មានទ្រីជាដើមដើម្បីបានមកនៅខាងខ្លួន។ ប៉ុន្តែអំពើនេះបានកាច់បំបាក់វិញដោយពូហំជាអ្នកជាស់តឿតមិត្តភក្តិដើម្បីឱ្យដៀសផុតពីអំពើទុច្ចរិតអស់នេះ។ លើសពីនេះទៅទៀតគឺតម្លៃអប់រំទីប្រាំមួយគឺបានអប់រំមនុស្សចេះគោរពច្បាប់ និងហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួន ហើយថែមទាំងចេះកែខ្លួនទៀតផង។ ជាក់ស្តែងនៅពេលដែលពូហំបានប្រព្រឹត្តកំហុសហើយ គាត់ មមិនបាត់រត់គេចខ្លួននោះទេ តែគាត់បែរជាហ៊ានប្រឈមមុខនឹងទោសទណ្ឌរបស់គាត់ដោយមិនមានការខ្លាចអោរឡើយ។ គាត់សុខចិត្តចេញមុខទទួលកំហុសរបស់ខ្លួន នៅចំពោះក្រុមមានសមត្ថកិច្ចដោយមិនលាក់លៀម។ មិនតែប៉ុណ្ណោះគាតមានស្មារតីភ្ញាក់រឭក ដោយចេញមុខបើកកកាយមេក្លោងធំនៅពីក្រោយខ្នងនៃរឿងហេតុបើកឡានបុកឡាន

ថៅកែហុងលីនេះទៀតផង។ ចំនេះនេះពិតជាសបញ្ជាក់ឱ្យឃើញថាគាត់មានស្មារតីទទួលខុសត្រូវ ននិងមានគំនិតភ្ញាក់រឭកមែន។

សរុបសេចក្តីមក រឿងថៅកែចិត្តចោរ តាមរយៈការភ្ញាក់រឭករបស់តួអង្គពូហំ បានបង្ហាញអោយឃើញពីតម្លៃអប់រំខ្ពស់ ស្របតាមលក្ខណៈរឿងអក្សរសិល្ប៍ជឿនលឿន។ ដូច្នេះយើងត្រូវយល់ប្រធានឱ្យបានច្បាស់លាស់ហើយទាញចេញនូវតម្លៃអប់រំពីរឿងឱ្យបានត្រឹមត្រូវ។

ឆ្លងកាត់តាមរយៈការបកស្រាយពីគំនិតអប់រំខាងលើ ប្រធានពិតជាមានលក្ខណៈត្រឹមត្រូវ និងបែមទាំងមានអត្ថន័យល្អស្របតាមទ្រឹស្តីអក្សរសិល្ប៍ប្រាកដមែន។ ហេតុដូច្នេះហើយទើបបានជាគេតែងពោជាទូទៅថា “ និយាយអក្សរសិល្ប៍ គឺនិយាយពីការអប់រំ”។ ដូច្នេះក្នុងនាមយើងជាកូនចៅជំនាន់ក្រោយ ក្នុងករណីចង់តែងនិពន្ធជារឿងផ្សេងៗ ត្រូវគិតលើតម្លៃអប់រំនៃរឿងជាសំខាន់ បើទោះបីប្រើប្រាស់វិធីអប់រំតាមបែបវិជ្ជមានក្តី និតមានបែបអវិជ្ជមានក្តី។

ប្រធានទី៣៨៖ ក្នុងរឿងកុលាបប៉ៃលិន ថៅចិត្របានពោលពាក្យយ៉ាងម៉ឺងម៉ាត់ថា” មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជគុណកុំព្រួយឱ្យសោះ”។ ចូរពន្យល់គំនិតខាងលើឱ្យបានក្បោះក្បាយ។ (វប្បធម៌ទូទៅ ប្រឡងគ្រូបឋមសិក្សា និងមត្តេយ្យសិក្សា ឆ្នាំ២០០៥។)

សេចក្តីអធិប្បាយ

នៅក្នុងរឿងកុលាបប៉ៃលិន ដែលជាស្នាដៃដ៏ល្បីល្បាញរបស់អ្នកនិពន្ធ ញ៉ុក ថែម ដែលបាននិពន្ធឡើងនៅឆ្នាំ មួយពាន់ប្រាំបួនរយសាមសិបប្រាំមួយ ឬ មួយពាន់ប្រាំបួនរយសែសិបបី។ តាមរយៈដំណើររឿងបានបង្ហាញថា ក្រោយពីឪពុកបានស្លាប់ទៅចៅចិត្របានធ្លាក់ទៅក្នុងជីវភាពគ្មានទីពុំណាក់អាស្រ័យ។ ប៉ុន្តែក្រោយពីបានយកសំបុត្ររបស់គ្រូពេទ្យស្អាតទៅដល់ផ្ទះលោករតនសម្បត្តិលោកនៅតែមានមន្ទិលសង្ស័យលើសមត្ថភាពរបស់ចៅចិត្រ។ដោយហេតុនេះហើយទើបបានចៅចិត្របានពោលទៅកាន់លោករតនសម្បត្តិថា" មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទក៏គង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជគុណកុំព្រួយអោយសោះ"។

តើសំដីនេះបង្ហាញពីទឹកចិត្តរបស់ចៅចិត្រយ៉ាងដូចម្តេចខ្លះ?

ដើម្បីបានជាជំនួយដល់ការបកស្រាយទស្សនៈប្រធានខាងលើ យើងគប្បីស្វែងយល់នំយនៃពាក្យគន្លឹះមាននៅក្នុងប្រធានជាមុនសិន។ ពាក្យ"ទ្រាំ" មានន័យថាតស៊ូ អត់ធ្មត់ អំណត់។ ចំណែកពាក្យ"ម៉ឹងម៉ាត់"វិញមានន័យថា ដាច់ខាត ម៉ត់ចត់ ច្បាស់លាស់ ត្រឹមត្រូវ។ តាមការពន្យល់ពាក្យខាងលើនេះ ប្រធានចង់បង្ហាញថា សំដីរបស់ចៅចិត្រថា មនុស្សដៃទៃគេអត់ធន តស៊ូអំណត់ ធ្វើបានយ៉ាងណា ឯខ្ញុំបាក៏គង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជគុណកុំព្រួយអោយសោះ។

តួយ៉ាង ក្រោយពីចៅចិត្របានទៅដល់ប៉ៃលិន ហើយជួយលោករតនសម្បត្តិ ចៅចិត្រពិតជានិយាយយ៉ាងម៉ត់មាំថា "មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ខ្ញុំបាទក៏គង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជគុណកុំព្រួយអោយសោះ។ តាមរយៈពាក្យសំដីនេះ គឺចង់បង្ហាញអោយឃើញថា តស៊ូរាល់ការលំបាកគ្រប់បែបយ៉ាងដោយមិនមានការត្អូញត្អែរសូម្បីតិចតួចឡើយ។ លើសពីនេះទៀត សំដីនេះក៏បានបង្ហាញពីការជឿជាក់លើសមត្ថភាពរបស់ខ្លួនលើផ្នែកប្រាជ្ញានិងកាយសម្បទាទៀតផង។ ជាក់ស្តែងចៅចិត្រជាមនុស្សដែលបានរៀនសូត្រខ្ពង់ខ្ពស់គ្រាន់បើដែរ រហូតដល់ប្រឡងជាប់ប្រកាសនីយប័ត្រ។ ចៅចិត្រគិតថា ខ្លួនឯងនឹងប្រើប្រាស់សម្បត្តិទាំងនោះដើម្បីជួយការងាររបស់លោករតនសម្បត្តិអោយប្រសើរឡើង។ តួយ៉ាង នៅពេលចៅចិត្របានចូលធ្វើជាកម្មករជីកត្បូងមក ចៅចិត្របានជួយការងារដល់លោករតនសម្បត្តិជាច្រើន ហើយថែមទាំងបានជួយពិនិត្យបញ្ជីត្បូងជំនួសលោករតនសម្បត្តិថែមទៀតផង។ មិនតែប៉ុណ្ណោះចៅចិត្រក៏បានបង្ហាញពីកាយសម្បទាមាំមួនរបស់ខ្លួនដែលអាចបំពេញការងារជាកម្មករជីកត្បូងបាន ដូចសំដីមួយបានពោលថា" ខ្ញុំបាទទទួលអត់ធន់សេចក្តីលំបាកគ្រប់យ៉ាងទាំងអស់ សូមអោយតែមានការងារធ្វើនឹងគេចុះ"។ នេះហើយជាការប្តេជ្ញាចិត្តយ៉ាងមុតមាំដែលកម្រនឹងរកបាន។ ពាក្យសំដីនេះផងដែរ ក៏បានបង្ហាញអោយឃើញដែរថា ចៅចិត្រជាមនុស្សដែលមានមនសិការក្នុងការងារ។ ចំនុចនេះចង់មានន័យថា ចៅចិត្រស្រឡាញ់ការងារដែលខ្លួនបានបំពេញណាស់ ព្រោះក្រោយពីបានចូលការងារមក ចៅចិត្របានកសាងស្នាដៃជាច្រើន រហូតដល់លោករតនសម្បត្តិទុកចិត្តប្រគល់បញ្ជីត្បូងអោយចៅចិត្រកាន់ការជំនួសគាត់ទៀតផង។ លើសពីនេះទៀត ចៅចិត្របានសម្រេចនូវគោលបំណងរបស់ខ្លួនគឺបានរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់គឺនាងឃុននារី។ ចំណុចមួយទៀតពាក្យសំដីនេះក៏បានបង្ហាញថា ចៅចិត្របានស្តាប់តាមការទូន្មានរបស់លោកឪពុកគឺតា ចឹមឥតឃ្លាត គឺពឹងលើសមត្ថភាពរបស់ខ្លួនឯងជាធំ។ ដោយមានពាក្យទូន្មាននេះហើយ ទើបចៅចិត្របានកំណត់គោលដៅរបស់ខ្លួនបានច្បាស់លាស់ និងត្រឹមត្រូវបែបនេះ។ មួយវិញទៀតចៅចិត្រក៏មិនចង់ក្លាយខ្លួនជាមនុស្សដែលរើសអើងការងារ ឬមុខរបរអ្វីមួយឡើយ។ គាត់ស្ម័គ្រចិត្តធ្វើការជាកម្មករជីកត្បូងដៃឡជាការងារប្រើកម្លាំង បើទោះបីខ្លួនមានចំណេះដឹងរហូតមានប្រកាសនីយបត្រក៏ដោយក្តី ។ ហើយម្យ៉ាងទៀត ចៅចិត្រក៏មិនចង់បណ្តោយខ្លួនអោយក្លាយជាមនុស្សបញ្ឈើរក្អែកទេ ពោលគឺចង់មានជីវិតមួយផ្ទាល់ខ្លួន ដឹងនាំជីវិតផ្ទាល់ដោយដៃទាំង

ពីរបស់ខ្លួនតែម្តង។ មួយទៀតដោយសារតែចៅចិត្រយល់ថា ទោះបីជាការធ្វន់ស្រាលយ៉ាងណាក៏ដោយ អោយតែមានសេចក្តីអំណត់ និងជឿជាក់លើសមត្ថភាពខ្លួនឯង ពិតណាស់នឹងទទួលបាននូវជោគជ័យជាក់ជាមិនខានឡើយ។ គាត់មិនបានដេកចាំព្រេងសំណាង ឬវាសនា ដោយផ្តេកផ្តួលខ្លួនទៅតាមយថាកម្មនោះឡើយ។ ពិសេសជានេះទៅទៀត ពាក្យសម្តីនេះបានបង្ហាញពីគំនិតមួយដ៏ត្រឹមត្រូវដែលចៅចិត្របានគិតថា ខ្លួនចាំបាច់ត្រូវបំបាត់អ្នកដែលដែលមានគំនិតបុរេវិនិច្ឆ័យ ពោលគឺចង់លុបបំបាត់ទស្សនៈចុះចាញ់ជាមុនសិន។ ហើយចំណុចចុងក្រោយទៀតគឺ ដោយសារចៅចិត្របង្ហាញអោយមនុស្សទូទៅ ក៏ដូចជាលោកវតនសម្បត្តិនិងនាងឃុននារីថា កុំអោយមើលមនុស្សឃើញតែលើសម្បកខាងក្រៅអោយសោះ។

សរុបសេចក្តីមក តាមរយៈសំដីនេះបញ្ជាក់អោយឃើញពីទឹកចិត្តខ្ពង់ខ្ពស់ចំពោះការងាររបស់ចៅចិត្រ ហើយក្រោយមកទឹកចិត្តនេះក៏បានបង្ហាញយ៉ាងជាក់ច្បាស់នៅក្នុងដំណើររឿង។

ឆ្លងតាមការពន្យល់លើសំដីរបស់ចៅចិត្ររួចខាងមក ប្រធាននេះពិតជាមានតម្លៃខ្ពង់ខ្ពស់ ព្រោះបានបង្ហាញពីតម្លៃនៃការតាំងចិត្តដ៏ប្រសើររបស់ចៅចិត្រ។ កាលណាមនុស្សមានទឹកចិត្រ ទទួលបានជោគជ័យក្នុងជីវិតជាក់ជាមិនខាន។ ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្សទាំងអស់ ត្រូវយកគំនិតរបស់ចៅចិត្រមកដាក់ក្នុងខ្លួន ដើម្បីប្រើប្រាស់នៅពេលខ្លួនចេញទៅប្រកបការងារផ្សេងៗនៅក្នុងសង្គម។

ប្រធានទី១៣៩៖ លក្ខណៈសំខាន់របស់រឿងគឺទំនាស់។ ការចេះដោះស្រាយទំនាស់ក្នុងខ្លួនរបស់តួអង្គ ដោយជោគជ័យមានតម្លៃអប់រំធំធេងបំផុត។ ចូរពន្យល់តម្លៃអប់រំក្នុងការដោះស្រាយទំនាស់ក្នុងខ្លួនរបស់ពូហំក្នុងរឿងថៅកែចិត្តចោរអោយបានច្បាសលាស់។(ប្រឡងគ្រូមធ្យមសិក្សា ឆ្នាំ២០០៦ ឯកទេសទី១)

សេចក្តីអធិប្បាយ

អក្សរសិល្ប៍ គឺជាការលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ។ ការដោះស្រាយគឺដោះស្រាយលើទំនាស់ផ្សេងៗដែលកើតមានឡើងនៅក្នុងអក្សរសិល្ប៍។ អាស្រ័យដោយហេតុនេះហើយ ទើមានប្រធានមួយបានពោលថា “ លក្ខ

ណៈសំខាន់របស់រឿងគឺទំនាស់។ ការចេះដោះស្រាយទំនាស់ក្នុងខ្លួនរបស់តួអង្គ ដោយជោគជ័យមានតម្លៃអប់រំធំធេងបំផុត”។

តើតម្លៃអប់រំ ក្នុងការដោះស្រាយទំនាស់ក្នុងខ្លួនតាមរយៈការភ្ញាក់ខ្លួនរបស់ពូហំមានដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយប្រធានខាងលើ យើងគប្បីយល់ន័យនៃពាក្យគន្លឹះរបស់ប្រធានមួយចំនួនជាមុនសិន។ ពាក្យ”ទំនាស់” គឺជាការប្រឈមមុខដាក់គ្នា រវាងកម្លាំងពីរឬច្រើនផ្ទុយគ្នា ឬការឈ្លោះទាស់ទែងគ្នា ការមិនចុះសម្រុងឬការខ្វែងគំនិតគ្នា។ រីឯ”ទំនាស់ក្នុងខ្លួន” គឺជាការប្រឈមមុខដាក់គ្នារវាងតួអង្គ និងអារម្មណ៍ ចិត្តរបស់ខ្លួន។ ចំណែកឯ”តម្លៃអប់រំ” មានន័យថាការដឹងនាំទៅរកផ្លូវល្អ ការអោយដំបូន្មានល្អបទពិសោធល្អ។ តាមរយៈន័យនៃពាក្យខាងលើប្រធានចង់បញ្ជាក់ថា ការប្រឈមមុខដាក់គ្នារវាងកម្លាំងពីរ ឬច្រើនផ្ទុយគ្នាគឺជាលក្ខណៈសំខាន់របស់រឿង។ ឯការចេះដោះស្រាយការមិនចុះសម្រុងក្នុងខ្លួនរបស់តួអង្គហំ គឺជាមាគ៌ាដឹកនាំទៅរកផ្លូវល្អប្រកបដោយភាពជោគជ័យ។

តួយ៉ាងមិញ តាមរយៈរឿងថៅកែចិត្តចោររបស់លោកអ៊ុំ ឈឿននិងពៅ យូឡេង ក៏បានបង្ហាញថា តួអង្គហំបានសាងនូវអំពើមួយ គឺធ្វើតាមការបញ្ជារបស់ថៅកែ ដោយបើកឡានទៅបុកឡានថៅកែហុងលី។ តាមរយៈសកម្មភាពនេះ វាបានបង្ហាញពីការដោះស្រាយទំនាស់ក្នុងខ្លួនរបស់តួអង្គប្រកបដោយភាពជោគជ័យ ហើយមានតម្លៃអប់រំធំធេងណាស់។ បានជាគេហ៊ាននិយាយដូច្នេះ ដោយសារពូហំបានយល់ថាលុយអាចដោះស្រាយបញ្ហារបស់ខ្លួនបាន។ ជាក់ស្តែងដើម្បីជួយម្តាយធ្វើបុណ្យ សង្គ្រោះប្រពន្ធពីសេចក្តីស្លាប់ និងចង់អោយកូនស្រីបានចូលរៀន គាត់មិនខ្លាចសូម្បីជីវិត ដោយហ៊ានប្រថុយបើកឡានទបុកឡានរបស់ថៅកែហុងលី ដើម្បីទទួលបានប្រាក់មួយម៉ឺនរៀលពីថៅកែ។ ប៉ុន្តែក្រោយមកមកទៀតទើបពូហំបានដឹងការពិតថា លុយដែលបានមកពីអំពើទុច្ចរិត មិនអាចដោះស្រាយបញ្ហាទាំងអស់បាននោះទេ។ យ៉ាងណាមិញ តាមរយៈដំណើររឿង ក្រោយមានស្មារតីភ្ញាក់រឭកហើយនោះ គាត់មិនបានទទួលប្រាក់ពីថៅកែចិត្តចោរឡើយ តែសុខចិត្តអោយប៉ូលីសចាប់ខ្លួនដោយមិនប្រកែកអ្វីឡើយ។ ចំណុចមួយទៀត គឺពូហំមានស្មានរតីលះបង់ខ្ពស់ដោយហ៊ានលះបង់សេចក្តីសុខតូច ដើម្បីសេចក្តីសុខធំ។ បើយ៉ាងពិនិត្យមើលតាមដំណើររឿងយើងឃើញថា ពូហំឈប់ចង់បានលុយកខ្វក់នោះទៀតហើយ ហើយប្រែជាប្រឆាំងនឹងថៅកែដោយមិនភ្លាចរអាអ្វីឡើយ។ នេះចំជាមានស្មារតីភ្ញាក់រឭកប្រកដមែន។ មិនតែប៉ុណ្ណោះគាត់ក៏ហ៊ានលះបង់អំពើទុច្ចរិត ដោយហ៊ានចេញមុខដើម្បីទទួលខុសត្រូវរាល់ទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់។ គាត់ បានប្រគល់ខ្លួនទៅអោយក្រុមប៉ូលីសដោយឥតមានប្រកែកឬប្រឆាំងសូម្បីបន្តិចឡើយ។ មួយវិញទៀតពូហំលែងចង់បានលុយដែលបានមកអំពើអយុត្តិធម៌ទៀតហើយ គាត់បានទទួលស្គាល់កំហុសរបស់ខ្លួនហើយកែប្រែខ្លួនក្លាយជាមនុស្សប្រសើរម្នាក់ផងដែរ។

រួមសេចក្តីមក តម្លៃអប់រំក្នុងការដោះស្រាយទំនាស់ក្នុងខ្លួនរបស់តួអង្គតាមរយៈការភ្ញាក់រឭករបស់តួអង្គហំ បានអប់រំមនុស្សទៅរកទង្វើមានជាច្រើន។

ឆ្លងកាត់តាមរយៈការបកស្រាយប្រធានខាងលើ ប្រធានពិតជាមានអត្ថន័យល្អប្រសើរក្រៃលែង ព្រោះមានតម្លៃអប់រំល្អៗ នាំអោយមនុស្សចេះភ្ញាក់រឭក ស្គាល់ខុស ស្គាល់ត្រូវ ចេះកែប្រែកំហុសហើយប្រព្រឹត្តអំពើសុចរិតយុត្តិធម៌។ ដូច្នេះក្នុងនាមយើង ជាកូនខ្មែរសម័យថ្មីនេះ មុននឹងធ្វើការសម្រេចចិត្តទៅលើអ្វីមួយ ត្រូវចេះត្រិះរិះពិចារណាអោយបានច្បាស់លាស់ ទើបមមិនមានវិប្បដិសារីទៅថ្ងៃក្រោយ។

ប្រធានទី៤០៖ ទស្សនៈប្រធានមួយបានពោលថា" បង្រៀនមនុស្សម្នាក់អោយចេះស្ងួចត្រី ប្រសើរជាអោយត្រីទៅមនុស្សនោះ"។ ចូរពន្យល់ពុំនោល ដោយលើកឧទាហរណ៍ក្នុងអត្ថបទ "ទីពឹងថ្មី" នៃរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់មកបញ្ជាក់អោយបានច្បាស់លាស់។ (ប្រឡងគ្រូមធ្យមសិក្សា ឆ្នាំ២០០៦ ឯទេសទី២)។

សេចក្តីអធិប្បាយ

មនុស្សម្នាក់ៗដែលរស់នៅលើលោកយើងនេះ តែងតែប្រថ្នាចង់បានការងារមួយជាក់លាក់ ច្បាស់លាស់ និងសមរម្យ។ ប៉ុន្តែមានមនុស្សមួយចំនួនមិនចេះស្វែងរក ឬរកស៊ីដោយខ្លួនឯងឡើយគឺចាំតែគេជួយនេះជួយនោះមិនដាច់ តែនៅមិនមានការរីកចម្រើន។ ដោយយល់ឃើញបែបនេះហើយ ទើបានជាមានប្រធានមួយបានពោលថា "បង្រៀនមនុស្សម្នាក់អោយចេះស្ងួចត្រី ប្រើសើរជាងអោយត្រីទៅមនុស្សនោះ"។

តើពុំនោលខាងលើនេះចង់មានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

មុននឹងឈានចូលទៅដល់ការបកស្រាយប្រធានបទខាងលើ យើងគប្បីស្វែងយល់ន័យនៃពាក្យដែលមាននៅក្នុងប្រធានមួយចំនួនជាមុនសិន។ពាក្យថា"បង្រៀង" មានន័យថាបង្ហាត់បង្ហាញអោយចេះដឹង ធ្វើបាន ហើយថែមទាំងស្ទាត់ជំនាញ។ រីឯ"អោយ" ចង់សំដៅដល់ការផ្តល់ ជូន ប្រគល់។ តាមរយៈន័យនៃពាក្យនេះ ប្រធានចង់បង្ហាញថា ការបង្ហាត់បង្រៀនមនុស្សអោយចេះស្ងួចត្រី គឺប្រើជាជាងអោយត្រីទៅមនុស្សស្រាប់ៗ។

តួយ៉ាង យើងដឹងហើយថា បើយើងអោយត្រីទៅនរណាម្នាក់ហូប គឺហូបបានតែមួយពេលខ្លីប៉ុណ្ណោះ ហើយថ្ងៃក្រោយមកគេនៅតែខ្វះខាតម្ហូបដដែល។ ប្រសិនបើក្នុងករណីយើងមិនបានអោយទៅធ្វើជាម្ហូបទេ បុគ្គលម្នាក់នោះតែងគ្មានអ្វីបរិភោគ ហើយនៅតែរំពឹងគេដដែល។ ប៉ុន្តែបើក្នុងករណីបើយើងបង្រៀនបុគ្គលម្នាក់នោះអោយគេមានជំនាញនៅក្នុងការស្ងួចត្រី នោះគេ នឹងអាចរកត្រីបានហូបដោយខ្លួនឯងគ្រប់ពេល ដោយមិនត្រូវការការផ្គត់ផ្គង់ ឬជំនួយពីអ្នកដទៃទៀតដែរ។

តាមរយៈន័យចំរិញ គឺមានន័យផ្សេងពីន័យខាងលើ។ គេប្រៀបធៀងអ្នកបង្ហាញបង្រៀនទៅនឹងអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ហើយត្រីសំដៅទៅលើមុខរបរជំនាញផ្សេងៗគឺដើម្បីចិញ្ចឹមជីវិត ដែលមានលក្ខណៈប្រសើរជាងការរស់នៅដោយសារពឹងពាក់ ឬការផ្តល់ពីអ្នកដទៃ។ តាមរយៈគំនិតនេះ គឺត្រូវបង្ហាញឡើងតាមរយៈរឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់ត្រង់វគ្គទីដប់ប្រាំមួយដែលមានចំណងជើងថា “ទីពឹងថ្មី” ។ បើយើងមើលតាមដំណើរនៃឃើញថា សមមិនទទួលប្រាក់៥០០រៀលពីលោករដ្ឋមន្ត្រីក្មេងឡើយតែសមបែជាសុំការងារធ្វើទៅវិញ។ តាមគំនិតនេះដោយសារសមគិតថា ប្រាក់៥០០រៀលនោះគ្រាន់តែជាមធ្យោបាយដោះស្រាយបញ្ហាចំពោះមុខបានតែមួយពេលមួយខ្លីប៉ុណ្ណោះ។តែបើសមមានការងារធ្វើវិញ គាត់អាចចិញ្ចឹមជីវិត ឬដោះស្រាយបញ្ហាបានយូរអង្វែងតែម្តង។ មួយវិញទៀត កាលណាមនុស្សមានការងារធ្វើប្រចាំជីវិត និងមានជំនាញច្បាស់លាស់ហើយនោះ ជីវិតរបស់គេពិតជាមានតម្លៃ និងអនាគតរុងរឿង។

រួមសេចក្តីមក ការមានសមត្ថភាព និងជំនាញក្នុងមុខរបរណាមួយច្បាស់លាស់ នាំអោយជីវិតនិងសង្គមមានការរីកចម្រើនរុងរឿង។

ឆ្លងកាត់តាមរយៈការបកស្រាយទាំងន័យចំ និងន័យធៀបរបស់ប្រធានខាងលើរួចមក បង្ហាញថាប្រធានពិតជាមានអត្ថន័យអប់រំមនុស្សអោយចេះខិតខំរកជំនាញក្នុងការប្រកបមុខរបរដើម្បីចិញ្ចឹមជីវិតរៀងខ្លួនៗ។ ដូច្នេះក្នុងនាមយើងជាកូនចៅជំនាន់ក្រោយ ត្រូវចេះខិតខំប្រឹងប្រែងរៀនសូត្រអោយមានចំណេះដឹង និងជំនាញ ដើម្បីមានការងារធ្វើសម្រាប់ចិញ្ចឹមជីវិតជៀសវាងការពឹងពាក់លើអ្នកដទៃទាំងស្រុងទើបជាការប្រសើរ។

ប្រធានទី៤១៖ ចៅចិត្រជាតួអង្គឯនៅក្នុងរឿង កុលាប៉ៃលិន។ តើចៅចិត្រមានគុណសម្បត្តិអ្វីខ្លះ សម្រាប់យុវជនយើងយកតម្រាប់តាម? ចូរលើកយកឧទាហរណ៍ជាក់ស្តែងមកបញ្ជាក់។ (ប្រឡងគ្រូបឋម និងមត្តេយ្យសិក្សា ឆ្នាំ ២០០៦,២៣.តុលា.២០១៧)

សេចក្តីអធិប្បាយ

រឿងកុលាបប៉ៃលិន គឺជាអក្សរសិល្ប៍ខេមរនិយមមួយដែលត្រូវបានតែងនិពន្ធដោយលោក ញ៉ុក ថែម នៅឆ្នាំមួយពាន់ប្រាំបួនរយសាមសិបប្រាំមួយ ឬមួយពាន់ប្រាំមួយរយសែសិបបី។ តាមរយៈដំណើររឿងចៅចិត្របានបង្កើតចេញនៅគុណសម្បត្តិជាច្រើនសម្រាប់មនុស្សយកតម្រាប់តាម។ អាស្រ័យហេតុនេះហើយ ទើបបានជាគេចាត់ទុកថា "ចៅចិត្រជាតួអង្គឯកក្នុងរឿងកុលាបប៉ៃលិន"។

តើចៅចិត្រមានគុណសម្បត្តិអ្វីខ្លះ សម្រាប់អោយយុវជនយើងយកតម្រាប់តាម?

ដើម្បីមានភាពងាយស្រួលក្នុងការបកស្រាយប្រធានខាងលើ យើងគប្បីស្វែងយល់នំយនៃពាក្យរបស់ប្រធានមួយចំនួនសិន។ ពាក្យថា"តួអង្គឯក" មានន័យថាតួអង្គដែលសំខាន់ជាងគេ ហើយមានសកម្មភាពវិជ្ជមានក្នុងរឿងច្រើនជាងគេ។ រីឯ"គុណសម្បត្តិ" មានន័យថាលក្ខណៈល្អប្រសើរ មានសម្បត្តិ ចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ។ តាមរយៈន័យនៃពាក្យខាងលើនេះប្រធានចង់បញ្ជាក់ថា ចៅចិត្រជាតួអង្គសំខាន់ជាងគេនៅក្នុងរឿង មានសកម្មភាពវិជ្ជមានច្រើនប្រកបដោយលក្ខណៈសម្បត្តិ។

តួយ៉ាង តាមរយៈការសិក្សារឿងកុលាប៉ៃលិន យើងសង្កេតឃើញថាចៅចិត្រមានគុណសម្បត្តិលើផ្នែកបីសំខាន់ៗ។ គុណសម្បត្តិទីមួយ គឺលើផ្នែករូបសម្បត្តិ។ ចៅចិត្រ ជាមនុស្សដែលមានសុខភាពល្អមានកម្លាំងមាំមួន។ ថ្វីត្បិតតែតាមរយៈដំណើររឿង ចៅចិត្រមានរាងកាយស្គមក៏មែនពិត តែកម្លាំងមាំមួនខ្លាំងក្លា។ ជាក់ស្តែងដូចពាក្យសម្តីរបស់ចៅចិត្រនិយាយទៅនាងឃុននារីថា "មនុស្សត្រង់ គេមិនសម្គាល់ថាជាមនុស្សល្ងង់ទេ ហើយមនុស្សស្គមដូចខ្ញុំនេះក៏មិនសម្គាល់ថាជាមនុស្សគ្មានកម្លាំងដែរ គ្រាន់តែខ្ញុំមានរាងកាយស្គមបន្តិចប៉ុណ្ណោះទេតើ"។ លើសពីនេះទៅទៀត ចៅចិត្របានក្លាយខ្លួនជាកម្មករជីកត្បូង ជីកព្រឹកដល់ល្ងាច ដោយមិនមានហត់នឿយអ្វីឡើយ។ មួយទៀតចៅចិត្រជាមនុស្សដែលមានរាងកាយល្អ សមរម្យ និងកាយសម្បទាគ្រប់គ្រាន់។ យ៉ាងណាមិញចៅចិត្រមិនមែនជាជនពិការខ្វះដៃខ្វះជើងនោះឡើយ។ ចំណែកឯគុណសម្បត្តិទីពីរ គឺលើផ្នែក ចរិយាសម្បត្តិ តាមរយៈរឿងផងដែរ ក៏បានបង្ហាញថា ចៅចិត្រជាមនុស្សដែលមានចរិតលក្ខណៈស្លូតបូត សុភាពរាបសារ។ ដោយសារចរឹតស្លូតបូត និងសុភាពរាបសារបែបនេះហើយ ទើបបានក្រុមកម្មករឯទៀត និងចៅហ្វាយនាយគោរពស្រឡាញ់ចៅចិត្រជាខ្លាំង។ មួយវិញទៀតចៅចិត្រ ជាមនុស្សដែលពោរពេញទៅដោយការព្យាយាម អត់ធន គ្រប់ការលំបាកនានាដោយមិនមានការត្អូញត្អែរសូម្បីពាក្យសម្តីតិចតួចឡើយ។ ក្នុងជីវភាពជាកម្មករជីកត្បូង ចៅចិត្របានជីករ៉ែក្រោមកម្តៅថ្ងៃដោយឥតមានរុញរាឡើយ។ ហើយពេលទៅផ្សារជាមួយនឹងនាងឃុននារី ចៅចិត្របានយួរកន្ត្រកដែលមានឥវ៉ាន់ជាច្រើន ដោយមិនមានការហត់នឿយដែរ។ ប៉ុន្តែពីលើសេចក្តីតស៊ូព្យាយាមរបស់ចៅចិត្រក៏ជាមនុស្សដែលមានសេចក្តីអង់អាចក្លាយហ៊ានប្រឈមមុខនឹងក្រុមចោរដែលមានគ្នាច្រើនដោយឥតញញើតសោះឡើយ។ ហើយក្រោយមកទៀត ក៏បានប្រយុទ្ធជាមួយមេចោរផាន់ដែលមានមាឌមាំ ខ្លាំងទៀតផង។ លើសពីនេះទៅទៀតនោះ ចៅចិត្រ ជាមនុស្សដែលមានសេចក្តីត្រង់នឹងចៅហ្វាយនាយ កម្មករ និងនាងឃុននារី។ ចៅចិត្រ បានជួយការងារកាន់បញ្ជីត្បូងជំនួសលោកតេនសម្បត្តិ ស្រឡាញ់ចូលចិត្តកម្មករជីករ៉ែទាំងអស់ស្មើៗគ្នា។ ហើយថែមទាំងមានសេចក្តីស្នេហាស្មោះត្រង់ចំពោះឃុននារីទៀតផងដែរ។ មួយទៀតផងដែរ ចៅចិត្តជាកូនកតញ្ញូចំពោះអ្នកមានគុណ។ ចៅចិត្រ បានធ្វើបុណ្យបញ្ជូនកុសលដល់ ឪពុកដែលបានចែកឋានទៅតាមប្រពៃណី និងគោរពតាមពាក្យបណ្តាំរបស់ឪពុករហូតមិនដែលប្រាស់ចាកបន្តិចម្តងណាឡើយ។ ចៅចិត្រក៏ជាមនុស្សដែលចេះជួយទុក្ខធុរៈអ្នកដទៃផងដែរ។ នៅពេលតាសុន បានពឹងចៅចិត្រអោយបើកឡានជំនួសគាត់ ចៅចិត្រីករាយនឹងធ្វើដោយមិនមានបដិសេធឡើយ។ ហយមិនតែប៉ុណ្ណោះ គាត់ ជាមនុស្សដែលចេះសម្របទៅតាមសង្គម ចេះរស់នៅដោយសេចក្តីថ្លៃថ្នូរ និងឧត្តុងឧត្តម។ចំណែកគុណសម្បត្តិទីបីវិញ គឺស្ថិតនៅលើផ្នែកវិជ្ជាសម្បត្តិ ។ គឺចៅចិត្រជាមនុស្សដែឡមានចំណេះដឹងខ្ពស់បង្គួរ ព្រោះខ្លួនបានប្រឡងជាប់ប្រកាសនីយបត្រ។ មិនតែប៉ុណ្ណោះថែមទាំងចេះបើកឡាន និងជួយជួសជុលរថយន្តទៀតផង។ ចៅចិត្រ ជាមនុស្សដែលមានលក្ខណៈជាអ្នកដឹកនាំ អ្នកគ្រប់គ្រង ព្រោះចៅចិត្របានគ្រប់គ្រងក្រុមកម្មករជីងត្បូង និងគ្រប់គ្រងបញ្ជីរត្បូងបានល្អត្រឹមត្រូវ។ ម្យ៉ាងទៀត ចៅចិត្រជាមនុស្សដែលមានការត្រិះរិះពិចារណា ប្រកបដោយវិចារណញ្ញាណ។ ចំណេះដឹងខាងផ្នែកបុរស ក៏ចៅចិត្រចេះ ចំណែកខាងផ្នែកស្រីក៏ចៅចិត្រចេះដែរ ជាក់ស្តែងគាត់ ចេះដាំបាយ និងច្រៀងបទយូរគិរម្យបានពិរោះថែមទៀតផង។

សរុបសេចក្តីមក លក្ខណៈសម្បត្តិរបស់ចៅចិត្រមានតម្លៃអាចអោយយុវវ័យយកតម្រាប់តាមបាន។

ឆ្លងតាមរយៈការបកស្រាយមកខាងលើ ប្រធានពិតជាមានអត្ថន័យប្រសើរក្រៃលែង ព្រោះវាមានអត្ថន័យល្អ សម្រាប់អោយយុវវ័យសម័យថ្មី យកជាគម្រូវិភាព។ ដូច្នេះក្នុងនាមជាយុវជនគ្រប់រូប។ គប្បីធ្វើខ្លួនអោយមានលក្ខណៈល្អ ដូចជាចៅចិត្រទើបប្រសើរ។

ប្រធានទី៤២៖ លោករដ្ឋមន្ត្រីវ័យក្មេងបានជួយសង្គ្រោះ “សម” ។ ចូរបង្ហាញពីហេតុផលដែលនាំអោយលោករដ្ឋមន្ត្រីក្មេងបំពេញនូវអំពើមនុស្សធម៌នេះ ដោយលើកយកអត្ថបទ “ទីពឹងថ្មី” នៅក្នុងរឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់មកបញ្ជាក់អោយបានក្បោះក្បាយ។ (ប្រឡងគ្រូមធ្យមសិក្សា ឆ្នាំ ២០០៧)។

សេចក្តីអធិប្បាយ

មនុស្សម្នាក់ៗ កើតមកគឺប្រាថ្នាចង់បានការជួយសង្គ្រោះគ្នាទៅវិញទៅមកជាដរាប។ បើកាលណាមនុស្សបានបំពេញនូវគុណធម៌និងសប្បុរសធម៌បែបនេះ វា បានជួយសង្គ្រោះគ្នាទៅវិញទៅមកហើយការរស់នៅក្នុងសង្គមទៀតសោត ក៏ទទួលបានការរីកចម្រើនផងដែរ។ អាស្រ័យដោយហេតុនេះហើយ បានជានៅក្នុងរឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់របស់លោក សួន សុរិន្ទ តាមរយៈតួអង្គលោករដ្ឋមន្ត្រីក្មេងបានជួយសង្គ្រោះ “សម”។

តើមានហេតុផលអ្វីខ្លះ ដែលនាំអោយលោករដ្ឋមន្ត្រីក្មេងបំពេញនូវអំពើមនុស្សធម៌នេះ?

ដើម្បីជាជំនួយដល់ការដោះស្រាយបញ្ហារបស់ប្រធានខាងលើ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះរបស់ប្រធានមួយចំនួនជាមុនសិន។ ពាក្យថា “ជួយសង្គ្រោះ” មានន័យថាជួយស្រោចស្រង់ ជួយជ្រោមជ្រែង ជួយផ្គត់ផ្គង់ទំនុកបម្រុង គ្រាំពារ ឧត្តម អោយរួចផុតពីសេចក្តីទុក្ខលំបាកវេទនា។ រីឯពាក្យ” អំពើមនុស្សធម៌” គឺជាអំពើទាំងឡាយណាដែលនាំអោយមនុស្សប្រកាន់ភ្ជាប់នូវអំពើល្អ ជាមួយមនុស្សផង។តាមរយៈការពន្យល់ពាក្យខាងលើ ប្រធានចង់មានន័យថា

លោករដ្ឋមន្ត្រីក្មេងបានជួយស្រោចស្រង់ ជួយជ្រោមជ្រែង និងទំនុកបម្រុងដល់សមដែលជាទង្វើមួយដ៏ប្រសើរ ជួយសមអោយរួចផុតពីសេចក្តីលំបាកក្នុងជីវិត។

យ៉ាងណាមុញ យើងបានដឹងហើយថា តាមរយៈដំណើរនៃរឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់ ត្រង់វគ្គទី១៦ មានចំណងជើងថា “ទីពឹងថ្មី” លោករដ្ឋមន្ត្រីក្មេងបានបើកឡានទៅបុកបុរសម្នាក់គឺ សម។ ក្នុងគ្រោះថ្នាក់ចរាចរណ៍នោះ សមបានទទួលរងរបួសស្រាល ដោយត្រូវរលាត់ក្បាលជង្គង់បន្តិច។ ក្រោយមកត្រូវលោកបានជួយសង្គ្រោះសម ដោយជូនទៅមន្ទីពេទ្យ នឹងជួយរកការងារអោយសមធ្វើដោយមិនមានលក្ខណ្ឌ។ ការដែលលោមព្រមជួយសង្គ្រោះសមគឺដោយសារលោកបានសម្លឹងឃើញនូវគុណសម្បត្តិរបស់សមជាច្រើន។ គុណសម្បត្តិទីមួយ គឺលោកបានមើលឃើញថាសមជាមនុស្សដែលមានអត្តចរិតស្លូតបូត ស្មោះត្រង់ នឹងមានសេចក្តីអំណត់អត់ធន។តាមដំណើរនៃរឿង លោករដ្ឋមន្ត្រីក្មេងបានឃើញថា សមបានសំដែងនូវអាកប្បកិរិយាសុភាពរាសារ និយាយពាក្យសម្តីទន់ភ្លន់ ហើយថែមទាំងនិយាយការលំបាករបស់ខ្លួនទាំងអស់ប្រាប់ទៅលោកមន្ត្រីទៀតផង។ បើទោះបីរបួសរបស់ខ្លួនឈឺផ្សារបន្តិចក្តី ប៉ុន្តែសមមានការអត់ធ្មត់ក្នុងចិត្តដោយមិនបាន បង្ហាញអោយលោករដ្ឋមន្ត្រីលោកបានឃើញឡើយ។ចំណែកគុណសម្បត្តិទីពីរវិញ គឺលោកបានថែមទាំងសម្លឹងឃើញថាសមជាមនុស្សមិមានសេចក្តីលោភលន់ ស្រឡាញ់ប្រាក់កាសហួសហេតុនោះឡើយ។ គុណសម្បត្តិបានបង្ហាញតាមរយៈដំណើររឿង គឺនៅពេលដែលលោលបានជូនប្រាក់ ប្រាំរយរៀលទៅសម តែសមមិនទទួលយកប្រាក់នោះឡើយ ដែលគោងទាមទារចង់បាននេះបាននោះតាមសភាពអ្នករងគ្រោះថ្នាក់នោះឡើយ។ និងគុណសម្បត្តិទីបី សមគឺជាមនុស្សដែលចេះទទួលកំហុស ឃើញថាខ្លួនខុសក៏ព្រមទទួលយកភ្លាមដោយមិនមានប្រកែកតវាឡើយ គឺនៅពេលលោក
មន្ត្រីក្មេងបានបម្រុងនឹងយកសមទៅមន្ទីពេទ្យដើម្បីព្យាបាល ស្រាប់តែសមប្រាប់ទៅរដ្ឋមន្ត្រីក្មេងកុំអោយយកទៅធ្វើអ្វី ព្រោះនេះជាកំហុសរបស់ខ្លួនប៉ុណ្ណោះ ហើយថែមទាំងថាជារបួសស្រាលទៀត។ មិនតែប៉ុណ្ណោះសម ក៏ជាមនុស្សដែលស្រឡាញ់ការងារសុចរិតផងដែរ។ ខ្លួនបានគិតថា ការងារសុចរិតគឺជាការងារមួយដែលប្រសើរលើសអ្វីៗទាំងអស់ ហើយមានតែការងារនេះហើយដែលអាចកសាងខ្លួនអោយផុតពីសេចក្តីទុក្ខលំបាកបាន ។ នៅក្នុងវគ្គទី១១ដែល នៅពេលដែលលោករដ្ឋមន្ត្រីបានជូនប្រាក់ទៅសម តែសមបានប្រកែងមិនយក ហើយប្រាប់លោកថាចង់បានការងារធ្វើដូចដែលសំដីរបស់សមថា” សូមកុំអោយប្រាក់ខ្ញុំបាទធ្វើអ្វី សូមលោកផ្តល់ការងារអោយខ្ញុំបាទវិញប្រសើរជាង”។តាមរយៈសំដីនេះហើយដែលបង្ហាញថាសមជាមនុស្សដែលស្រឡាញ់ការងារជាងប្រាក់កាស។

បើនិយាយចំពោះលោករដ្ឋមន្ត្រីក្មេងវិញ គឺលោកជាបញ្ញវន្តម្នាក់ដែលមានចំណេះដឹងខ្ពង់ខ្ពស់បានបញ្ចប់ការសិក្សាពីប្រទេសបារាំង ទើបលោកបានយល់ច្បាស់ពីសេចក្តីទុក្ខលំបាកនានារបស់មនុស្ស ឬរបស់រាស្ត្របានច្បាស់លាស់បែបនេះ។ មិនតែប៉ុណ្ណោះលោករដ្ឋមន្ត្រីក្មេងក៏ជាមនុស្សដែលមានសុជីវធម៌ និងសីលធម៌ក្នុងការរស់នៅ ការនិយាយស្តីទៀតផង។ ជាក់ស្តែងនៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើងនោះ លោករដ្ឋមន្ត្រីក្មេងមិនបានប្រកាន់ខ្លួនជាអ្នកធំនោះឡើយ តែលោកបានចុះមកគ្រាសមដាក់លើរថយន្តមិនប្រកាន់វណ្ណៈអ្វីទាំងអស់ ។នៅលើរថយន្ត លោកបានប្រើពាក្យសម្តីទន់ភ្លន់ សុភាពរាបសារ (ខ្ញុំ បាទ) និយាយជាមួយនឹងសមដោយមានក្រមសីលធម៌ក្នុងខ្លួនជានិច្ច។ ម្យ៉ាងទៀតបានជាលោកជួយសង្គ្រោះសម ក៏ព្រោះតែលោកមានសេចក្តីអាណិតអាសូរ មានការសណ្តោសប្រណី និងមិនមានចិត្តរើសអើងចំពោះអ្នកក្រីក្រសូម្បីតែបន្តិចណាឡើយ។ មួយវិញទៀត ដោយសារតែលោកជាមនុស្សដែលមានការទទួលខុសត្រូវ ចេះគោរពសិទ្ធិមនុស្សបែបនេះហើយ ទើបលោកបានជួយសង្គ្រោះសមដោយទឹកចិត្តអាណិតអាសូរ ហើយមិចង់បានអ្វីក្រៅពីសេចក្តីស្មោះត្រង់ពីសមវិញឡើយ។

រួមសេចក្តីមក ការជួយសង្គ្រោះ “សមម” ពីសំណាក់លោករដ្ឋមន្ត្រីក្មេងគឺពិតជាអំពើមនុស្សធម៌មួយយ៉ាងពិតប្រាកដ។

ឆ្លងកាត់តាមការបកស្រាយខាងលើមក គំនិតរបស់ប្រធានគឺជាគតិមួយដ៏ល្អ ពោលគឺមានបំណងអប់រំដល់មនុស្សអោយចេះស្រឡាញ់អំពើល្អ មានទឹកចិត្តមនុស្សធម៌ និងត្រូវចេះជួយអ្នកក្រីក្រទន់ខ្សោយ ដោយមិនត្រូវសម្លឹងយើញតែផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ។ ដូច្នេះក្នុងនាមយើងជាកុលបុត្រជំនាន់ក្រោយ ត្រូវចេះប្រកាន់ខ្ជាប់នូវគំនិត និងទឹកចិត្តមនុស្សធម៌ ការចេះជួយសង្គ្រោះទៅវិញទៅមក ដើម្បីរួមគ្នាអភិវឌ្ឍសង្គម។

ចំណាំ ការធ្វើសេចក្តីផ្តើមមិនចាកនឹងប្រធានប្រធាននោះលើបញ្ហាពីរឿងក្នុងអត្ថបទសិល្ប៍យើងត្រូវ៖
និយាយពីស្នាដៃរបស់អ្នកនិពន្ធ (ឧ.រឿងកុលាបប៉ៃលិន ជាស្នាដៃរបស់អ្នកនិពន្ធលោក ញ៉ុក ថែម នៅឆ្នាំ១៩៣៦ ឬ ១៩៤៣.....។
និយាយពីទ្រឹស្តីអក្សរសិល្ប៍(ឧ។ អក្សរសិល្ប៍ គឺជាការសិក្សាពីមនុស្សដើម្បីមនុស្ស.....ដោយយល់ឃើញបែបនេះហើយ ទើបមាន.....។
ប្រធានតែងសេចក្តីនេះ មានច្រើនប្រភេទច្រើនបែបដូចខាងក្រោម៖
បែបសុភាសិត
បែបពាក្យស្លោកឬទូទៅ
បែបប្រៀបធៀប
បែបចោទជាសំណួរឬក្នុងក្របខណ្ឌអក្សរសិល្ប៍
សូមអភ័យទោសរាល់កំហុស កើតឡើងដោយអចេតនាកើតមានឡើង ក្នុងការវាយជាអត្ថបទសំណេរមួយនេះ

ប្រធានទី៤៣៖ សុភាសិតចាស់បុរាណបានពោលថា “ ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច”។តើសុភាសិតមួយឃ្លានេះចង់មានអត្ថន័យដូចម្តេច? ចូរពន្យល់បកស្រាយអោយបានច្បាស់លាស់។

សេចក្តីអធិប្បាយ

មនុស្សម្នាក់ៗ មិនអាចរស់នៅតែម្នាក់ឯងនៅលើពិភពលោកដ៏ធំទូលាយនេះបានទេ។ វាប្រៀបបាននឹងមនុស្សដែលរស់នៅលើផែនដី ដែលតែងមានចំណុចខ្វះខា មិនគ្រប់ជ្រុងជ្រោយទាំងអស់ជាដើម។ សម្រាប់សុភាសិតមួយឃ្លាដែលថា “ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច” ក៏បានបង្ហាញលក្ខណៈបែបនេះផងដែរ។
តើសុភាសិតមួយឃ្លានេះចង់មានអត្ថន័យដូចម្តេច? និងមានតម្លៃអប់រំដូចម្តេច?
ដើម្បីងាយស្រួលក្នុងការបកស្រាយសុភាសិតខាងលើអោយបានស៊ីជម្រៅនឹងច្បាសលាស់នោះ យើងគប្បីស្វែងយល់ពីអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ពាក្យថា”ភ្លាត់” មានន័យថាមិនត្រឹមត្រូវខុសឬខុសភ្លាត់។ រីឯ” ស្ទាត់” ជាការយល់ដឹងអ្វីមួយបានច្បាស់លាស់ មិនស្ទាក់ស្ទើរ។ចំណែកឯ”ដំរី” ជាសត្វចតុបាតមួយដែលមានកម្លាំងខ្លាំងហើយមានជើងបួនអាចផ្លាស់ទីមួយទៅទីកន្លែងមួយទៀតបានដោយសារជើងបួនរបស់វា។តាមន័យនេះប្រធានចង់មានន័យថា ដំរីមានជើងបួនធំយ៉ាងណាក៏នៅតែមានភ្លាត់ ខុសដែរ។

ជាការពិត តាមធម្មជាតិសត្វដំរី ជាសត្វចតុបាតមួយដែលមានកម្លាំងខ្លាំង មានជើងបួនហើយផ្លាស់ទីតំបន់មួយទៅតំបន់មួយដោយប្រើជើងទាំងបួនរបស់វា ហេតុដូច្នេះហើយជំហររបស់សត្វដំរីគឺមានភាពរឹងមាំណាស់ ហើយក៏មិន

ងាយនឹងចុះត្រុដង្រោមដែរ។ ប៉ុន្តែ បើទោះបីជាសត្វដំរីមានជើងបួនរឹងមាំយ៉ាងណា និងមានកម្លាំងមហិមាយ៉ាងណាក៏ដោយក៏មិនអាចគេចផុតពីកម្លាំងប្រជ្ញារបស់មនុស្សបានដែរ។ ជាក់ស្តែងសត្វដំរីនេះតែងរស់នៅធម្មជាតិនៅក្នុងព្រៃជ្រៅ ប៉ុន្តែត្រូវចាញ់ក្រោមដៃរបស់មនុស្សតូចមួយ អាចបញ្ជាទៅណាក៏បានតាមចិត្ត។ ចំណុចទាំងអស់របស់សត្វដំរីនេះ វាមិនខុសអ្វីពីប្រាជ្ញារបស់មនុស្សទេ។ បើទោះបីក្នុងនាមជាអ្នកប្រាជ្ញក៏ទាមទារអោយធ្វើការសិក្សាស្រាវជ្រាវជាប្រចាំដែរ។ មានចំណុចខ្លះមនុស្សពិតជាមិនបានដឹងប្រាកដណាស់ ព្រោះតែគេមិនបានសិក្សា មិនដែលបានជួប ឬពេលខ្លះទៀតនោះ គេធ្លាប់ចេះ គេធ្លាប់ដឹង ប៉ុន្តែត្រូវភ្លេចដោយប្រការណ៍ណាមួយក៏មានដែរ។ តួយ៉ាងអ្នកប្រាជ្ញខាងអក្សរសាស្ត្រ ពិតណាស់មិនអាចយល់ដឹងគ្រប់សព្វពីអក្សរសាស្ត្របាននោះទេ គឺតែនៅមានចំណុចខ្វះខាតជាក់ជាមិនខាន់។

សរុបសេចក្តីមក សុខភាសិតដែលថា ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្មាត់គង់មានភ្លេច” គឺពិតជាត្រឹមត្រូវណាស់ និងសមស្របនឹងការពិតទៀតផង។

ឆ្លងកាត់តាមការបកស្រាយនូវសុភាសិតខាងលើ យើងឃើញថាសុភាសុតនេះពិតជាមានអត្ថន័យល្អប្រសើរ និងមានតម្លៃអប់រំល្អទៀតផង។ វាបានអប់រំដល់មនុស្សមានគំនិតតស៊ូព្យាយាម អំណត់អត់ធ្មត់គ្រប់បែបយ៉ាងទាំងអស់ ដើម្បីសម្រេចបានជោគជ័យក្នុងជីវិត។ ដូច្នេះក្នុងនាមយើង ជាកុលបុត្រខ្មែរជំនាន់ក្រោយត្រូវប្រកាន់គំនិតរបស់សុភាសិតខាងលើជាក់ក្នុងខ្លួនជានិច្ច ទើបប្រសើរ៕

មនុស្សសូមកុំមើលងាយមនុស្សដូចគ្នា
ថ្ងៃនេះគេក្រ មិនល្អ មិនប្រាកដថា គេនៅតែក្រ មិនល្អ នៅថ្ងៃអនាគតនោះទេ!
ចេះឯង អោយក្រែងចេះគេ!!!

ប្រធានទី៤៤៖ សុភាសិតខ្មែរមួយបានចែងថា”ដឹងធ្វើយត្បិតដង កូនសោតតែងឆ្គងត្បិតឪពុក”។
ចូរពន្យល់បកស្រាយ។
សេចក្តីអធិប្បាយ

នៅក្នុងសង្គមគ្រួសារ មាតាបិតា ជាអ្នកមានគុណក្រាស់ក្រៃលើកូនៗ និងមនុស្សទូទៅ។ ក្នុងការអប់រំកូនចៅអោយដើរលើផ្លូវ ផ្លូវដែលសុចរិត មានសីលធម៌ គឺជាទំនួលខុសត្រូវរបស់លោកទាំងពីរ។ កាលណាកូនធ្វើអ្វីមួយមិនសាកសមឬខ្វះសីលធម៌គេតែនិយាយថា មកពីឪពុកម្តាយមនបានប្រៀនប្រដៅ។ ហេតុដូច្នេះហើយទើបបានជាមានសុភាសិតមួយបានពោលថា” ដឹងធ្វើយត្បិតដង កូនសោតរែងឆ្គងត្បិតឪពុក”។

តើសុភាសិតនេះចង់មានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីមានភាពងាយស្រួល ដល់ការបកស្រាយប្រធានខាងលើ យើងគប្បីស្វែងយល់នូវន័យនៃពាក្យថា”ដឹង ធ្វើយ ឆ្គង” ជាមុនសិន។ពាក្យថា”ដឹង” គឺជាឈ្មោះឧបករណ៍រោងជាងមួយធ្វើពីដែក សម្រាប់បកចាកលើឈើ។ រីឯ”ធ្វើយ” មកពីពីពាក្យថា “ងើយ”មានន័យថាធ្វើអាកប្បកិរិយាងើយទៅលើ។ ចំណែក”ឆ្គង” មានន័យថាខុសឆ្គង ឆ្គាំឆ្គង។ តាមរយៈន័យនេះ ប្រធានចង់មានន័យសុភាសិតចង់មានន័យថា ឧបករណ៍រោងជាងមួយធ្វើពីដែក សម្រាប់បក់ចាំងលើឈើ ងើយឡើងព្រោះដងឯងកូនចៅដែលមានការខុសឆ្គង ឬឆ្គាំឆ្គងមកពីឪពុក។

យ៉ាងណាមិចផ្លែដឹង កាលណាគេយកវាទៅប្រើគេត្រូវដាក់ដងឱ្យវា។ ក្នុងករណីអ្នកប្រើបានដាក់ដងដឹងអោយមានរាងច្រងាង នោះវានឹងផ្លែដឹងនឹងងើយខុសធម្មតានិងពិបាកប្រើប្រាស់។ផ្ទុយទៅវិញបើគែបើដងដឹងមានលក្ខណៈត្រង់ល្អ ស្របនឹងលក្ខណៈរបស់ផ្លែដឹង ពេលនោះវានឹងមានភាពងាយស្រួលប្រើ។ ដូច្នេះដងដឹងគឺជាប្រភពងាយស្រួល

ប្រើ ឬមិនមានភាពងាយស្រួលប្រើ។ ចំណុចអស់ទាំងនេះ វាមិនខុសពីការអប់រំកូនចៅឡើយ ។ គេប្រៀបធៀបផ្លែដឹង ទោ នឹងកូនចៅ ឯដងដឹងប្រៀបបានទៅនឹងឪពុក។ ដូច្នេះឪពុកមានភាពកិច្ចធំណាស់ក្នុងការកំណត់លក្ខណៈអត្តចរិតរបស់ កូនចៅ។ នៅពេលកូនក្លាយខ្លួនទៅជាមនុស្សគ្មានសីលធម៌ មិនស្គាល់ចាស់ទុំ មិនគោរពអ្នកដទៃ ធ្វើចរិតឈ្លើយ ច្រងេងច្រងាង នាំអោយគេជៀលដល់ពូជ។ នេះដោយសារតែឪពុកម្តាយមិនបានអប់រំបង្រៀនប្រដៅកូនចៅនោះបានល្អ និងត្រឹមត្រូវ។ ប៉ុន្តែងកូនដែលទទួលបាននូវការអប់រំល្អ ស្តាប់ការទូន្មានឪពុក កូននោះនឹងមានសីលធម៌ មានចរិតលក្ខ ណៈល្អ ហើយជាមនុស្សដែលមានប្រយោជន៍សម្រាប់សង្គម។ ចំណុចនេះកើតឡើង និងចាប់ផ្តើមពីឪពុកជាអ្នកអប់រំទូន្មា ន។ និយាយដោយខ្លីបើឪពុកអប់រំកូនបានល្អ នោះកូននឹងល្អ តែបើគាត់មិនបានអប់រំទូន្មាននោះទេ កូននឹងដើរលើផ្លូវខុស ជាក់ជាមិនខានឡើយ។

សរុបសេចក្តីមក សុភាសិតខាងលើដែលបាននិយាយថា “ដឹងធ្វើយត្បិតដង កូនសោតរៃងឆ្គងត្បិតឪពុក” គឺពិត ជាត្រឹមត្រូវប្រាកដមែន។

ឆ្លងកាត់តាមរយៈការបកស្រាយខាងលើ សុភាសុតពិតមានអត្ថន័យល្អ ព្រោះបានផ្តល់តម្លៃអប់រំ ទូន្មានដល់ មនុស្សទូទៅ ជាពិសេសឪពុកម្តាយទូទៅ អោយចេះអប់រំកូនចៅអោយបានល្អត្រឹមត្រូវនឹងប្រសើរឡើង។ ដូច្នេះក្នុងនាម ជាមាតាបិតាគ្រប់រូបត្រូវអប់រំកូនចៅអោយបានល្អ ទាន់កូនចៅនៅក្មេង ឯកូនចៅក៏ត្រូវស្តាប់ការទូន្មានរបស់ឪពុកម្តាយផង ដែរ។

ប្រធានទី៤៥៖ គេតែងនិយាយថា “ យុវជនគឺជាកម្លាំងចលករមួយដ៏សំខាន់ មិនអាចខ្វះបាន”។ តើមតិនេះមានអត្ថន័យ ដូចម្តេច? ចូរពន្យល់បកស្រាយ។

សេចក្តីអធិប្បាយ

នៅក្នុងសង្គម យុវជន គឺជាកម្លាំងចលករមួយដ៏ខ្លាំងក្លាសម្រាប់អភិវឌ្ឍប្រទេសជាតិរបស់ខ្លួនអោយបានការរីក ចម្រើនឡើង។ ព្រោះយុវជន គឺជាវ័យមួយដែលមានការលូតលាស់ខាងផ្នែកសប្បទា ចិត្តគំនិត និងប្រាជ្ញា។ អាស្រ័យ ដោយហេតុនេះហើយទើបគេនិយាយថា “យុវជន គឺជាកម្លាំងចលករមួយដ៏សំខាន់ មិនអាចខ្វះបាន”។

តើការលើឡើងខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីធ្វើការបកស្រាយប្រធានខាងលើអោយបានក្បោះក្បាយនឹងស៊ីជម្រៅថែមទៀតនោះ យើងគប្បីស្វែងយល់ នូវអត្ថន័យនៃពាក្យគន្លឹះដែលមាននៅក្នុងប្រធានជាមុនសិន។ ពាក្យថា “កម្លាំង” មានន័យធ្វើអោយខ្លាំងក្លា ។ ចំណែក ឯ”ខ្វះបាន” មានន័យត្រូវការជាចាំបាច់ដោយមិនអាចផ្តាច់ចេញបាន។ដូច្នេះតាមន័យនេះប្រធានចង់និយាយ យុវជន ជា កម្លាំងចលករដ៏សំខាន់ មិនអាចខ្វះបាន។

តាមប្រធានខាងលើនិយាយថា” យុវជន ជាកម្លាំងចលករដ៏សំខាន់ មិនអាចខ្វះបាន” ពិតជាត្រឹមត្រូវព្រោះ យើង ដឹងហើយថា យុវជន ជាវ័យមួយដែលមានការលូតលាស់ទាំងកាយសប្បទា និងសតិអារម្មណ៍។ ចំពោះផ្នែកសប្បទាយុវ ជន មានកម្លាំងខ្លាំក្លា។ គេអាចធ្វើការងារផ្សេងៗបានគ្រប់យ៉ាង មានចិត្តតស៊ូអំណត់ ពុះពារគ្រប់ឧបសគ្គនានាដែល មានចំពោះមុខ។ នៅពេលអស់កម្លាំង គេគ្រាន់តែបរិភោគបាយ និងសម្រាន្តបន្តិចនោះ កម្លាំងរបស់យុវជននឹងមកដូច

ដើមវិញ។ចំណែកខាងផ្នែកចិត្តគំនិតវិញ យុវជនក៏មានលក្ខណៈប្រសើរដែរ។ ជាក់ស្តែងយុវជនជាវ័យដែលមានគំនិតជ្រះថ្លា ប្រៀបបាននឹងក្រដាសសរមួយសន្លឹកដូច្នេះដែរ។ នៅពេលយើងអប់រំយុវជនអោយដើរលើផ្លូវត្រឹមត្រូវ គេនឹងមានប្រយោជន៍ខ្លាំងសម្រាប់ប្រទេសជាតិ ។មួយវិញទៀតយុវជន តែងមានគំនិតនិងផុសផុលមានទស្សនៈល្អៗក្នុងការបម្រើដល់សង្គមជាតិ។.....ជាសក្តី.....តួយ៉ាង.....។បន្ថែមពីនេះទៀត.....ប៉ុន្តែ.....។

សរុបសេចក្តីមក ពាក្យដែលគេនិយាយថា “យុវជនជាកម្លាំងចលករមួយដ៏សំខាន់ មិនអាចខ្វះបាន” ពិតជាត្រឹមត្រូវ ព្រោះយុវជនជាវ័យមួយដែលមានការលូតលាស់ខាងផ្នែករាងកាយ និងប្រាជ្ញាស្មារតីខ្លាំងក្លា។

ឆ្លងកាត់តាមការបកស្រាយអំពីពុំនោលខាងលើ យើងអាចធ្វើការវិនិច្ឆ័យបានថា ប្រធានពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំដល់ប្រជាជាតិមួយអោយបានស្គាល់ពីកម្លាំងដ៏ខ្លាំងក្លាយរបស់យុវជន។ ដូច្នេះក្នុងនាមយើងជាយុវជនសម័យថ្មី ត្រូវយកសមត្ថភាពរបស់ខ្លួន ទើបម្រើដល់សង្គមជាតិ ទើបមានឈ្មោះថាយុវជនថ្លៃថ្នូរ។